# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៧៦

បាលីប្រែ ៩៥

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# អភិធម្មបិដក

## និង

## បរមត្ថទីបនី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## បដ្ឋាន

## បឋមភាគ

## ៧៦

## បាលីប្រែ ៩៤



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៧៦
# អភិធម្មបិដក

## បដ្ឋាន បឋមភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ*

## មាតិកានិក្ខេបវារៈ

[ ១ ] *ហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ អវិគតប្បច្ច័យ ។*

# អដ្ឋកថា
## បរមត្ថទីបនី

# បដ្ឋានប្បករណ៍
## អារម្ភកថា

ព្រះសម្មាសម្ពុទ្ធ ទ្រង់ជាទេវតា ក្រៃលែងជាងទេវតាទាំងឡាយ ជាបុគ្គលដែលទេវតា និងទានវធ្វើការបូជាហើយ ទ្រង់មានសំវរៈដ៏បរិសុទ្ធ ទ្រង់មានព្រះវិរិយភាពធំ ទ្រង់ជាឥសីទី ៧ ទ្រង់រម្ងាប់នាម និងរូបបានដោយឥតសេសសល់ កាលទ្រង់សម្ដែងយមកប្បករណ៍ចប់ហើយ ទើបទ្រង់សម្ដែងបករណ៍ទី ៧ ដែលជាលំដាប់បន្ទាប់អំពីយមកប្បករណ៍ ដែលមានអត្ថជ្រាលជ្រៅនោះ ដោយអត្ថផង ដោយធម៌ផង ឈ្មោះថា បដ្ឋាន ដែលជាទេសនា ប្រដាប់ដោយន័យជ្រាលជ្រៅក្រៃលែង ។

ឥឡូវនេះ ដល់លំដាប់នៃកិច្ចពណ៌នាបដ្ឋានប្បករណ៍នោះហើយ ព្រោះហេតុនោះ ខ្ញុំ ( ពុទ្ធឃោសាចារ្យ ) នឹងពណ៌នាបដ្ឋានប្បករណ៍នោះ ចូរសាធុជនទាំងឡាយ តាំងចិត្តស្ដាប់នូវកិច្ចពណ៌នានោះចុះ ។

### អធិប្បាយ បច្ចយុទ្ទេស

[ ១ ] មានសេចក្ដីផ្ដើមថា ក្នុងអនុលោមបដ្ឋាន ព្រះសម្មាសម្ពុទ្ធទ្រង់អាស្រ័យតិកៈ ២២ ឲ្យឈ្មោះថា តិកបដ្ឋាន ។ ទ្រង់អាស្រ័យទុកៈ

១០០ ឲ្យឈ្មោះថា ទុកបដ្ឋាន ។ បន្ទាប់អំពីនោះ ទ្រង់រួមតិកៈ ២២ ចូលក្នុងទុកៈ ១០០ ហើយទ្រង់ឲ្យឈ្មោះថា ទុកត្តិកបដ្ឋាន ។ បន្ទាប់អំពីនោះ ទ្រង់បញ្ចូលទុកៈ ១០០ ក្នុងតិកៈ ២២ ហើយទ្រង់ឲ្យឈ្មោះថា តិកទុ-កបដ្ឋាន ។ ម្យ៉ាងទៀត ទ្រង់សម្តែងតិកៈ ចូលក្នុងតិកៈប៉ុណ្ណោះ ហើយទ្រង់ឲ្យឈ្មោះថា តិកត្តិកបដ្ឋាន ។ ទ្រង់បន្ថែមទុកៈចូលក្នុងទុកៈប៉ុណ្ណោះ ហើយទ្រង់ឲ្យឈ្មោះថា ទុកទុកបដ្ឋាន ។ ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះថា

> ន័យទាំង ៦ គឺតិកបដ្ឋានដ៏ប្រសើរ ១ ទុកបដ្ឋានដ៏ឧត្តម ១ ទុកត្តិកបដ្ឋាន ១ តិកទុកបដ្ឋាន ១ តិកត្តិ-កបដ្ឋាន ១ ទុកទុកបដ្ឋាន ១ ជាន័យដ៏ជ្រៅ ក្នុងអនុលោម ដូច្នេះ ។

ក្នុងបច្ចនីយបដ្ឋាន ក៏ទ្រង់សម្តែងបដ្ឋានដោយន័យ ៦ ក្នុងបច្ចនីយៈយ៉ាងនេះ គឺទ្រង់អាស្រ័យតិកៈ ២២ សម្តែងនូវតិកបដ្ឋាន ទ្រង់អាស្រ័យទុកៈ ១០០ សម្តែងនូវទុកបដ្ឋាន ទ្រង់បញ្ចូលតិកៈ ២២ ចូលក្នុងទុកៈ ១០០ ហើយទ្រង់ឲ្យឈ្មោះថា ទុកត្តិកបដ្ឋាន ទ្រង់បន្ថែមទុកៈ ១០០ ចូលក្នុងតិកៈ ២២ ហើយទ្រង់ឲ្យឈ្មោះថា តិកទុកបដ្ឋាន ទ្រង់បន្ថែមតិកៈចូលក្នុងតិកៈប៉ុណ្ណោះ ហើយទ្រង់ឲ្យឈ្មោះថា តិកត្តិកបដ្ឋាន ទ្រង់បញ្ចូលទុកៈចូលក្នុងទុកៈប៉ុណ្ណោះ ហើយទ្រង់ឲ្យឈ្មោះថា ទុកទុកបដ្ឋាន ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

នយទាំង ៦ គឺតិកប្បដ្ឋានដ៏ប្រសើរ ១ ទុកប្បដ្ឋានដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន ១ តិកត្តិកប្បដ្ឋាន ១ ទុកទុកប្បដ្ឋាន ១ ជានយដ៏ជ្រៅ ក្នុងបច្ចនីយៈ ដូច្នេះ ។

ក្នុងអនុលោមបច្ចនីយប្បដ្ឋាន បន្ទាប់អំពីនោះមក ទ្រង់ក៏សម្តែងនយ ៦ ដោយឧបាយនេះដូចគ្នា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

នយទាំង ៦ គឺតិកប្បដ្ឋានដ៏ប្រសើរ ១ ទុកប្បដ្ឋានដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន ១ តិកត្តិកប្បដ្ឋាន ១ ទុកទុកប្បដ្ឋាន ១ ជានយដ៏ជ្រៅ ក្នុងអនុលោម-បច្ចនីយៈ ដូច្នេះ ។

បន្ទាប់អំពីនោះ ក្នុងបច្ចនីយានុលោមប្បដ្ឋាន ក៏ទ្រង់សម្តែងនយ ៦ នេះដូចគ្នា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

នយទាំង ៦ គឺតិកប្បដ្ឋានដ៏ប្រសើរ ១ ទុកប្បដ្ឋានដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន ១ តិកត្តិកប្បដ្ឋាន ១ ទុកទុ-កប្បដ្ឋាន ១ ជានយដ៏ជ្រៅ ក្នុងបច្ចនីយានុលោម ដូច្នេះ ។

ពិតហើយ ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ក្នុងអនុលោមនយ មានបដ្ឋាន ៦ ក្នុងបច្ចនីយនយ មានបដ្ឋាន ៦ ក្នុងអនុលោមបច្ចនីយនយ មានបដ្ឋាន ៦ ក្នុងបច្ចនីយានុលោមនយ មានបដ្ឋាន ៦ ដូចពោលមកហើយ ឈ្មោះថា បដ្ឋានមហាបករណ៍ ដែលជាទីប្រជុំនៃសមន្តប្បដ្ឋាន ២៤ ក្នុង

បដ្ឋាននោះ ព្រះមានព្រះភាគត្រាស់ថា បករណ៍ជាទីរួមនៃសមន្តប្បដ្ឋាន ២៤ នេះ ឈ្មោះថា បដ្ឋានមហាបករណ៍ ដោយអំណាចជាទីរួមនៃសមន្តប្បដ្ឋាន ២៤ ទាំងឡាយណា ដូច្នេះ អ្នកសិក្សាគប្បីជ្រាបអត្ថនៃឈ្មោះរបស់បដ្ឋាន ទាំងនោះ និងរបស់បករណ៍នេះ យ៉ាងនេះមុន ។

សួរថា ឈ្មោះថា បដ្ឋាន ព្រោះអត្ថដូចម្តេច ឆ្លើយថា ព្រោះអត្ថថា ជាបច្ច័យមានប្រការផ្សេងៗ ។ ពិតហើយ **ប** អក្ខរៈ សំដែងអត្ថថា ច្រើន យ៉ាង ។ **ឋាន** សព្ទ សំដែងអត្ថថា ជាបច្ច័យ ។ ពិតហើយ បច្ច័យ លោក ហៅថា **ឋាន** ដូចក្នុងប្រយោគជាដើមថា **ឋានាឋានកុសលតា** ភាពជា អ្នកឈ្លាសក្នុងឋានៈ និងអឋានៈ ដូច្នេះ ។ បណ្តាបដ្ឋាន ២៤ នេះ បដ្ឋាន នីមួយៗ ក៏ឈ្មោះថា បដ្ឋាន ១ ព្រោះព្រះមានព្រះភាគ ទ្រង់សំដែងដោយ អំណាចនៃបច្ច័យមានប្រការផ្សេងៗ បករណ៍ទាំងអស់នេះ អ្នកសិក្សាគប្បី ជ្រាបថា បដ្ឋាន ព្រោះជាទីប្រជុំចុះនៃបដ្ឋានទាំងនេះ ។

ន័យម្យ៉ាងទៀត សួរថា ឈ្មោះថា បដ្ឋាន ព្រោះអត្ថដូចម្តេច ឆ្លើយ ថា ព្រោះអត្ថថា ចែក ពិតហើយ បដ្ឋាន ប្រាកដដោយអត្ថថា ចែក ក្នុងទី មកថា **បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ** គឺការប្រាប់ ការសំដែង ការបញ្ជាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យ ងាយ ដូច្នេះ ។ បណ្តាបដ្ឋានទាំង ២៤ នេះ បដ្ឋានសូម្បីតែមួយ ក៏ឈ្មោះ ថា បដ្ឋាន ១ ព្រោះព្រះមានព្រះភាគទ្រង់ចែកធម៌ទាំងឡាយ មានកុសល ជាដើម ដោយអំណាចនៃបច្ច័យ មានហេតុប្បច្ច័យជាដើម ។ បករណ៍ទាំង

អស់នេះ អ្នកសិក្សាគប្បីជ្រាបថា ឈ្មោះថា បដ្ឋាន ព្រោះជាទីប្រជុំនៃបដ្ឋានទាំងនោះ ។

ន័យម្យ៉ាងទៀត សួរថា ឈ្មោះថា បដ្ឋាន ព្រោះអត្ថដូចម្តេច ឆ្លើយថា ព្រោះអត្ថថា ទៅ អធិប្បាយថា ដោយអត្ថថា ប្រព្រឹត្តទៅ ។ ពិតហើយក្នុងអាគតដ្ឋាន ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា **គោដ្ឋា បដ្ឋិត-គាវោ** ចូលទៅរកក្រោលគោដែលមានគោចេញហើយ ដូច្នេះ ។ សព្ទថា **បដ្ឋិតគាវោ** លោកប្រើពាក្យថា **បដ្ឋាន** ណា ពាក្យថា **បដ្ឋាន** នោះដោយអត្ថ បានដល់ ការប្រព្រឹត្តទៅ ។ បណ្តាបដ្ឋាន ២៤ នេះ បដ្ឋានទីមួយៗ ក៏ឈ្មោះថា បដ្ឋាន ១ ព្រោះមានការប្រព្រឹត្តទៅ ដោយអំណាចការសម្ពន្ធគ្នា ព្រោះបានន័យដែលមានសេចក្តីពិស្តារក្នុងធម៌ទាំងឡាយ មានកុសលជាដើម ដែលចែកចេញជាប្រភេទ មាន **ហេតុប្បច្ច័យ** ជាដើម នៃសព្វញ្ញុតញ្ញាណ ដែលមានការប្រព្រឹត្តទៅមិនជំទាស់គ្នាក្នុងបករណ៍ទាំងឡាយមានធម្មសង្គណិប្បករណ៍ជាដើម ដែលមានន័យមិនពិស្តារពេក ។ បករណ៍ទាំងអស់នេះ គប្បីជ្រាបថា ឈ្មោះថា បដ្ឋាន ព្រោះជាទីប្រជុំនៃបដ្ឋានទាំងនេះ ។

បណ្តាបដ្ឋានទាំង ៦ នោះ បដ្ឋានទី ១ ក្នុងអនុលោមប្បដ្ឋាន ឈ្មោះថា តិកប្បដ្ឋាន ព្រោះព្រះមានព្រះភាគទ្រង់សម្តែងដោយអំណាចតិកមាតិកា ។

គប្បីជ្រាបការចែកវិគ្គហៈក្នុងពាក្យថា បដ្ឋាន ដូចតទៅ

បដ្ឋាននៃតិកៈទាំងឡាយ មានក្នុងបករណ៍នេះ ព្រោះហេតុនោះ បករណ៍

នេះ ឈ្មោះថា តិកប្បដ្ឋាន អធិប្បាយថា បច្ច័យ មានប្រការផ្សេងៗ នៃតិកៈទាំងឡាយ មានក្នុងទេសនានេះ ។ ក្នុងវិកប្បទី ២ សេចក្តីថា បដ្ឋាន នៃតិកៈទាំងឡាយនោះឯង ឈ្មោះថា តិកប្បដ្ឋាន អធិប្បាយថា ការចែកតិកៈទាំងឡាយដោយអំណាចនៃបច្ច័យ មានហេតុជាដើម ។ ក្នុងវិកប្បទី ៣ សេចក្តីថា បដ្ឋាន គឺតិកៈទាំងឡាយដែលបានសេចក្តីពិស្តារ ព្រោះចែកចេញទៅដោយប្រភេទនៃហេតុប្បច្ច័យជាដើម ឈ្មោះថា តិកប្បដ្ឋាន បានដល់ ភូមិជាទីប្រព្រឹត្តទៅ ដោយមិនសម្ពន្ធគ្នានៃសព្វញ្ញុតញ្ញាណ ។ ក្នុងទុកប្បដ្ឋានជាដើម ក៏ន័យនេះដូចគ្នា ។ អ្នកសិក្សាកាលជ្រាបបដ្ឋាន ៦ ក្នុងអនុលោមយ៉ាងនេះហើយ គប្បីជ្រាបក្នុងបច្ចនីយៈជាដើម ដោយឧបាយនេះ ។

បដ្ឋានទាំងនេះ ន័យនីមួយៗ ៦ គឺក្នុងអនុលោម ក្នុងបច្ចនីយៈ ក្នុងអនុលោមប្បច្ចនីយៈ ក្នុងបច្ចនីយានុលោម ទើបរួមជា ២៤ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ហៅថា សមន្តប្បដ្ឋាន ២៤ ។

បករណ៍ជាទីរួមនៃសមន្តប្បដ្ឋាន ២៤ នោះ ឈ្មោះថា បដ្ឋានមហាបករណ៍ ដោយអំណាចជាទីប្រជុំនៃសមន្តប្បដ្ឋាន ពោល គឺខ្ទុកប្បដ្ឋាន ទាំង ២៤ នេះ ដោយប្រការដូច្នេះ ។

បដ្ឋាននេះ ព្រះមានព្រះភាគត្រាស់ហៅថា តិកប្បដ្ឋាន ទុកប្បដ្ឋាន ។បេ។ តិកត្តិកប្បដ្ឋាន ទុកទុកប្បដ្ឋាន ព្រោះទ្រង់សម្តែងដោយអាស្រ័យតិកៈជាដើមឯណា ដើម្បីនឹងសម្តែងបច្ច័យដែលជាហេតុឲ្យទ្រង់ចែកតិកៈជាដើមនោះ ដោយមិនទាក់ទងនឹងតិកៈជាដើមនោះ ទើបត្រាស់ពាក្យៈឈ្មោះថា មាតិកា-

និក្ខេបវារៈនៃបដ្ឋាននោះមុន តាំងអំពីខាងដើម ។

ពាក្យថា បច្ចយវិភង្គវារៈ ជាឈ្មោះរបស់មាតិកានិក្ខេបវារៈនោះឯង បច្ចយវិភង្គវារៈនោះ មាន ២ គឺដោយឧទ្ទេស និងនិទ្ទេស ។ វារៈនេះ គឺ ហេតុប្បច្ចយោ ។បេ។ អវិគតប្បច្ចយោ ជាឧទ្ទេសនៃបច្ចយវិភង្គវារៈនោះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបច្ច័យទាំងនោះដូចតទៅ

ហេតុនោះផង ជាបច្ច័យផង ព្រោះហេតុនោះ ទើបឈ្មោះថា ហេតុប្បច្ច័យ អធិប្បាយថា ជាបច្ច័យ ព្រោះជាហេតុ គឺជាបច្ច័យព្រោះភាព ជាហេតុ ដូច្នេះ ។ ក្នុងអារម្មណប្បច្ច័យជាដើម ក៏ន័យនេះដូចគ្នា ។ បណ្ដា បច្ច័យទាំងនោះ ពាក្យថា **ហេតុ** នេះ ជាឈ្មោះនៃការណៈ និងមូលដែល ជាចំណែកប្រកប ( អវយវៈ ) ។ ពិតហើយ ចំណែកប្រកបក្នុងពាក្យទាំង ឡាយថា **បដិញ្ញា ហេតុ** ( ហេតុដែលនាំឲ្យប្ដេជ្ញា ) ជាដើម សត្វលោក ហៅថា ហេតុ ឯក្នុងសាសនា ការណៈ ហៅថា ហេតុ ក្នុងពាក្យទាំងឡាយ ថា ធម៌ទាំងឡាយណា គឺខន្ធ ៥ តែងកើតអំពីហេតុ ដូច្នេះជាដើម ។ ឫស គល់ ហៅថា ហេតុ ដូចក្នុងប្រយោគជាដើមថា កុសលហេតុ ៣ អកុ-សលហេតុ ៣ ដូច្នេះ ក្នុងហេតុប្បច្ច័យនេះ ពាក្យថា ហេតុ នោះ សំដៅ ដល់ ឫសគល់ ។

ក្នុងបទថា **បច្ចយោ** នេះ មានវចនត្ថៈដូចតទៅ

ផល រមែងអាស្រ័យប្រព្រឹត្តទៅអំពីធម៌នេះ ព្រោះហេតុនោះ ទើប ធម៌នេះ ឈ្មោះថា បច្ច័យ អធិប្បាយថា ប្រព្រឹត្តទៅដោយមិនលះបង់

ធម៌នោះ ៗ ពិតហើយ ធម៌ណា តាំងនៅ ឬកើតឡើង ព្រោះមិនលះបង់នូវធម៌ណា ធម៌នោះ លោកពោលថា ជាបច្ច័យដល់ធម៌នោះ ៗ តែដោយលក្ខណៈ ធម៌ដែលជួយឧបការៈ ឈ្មោះថា បច្ច័យ ។ ពិតហើយ ធម៌ណាជួយឧបការៈដល់ការតាំងនៅ ឬការកើតឡើងនៃធម៌ណា ធម៌នោះ លោកហៅថា ជាបច្ច័យដល់ធម៌នោះ ៗ ពាក្យថា បច្ច័យ ហេតុ ការណៈ និទានសម្ភវៈ បភវៈជាដើម ពោលដោយអត្ថហើយ ក៏ដូចគ្នានោះឯង ផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ ។ ពោលដោយសង្ខេប ដែលឈ្មោះថា ហេតុព្រោះអត្ថថា ជាមូល ឈ្មោះថា បច្ច័យ ព្រោះអត្ថថា ជួយឧបការៈ ព្រោះហេតុនោះ ទើបធម៌ដែលជួយឧបការៈ ឈ្មោះថា ហេតុប្បច្ច័យ ព្រោះអត្ថថា ជាឫសគល់ ។

ពិតហើយ អាចារ្យទាំងឡាយអធិប្បាយថា ហេតុនោះ ក៏បានដល់ធម៌ដែលធ្វើកុសលជាដើម ឲ្យសម្រេចភាពជាកុសលជាដើម ដូចគ្រាប់ស្រូវសាលីជាដើម ឲ្យសម្រេចជាស្រូវសាលីជាដើម ឬពណ៌នៃកែវមណីជាដើម ឲ្យសម្រេចជាពណ៌កែវមណីជាដើម ដូច្នោះ អធិប្បាយថា កាលបើដូច្នោះ ភាពជាហេតុប្បច្ច័យ រមែងមិនសម្រេចក្នុងរូប ដែលមានហេតុនោះជាសមុដ្ឋានព្រោះថា ហេតុនោះ មិនបានឲ្យរូបទាំងនោះសម្រេចភាពជាកុសលជាដើមតែឈ្មោះថា មិនជាបច្ច័យក៏មិនមែន ដូច្នេះ ។ សមដូចព្រះមានព្រះភាគត្រាស់ថា ហេតុ ជាបច្ច័យនៃពួកធម៌ដែលប្រកបដោយហេតុផង នៃពួករូបដែលតាំងឡើងអំពីធម៌នោះផង ដោយហេតុប្បច្ច័យ ដូច្នេះ ។ម្យ៉ាងទៀត

វៀរចាកហេតុនោះ អហេតុកចិត្ត ក៏សម្រេចជាអព្យាកតធម៌បាន ។

ម្យ៉ាងទៀត សូម្បីសហេតុកចិត្ត ក៏សម្រេចភាពជាកុសលជាដើមបាន ទាក់ទងដោយយោនិសោមនសិការជាដើម ហេតុដែលសម្បយុត្តមិនទាក់ទងឡើយ ។ បើបណ្ដាហេតុដែលសម្បយុត្ត គប្បីជាកុសលជាដើមបាន តាមសភាពឯង បណ្ដាធម៌ដែលសម្បយុត្តដោយហេតុនោះ ក៏ត្រូវទាក់ទងចំពោះដោយហេតុ អលោភៈ គប្បីជាកុសល ឬអព្យាកតៈក៏បាន ។ តែព្រោះប្រព្រឹត្តទៅបានដោយប្រការទាំង ២ ព្រោះហេតុនោះ ទើបអលោភៈ ជាកុសល ឬអព្យាកតៈក្នុងធម៌ទាំងឡាយតាមដែលប្រកប ។ ដោយប្រការដូចពោលមកហើយនេះ ចាំបាច់ពិចារណាភាពជាកុសលជាដើម ក្នុងហេតុទាំងឡាយទៀត កាលមិនកាន់យកអត្ថ គឺឫសគល់នៃហេតុដូចគ្នា និងការឲ្យធម៌ទាំងឡាយ សម្រេចជាកុសលជាដើម កាន់យកដោយអំណាចការឲ្យសម្បយុត្តធម៌ សម្រេចការតាំងមាំដោយល្អ រមែងមិនខុស ។ ពិតហើយ ធម៌ទាំងឡាយដែលបានហេតុប្បច្ច័យហើយ រមែងតាំងមាំដោយល្អ ដូចដើមឈើដែលមានឫសដុះដាលហើយ ។ ឯធម៌ដែលមិនមានហេតុ រមែងមិនតាំងមាំដោយល្អ ដូចចកដែលជាពូជកើតក្នុងទឹកជាដើម ។ ធម៌ដែលឧបការៈ ដោយអត្ថថា ជាឫសគល់ គឺជាធម៌ដែលមានឧបការៈ ដោយឲ្យសម្រេចនូវការតាំងមាំដោយល្អ អ្នកសិក្សាគប្បីជ្រាបថា ជាហេតុប្បច្ច័យ ដោយប្រការដូច្នេះ ។

គប្បីជ្រាបអធិប្បាយក្នុងបច្ច័យដទៃៗ បន្ទាប់អំពីនោះដូចតទៅ

ធម៌ដែលជួយឧបការៈ ដោយភាពជាអារម្មណ៍ ឈ្មោះថា អារម្មណប្បច្ច័យ ។ អារម្មណប្បច្ច័យមាន ៦ យ៉ាង ដោយអំណាចនៃរូបារម្មណ៍ជាដើម ធម៌ឯណានីមួយដែលមិនជាអារម្មណ៍មិនមាន ព្រោះទ្រង់ផ្ដើមថា រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុជាដើម ហើយឲ្យចប់ដោយពាក្យថា ពួកធម៌ណាៗ ប្រារព្ធនូវធម៌ណាៗ ហើយកើតឡើង ពួកធម៌នោះៗ គឺចិត្ត ចេតសិក ធម៌ជាបច្ច័យនៃពួកធម៌នោះៗ ដោយអារម្មណប្បច្ច័យ ។ ដូចបុរសទុព្វលចាប់ឈើច្រត់ ឬខ្សែ ទើបក្រោកឡើងបាន យ៉ាងណា ធម៌គឺចិត្ត និងចេតសិក ក៏យ៉ាងនោះ ក៏ត្រូវប្រារព្ធអារម្មណ៍ មានរូបជាដើម ទើបកើតឡើង ហើយតាំងនៅបាន ព្រោះហេតុនោះ ធម៌ទាំងឡាយ ដែលជាអារម្មណ៍របស់ចិត្ត និងចេតសិកទាំងអស់ គប្បីជ្រាបថា ជាអារម្មណប្បច្ច័យ ។

ធម៌ដែលជួយឧបការៈ ដោយអត្ថថា ជាធំ ឈ្មោះថា អធិបតិប្បច្ច័យ ។ អធិបតិប្បច្ច័យនោះ មាន ២ យ៉ាង គឺសហជាតាធិបតិប្បច្ច័យ ១ អារម្មណាធិបតិប្បច្ច័យ ១ ។ ក្នុង ២ យ៉ាងនោះ ធម៌ ៤ យ៉ាង គឺឆន្ទៈ វិរិយៈ ចិត្ត និងវីមង្សា អ្នកសិក្សាគប្បីជ្រាបថា ជាសហជាតាធិបតិប្បច្ច័យ ព្រោះព្រះបាលីថា ឆន្ទាធិបតិ ជាបច្ច័យនៃពួកធម៌ដែលប្រកបដោយឆន្ទៈផង នៃពួករូបដែលកើតអំពីឆន្ទៈនោះផង ដោយអធិបតិប្បច្ច័យ ដូច្នេះជាដើម ។ ឯអធិបតិប្បច្ច័យនោះ រមែងមិនកើតគ្រាតែមួយ ។ ពិតហើយ ក្នុងពេលណាចិត្តធ្វើឆន្ទៈឲ្យជាធុរៈ គឺឲ្យជាប្រធាន ប្រព្រឹត្តទៅ ក្នុងពេលនោះ ឆន្ទៈជា

អធិបតី ចំណែកវីរិយៈ ចិត្តៈ វីមង្សា ក្រៅអំពីនេះ មិនជាអធិបតីឡើយ ។ ក្នុងអធិបតីដ៏សេស ក៏មានន័យដូចគ្នា ។

ឯអរូបធម៌ទាំងឡាយ គឺចិត្ត និងចេតសិក ធ្វើធម៌ណាឲ្យធ្ងន់ រមែងប្រព្រឹត្តទៅ ធម៌នោះ ឈ្មោះថា ជាអារម្មណាធិបតិប្បច្ច័យដល់អរូបធម៌ទាំងនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ពួកធម៌ណាៗ ធ្វើនូវធម៌ណាៗ ឲ្យជាទីគោរព ហើយកើតឡើង ពួកធម៌នោះៗ គឺចិត្ត ចេតសិកធម៌ ជាបច្ច័យនៃពួកធម៌នោះៗ ដោយអធិបតិប្បច្ច័យ ដូច្នេះ ។

ធម៌ដែលជួយឧបការៈ ដោយការមិនមានរវាងចន្លោះ ឈ្មោះថា អនន្តរប្បច្ច័យ ។

ធម៌ដែលជួយឧបការៈ ដោយការមិនមានរវាងចន្លោះដោយល្អ ឈ្មោះថា សមនន្តរប្បច្ច័យ ។ បច្ច័យទាំង ២ នេះ ដោយច្រើន អាចារ្យទាំងឡាយអធិប្បាយយឺតយូរ ចំណែកខ្លឹមសារក្នុងបច្ច័យទាំង ២ មានដូចតទៅ ពិតហើយ ការកំណត់ចិត្តណាថា មនោធាតុ មានក្នុងលំដាប់ចក្ខុវិញ្ញាណ មនោវិញ្ញាណធាតុ មានក្នុងលំដាប់នៃមនោធាតុ ដូច្នេះជាដើម ការកំណត់ចិត្តនោះរមែងសម្រេចបានដោយអំណាចចិត្តដែលកើតមុនប៉ុណ្ណោះ មិនមានដោយប្រការដទៃឡើយ ព្រោះហេតុនោះ ធម៌ដែលអាចឲ្យចិត្តុប្បាទដែលសមគួរដល់ខ្លួន កើតឡើងក្នុងលំដាប់រៀងៗ ខ្លួន ឈ្មោះថា អនន្តរប្បច្ច័យ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ពាក្យថា អនន្តរប្បច្ច័យ បានដល់ចក្ខុវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះក្តី ជាបច្ច័យ

នៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយអនន្តរប្បច្ច័យ ដូច្នេះជាដើម ។ ធម៌ណា ជាអនន្តរប្បច្ច័យ ធម៌នោះឯង ជាសមនន្តរប្បច្ច័យផងដែរ ។ ពិតហើយ ក្នុងបច្ច័យ ២ យ៉ាងនេះ ផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ ដូចឧបចយៈ និងសន្តតិ និងដូចពាក្យគូគ្នាថា អធិវចនៈ គឺពាក្យហៅឈ្មោះ និងនិរុត្តិ គឺកាសានិយាយ ដូច្នោះ ។ តែកាលពោលដោយអត្ថហើយ មិនមានការប្លែកគ្នាឡើយ ។

ការយើញឯណារបស់អាចារ្យទាំងឡាយថា ឈ្មោះថា អនន្តរប្បច្ច័យ ព្រោះការមិនមានរវាងចន្លោះនៃកាលដែលវែងឆ្ងាយ ឈ្មោះថា សមនន្តរប្បច្ច័យ ព្រោះការមិនមានរវាងចន្លោះនៃកាល មតិនោះក៏ខុសចាកព្រះបាលីជាដើមថា នេវសញ្ញានាសញ្ញាយតនកុសលរបស់បុគ្គល កាលចេញចាកនិរោធជាបច្ច័យនៃផលសមាបត្តិ ដោយសមនន្តរប្បច្ច័យ ដូច្នេះជាដើម ។ ពាក្យណា ដែលអាចារ្យទាំងឡាយពោលក្នុងបច្ច័យទាំង ២ នេះថា ការអាចក្នុងការញ៉ាំងធម៌ទាំងឡាយឲ្យកើតឡើង មិនទាន់វិនាសទៅ តែធម៌ទាំងឡាយមិនទាន់កើតឡើងក្នុងលំដាប់ដោយល្អ ព្រោះត្រូវកម្លាំងភាវនាហាម ពាក្យនោះ សំដៅដល់ការមិនមានរវាងចន្លោះនៃកាលនោះឯង ។ ពិតហើយ ខ្ញុំសូមពោលត្រឹមប៉ុណ្ណោះថា ការមិនមានរវាងចន្លោះនៃកាល ក្នុងបច្ច័យទាំង ២ នោះ រមែងមិនមាន ព្រោះកម្លាំងនៃភាវនា ព្រោះមិនមានចន្លោះនៃកាល ព្រោះហេតុនោះ ទើបមិនគួរជាសមនន្តរប្បច្ច័យ ពិតហើយ មានលទ្ធិថា ធម៌ទាំងនោះ ជាសមនន្តរប្បច្ច័យ ព្រោះមិនមានរវាងចន្លោះនៃកាលវេលា

ព្រោះហេតុនោះ អ្នកសិក្សាកុំប្រកាន់មាំពេក គប្បីឃើញថា ក្នុងបច្ច័យទាំង ២ នោះ ផ្សេងគ្នាដោយព្យញ្ជនៈប៉ុណ្ណោះ ដោយអត្ថមិនផ្សេងគ្នាឡើយ ។ សេចក្តីនេះដូចម្តេច សេចក្តីថា ចន្លោះនៃធម៌ទាំងនោះមិនមាន ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា អនន្តរ ។ ការមិនមានរវាងចន្លោះដោយល្អ ព្រោះមិនមានការតាំងនៅនៃធម៌ទាំងនោះ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា សមនន្តរ ( មិនមានរវាងចន្លោះដោយល្អ ព្រោះមិនមានការតាំងនៅ ) ។

ធម៌ដែលជួយឧបការៈ ព្រោះកាលកើតឡើង ក៏ញុំាងធម៌ដទៃឲ្យកើតព្រមគ្នា ដូចប្រទីបជាឧបការៈដល់ពន្លឺ ឈ្មោះថា សហជាតបច្ច័យ ។

សហជាតបច្ច័យនោះ មាន ៦ យ៉ាង ដោយអំណាចនៃអរូបក្ខន្ធជាដើម ។ សមដូចព្រះមានព្រះភាគត្រាស់ថា ពួកធម៌ ៤ ដែលមិនមានរូបជាបច្ច័យនៃគ្នានិងគ្នា ដោយសហជាតបច្ច័យ មហាភូតរូប ៤ ជាបច្ច័យនៃគ្នានិងគ្នា ដោយសហជាតបច្ច័យ នាមរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយសហជាតបច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកចិត្តចេតសិកធម៌ ជាបច្ច័យនៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន ដោយសហជាតបច្ច័យ មហាភូតរូបជាបច្ច័យនៃឧបាទារូបទាំងឡាយ ដោយសហជាតបច្ច័យ ជួនកាល ពួកធម៌ដែលមានរូប ជាបច្ច័យនៃពួកធម៌ដែលមិនមានរូប ដោយសហជាតបច្ច័យ ជួនកាល មិនមែនជាបច្ច័យដោយសហជាតបច្ច័យទេ ដូច្នេះ ។ ពាក្យនេះលោកពោលសំដៅដល់ហទយវត្ថុប៉ុណ្ណោះ ។

ធម៌ដែលជួយឧបការៈ ដោយការឧបការៈដល់គ្នានិងគ្នាឲ្យកើតឡើង និងគាំទ្រដល់គ្នានិងគ្នា ដូចឈើ ៣ កំណាត់ ពឹងគ្នាទៅវិញទៅមក ឈ្មោះថា អញ្ញមញ្ញប្បច្ច័យ ។

អញ្ញមញ្ញប្បច្ច័យនោះ មាន ៣ យ៉ាង ដោយអំណាចនៃអរូបក្ខន្ធជាដើម សមដូចព្រះមានព្រះភាគត្រាស់ថា ខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ មហាភូតរូប ៤ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ នាមរូបជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ដូច្នេះ ។

ធម៌ដែលជួយឧបការៈ ដោយភាពជាទីតាំង និងដោយភាពជាទីអាស្រ័យ ដូចផែនដី និងផ្ទាំងសំពត់ជាដើម ជាទីទទួល និងអាស្រ័យរបស់ដើមឈើ និងចិត្រកម្ម ( រូបគំនូរ ) ជាដើម ឈ្មោះថា និស្សយប្បច្ច័យ ។

និស្សយប្បច្ច័យនោះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងសហជាតប្បច្ច័យយ៉ាងនេះថា ខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យនៃគ្នានិងគ្នាដោយនិស្សយប្បច្ច័យ ដូច្នេះ ។ តែក្នុងនិស្សយប្បច្ច័យនេះ ចំណែកទី ៦ លោកចែកយ៉ាងនេះថា ចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ សោតាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយសោតវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ ឃានាយតនៈ ជាបច្ច័យនៃឃានវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយឃានវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ ជិវ្ហាយតនៈ ជាបច្ច័យនៃជិវ្ហាវិញ្ញាណធាតុផង នៃ

ពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ មនោធាតុក្តី មនោ-វិញ្ញាណធាតុក្តី អាស្រ័យនូវរូបណាហើយ ប្រព្រឹត្តទៅ រូបនោះ ជាបច្ច័យនៃមនោធាតុផង នៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ ដូច្នេះ ។

ឯក្នុងពាក្យថា ឧបនិស្សយប្បច្ច័យនេះ មានវិចនត្ថៈដូចតទៅ ដែលឈ្មោះថា **និស្សយ** ព្រោះអត្ថថា ដែលផលរបស់ខ្លួនចូលទៅអាស្រ័យ គឺមិនបដិសេធផលរបស់ខ្លួន ព្រោះផលមានការអាស្រ័យហេតុនោះ ប្រព្រឹត្តទៅ ។ ទីអាស្រ័យដែលមានកម្លាំងច្រើន ឈ្មោះថា ឧបនិស្ស័យ ដូចទោមនស្សយ៉ាងធ្ងន់ ឈ្មោះថា ឧបាយាសៈ ដូច្នោះ ។ ពាក្យនេះ ជាឈ្មោះនៃហេតុដែលមានកម្លាំង ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបថា ធម៌ដែលជួយឧបការៈដោយភាពជាហេតុមានកម្លាំង ឈ្មោះថា ឧបនិស្សយប្បច្ច័យ ។

ឧបនិស្សយប្បច្ច័យ មាន ៣ យ៉ាង គឺអារម្មណូបនិស្សយ អនន្ត-រូបនិស្សយ និងបកតូបនិស្សយ ។

បណ្តាឧបនិស្ស័យ ៣ យ៉ាងនោះ អារម្មណូបនិស្ស័យ ទ្រង់ចែកមិនផ្សេងគ្នាអំពីអារម្មណាធិបតីឡើយ ដោយន័យថា បុគ្គលឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយ ពិចារណា ធ្វើពួកកុសលដែលខ្លួនធ្លាប់សន្សំហើយក្នុងកាលមុនឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយ

ពិចារណា ចេញចាកឈាន ធ្វើឈានឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយ ពិចារណា ពួកសេក្ខបុគ្គល ធ្វើគោត្រភូឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយ ពិចារណា ធ្វើវោទានឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយ ពិចារណា ពួកសេក្ខបុគ្គលចេញចាកមគ្គ ធ្វើមគ្គឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយ ពិចារណា ដូច្នេះ ។ បណ្តាកុសលធម៌ មានការឲ្យទានជាដើមនោះ ធម៌ គឺចិត្ត និងចេតសិក ធ្វើអារម្មណ៍ណាឲ្យកើតឡើង អារម្មណ៍នោះ រាប់ថា ជាអារម្មណ៍ដែលមានកម្លាំងក្នុងអារម្មណ៍ទាំងឡាយ សម្រាប់ចិត្ត និងចេតសិកទាំងនោះ ដោយកំណត់ទីពិតប្រាកដ ។ ហេតុនោះ អ្នកសិក្សាគប្បីជ្រាបការផ្សេងគ្នានៃអារម្មណាធិបតី និងអារម្មណូបនិស្ស័យយ៉ាងនេះ ឈ្មោះថា **អារម្មណាធិបតិ** ព្រោះអត្ថថា ត្រឹមតែជាធម៌ដែលចិត្ត និងចេតសិក គប្បីធ្វើឲ្យធ្ងន់ ឈ្មោះថា **អារម្មណូបនិស្សយ** ព្រោះអត្ថថា ជាហេតុឲ្យចិត្ត និងចេតសិក មានកម្លាំង ។

អនន្តរូបនិស្ស័យ ក៏ទ្រង់ចែកមិនផ្សេងគ្នាអំពីអនន្តរប្បច្ច័យ ដោយន័យថា ពួកកុសលធម៌មុនៗ ជាបច្ច័យនៃពួកកុសលធម៌ក្រោយៗ ដោយឧបនិស្សយប្បច្ច័យ ដូច្នេះជាដើម តែក្នុងនិក្ខេបនៃមាតិកា មានការតាំងបច្ច័យទាំង ២ នោះប្លែកគ្នា ព្រោះអនន្តរប្បច្ច័យ មកហើយដោយន័យថា ចក្ខុវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយអនន្តរប្បច្ច័យ ដូច្នេះជាដើម ឯឧបនិស្សយប្បច្ច័យ មកហើយដោយន័យថា ពួកកុសលធម៌មុនៗ ជាបច្ច័យនៃពួកកុសលធម៌ក្រោយៗ ដោយឧបនិស្ស-

យប្បច្ច័យ ដូច្នេះជាដើម ។ និក្ខេបនៃមាតិកានោះ កាលពោលដោយអត្ថ ហើយ ក៏ដូចគ្នានោះឯង ហេតុនោះ អ្នកសិក្សាគប្បីជ្រាបថា ឈ្មោះថា អនន្តរប្បច្ច័យ ព្រោះអាចឲ្យចិត្តុប្បាទ ដែលសមគួរកើតឡើងក្នុងលំដាប់រៀង ខ្លួន និងឈ្មោះថា អនន្តរូបនិស្សយប្បច្ច័យ ព្រោះចិត្តដែលកើតមុន មាន កម្លាំងក្នុងការឲ្យចិត្តដទៃក្រោយកើតឡើង ដូចក្នុងហេតុប្បច្ច័យជាដើម សូម្បី វៀរធម៌ខ្លះចេញ ក៏រមែងកើតបាន យ៉ាងណា វៀរចិត្តដែលជាប់តគ្នានៃខ្លួន ចេញ ចិត្តដែលកើតឡើងបាន រមែងមិនមាន ព្រោះហេតុនោះ ទើបឈ្មោះ ថា ជាបច្ច័យមានកម្លាំង ។

គប្បីជ្រាបការផ្សេងគ្នា របស់អនន្តរប្បច្ច័យ និងអនន្តរូបនិស្សយប្បច្ច័យ ទាំង ២ នោះដូចតទៅ ឈ្មោះថា អនន្តរប្បច្ច័យ ដោយអំណាចការញុំាង ចិត្តដែលសមគួរឲ្យកើតឡើង ក្នុងលំដាប់រៀងៗ ខ្លួន ឈ្មោះថា អនន្តរូ-បនិស្សយប្បច្ច័យ ដោយអំណាចជាហេតុដែលមានកម្លាំង ដោយប្រការដូច្នេះ ។

ឯបកតូបនិស្ស័យ មានអធិប្បាយដូតទៅ ឧបនិស្ស័យដែលបុគ្គលធ្វើ មុន ឈ្មោះថា បកតូបនិស្ស័យ ។ ដែលឈ្មោះថា **បកត** គឺវត្ថុដែលធ្លាប់ ធ្វើមកហើយ បានដល់ ធម៌ដែលមានសទ្ធា និងសីលជាដើម ដែលបុគ្គល ឲ្យសម្រេចហើយ ក្នុងសន្តានរបស់ខ្លួន ឬឧតុ និងភោជនជាដើម ដែល បុគ្គលចូលទៅសេពហើយ ។

ម្យ៉ាងទៀត ឧបនិស្ស័យដោយប្រក្រតីនោះឯង ឈ្មោះថា បកតូ-បនិស្ស័យ អធិប្បាយថា ជាបច្ច័យដែលមិនលាយឡំជាមួយអារម្មណប្បច្ច័យ

និងអនន្តរប្បច្ច័យ ។ ពិតហើយ អ្នកសិក្សាគប្បីជ្រាបប្រភេទ មានប្រការមិនមែនតិចនៃបកតូបនិស្ស័យនោះ ដោយន័យថា ឯបកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធា ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើត ធ្វើវិបស្សនាឲ្យកើត ធ្វើមគ្គឲ្យកើត ធ្វើអភិញ្ញាឲ្យកើត ធ្វើសមាបត្តិឲ្យកើត សីល ... សុតៈ ... ចាគៈ ... អាស្រ័យបញ្ញា ហើយឲ្យទាន ។បេ។ ធ្វើសមាបត្តិឲ្យកើត សទ្ធា ... សីល សុតៈ ចាគៈ ... បញ្ញា ជាបច្ច័យនៃសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា ដោយឧបនិស្សយប្បច្ច័យ ដូច្នេះជាដើម ព្រោះអត្ថថា ជាហេតុមានកម្លាំងផង ព្រោះហេតុនោះ ទើបឈ្មោះថា បកតូបនិស្ស័យ ដោយប្រការដូច្នេះឯង ។

ធម៌ដែលជួយឧបការៈ ដោយការកើតឡើងមុន ហើយកំពុងប្រព្រឹត្តទៅ ឈ្មោះថា បុរេជាតប្បច្ច័យ ។

បុរេជាតប្បច្ច័យនោះ មាន ១១ យ៉ាង ដោយអំណាចវត្ថុ អារម្មណ៍ និងហទយវត្ថុក្នុងបញ្ចទ្វារ ដូចព្រះមានព្រះភាគត្រាស់ថា ចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ សោតាយតនៈ ... ឃានាយតនៈ ... ជិវ្ហា-យតនៈ ... កាយាយតនៈ ... រូបាយតនៈ ... សទ្ទាយតនៈ ... គន្ធាយតនៈ រសាយតនៈ ... ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃមនោធាតុ

ផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយបុរេជាតប្បច្ច័យ មនោធាតុក្តី មនោវិញ្ញាណធាតុក្តី អាស្រ័យនូវរូបណា ហើយប្រព្រឹត្តទៅ រូបនោះជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយបុរេជាតប្បច្ច័យ ជួនកាល ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ ជួនកាល មិនមែនជាបច្ច័យដោយបុរេជាតប្បច្ច័យ ដូច្នេះ ។

អរូបធម៌ ជាធម៌ជួយឧបការៈ ដោយអត្ថថា ទល់ទ្រដល់រូបធម៌ដែលកើតមុន ដូចចេតនាដែលសង្ឃឹមអាហារ ជួយគាំទ្រដល់កូនត្មាត[១] ឈ្មោះថា បច្ឆាជាតប្បច្ច័យ ។

សមដូចព្រះមានព្រះភាគត្រាស់ថា ពួកចិត្តចេតសិកធម៌ ដែលកើតក្រោយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ដូច្នេះ ។

ធម៌ដែលជួយឧបការៈ ដើម្បីឲ្យធម៌ទាំងឡាយដែលកើតជាប់តគ្នាស្ទាត់ជំនាញ និងមានកម្លាំង ដោយអត្ថថា សេព ដូចការប្រកបសេចក្តីព្យាយាមជំបូងៗ ក្នុងការរៀនសូត្រជាដើម ឈ្មោះថា អាសេវនប្បច្ច័យ ។

អាសេវនប្បច្ច័យនោះ មាន ៣ យ៉ាង ដោយអំណាចនៃកុសលជវនអកុសលជវន និងកិរិយាជវន ដូចព្រះមានព្រះភាគត្រាស់ថា ពួកកុសលធម៌

---

១- បានឮថា កូនត្មាតតែងទន្ទឹងថា នៅពេលដែលមេរបស់អញមក នឹងបានចំណីយ៉ាងនេះ កូនត្មាតក៏រស់បានរហូតដល់ថ្ងៃដែលខ្លួនចេះហើរ ព្រោះមេត្មាតពួកខ្លះ មិនពាំចំណីមកឲ្យកូន ដូចបក្សីដទៃទេ ។

មុនៗ ជាបច្ច័យនៃពួកកុសលធម៌ក្រោយៗ ដោយអាសេវនប្បច្ច័យ ពួកអកុសលធម៌មុនៗ ។បេ។ នៃពួកកិរិយាព្យាកតធម៌ក្រោយៗ ដោយអាសេវនប្បច្ច័យ ដូច្នេះ ។

ធម៌ដែលជួយឧបការៈ ដោយភាពជាកិរិយា គឺសេចក្ដីព្យាយាម ( បយោគ ) នៃចិត្ត ឈ្មោះថា កម្មប្បច្ច័យ ។

កម្មប្បច្ច័យនោះ មាន ២ យ៉ាង គឺកុសលចេតនា និងអកុសលចេតនាដែលកើតក្នុងខណៈផ្សេងគ្នា និងចេតនាទាំងអស់ដែលកើតព្រមគ្នា សមដូចព្រះមានព្រះភាគត្រាស់ថា កុសលាកុសលកម្មក្ដី កដត្តាកម្មនៃវិបាកក្ខន្ធទាំងឡាយក្ដី ជាបច្ច័យនៃរូបទាំងឡាយ ដោយកម្មប្បច្ច័យ ជាបច្ច័យនៃធម៌ទាំងឡាយ ដែលប្រកបដោយចេតនាផង នៃរូបទាំងឡាយដែលកើតអំពីធម៌នោះផង ដោយកម្មប្បច្ច័យ ដូច្នេះ ។

ធម៌ គឺវិបាកដែលជួយឧបការៈ ដោយការមិនមានឧស្សាហ៍ ព្រោះការមិនមានឧស្សាហ៍ ឈ្មោះថា វិបាកប្បច្ច័យ ។

វិបាកប្បច្ច័យនោះ រមែងជាបច្ច័យដល់រូប ដែលមានចិត្តជាសមុដ្ឋានក្នុងបវត្តិកាល ដល់កដត្តារូបក្នុងបដិសន្ធិកាល និងដល់ធម៌ដែលសម្បយុត្តដោយវិបាកចិត្តនោះ ក្នុងកាលទាំងអស់ សមដូចព្រះមានព្រះភាគត្រាស់ថា វិបាកាព្យាកតក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ។បេ។ ក្នុងខណៈនៃបដិសន្ធិ វិបាកាព្យាកតក្ខន្ធ ១ ។បេ។ ខន្ធ

២ ជាបច្ច័យនៃខន្ធ ២ និងពួកកដត្តារូប ដោយវិបាកប្បច្ច័យ ពួកខន្ធជាបច្ច័យនៃវត្ថុ ដោយវិបាកប្បច្ច័យ ដូច្នេះ ។

អាហារ ៤ ជាធម៌ជួយឧបការៈ ដោយអត្ថថា ជួយគាំទ្រដល់រូប និងនាម ឈ្មោះថា អាហារប្បច្ច័យ សមដូចព្រះមានព្រះភាគសម្ពុទ្ធត្រាស់ថា កពលិង្ការាហារ ជាបច្ច័យនៃកាយនេះ ដោយអាហារប្បច្ច័យ អាហារទាំងឡាយ ដែលមិនមានរូប ជាបច្ច័យនៃសម្បយុត្តធម៌ផង នៃរូបទាំងឡាយដែលកើតអំពីសម្បយុត្តធម៌នោះផង ដោយអាហារប្បច្ច័យ ដូច្នេះ ។ ឯក្នុងបញ្ហាវារៈ ព្រះមានព្រះភាគត្រាស់ថា ក្នុងខណៈនៃបដិសន្ធិ ពួកវិបាកាព្យាកតាហារ ជាបច្ច័យនៃពួកសម្បយុត្តកខន្ធ និងពួកកដត្តារូប ដោយអាហារប្បច្ច័យ ដូច្នេះ ។

ឥន្ទ្រិយ ២០ វៀរឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ដែលជួយឧបការៈ ដោយអត្ថថា ជាធំក្រៃលែង ឈ្មោះថា ឥន្ទ្រិយប្បច្ច័យ ។ បណ្តាឥន្ទ្រិយទាំងនោះ ឥន្ទ្រិយ ៥ មានចក្ខុន្ទ្រិយជាដើម ជាបច្ច័យចំពោះ ដល់អរូបធម៌ប៉ុណ្ណោះ ឥន្ទ្រិយដ៏សេស ជាបច្ច័យដល់រូបធម៌ និងអរូបធម៌ សមដូចព្រះមានបុណ្យត្រាស់ថា ចក្ខុន្ទ្រិយ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុ ... សោតិន្ទ្រិយ ... ឃានិន្ទ្រិយ ... ជិវ្ហិន្ទ្រិយ ... កាយិន្ទ្រិយ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយឥន្ទ្រិយប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃកដត្តារូបទាំងឡាយ ដោយឥន្ទ្រិយប្បច្ច័យ ពួកឥន្ទ្រិយដែលមិនមានរូប ជាបច្ច័យនៃសម្បយុត្តធម៌ផង នៃរូបទាំងឡាយ ដែលកើតអំពីសម្បយុត្តធម៌នោះផង ដោយឥន្ទ្រិយប្បច្ច័យ ដូច្នេះ ។ ក្នុងបញ្ហាវារៈ ព្រះ

មានព្រះភាគត្រាស់ថា ក្នុងខណៈនៃបដិសន្ធិ ពួកវិបាកាព្យាកតឥន្ទ្រិយ ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និងពួកកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ ដូច្នេះ ។

អង្គឈាន ៧ មានកុសលជាដើម វៀរសុខវេទនា និងទុក្ខវេទនា ដែលប្រព្រឹត្តទៅតាមផ្លូវកាយ ក្នុងទ្វិបញ្ចវិញ្ញាណចិត្ត ដែលជួយឧបការៈដោយអត្ថថា ចូលទៅសម្លឹងអារម្មណ៍ ឈ្មោះថា ឈានប្បច្ច័យ សមដូចព្រះមានព្រះភាគត្រាស់ថា អង្គឈានទាំងឡាយ ជាបច្ច័យនៃពួកធម៌ ដែលប្រកបដោយឈានផង នៃរូបទាំងឡាយ ដែលកើតអំពីធម៌នោះផង ដោយឈានប្បច្ច័យ ដូច្នេះ ។ ឯក្នុងបញ្ហាវារៈ ព្រះមានព្រះភាគត្រាស់ថា ក្នុងខណៈនៃបដិសន្ធិ ពួកអង្គឈានដែលជាវិបាកាព្យាកតៈ ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និងពួកកដត្តារូប ដោយឈានប្បច្ច័យ ដូច្នេះ ។

អង្គមគ្គ ១២ មានកុសលជាដើម ដែលជួយឧបការៈ ដោយអត្ថថាជាហេតុនាំទៅក្នុងផ្លូវណាមួយ ឈ្មោះថា មគ្គប្បច្ច័យ សមដូចព្រះមានព្រះភាគត្រាស់ថា អង្គមគ្គទាំងឡាយ ជាបច្ច័យនៃពួកធម៌ដែលប្រកបដោយមគ្គផង នៃរូបទាំងឡាយដែលកើតអំពីធម៌នោះផង ដោយមគ្គប្បច្ច័យ ដូច្នេះ ។ ឯក្នុងបញ្ហាវារៈ ព្រះមានព្រះភាគត្រាស់ថា ក្នុងខណៈនៃបដិសន្ធិ ពួកអង្គមគ្គដែលជាវិបាកាព្យាកតៈ ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និងពួកកដត្តារូប ដោយមគ្គប្បច្ច័យ ដូច្នេះ ។ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ ទាំង ២ នេះ គប្បីជ្រាបថា រមែងមិនបានក្នុងទ្វិបញ្ចវិញ្ញាណចិត្ត និងអហេតុកចិត្ត តាមដែលពោល គឺសំដៅដល់ទ្វិបញ្ចវិញ្ញាណ មិនជាឈានប្បច្ច័យ អហេតុកចិត្ត មិន

ជាមគ្គប្បច្ច័យ ។

អរូបធម៌ដែលជួយឧបការៈ ដោយភាពជាសភាវៈប្រកបរួមគ្នា គឺមានវត្ថុដូចគ្នា មានអារម្មណ៍ដូចគ្នា កើតឡើងក្នុងខណៈជាមួយគ្នា រលត់ព្រមគ្នា ឈ្មោះថា សម្បយុត្តប្បច្ច័យ សមដូចព្រះមានព្រះភាគត្រាស់ថា ខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយសម្បយុត្តប្បច្ច័យ ដូច្នេះ ។

រូបធម៌ដែលជួយឧបការៈ ដោយមិនចូលដល់ភាវៈដែលមានវត្ថុតែមួយជាដើម ជាវិប្បយុត្តប្បច្ច័យដល់អរូបធម៌ សូម្បីអរូបធម៌ក៏ជាវិប្បយុត្តប្បច្ច័យដល់រូបធម៌ ។

វិប្បយុត្តប្បច្ច័យនោះ មាន ៣ យ៉ាង គឺសហជាតវិប្បយុត្ត បច្ឆាជាតវិប្បយុត្ត និងបុរេជាតវិប្បយុត្ត សមដូចដែលព្រះមានព្រះភាគត្រាស់ថា សហជាត គឺពួកកុសលក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកកុសលខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ដូច្នេះ ។ ឯក្នុងសហជាតវិភង្គនៃអព្យាកតបទ ព្រះមានព្រះភាគត្រាស់ថា ក្នុងខណៈនៃបដិសន្ធិ ពួកវិបាកាព្យាកតក្ខន្ធ ជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ពួកខន្ធជាបច្ច័យនៃវត្ថុ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយវិប្បយុត្តប្បច្ច័យ ដូច្នេះ ឯបុរេជាត គប្បីជ្រាបដោយអំណាចនៃវត្ថុ មានចក្ខុន្ទ្រិយជាដើម ដូចព្រះមានព្រះភាគត្រាស់ថា ឯបុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ។បេ។ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ ។ វត្ថុ ជាបច្ច័យដល់វិបាកាព្យាកតក្ខន្ធ

កិរិយាព្យាកតក្ខន្ធ វត្ថុ ជាបច្ច័យដល់កុសលក្ខន្ធ វត្ថុ ជាបច្ច័យដល់អកុ-សលក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ដូច្នេះ ។

ធម៌ដែលជួយឧបការៈ ដោយអត្ថថា ជួយគាំទ្រដល់ធម៌ ដែលដូចគ្នា ដោយសភាវៈដែលនៅមាន ដែលមានការកើតឡើងចំពោះមុខ ជាលក្ខណៈ ឈ្មោះថា អត្ថិប្បច្ច័យ ។

សម្រាប់អត្ថិប្បច្ច័យនោះ ព្រះមានព្រះភាគទ្រង់តាំងមាតិកា ៧ យ៉ាង គឺអរូបក្ខន្ធ ១ មហាភូតរូប ១ នាមរូប ១ ចិត្តចេតសិក ១ មហាភូតរូប ១ អាយតនៈ ១ និងវត្ថុ ១ សមដូចព្រះមានព្រះភាគត្រាស់ថា ខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយអត្ថិប្បច្ច័យ មហាភូតរូប ៤ ជាបច្ច័យនៃគ្នានិងគ្នា នាមរូប ជាបច្ច័យនៃគ្នានិងគ្នា ក្នុងខណៈនៃបដិសន្ធិ ពួកចិត្តចេតសិកធម៌ ជាបច្ច័យនៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន មហាភូតរូប ជាបច្ច័យនៃឧបាទារូបទាំងឡាយ ចក្ខាយតនៈ ជាបច្ច័យនៃចក្ខុ-វិញ្ញាណធាតុ ។បេ។ កាយាយតនៈ ។បេ។ រូបាយតនៈ ។បេ។ ផោដ្ឋព្វ-យតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ រូបាយតនៈ ។បេ។ ផោដ្ឋព្វ-យតនៈ ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយអត្ថិប្បច្ច័យ មនោធាតុក្តី មនោវិញ្ញាណធាតុក្តី អាស្រ័យរូបណា ហើយប្រព្រឹត្តទៅ រូបនោះ ជាបច្ច័យនៃមនោធាតុផង នៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ

ដូច្នេះ ។ ឯក្នុងបញ្ហាវារៈ ព្រះមានព្រះភាគទ្រង់សម្តែងថា **សហជាតំ បុរេជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ** ហើយទ្រង់អធិប្បាយក្នុងសហជាតប្បច្ច័យមុន ដោយន័យថា កុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ដូច្នេះជាដើម ។ ក្នុងបុរេជាតប្បច្ច័យ ទ្រង់អធិប្បាយដោយអំណាចចក្ខុបសាទជាដើមដែលកើតមុន ។ ក្នុងបច្ឆាជាតប្បច្ច័យ ទ្រង់អធិប្បាយដោយអំណាចចិត្ត និងចេតសិក ដែលកើតខាងក្រោយ ជាបច្ច័យដល់កាយនេះ ដែលកើតមុន ។ ឯក្នុងអាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ ទ្រង់អធិប្បាយយ៉ាងនេះថា កពឡិង្ការាហារជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ដូច្នេះ ។

អរូបធម៌ដែលរលត់ទៅ ដោយមិនមានរវាងចន្លោះ ដែលជាឧបការៈដោយការឲ្យឱកាសដល់រូបធម៌ ដែលកើតក្នុងលំដាប់នៃខ្លួនប្រព្រឹត្តទៅ ឈ្មោះថា នត្ថិប្បច្ច័យ ដូចព្រះមានព្រះភាគត្រាស់ថា ពួកចិត្តចេតសិកធម៌ ដែលរលត់ក្នុងលំដាប់ស្មើ ជាបច្ច័យនៃពួកចិត្តចេតសិកធម៌ជាបច្ចុប្បន្ន ដោយនត្ថិប្បច្ច័យ ដូច្នេះ ។

ធម៌ដែលជានត្ថិប្បច្ច័យនោះឯង ឈ្មោះថា វិគតប្បច្ច័យ ព្រោះជួយឧបការៈដោយភាវៈដែលប្រាសទៅ ដូចព្រះមានព្រះភាគត្រាស់ថា ពួកចិត្តចេតសិកធម៌ដែលទៅប្រាសក្នុងលំដាប់ស្មើ ជាបច្ច័យនៃពួកចិត្តចេតសិកធម៌ជាបច្ចុប្បន្ន ដោយវិគតប្បច្ច័យ ដូច្នេះ ។

ធម៌ដែលជាអត្ថិប្បច្ច័យនោះឯង អ្នកសិក្សាគប្បីជ្រាបថា ឈ្មោះថា អវិគតប្បច្ច័យ ព្រោះជួយឧបការៈដោយភាវៈដែលមិនទាន់ប្រាសទៅ ។ តែព្រះមានព្រះភាគត្រាស់បច្ច័យទាំង ២ នេះ ក៏ដោយអំណាចរបស់វេនេយ្យ-សត្វ ដែលគប្បីទូន្មានយ៉ាងនោះ ដោយទេសនាវិលាស ដូចទ្រង់ត្រាស់សហេតុកទុកៈហើយ ហើយនៅត្រាស់សហេតុសម្បយុត្តទុកៈជាដើមទៀត ។

ដើម្បីការមិនវង្វេងក្នុងបច្ច័យ ២៤ នេះ អ្នកសិក្សាគប្បីជ្រាប
វិនិច្ឆ័យដោយធម៌ ដោយកាល ដោយការចែក ដោយ
ប្រការផ្សេងៗ និងដោយបច្ចុប្បន្ន ។

បណ្ដាពាក្យទាំងនោះ ពាក្យថា ដោយធម៌ សេចក្ដីថា បណ្ដាបច្ច័យ ២៤ នេះ ហេតុប្បច្ច័យ បានដល់ ចំណែកមួយនៃនាមធម៌ បណ្ដានាមធម៌ និងរូបធម៌ទាំងឡាយ ។ អារម្មណប្បច្ច័យ បានដល់ នាមធម៌ និងរូបធម៌ទាំងអស់ ព្រមទាំងបញ្ញត្តិ និងមិនមានបញ្ញត្តិ ។ ក្នុងអធិបតិប្បច្ច័យ សហជាតា-ធិបតិប្បច្ច័យ បានដល់ ចំណែកមួយនៃនាមធម៌ ។ កម្មប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យក៏ដូចគ្នា អារម្មណាធិបតិប្បច្ច័យ បានដល់ ធម៌ដែលជាអារម្មណ៍ទាំងអស់ ដែលចិត្ត និងចេតសិកគប្បីធ្វើឲ្យធ្ងន់ ។ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ វិបាកប្បច្ច័យ សម្ប-យុត្តប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ បានចំពោះនាមធម៌ប៉ុណ្ណោះ ។ សូម្បីពោលថា ជាចំណែកមួយនៃនាមធម៌ក៏បាន ព្រោះមិនបានសង្គ្រោះនិព្វានចូលផង ។ បុរេជាតប្បច្ច័យ ជាចំណែកមួយនៃរូបធម៌ ។ បច្ច័យដ៏សេស បាន

ទាំងនាមធម៌ និងរូបធម៌ ដោយអំណាចនៃធម៌តាមដែលមាននោះឯង ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ក្នុងអធិការនេះ ដូចពណ៌នាមកហើយប៉ុណ្ណេះ ។

ពាក្យថា ដោយកាល សេចក្ដីថា

បណ្ដាបច្ច័យទាំងនេះ បច្ច័យ ១៥ ជាបច្ចុប្បន្នកាល បច្ច័យ
៥ ជាអតីតកាល បច្ច័យ ១ អាស្រ័យកាលទាំង ២ បច្ច័យ
៣ ប្រព្រឹត្តទៅក្នុងកាលទាំង ៣ និងផុតចាកកាលផងដែរ ។

ពិតហើយ បណ្ដាបច្ច័យទាំងនេះ បច្ច័យ ១៥ គឺហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ជាបច្ចុប្បន្នធម៌តែម្យ៉ាង ។

បច្ច័យទាំង ៥ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ជាអតីតតែម្យ៉ាង ។

ឯបច្ច័យ ១ គឺកម្មប្បច្ច័យ ដែលអាស្រ័យកាលទាំង ២ ដែលជាបច្ចុប្បន្ន និងអតីត ។ បច្ច័យ ៣ ដ៏សេស គឺអារម្មណាប្បច្ច័យ អធិបតិប្បច្ច័យ ឧបនិស្សយប្បច្ច័យ ប្រព្រឹត្តទៅក្នុងកាលទាំង ៣ ក៏បាន ជាកាលវិមុត្តក៏បាន ព្រោះសង្គ្រោះនិព្វាន និងបញ្ញត្តិចូលផង ។

អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយកាល ក្នុងបច្ច័យទាំងនេះ ដូចពណ៌នាមកហើយ ។ ឯពាក្យនេះថា ដោយការចែកជាប្រការផ្សេងៗ និងដោយបច្ចយុប្បន្ន មានអត្ថជាក់ច្បាស់ក្នុងនិទ្ទេសវារៈនោះឯង ។៚

## អធិប្បាយបច្ចយុទ្ទេស ចប់

# អភិធម្មបិដក

## បច្ចយវិភង្គវារៈ

[ ២ ] *ពាក្យថា ហេតុប្បច្ច័យ បានដល់ ហេតុជាបច្ច័យនៃពួកធម៌ដែលប្រកបដោយហេតុផង នៃពួករូបដែលតាំងឡើងអំពីធម៌នោះផង ដោយហេតុប្បច្ច័យ ។*

# អដ្ឋកថា
# បច្ចយនិទ្ទេស

## អធិប្បាយ ហេតុប្បច្ចយនិទ្ទេស

[ ២ ] ឥឡូវនេះ ដើម្បីនឹងសម្ដែងពង្រីកបច្ច័យទាំងអស់នេះ តាមលំដាប់បច្ច័យដែលបានលើកឡើងហើយ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា ឈ្មោះថា ហេតុប្បច្ច័យជាដើម បានដល់ ហេតុជាបច្ច័យនៃពួកធម៌ដែលប្រកបដោយហេតុផង នៃពួករូបដែលតាំងឡើងអំពីធម៌នោះផង ដោយហេតុប្បច្ច័យ ។ បណ្ដាបច្ច័យ ២៤ នោះ ព្រះមានព្រះភាគ ទ្រង់លើកហេតុប្បច្ច័យឡើងសម្ដែងមុនបច្ច័យទាំងពួង ហើយទ្រង់ចែកទៅតាមលំដាប់ដែលទ្រង់តាំងទុក ។ ក្នុងបច្ច័យដ៏សេស អ្នកសិក្សាគប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់លើកបទដែលគួរចែកឡើងមុន និងធ្វើការវិសជ្ជនាដោយន័យនេះដូចគ្នា ។ ឯសម្ពន្ធបទក្នុងអធិការនេះ មានដូចតទៅ បច្ច័យណា ដែលព្រះមានព្រះភាគ ទ្រង់លើកឡើងក្នុងឧទ្ទេសនៃបច្ច័យថា ហេតុប្បច្ច័យ ។ បច្ច័យនោះ អ្នកសិក្សាគប្បីជ្រាបដោយនិទ្ទេសយ៉ាងនេះថា ហេតុ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយហេតុ និងដល់រូប ដែលមានហេតុនោះ ជាសមុដ្ឋាន ដោយហេតុប្បច្ច័យ ។ អ្នកសិក្សាគប្បីជ្រាបសម្ពន្ធ និងការវិសជ្ជនាបទដែលគួរចែកដោយបច្ច័យទាំងអស់ ដោយឧបាយនេះ ។

ឥឡូវនេះ មានពាក្យសួរថា ក្នុងពាក្យថា **ហេតូ ហេតុសម្បយុត្តកានំ** នេះ ព្រះមានព្រះភាគមិនត្រាស់ថា **ហេតុសម្បយុត្តកានំ** តែត្រាស់ថា **ហេតូ ហេតុសម្បយុត្តកានំ** ដូច្នេះ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាការកំណត់បច្ច័យ និងបច្ចយុប្បន្ន ។ ពិតហើយ កាលព្រះមានព្រះភាគត្រាស់ថា **ហេតុសម្បយុត្តកានំ** ការកំណត់បច្ច័យថា ធម៌ឈ្មោះនោះ ជាបច្ច័យដល់ធម៌ទាំងឡាយ ដែលសម្បយុត្តដោយហេតុ ដោយហេតុប្បច្ច័យ ដូច្នេះ បុគ្គលណាម្នាក់ក៏ដឹងមិនបាន ។ម្យ៉ាងទៀត ព្រោះមិនកាន់យកអត្ថថា ធម៌ទាំងឡាយ ដែលសម្បយុត្តដោយហេតុ ឈ្មោះថា **ហេតុសម្បយុត្តកានំ** អត្ថគប្បីមានថា ហេតុ ជាបច្ច័យដល់ធម៌ពួកណាមួយ ដែលសម្បយុត្តដោយហេតុប្បច្ច័យ ។ កាលបើយ៉ាងនោះ សូម្បីចក្ខុវិញ្ញាណចិត្តជាដើម ដែលមិនប្រកបដោយហេតុ ក៏ឈ្មោះថា **សម្បយុត្តកា** ដូចធម៌ មានកុសលជាដើម ដែលប្រកបដោយហេតុ ក៏ឈ្មោះថា **សម្បយុត្តកា** ផងដែរ បណ្តាបច្ចយុប្បន្នទាំងនោះ កាលព្រះមានព្រះភាគត្រាស់ថា ហេតុនេះ ជាបច្ច័យដល់ធម៌ឈ្មោះនោះ ដែលសម្បយុត្តគ្នា ការកំណត់ធម៌ដែលជាបច្ចយុប្បន្ន បុគ្គលណាម្នាក់ក៏ដឹងមិនបាន ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់កំណត់ទាំងបច្ច័យ និងបច្ចយុប្បន្ន ទើបត្រាស់ថា **ហេតូ ហេតុសម្បយុត្តកានំ** ដូច្នេះ ។

សេចក្តីនោះ មានអធិប្បាយថា ហេតុដែលសម្បយុត្ត ជាបច្ច័យដល់ធម៌ទាំងឡាយ មានកុសលជាដើម ដែលសម្បយុត្តដោយហេតុ ដោយ

អំណាចនៃហេតុប្បច្ច័យ ។ ក្នុងពាក្យនោះ ព្រះមានព្រះភាគក៏មិនត្រាស់ថា **បច្ចយោ** តែម្យ៉ាង ត្រាស់ថា **ហេតុប្បច្ចយេន** ផងដែរ ដើម្បីបដិសេធភាពដែលហេតុជាបច្ច័យដោយប្រការដទៃ ។ ពិតហើយ ហេតុនេះ ជាបច្ច័យដោយហេតុប្បច្ច័យក៏បាន ដោយអំណាចនៃសហជាតប្បច្ច័យជាដើមក៏បាន ។ ព្រះមានព្រះភាគត្រាស់ពាក្យថា **ហេតុប្បច្ចយេន** ក្នុងអធិការនោះ ក៏ដើម្បីបដិសេធភាពដែលហេតុនេះ ជាបច្ច័យដោយប្រការដទៃ ដោយអំណាចនៃបច្ច័យ មានសហជាតប្បច្ច័យជាដើម ។

សួរថា កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគមិនត្រាស់ថា **តំសម្បយុត្តកានំ** បែរជាត្រាស់ថា **ហេតុសម្បយុត្តកានំ** ឆ្លើយថា ព្រោះបច្ច័យដែលនឹងអធិប្បាយមិនទាន់ប្រាកដ ។ ពិតហើយ កាលព្រះមានព្រះភាគត្រាស់ថា **តំសម្បយុត្តកានំ** ធម៌ទាំងឡាយនោះ ឈ្មោះថា **តំសម្បយុត្តកា** ដោយធម៌ដែលជាហេតុឯណា ធម៌ដែលជាហេតុនោះ ព្រះមានព្រះភាគក៏គប្បីចង្អុលបង្ហាញថា ធម៌ឈ្មោះនេះ មិនទាន់ប្រាកដ ព្រោះធម៌នោះ មិនទាន់ប្រាកដ បណ្ឌិតហៅធម៌ដែលសម្បយុត្តដោយហេតុឯណានោះថា **តំសម្បយុត្តកា** ដូច្នេះ ដើម្បីសម្តែងហេតុនោះដោយសង្ខេប ទើបព្រះមានព្រះភាគត្រាស់ថា **ហេតុសម្បយុត្តកានំ** ដូច្នេះ ។

ឯក្នុងបទថា **តំសមុដ្ឋានានំ** នេះ ព្រះមានព្រះភាគ ទ្រង់ប្រើសព្ទថា **តំ** ព្រោះបច្ច័យដែលគួរអធិប្បាយប្រាកដហើយ ។ ពិតហើយ ក្នុងអធិការ

នេះ មានអត្ថដូចតទៅ ហេតុទាំងនោះផង ធម៌ដែលសម្បយុត្តដោយហេតុផង ជាសមុដ្ឋាននៃរូបទាំងនោះ ព្រោះហេតុនោះ ទើបរូបទាំងនោះ ឈ្មោះថា មានហេតុ និងធម៌ដែលសម្បយុត្តដោយហេតុនោះ ជាសមុដ្ឋាន ។ ហេតុជាបច្ច័យដល់រូបទាំងនោះ ដែលមានហេតុ និងធម៌ ដែលសម្បយុត្តដោយហេតុនោះ ជាសមុដ្ឋាន អធិប្បាយថា ដល់រូបដែលកើតអំពីហេតុ និងធម៌ដែលសម្បយុត្តដោយហេតុ ។ ទ្រង់កាន់យករូប ដែលមានចិត្តជាសមុដ្ឋានដោយពាក្យនេះ ។ សួរថា រូបនោះ រមែងកើតឡើងដោយធម៌ដទៃក្រៅអំពីចិត្តបានឬ ឆ្លើយថា កើតឡើងបាន ។ ពិតហើយ ចិត្ត និងចេតសិកទាំងអស់ កើតព្រមគ្នាហើយ រមែងឲ្យរូបកើតឡើងបាន តែព្រះមានព្រះភាគត្រាស់ដោយលោកិយធម្មទេសនាថា រូបបែបនោះ មានចិត្តជាសមុដ្ឋានព្រោះភាពដែលចិត្តជាធំ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ពួកចិត្តចេតសិកធម៌ ជាបច្ច័យនៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋានដោយសហជាតប្បច្ច័យ ដូច្នេះ ។ សួរថា បើយ៉ាងនោះ ព្រះមានព្រះភាគត្រាស់ក្នុងអធិការនេះថា **តំសមុដ្ឋានានំ** មិនត្រាស់ថា **ចិត្តសមុដ្ឋានានំ** ដូច្នេះ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសង្គ្រោះរូប ដែលមិនមានចិត្តជាសមុដ្ឋានចូលមកផង ។ ពិតហើយ ក្នុងបញ្ហាវារៈ មានព្រះបាលីដែលនាំមកអាងថា ពួកវិបាកាព្យាកតហេតុ ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និងពួកកដត្តារូបដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។ ព្រះមានព្រះភាគ មិនត្រាស់ថា **ចិត្តសមុដ្ឋានានំ** តែត្រាស់ថា **តំសមុដ្ឋានានំ** ក្នុងអធិការនេះ ក៏ដើម្បី

សង្គ្រោះកដត្តារូបនោះផង ។

មានអធិប្បាយថា ហេតុទាំងនោះ និងធម៌ដែលសម្បយុត្តដោយហេតុ សូម្បីមិនបានញុំាងចិត្តជរូបឲ្យកើតបាន តែក៏ចាត់ជាសមុដ្ឋាននៃរូបទាំងនោះ ដោយអំណាចសហជាតប្បច្ច័យជាដើម ព្រោះហេតុនោះ ទើបរូបទាំងនោះ ឈ្មោះថា មានហេតុ និងធម៌ដែលសម្បយុត្តដោយហេតុនោះ ជាសមុដ្ឋាន ។ ( ហេតុជាបច្ច័យ ) ដល់កម្មជរូបទាំងនោះ ដែលមានហេតុ និងធម៌ដែលសម្បយុត្តដោយហេតុនោះ ជាសមុដ្ឋាន ។ ហេតុជាបច្ច័យដល់ចិត្តជរូប ក្នុងបវត្តិកាល និងដល់កដត្តារូប ក្នុងបដិសន្ធិកាល ដោយហេតុប្បច្ច័យ ។ ក្នុងព្រះបាលីដែលមកក្នុងទីដទៃ បទថា **តំសមុដ្ឋានានំ** អ្នកសិក្សាគប្បីជ្រាបអធិប្បាយ ដោយឧបាយនេះ ។

សួរថា ព្រោះហេតុអ្វី ទើបហេតុនេះ ជាហេតុប្បច្ច័យដល់កដត្តារូប ក្នុងបដិសន្ធិកាលតែម្យ៉ាង មិនជាហេតុប្បច្ច័យ ក្នុងបវត្តិកាលផង ឆ្លើយថា ព្រោះកម្មជរូប មានការប្រព្រឹត្តទៅទាក់ទងជាមួយចិត្ត ក្នុងបដិសន្ធិកាល ។ ពិតហើយ ក្នុងបដិសន្ធិកាល កម្មជរូប មានការប្រព្រឹត្តទៅ ទាក់ទងជាមួយចិត្ត គឺរមែងកើតឡើង និងតាំងនៅបានដោយចិត្ត ព្រោះថា ក្នុងខណៈនោះ ចិត្តមិនអាចញុំាងចិត្តជរូបឲ្យកើតឡើងបាន រូបទាំងនោះ វៀរចិត្តហើយ មិនអាចកើតឡើង និងតាំងនៅបាន សមដូចព្រះមានព្រះភាគត្រាស់ថា វិញ្ញាណជាបច្ច័យនៃនាមរូប កាលវិញ្ញាណនោះ តាំងនៅ ទើបនាមរូបកើតឡើងបាន ដូច្នេះ ។

តែក្នុងបវត្តិកាល កម្មជរូបទាំងនោះ សូម្បីចិត្តនៅមាន ក៏មានការទាក់ទងដោយកម្មប៉ុណ្ណោះ មិនទាក់ទងដោយចិត្តឡើយ ។ ម្យ៉ាងទៀត សម្រាប់បុគ្គលដែលចូលនិរោធ សូម្បីមិនមានចិត្ត កម្មជរូបក៏កើតបាន ។

សួរថា ព្រោះហេតុអ្វី ទើបក្នុងបដិសន្ធិក្ខណៈ ចិត្តមិនអាចឲ្យចិត្តជរូបកើតឡើងបាន ឆ្លើយថា ព្រោះមានកម្លាំងខ្សោយ ដោយត្រូវកម្លាំងកម្មបន្សាត់ទៅ និងមិនទាន់មានទីអាស្រ័យមាំទាំ ។ ពិតហើយ ក្នុងបដិសន្ធិកាល ចិត្តនោះ ត្រូវកម្លាំងកម្មបន្សាត់ទៅ និងឈ្មោះថា មិនទាន់មានទីអាស្រ័យមាំទាំ ព្រោះមិនទាន់មានវត្ថុរូបដែលជាបុរេជាតបច្ច័យ ព្រោះហេតុនោះ ទើបឈ្មោះថា មានកម្លាំងខ្សោយ ។

ព្រោះហេតុនោះ ទើបបដិសន្ធិចិត្ត មិនអាចឲ្យរូបកើតឡើងបាន ដូចបុគ្គលដែលកំពុងតែធ្លាក់ជ្រោះ មិនអាចសម្តែងសិប្បៈណាមួយបានឡើយដូច្នោះ ។ កម្មជរូបប៉ុណ្ណោះ តាំងនៅក្នុងឋានៈនៃរូប ដែលមានចិត្តជាសមុដ្ឋានសម្រាប់បុគ្គលនោះ ។ ចិត្តនោះ ក៏តាំងនៅក្នុងឋានៈជាពូជនៃកម្មជរូបប៉ុណ្ណោះ ។ ឯកម្ម ប្រៀបដូចស្រែ កិលេស ប្រៀបដូចទឹក សម្រាប់កម្មជរូបនោះ ព្រោះហេតុនោះ ក្នុងបដិសន្ធិក្ខណៈ រូបកាយ រមែងកើតឡើងបានដោយអានុភាពរបស់ចិត្ត ប្រៀបដូចកាលមានស្រែ និងទឹក ដើមឈើ រមែងកើតឡើងបាន ដោយអានុភាពនៃគ្រាប់ពូជ ក្នុងកាលកើតឡើងគ្រាដំបូង ។ វៀរចាកចិត្ត កម្មជរូប រមែងប្រព្រឹត្តទៅបាន ព្រោះកម្ម ប្រៀបដូចគ្រាប់ពូជអស់ហើយ ដើមឈើ ក៏ចម្រើនធំឡើងបាន ដោយអានុភាពនៃដី និងទឹក

នោះឯង សមដូចព្រះមានព្រះភាគត្រាស់ថា កម្ម ជាស្រែ វិញ្ញាណ ជាពូជ តណ្ហា ជាទឹក ដូច្នេះ ។ សេចក្តីនេះ អ្នកសិក្សាគប្បីកាន់យកដោយអំណាចនៃឱកាស ( ភូមិ ) ប៉ុណ្ណោះ ។ ពិតហើយ ឱកាសមាន ៣ គឺឱកាសនៃនាម ឱកាសនៃរូប ឱកាសនៃនាម និងរូប ។ បណ្តាឱកាសទាំង ៣ នោះ អរូបភព ឈ្មោះថា ឱកាសនៃនាម ព្រោះឈ្មោះថា ក្នុងអរូបភពនោះ អរូបធម៌ប៉ុណ្ណោះ រមែងកើតឡើងដោយវៀរនូវរូបជាបច្ច័យ ដោយហោចសូម្បីហទយវត្ថុ ។

អសញ្ញភព ឈ្មោះថា ឱកាសនៃរូប ព្រោះថា ក្នុងអសញ្ញភពនោះ រូបធម៌ រមែងកើតឡើងដោយវៀរនូវនាមជាបច្ច័យ សូម្បីត្រឹមបដិសន្ធិចិត្ត ។

បញ្ចវោការភព ឈ្មោះថា ឱកាសនៃនាម និងរូប ព្រោះថា ក្នុងបញ្ច-វោការភពនោះ ក្នុងបដិសន្ធិកាល វៀរត្រឹមវត្ថុរូប អរូបធម៌ រមែងកើតឡើងមិនបានឡើយ និងវៀរបដិសន្ធិចិត្តហើយ រូបធម៌ដែលកើតអំពីកម្ម រមែងកើតឡើងមិនបានដូចគ្នា រូបធម៌ផង អរូបធម៌ផង រមែងកើតឡើងជាគូគ្នាដូច្នេះ ។ ដូចក្នុងវាំងដែលមានក្អាក់ងារ មានអ្នកយាមទ្វារ វៀរព្រះរាជបញ្ជានៃព្រះរាជាហើយ បុគ្គលណាចូលទៅមុនមិនបាន តែក្រោយអំពីបានទទួលអនុញ្ញាត សូម្បីវៀរព្រះរាជបញ្ជា ក៏ចូលទៅបាន ដោយអានុភាពនៃពាក្យបញ្ជាក្នុងកាលមុន យ៉ាងណា ក្នុងបញ្ចវោការភព វៀរបដិសន្ធិវិញ្ញាណដែលមានសហជាតបច្ច័យជាដើមជាបច្ច័យ រូបដែលកើតឡើងដំបូង ដោយអំណាចបដិសន្ធិមិនមាន តែខាងក្រោយបដិសន្ធិកាល ទោះបីវៀរបដិសន្ធិ-វិញ្ញាណ ដែលមានអានុភាពនៃសហជាតបច្ច័យជាដើមជាបច្ច័យ រូបដែល

កើតឡើងដោយអានុភាពកម្មក្នុងកាលមុន រមែងប្រព្រឹត្តទៅបាន ព្រោះកម្មនោះឯង យ៉ាងនោះ ។ ឯអសញ្ញកព រមែងមិនជាឱកាសនៃអរូប ព្រោះហេតុនោះ ក្នុងអសញ្ញភពនោះ វៀរអរូបដែលជាបច្ច័យ រូប ក៏រមែងប្រព្រឹត្តទៅបាន ព្រោះជាឱកាស ( ភូមិ ) របស់សត្វដែលមិនមានសញ្ញា ប្រៀបដូចក្នុងផ្ទះស្ងាត់ដែលគ្មានម្ចាស់ ឬក្នុងផ្ទះរបស់ខ្លួន បុគ្គលរមែងចូលទៅបានដូច្នោះ ។ អរូបភព រមែងមិនជាឱកាសនៃរូប ព្រោះហេតុនោះ ក្នុងអរូបភពនោះ វៀររូបដែលជាបច្ច័យចេញ អរូបធម៌ រមែងប្រព្រឹត្តទៅបាន ព្រោះជាឱកាស ( ភូមិ ) របស់សត្វដែលមិនមានសញ្ញា ។ បញ្ចវោការភព ជាឱកាសនៃរូប និងនាម ព្រោះហេតុនោះ ក្នុងបដិសន្ធិកាល ក្នុងបញ្ចវោការភពនេះ វៀរនាមដែលជាបច្ច័យហើយ រូបដែលកើតឡើងបាន មិនមានឡើយ ។ ហេតុនេះ ទើបបដិសន្ធិចិត្ត ជាបច្ច័យដល់កដត្តារូប ក្នុងបដិសន្ធិកាលប៉ុណ្ណោះ មិនជាបច្ច័យ ក្នុងបវត្តិកាលឡើយ ។

សួរថា កាលព្រះមានព្រះភាគត្រាស់ថា ហេតុជាបច្ច័យនៃពួកធម៌ដែលប្រកបដោយហេតុដោយហេតុប្បច្ច័យ ដូច្នេះ ក៏ស្មើគ្នានឹងការសង្គ្រោះយកអត្ថនេះទាំងអស់ហើយ មិនមែនឬ កាលបើយ៉ាងនោះ ពាក្យថា ហេតុជាបច្ច័យនៃពួកធម៌ដែលប្រកបដោយហេតុផង នៃពួករូបដែលតាំងឡើងអំពីធម៌នោះផង ដូច្នេះ ទ្រង់កាន់យកទៀត ព្រោះហេតុអ្វី ឆ្លើយថា ព្រោះទ្រង់បដិសេធភាពជាបច្ច័យដល់កដត្តារូបជាដើម ក្នុងបវត្តិកាល ។ ពិតហើយ កាលបើយ៉ាងនោះ កដត្តារូប និងរូបដែលមានឧតុ និងអាហារជាសមុដ្ឋាន

ទាំងឡាយណាកើតឡើង ក្នុងខណៈតែមួយជាមួយហេតុ ក្នុងបវត្តិកាល ហេតុត្រូវជាហេតុប្បច្ច័យដល់រូបទាំងនោះបាន តែហេតុមិនជាបច្ច័យដល់រូបទាំងនោះឡើយ ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់កាន់យកពាក្យនោះផង ក៏ដើម្បីបដិសេធភាពដែលហេតុជាបច្ច័យដល់កដត្តារូបជាដើមនោះ ក្នុងបវត្តិកាល ។

ឥឡូវនេះ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងហេតុប្បច្ច័យនេះ ដោយអំណាចបទទាំងនេះ គឺដោយការចែកដោយប្រការផ្សេងៗ និងដោយបច្ចយុប្បន្នដូចតទៅ

ពាក្យថា ដោយការចែកដោយប្រការផ្សេងៗ មានអធិប្បាយថា ឈ្មោះថា ហេតុនេះ ដោយជាតិមាន ៤ យ៉ាង គឺកុសលជាតិ ១ អកុសលជាតិ ១ វិបាកជាតិ ១ កិរិយាជាតិ ១ ។ បណ្ដាជាតិ ៤ នោះ កុសលហេតុពោលដោយលំដាប់នៃភូមិ មាន ៤ ដោយចែកជាកាមាវចរភូមិជាដើម ។ អកុសលហេតុ ជាកាមាវចរតែម្យ៉ាង ។ វិបាកហេតុ មាន ៤ យ៉ាង ដោយចែកជាកាមាវចរជាដើម កិរិយាហេតុ មាន ៣ គឺកាមាវចរ រូបាវចរ និងអរូបាវចរ ។ បណ្ដាហេតុទាំងនោះ កាមាវចរកុសលហេតុ ពោលដោយឈ្មោះ មាន ៣ ដោយអំណាចនៃអលោភហេតុជាដើម ។ ក្នុងរូបាវចរ-កុសលហេតុជាដើម ក៏ន័យនេះដូចគ្នា ។ អកុសលហេតុ មាន ៣ ដោយអំណាចលោភហេតុជាដើម ។ ឯវិបាកហេតុ កិរិយាហេតុ នីមួយៗ មាន ៣ ដោយអំណាចអលោភហេតុជាដើម ។ ឯការចែកហេតុនោះៗ ដោយប្រការ

*ផ្សេងៗ រមែងមានដោយអំណាចការប្រកបជាមួយចិត្តនោះៗ ឯង ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យដោយការចែកដោយប្រការផ្សេងៗ ក្នុងហេតុនេះប៉ុណ្ណេះ ។*

*ពាក្យថា បច្ចុយុប្បន្ន សេចក្តីថា អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យយ៉ាងនេះថា ធម៌ទាំងនេះ រមែងកើតឡើង ព្រោះបច្ច័យនេះ ហេតុនេះ ទើបបច្ច័យនេះ ឈ្មោះថា ជាបច្ច័យដល់នាមធម៌ទាំងនេះ ។ បណ្តាបច្ច័យទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងហេតុប្បច្ច័យនេះ ដូច្នេះ ។*

*កាមាវចរកុសលហេតុ ជាហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ក្នុងកាមភព និងរូបភពទាំងឡាយ ។ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ក្នុងអរូបភព ។*

*រូបាវចរកុសលហេតុ ជាហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្ត និងរូបដែលមានចិត្តជាសមុដ្ឋាន ក្នុងកាមភព និងរូបភពប៉ុណ្ណោះ ។*

*អរូបាវចរកុសលហេតុ ដូចគ្នានឹងកាមាវចរកុសលហេតុនោះឯង ។ លោកុត្តរកុសលហេតុ និងអកុសលហេតុក៏ដូចគ្នា ឯកាមាវចរវិបាកហេតុ ជាហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួន ក្នុងកាមភពប៉ុណ្ណោះ ជាហេតុប្បច្ច័យដល់កដត្តារូប ក្នុងបដិសន្ធិកាល និងជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋានក្នុងបវត្តិកាល ។*

រូបាវចរវិបាកហេតុ ជាហេតុប្បច្ច័យដល់ធម៌ មានប្រការដូចពោលហើយក្នុងរូបភពនោះឯង ។ អរូបាវចរវិបាកហេតុ ជាហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ក្នុងអរូបភព ។ លោកុត្តរវិបាកហេតុ ជាហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្ត និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ក្នុងកាមភពនិងរូបភព ជាហេតុប្បច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ក្នុងអរូបភព ឯក្នុងកិរិយាហេតុមានន័យនៃភាពជាបច្ច័យ ដូចគ្នានឹងកុសលហេតុក្នុងភូមិទាំង ៣ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យដោយធម៌ដែលជាបច្ចុប្បន្ន ក្នុងហេតុប្បច្ច័យនេះ ដូចពណ៌នាមក ដូច្នេះ ។ ល។

## អធិប្បាយហេតុប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## អារម្មណប្បច្ច័យ

[ ៣ ] ពាក្យថា អារម្មណប្បច្ច័យ បានដល់ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុផង នៃពួកធម៌ ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ សទ្ទាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណធាតុផង នៃពួកធម៌ ដែលប្រកបដោយសោតវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ គន្ធាយតនៈ ជាបច្ច័យនៃឃានវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយឃានវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ រសាយតនៈ ជាបច្ច័យនៃជិវ្ហាវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ ដែលប្រកបដោយមនោធាតុនោះផង ដោយអារម្មណប្បច្ច័យ ធម៌ទាំងពួង ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ ពួកធម៌ណាៗ ប្រារព្ធនូវធម៌ណាៗ ហើយ កើតឡើង ពួកធម៌នោះៗ គឺចិត្តចេតសិកធម៌ ជាបច្ច័យនៃពួកធម៌នោះៗ ដោយអារម្មណប្បច្ច័យ ។

# អធិប្បាយ

## អារម្មណប្បច្ចយនិទ្ទេស

[ ៣ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងអារម្មណប្បច្ច័យនិទ្ទេសដូចតទៅ

បទថា **រូបាយតនំ** បានដល់ អាយតនៈ ពោល គឺរូប ។ ក្នុងពាក្យដ៏សេសក៏ន័យនេះឯង ។ បទថា **ចក្ខុវិញ្ញាណធាតុយា** បានដល់ ដល់ធាតុ គឺចក្ខុវិញ្ញាណ ។ ក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។ បទថា **តំ សម្បយុត្តកានំ** បានដល់ ដល់ខន្ធ ៣ ដែលសម្បយុត្តដោយចក្ខុវិញ្ញាណធាតុនោះ អធិប្បាយថា រូបាយតនៈ ជាបច្ច័យដល់ខន្ធ ៤ ដែលអាស្រ័យចក្ខុបសាទទាំងអស់ដោយអារម្មណប្បច្ច័យ ។ ក្នុងពាក្យដទៃក្រៅអំពីនេះ ក៏ន័យនេះដូចគ្នា ។ បទថា **មនោធាតុយា** សេចក្តីថា អាយតនៈ ៥ មានរូបាយតនៈជាដើម ជាបច្ច័យដល់មនោធាតុទាំង ៣ មួយអន្លើដោយធម៌ ដែលសម្បយុត្តដោយអារម្មណប្បច្ច័យ តែមិនបានប្រព្រឹត្តទៅក្នុងខណៈតែមួយ ។ បទថា **សព្វេ ធម្មា** សេចក្តីថា អាយតនៈ ៥ មានរូបាយតនៈទាំងនេះជាដើមផង ញេយ្យធម៌ទាំងអស់ដ៏សេសផង ជាបច្ច័យដល់មនោវិញ្ញាណធាតុ ព្រមទាំងធម៌ដែលសម្បយុត្តដ៏សេស វៀរធាតុ ៦ ដោយអារម្មណប្បច្ច័យ ។

ដោយពាក្យថា **យំ យំ ធម្មំ អារព្ភ** ជាដើមនេះ ព្រះមានព្រះភាគទ្រង់សម្តែងថា ធម៌ទាំងឡាយណា ដែលហៅថា ជាអារម្មណ៍នៃវិញ្ញាណធាតុទាំង ៧ នេះ ធម៌ទាំងនោះ ជាអារម្មណប្បច្ច័យដល់ធាតុទាំងនោះ ក្នុងខណៈដែលធ្វើឲ្យជាអារម្មណ៍កើតឡើង ។ ទ្រង់សម្តែងថា ទោះបីធម៌ទាំងនោះយ៉ាងនោះក៏ពិត តែមិនជាអារម្មណប្បច្ច័យក្នុងពេលតែមួយឡើយ ព្រោះថា

ធម៌ទាំងឡាយណាមួយ ប្រារព្ធធម៌ណាមួយកើតឡើង ធម៌នោះៗ ជាអារម្មណប្បច្ច័យដល់ធម៌នោះៗ ដោយចំពោះប៉ុណ្ណោះ ។

បទថា **ឧប្បជ្ជន្តិ** អ្នកសិក្សាគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ដូចពាក្យថា ទឹក រមែងហូរទៅ ភ្នំ រមែងតាំងនៅ ដែលទ្រង់ត្រាស់ដោយអំណាចការពោលគ្របដណ្តប់ដល់កាលទាំងអស់ ។ ដោយបទនោះ រមែងសម្រេចសេចក្តីថា ធម៌ទាំងឡាយណា ប្រារព្ធធម៌ណាមួយកើតឡើងហើយ ធម៌ទាំងឡាយណា ប្រារព្ធធម៌ណាមួយនឹងកើតឡើង ធម៌ទាំងឡាយនោះកើតឡើងហើយផង នឹងកើតឡើងផង ដោយអារម្មណប្បច្ច័យប៉ុណ្ណោះ ។ បទថា **ចិត្តចេតសិកា ធម្មា** នេះ ជាការអធិប្បាយដោយសង្ខេប នូវធម៌ដែលទ្រង់ត្រាស់ថា **យេ យេ ធម្មា** ។ បទថា **តេ តេ ធម្មា** គឺធម៌ដែលជាអារម្មណ៍នោះៗ ។ បទថា **តេសំ តេសំ** បានដល់ ធម៌ គឺចិត្ត និងចេតសិកទាំងនោះ ។ នេះជាពាក្យអធិប្បាយព្រះបាលីក្នុងទីនេះ មានប្រមាណប៉ុណ្ណោះ ។

ឈ្មោះថា អារម្មណ៍នេះ ពោលជាចំណែកៗ ហើយ មាន ៦ យ៉ាង គឺរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ ។ បណ្តាអារម្មណ៍ទាំងនោះ អារម្មណ៍ដ៏សេស វៀរបញ្ញត្តិ ពោលដោយភូមិ មាន ៤ គឺកាមាវចរភូមិ រូបាវចរភូមិ អរូបាវចរភូមិ និងលោកុត្តរភូមិ ។ បណ្តាអារម្មណ៍ដែលទាក់ទងក្នុងភូមិទាំង ៤ នោះ អារម្មណ៍ដែលជាកាមាវចរ មាន ៥ យ៉ាង ដោយចែកជាកុសល អកុសល វិបាក កិរិយា និងរូប ។ អារម្មណ៍ដែលជារូបាវចរ និងអរូបាវចរនីមួយៗ មាន ៣ យ៉ាង

ដោយជាកុសល វិបាក និងកិរិយា ។ អារម្មណ៍ដែលជាលោកុត្តរភូមិ មាន ៣ យ៉ាង ដោយអំណាចជាកុសល វិបាក និងនិព្វាន ។ ម្យ៉ាងទៀត អារម្មណ៍ទាំងអស់ មាន ៧ យ៉ាង ដោយចែកជាកុសល អកុសល វិបាក កិរិយា រូប និព្វាន និងបញ្ញត្តិ ។ បណ្តាអារម្មណ៍ ៧ យ៉ាង កាលពោលដោយភូមិ អារម្មណ៍ដែលជាកុសល មាន ៤ អារម្មណ៍ដែលជាអកុសល ជាកាមាវចរតែម្យ៉ាង អារម្មណ៍ដែលជាវិបាក ប្រព្រឹត្តទៅក្នុងភូមិ ៤ អារម្មណ៍ដែលជាកិរិយា ប្រព្រឹត្តទៅក្នុងភូមិ ៣ រូប ប្រព្រឹត្តទៅក្នុងភូមិ ១ គឺកាមាវចរប៉ុណ្ណោះ សូម្បីនិព្វាន ក៏ប្រព្រឹត្តទៅក្នុងភូមិ ១ គឺជាលោកុត្តរប៉ុណ្ណោះ ឯបញ្ញត្តិផុតហើយចាកភូមិទាំងឡាយ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងអារម្មណប្បច្ច័យនេះ ដូចពណ៌នាមកនេះ ។

ក្នុងអារម្មណ៍នេះ ដែលផ្សេងគ្នាយ៉ាងនេះ អារម្មណ៍ដែលជាកាមាវចរកុសល ជាអារម្មណប្បច្ច័យដល់ធម៌ ៦ ពួកនេះ គឺកាមាវចរកុសល រូបាវចរកុសល អកុសល កាមាវចរវិបាក កាមាវចរកិរិយា រូបាវចរកិរិយា ។ អារម្មណ៍ដែលជារូបាវចរកុសល ជាអារម្មណប្បច្ច័យដល់ធម៌ ៦ ពួកនោះត្រឹម ៥ ពួក គឺវៀរកាមាវចរវិបាក ។ អារម្មណ៍ដែលជាអរូបាវចរកុសល ជាអារម្មណប្បច្ច័យដល់ធម៌ទាំង ៨ ពួកនេះ គឺកាមាវចរកុសល រូបាវចរកុសល អរូបាវចរកុសល អកុសល អរូបាវចរវិបាក កាមាវចរកិរិយា រូបាវចរកិរិយា និងអរូបាវចរកិរិយា ។ អារម្មណ៍ដែលជាលោកុត្តរកុសល ជាអារម្មណប្បច្ច័យដល់កុសល និងកិរិយាប៉ុណ្ណោះ ព្រោះកុសល និងកិរិយា

នោះ ជាកាមាវចរ និងរូបាវចរ ។ អារម្មណ៍ដែលជាអកុសលជាបច្ច័យដល់ធម៌ ៦ ពួកនេះ គឺកាមាវចរកុសល រូបាវចរកុសល អកុសល កាមាវចរ-វិបាក កាមាវចរកិរិយា និងរូបាវចរកិរិយា ។ អារម្មណ៍ដែលជាកាមាវចរវិបាក ជាអារម្មណប្បច្ច័យដល់ធម៌ ៦ ពួកនេះ គឺកាមាវចរកុសល រូបាវចរកុសល អកុសល កាមាវចរវិបាក កាមាវចរកិរិយា រូបាវចរកិរិយា ។ អារម្មណ៍ដែលជារូបាវចរវិបាក ជាអារម្មណប្បច្ច័យដល់ធម៌ ៥ ពួកនេះ គឺកាមាវចរ-កុសល រូបាវចរកុសល អកុសល កាមាវចរកិរិយា និងរូបាវចរកិរិយា ។ អារម្មណ៍ដែលជារូបាវចរវិបាក ក៏ជាអារម្មណប្បច្ច័យដល់ធម៌ ៥ ពួកនេះ ដូចគ្នា ។ អារម្មណ៍ដែលជាលោកុត្តរវិបាក ជាអារម្មណប្បច្ច័យចំពោះកុសល និងកិរិយាប៉ុណ្ណោះ ដោយកុសល និងកិរិយានោះ ជាកាមាវចរ និងរូបាវចរ ។

អារម្មណ៍ដែលជាកាមាវចរកិរិយា ជាអារម្មណប្បច្ច័យដល់ធម៌ ៦ ពួកនេះ គឺកាមាវចរកុសល រូបាវចរកុសល អកុសល កាមាវចរវិបាក កាមា-វចរកិរិយា និងរូបាវចរកិរិយា ។ បណ្ដាធម៌ ៦ ពួកនេះ អារម្មណ៍ដែលជារូបាវចរកិរិយា ជាអារម្មណប្បច្ច័យដល់ធម៌ ៥ ពួក វៀរកាមាវចរវិបាក ។ អារម្មណ៍ដែលជាអរូបាវចរកិរិយា ជាអារម្មណប្បច្ច័យដល់ធម៌ ៦ ពួកនេះ គឺធម៌ ៥ ពួកនោះ និងអរូបាវចរកិរិយា ។ អារម្មណ៍ គឺរូប ពោល គឺរូបក្ខន្ធ ដែលមានសមុដ្ឋាន ៤ ជាអារម្មណប្បច្ច័យដល់ធម៌ ៦ ពួកនេះ គឺកាមាវចរ-កុសល រូបាវចរកុសល អកុសល កាមាវចរវិបាក កាមាវចរកិរិយា និង រូបាវចរកិរិយា ។ អារម្មណ៍ គឺនិព្វាន ជាអារម្មណប្បច្ច័យដល់ធម៌ ៦ ពួក

នេះ គឺកាមាវចរកុសល រូបាវចរកុសល លោកុត្តរកុសល លោកុត្តរវិបាក កាមាវចរកិរិយា និងរូបាវចរកិរិយា ។ អាចារ្យពួកខ្លះ មិនយករូបាវចរ-កុសល និងរូបាវចរកិរិយា ។ ពាក្យនោះ អ្នកសិក្សាគប្បីពិចារណាតាមសមគួរ ។ ឯអារម្មណ៍ដែលជាបញ្ញត្តិ មានប្រការផ្សេងៗ ជាអារម្មណប្បច្ច័យដល់ធម៌ ៩ ពួកនេះ គឺកុសលដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ អកុសល រូបាវចរវិបាក អរូបាវចរវិបាក និងកិរិយាដែលប្រព្រឹត្តទៅ ក្នុងភូមិទាំង ៣ ។ បណ្តាអារម្មណ៍ទាំងនោះ អារម្មណ៍ណាៗ ជាបច្ច័យដល់ធម៌ណាៗ ធម៌នោះៗ ឈ្មោះថា ជាបច្ចយុប្បន្ននៃអារម្មណ៍នោះៗ ។ អ្នកសិក្សា គប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងអារម្មណប្បច្ច័យ ដូចពណ៌នាមកនេះ ដូច្នេះឯង ៕

## អធិប្បាយអារម្មណប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## អធិបតិប្បច្ច័យ

[ ៤ ] ពាក្យថា អធិបតិប្បច្ច័យ បានដល់ ឆន្ទាធិបតិ ជាបច្ច័យនៃពួកធម៌ដែលប្រកបដោយឆន្ទៈផង នៃពួករូបដែលកើតអំពីឆន្ទៈនោះផង ដោយអធិបតិប្បច្ច័យ វីរិយាធិបតិ ជាបច្ច័យនៃពួកធម៌ដែលប្រកបដោយវីរិយៈផង នៃពួករូបដែលកើតអំពីវីរិយៈនោះផង ដោយអធិបតិប្បច្ច័យ ចិត្តាធិបតិ ជាបច្ច័យនៃពួកធម៌ដែលប្រកបដោយចិត្តផង នៃពួករូបដែលកើតអំពីចិត្តនោះផង ដោយអធិបតិប្បច្ច័យ វីមំសាធិបតិ ជាបច្ច័យនៃពួកធម៌ដែលប្រកបដោយវីមំសៈផង នៃពួករូបដែលកើតអំពីវីមំសៈនោះផង ដោយអធិប-តិប្បច្ច័យ ពួកធម៌ណាៗ ធ្វើនូវធម៌ណាៗ ឲ្យជាទីគោរព ហើយកើតឡើង ពួកធម៌នោះៗ គឺចិត្តចេតសិកធម៌ ជាបច្ច័យនៃពួកធម៌នោះៗ ដោយអធិប-តិប្បច្ច័យ ។

# អធិប្បាយ

## អធិបតិប្បច្ចយនិទ្ទេស

[ ៤ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងអធិបតិប្បច្ចយនិទ្ទេសដូចតទៅ

បទថា **ឆន្ទាធិបតិ** បានដល់ អធិបតី ពោល គឺឆន្ទៈ ។ ពាក្យថា **ឆន្ទាធិបតិ** នោះ ជាឈ្មោះនៃកត្តុកម្យតាឆន្ទៈ ( ឆន្ទៈនៃភាពជាបុគ្គលប្រាថ្នាដើម្បីធ្វើ ) ដែលកើតឡើងក្នុងវេលាចិត្តធ្វើឆន្ទៈឲ្យធ្ងន់ ឲ្យជាធំកើតឡើង ។ ក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។

សួរថា ព្រោះហេតុអ្វី ក្នុងអធិបតិប្បច្ចយនិទ្ទេសនេះ ព្រះមានព្រះភាគមិនត្រាស់ថា អធិបតីជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយអធិបតី ដូចក្នុងនិទ្ទេសនៃហេតុប្បច្ច័យ ដែលត្រាស់ថា ហេតុជាបច្ច័យនៃពួកធម៌ ដែលប្រកបដោយហេតុ ដូច្នេះ តែទ្រង់សម្តែងទេសនា ដោយន័យថា ឆន្ទាធិបតីជាបច្ច័យនៃពួកធម៌ដែលប្រកបដោយឆន្ទៈ ដូច្នេះជាដើម ឆ្លើយថា ព្រោះអធិបតី មិនមានក្នុងខណៈជាមួយគ្នា ។ ពិតហើយ ក្នុងន័យមុន ហេតុ ២ ឬ ៣ ជាហេតុប្បច្ច័យក្នុងខណៈជាមួយគ្នាបាន ព្រោះមិនលះភាវៈ ដែលឧបការៈ ដោយអត្ថថា ជាឫសគល់ តែអធិបតី ជាឧបការៈ ដោយអត្ថថា ជាធំ និងធម៌ជាច្រើន ឈ្មោះថា មិនជាធំ ក្នុងខណៈជាមួយគ្នាឡើយ ព្រោះហេតុនោះ ធម៌ទាំងនោះ ទោះបីកើតឡើងជាមួយគ្នា ក៏មិនជាអធិបតិប្បច្ច័យក្នុងខណៈជាមួយគ្នាឡើយ ព្រោះភាវៈដែលអធិបតិប្បច្ច័យ មិនមានក្នុងខណៈជាមួយគ្នានោះ ។ ក្នុងអធិបតិប្បច្ច័យនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងទេសនា ដូចពោលមកហើយ ។

*ព្រះមានព្រះភាគ ទ្រង់សម្ដែងសហជាតាធិបតីយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្ដែងអារម្មណាធិបតី ទើបទ្រង់ផ្ដើមពាក្យថា* **យំ យំ ធម្មំ គរុំ កត្វា** *ជាដើម ។*

*បណ្ដាបទទាំងនោះ បទថា* **យំ យំ ធម្មំ** *គឺនូវធម៌ដែលជាអារម្មណ៍ណាមួយ ។ បទថា* **គរុំ កត្វា** *បានដល់ ធ្វើឲ្យធ្ងន់ គឺឲ្យធ្ងន់ពិតប្រាកដ ឲ្យជាធម្មជាតដែលគួរបាន មិនគួរបោះបង់ចោល មិនគួរមើលងាយ ដោយអំណាចការគោរព និងកោតក្រែង ឬដោយអំណាចការពេញចិត្ត ។ បទថា* **តេ តេ ធម្មា** *គឺធម៌ដែលគួរធ្វើឲ្យធ្ងន់នោះៗ ។ បទថា* **តេសំ តេសំ** *គឺធម៌ដែលធ្វើឲ្យធ្ងន់នោះៗ ។ បទថា* **អធិបតិប្បច្ចយេន** *គឺជាបច្ច័យ ដោយអំណាចអារម្មណាធិបតិប្បច្ច័យ ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ ។*

*ឈ្មោះថា អធិបតីនេះ មាន ២ យ៉ាង គឺសហជាតាធិបតី និងអារម្មណាធិបតី ។ ក្នុងអធិបតី ២ យ៉ាងនោះ សហជាតាធិបតីមាន ៤ យ៉ាង មានឆន្ទាធិបតីជាដើម ។ ក្នុង ៤ យ៉ាងនោះ អធិបតីនីមួយៗ កាលពោលដោយភូមិ មាន ៤ យ៉ាង គឺកាមាវចរជាដើម ។ បណ្ដាអធិបតីដែលជាកាមាវចរជាដើមនោះ អធិបតីដែលជាកាមាវចរ មាន ៣ យ៉ាង គឺកុសល អកុសល និងកិរិយា តែកាលដល់អកុសល រមែងមិនមានវីមំសាធិបតី ។ អធិបតីដែលជារូបាវចរ និងអរូបាវចរ នីមួយៗ មាន ២ យ៉ាង គឺកុសល និងកិរិយា ។ អធិបតីដែលជាលោកុត្តរ មាន ២ យ៉ាង គឺជាកុសល និង*

វិបាក តែពោលដោយជាតិ អារម្មណាធិបតី មាន ៦ យ៉ាង គឺកុសល អកុសល វិបាក កិរិយា រូប និងនិព្វាន ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងការចែកដោយប្រការផ្សេងៗ ក្នុងអធិការនេះ ដូចពណ៌នាមកនេះ ។

ក្នុងសហជាតាធិបតីនេះ ដែលផ្សេងគ្នាដូចពណ៌នាមកហើយនេះ អធិបតីពោល គឺកាមាវចរកុសល និងកាមាវចរកិរិយា ជាអធិបតិប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តជាមួយខ្លួន និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ក្នុងវេលាដែលសហជាតធម៌ធ្វើអធិបតីដទៃ មានឆន្ទៈជាដើម ឲ្យជាធំ កើតឡើងក្នុងចិត្តុប្បាទ ដែលប្រកបដោយហេតុ ២ និងហេតុ ៣ ។ ក្នុងអធិបតី ពោលគឺរូបាវចរកុសល និងរូបាវចរកិរិយាក៏ន័យនេះដូចគ្នា ។ ក្នុងអធិការនេះ បានចំពោះអធិបតីដែលជារូបាវចរកុសល និងរូបាវចរកិរិយាប៉ុណ្ណោះ ព្រោះថាធម៌ទាំងនោះ រមែងកើតឡើង ដោយមិនប្រាសចាកសហជាតាធិបតី ។ ឯអធិបតី ពោល គឺអរូបាវចរកុសល និងអរូបាវចរកិរិយា ដូចគ្នានឹងអធិបតីដែលជារូបាវចរ ក្នុងបញ្ចវោការភព ។ តែក្នុងចតុវោការភព រមែងជាអធិបតិប្បច្ច័យដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ។ អធិបតីដែលជាកាមាវចរទាំងអស់ ដែលកើតឡើងក្នុងចតុវោការភពនោះ ក៏ដូចគ្នា ។ អធិបតីដែលជាលោកុត្តរ ទាំងខាងកុសល និងវិបាក រមែងជាអធិបតិប្បច្ច័យដល់ធម៌ដែលសម្បយុត្ត និងរូបដែលមានចិត្តជាសមុដ្ឋានតែម្យ៉ាង ក្នុងបញ្ចវោការភព ។ ក្នុងចតុវោការភព ជាបច្ច័យចំពោះដល់អរូបធម៌ប៉ុណ្ណោះ ។

អកុសលជាអធិបតិប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តដោយពិតប្រាកដ

ក្នុងមិច្ឆត្តនិយតចិត្ត និងដល់រូបដែលមានចិត្តជាសមុដ្ឋានក្នុងកាមភព ។

អកុសលដែលជាអនិយតធម៌ គឺធម៌ដែលឲ្យផលមិនពិតប្រាកដក្នុងលំដាប់ចុតិចិត្ត ជាអធិបតិប្បច្ច័យដល់ធម៌ដែលសម្បយុត្ត និងដល់រូបដែលមានចិត្តជាសមុដ្ឋានទាំងនោះ ក្នុងវេលាដែលខ្វះជាអធិបតីក្នុងកាមភព និងរូបភព ។ ជាអធិបតិប្បច្ច័យចំពោះដល់អរូបធម៌ប៉ុណ្ណោះ ក្នុងអរូបភព ។ នេះជាន័យក្នុងសហជាតាធិបតិប្បច្ច័យ មានប្រមាណប៉ុណ្ណោះ ។

ឯក្នុងអារម្មណាធិបតិប្បច្ច័យ មានអធិប្បាយដូចតទៅ

អារម្មណាធិបតីដែលជាកាមាវចរកុសល ជាអារម្មណាធិបតិប្បច្ច័យដល់ធម៌ ២ ពួក គឺកាមាវចរកុសល និងអកុសល ដែលសហគតៈដោយលោភៈ ។ ក្នុងអារម្មណាធិបតិប្បច្ច័យដែលជាកុសល ក្នុងរូបាវចរ និងអរូបាវចរ ក៏ន័យនេះដូចគ្នា ។

ឯអារម្មណាធិបតីដែលជាលោកុត្តរកុសល ជាអារម្មណាធិបតិប្បច្ច័យដល់កុសលដែលជាញាណសម្បយុត្ត និងកិរិយាដែលជាញាណសម្បយុត្តដែលជាកាមាវចរ ។

ឈ្មោះថា អារម្មណាធិបតីដែលជាអកុសល ព្រះមានព្រះភាគត្រាស់ហៅថា ចិត្តុប្បាទដែលសហគតៈដោយលោភៈ ចិត្តុប្បាទនោះ ជាអារម្មណាធិបតិប្បច្ច័យចំពោះអកុសលដែលសហគតៈដោយលោភៈប៉ុណ្ណោះ ។

ឯអារម្មណាធិបតីខាងវិបាក ដែលជាកាមាវចរ រូបាវចរ និងអរូបាវចរ ជាអារម្មណាធិបតិប្បច្ច័យដល់អកុសល ដែលសហគតៈដោយលោភៈ

*ប៉ុណ្ណោះ ។ អារម្មណាធិបតីដែលជាលោកុត្តរវិបាក ជាអារម្មណាធិប-តិប្បច្ច័យដល់កុសលញាណសម្បយុត្ត និងកិរិយាញាណសម្បយុត្ត ខាងកាមាវចរប៉ុណ្ណោះ ។*

*កាលពោលដោយប្រភេទដែលជាកាមាវចរជាដើម អារម្មណាធិបតីដែលជាកិរិយាទាំង ៣ ជាអារម្មណាធិបតិប្បច្ច័យដល់អកុសល ដែលសហគតៈដោយលោភៈប៉ុណ្ណោះ ។ អារម្មណាធិបតីដែលជារូបក្ខន្ធ ពោលគឺរូបដែលកើតអំពីសមុដ្ឋានទាំង ៤ ជាអារម្មណាធិបតិប្បច្ច័យដល់អកុសលដែលសហគតៈដោយលោភៈប៉ុណ្ណោះ ។ និព្វាន ជាអារម្មណាធិបតិប្បច្ច័យដល់ធម៌ ៤ ពួក គឺកុសលញាណសម្បយុត្ត កិរិយាញាណសម្បយុត្តដែលជាកាមាវចរ លោកុត្តរកុសល និងលោកុត្តរវិបាក ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យដោយបច្ចយុប្បន្នក្នុងអារម្មណាធិបតិប្បច្ច័យនេះ យ៉ាងនេះឯង ។*

## អធិប្បាយអធិបតិប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## អនន្តរប្បច្ច័យ

[ ៥ ] ពាក្យថា អនន្តរប្បច្ច័យ បានដល់ ចក្ខុវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយអនន្តរប្បច្ច័យ មនោធាតុក្តី ពួកធម៌ដែលប្រកបដោយមនោធាតុនោះក្តី ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយអនន្តរប្បច្ច័យ សោតវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយអនន្តរប្បច្ច័យ មនោធាតុក្តី ពួកធម៌ដែលប្រកបដោយមនោធាតុនោះក្តី ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយអនន្តរប្បច្ច័យ ឃានវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយឃានវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយអនន្តរប្បច្ច័យ មនោធាតុក្តី ពួកធម៌ដែលប្រកបដោយមនោធាតុនោះក្តី ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយអនន្តរប្បច្ច័យ ជិវ្ហាវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយអនន្តរប្បច្ច័យ មនោធាតុក្តី ពួកធម៌ដែលប្រកបដោយមនោធាតុនោះក្តី ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះ

ផង ដោយអនន្តរប្បច្ច័យ កាយវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយអនន្តរប្បច្ច័យ មនោធាតុក្តី ពួកធម៌ដែលប្រកបដោយមនោធាតុនោះក្តី ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយអនន្តរប្បច្ច័យ ពួកកុសលធម៌មុនៗ ជាបច្ច័យនៃពួកកុសលធម៌ក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកកុសលធម៌មុនៗ ជាបច្ច័យនៃពួកអព្យាកតធម៌ក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកអកុសលធម៌មុនៗ ជាបច្ច័យនៃពួកអកុសលធម៌ក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកអកុសលធម៌មុនៗ ជាបច្ច័យនៃពួកអព្យាកតធម៌ក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកអព្យាកតធម៌មុនៗ ជាបច្ច័យនៃពួកអព្យាកតធម៌ក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកអព្យាកតធម៌មុនៗ ជាបច្ច័យនៃពួកកុសលធម៌ក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកអព្យាកតធម៌មុនៗ ជាបច្ច័យនៃពួកអកុសលធម៌ក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកធម៌ណាៗ កើតឡើងក្នុងលំដាប់នៃពួកធម៌ណាៗ ពួកធម៌នោះៗ គឺចិត្តចេតសិកធម៌ ជាបច្ច័យនៃពួកធម៌នោះៗ ដោយអនន្តរប្បច្ច័យ ។

# អធិប្បាយ

## អនន្តរប្បច្ចយនិទ្ទេស

[ ៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនន្តរប្បច្ចយនិទ្ទេសដូចតទៅ

បទថា **មនោធាតុយា** គឺដល់វិបាកមនោធាតុ ។ បទថា **មនោ-វិញ្ញាណធាតុយា** គឺដល់អហេតុកវិបាកមនោវិញ្ញាណធាតុ ដែលធ្វើសន្តី-រណកិច្ច គឺពិចារណាអារម្មណ៍ ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគ គួរត្រាស់ដល់មនោវិញ្ញាណធាតុ ដែលធ្វើវោដ្ឋព្វនៈ ជវន តទារម្មណៈ និងភវង្គ តែទ្រង់មិនបានត្រាស់ ទើបទ្រង់សង្ខេបទេសនា ដោយសម្ដែងន័យថា អ្នកសិក្សាគប្បីជ្រាបបានដោយន័យនេះ ។ ធាតុទាំងនោះ ដែលព្រះមានព្រះភាគទ្រង់សង្ខេបចូលក្នុងន័យទី ៦ ថា **បុរិមា បុរិមា កុសលា ធម្មា** ជាដើម អ្នកសិក្សាគប្បីជ្រាបថា ទ្រង់មិនត្រាស់ក្នុងអធិការនេះទៀតឡើយ ។

បណ្ដាបទទាំងនោះ បទថា **បុរិមា បុរិមា** អ្នកសិក្សាគប្បីជ្រាបថា បានដល់ កុសលជវន ធម៌ដែលរលត់ជាប់តគ្នាទៅក្នុងទ្វារទាំង ៦ ។

បទថា **បច្ឆិមានំ បច្ឆិមានំ** បានដល់ ធម៌ គឺកុសលជវនដែលកើតឡើងជាប់តគ្នាទៅនោះឯង ។

បទថា **កុសលានំ** បានដល់ កុសលចិត្តប្រភេទដូចគ្នា ។

ឯបទថា **អព្យាកតានំ** នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចតទារម្មណៈ ភវង្គ និងផលសមាបត្តិដែលកើតឡើង បន្ទាប់អំពីកុសល ។ បទថា **អព្យាកតានំ** ក្នុងអកុសលមូលកៈ បានដល់ អព្យាកតៈដែលជាតទារម្មណៈ និងភវង្គប៉ុណ្ណោះ ។ បទថា **អព្យាកតានំ** ក្នុងអព្យាកតមូលកៈ

បានដល់ អព្យាកតៈដែលជាកិរិយា និងវិបាកដែលប្រព្រឹត្តទៅដោយអំណាចនៃអាវជ្ជនៈ និងជវន ឬដោយអំណាចនៃកវត្ត ។ ន័យនេះ រមែងប្រើបានក្នុងវីថិចិត្តដែលប្រព្រឹត្តទៅតាំងអំពីកិរិយាមនោធាតុ ដែលធ្វើវោដ្ឋព្វនកិច្ចរហូតដល់មនោវិញ្ញាណធាតុនោះឯង ។

បទថា **កុសលានំ** បានដល់ កុសលជវនដួងទី ១ ដែលកើតបន្ទាប់អំពីវោដ្ឋព្វនចិត្តក្នុងបញ្ចទ្វារ និងដែលកើតបន្ទាប់អំពីអាវជ្ជនចិត្តក្នុងមនោទ្វារ ក្នុងបទថា **អកុសលានំ** ក៏ន័យនេះដូចគ្នា ។

បទថា **យេសំ យេសំ** នេះ ជាគ្រឿងកំណត់ដោយសង្ខេបនូវធម៌ដែលជាអនន្តរប្បច្ច័យទាំងអស់ ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះប៉ុណ្ណេះ ។

ឈ្មោះថា អនន្តរប្បច្ច័យនេះ អ្នកសិក្សាគប្បីជ្រាបថា បានដល់ ពួកនៃអរូបធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ វៀរនិព្វាន ។ អនន្តរប្បច្ច័យនេះ ចែកដោយអំណាចនៃជាតិបាន ៤ ជាតិ គឺជាកុសល អកុសល វិបាក និងកិរិយា ។ ក្នុង ៤ ជាតិនោះ អនន្តរប្បច្ច័យដែលជាកុសល មាន ៤ យ៉ាងចែកជាកាមាវចរជាដើម ។ អកុសលជាកាមាវចរតែម្យ៉ាង ។ វិបាកប្រព្រឹត្តទៅក្នុងភូមិទាំង ៤ ឯអនន្តរប្បច្ច័យ ដែលជាកិរិយាប្រព្រឹត្តទៅក្នុងភូមិ ៣ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងអនន្តរប្បច្ច័យនេះ ដូចពណ៌នាមកហើយ ។

ក្នុងអនន្តរប្បច្ច័យ ដែលចែកបានដូចសម្តែងមកហើយ កាមាវចរ-

កុសល ជាអនន្តរប្បច្ច័យដល់កាមាវចរកុសលដែលដូចគ្នានឹងខ្លួនប៉ុណ្ណោះ ។ ឯកាមាវចរកុសលដែលជាញាណសម្បយុត្ត ជាអនន្តរប្បច្ច័យដល់ធម៌ ៣ ពួក គឺរូបាវចរកុសល អរូបាវចរកុសល និងលោកុត្តរកុសល ។

កាមាវចរកុសល ជាអនន្តរប្បច្ច័យដល់ធម៌ ៤ ពួក គឺកាមាវចរវិបាក រូបាវចរវិបាក អរូបាវចរវិបាក និងលោកុត្តរវិបាកដែលជាញាណសម្បយុត្ត ។

រូបាវចរកុសល ជាអនន្តរប្បច្ច័យដល់ធម៌ ៣ គឺរូបាវចរកុសល កាមាវចរវិបាកដែលជាញាណសម្បយុត្ត និងរូបាវចរវិបាក ។ អរូបាវចរកុសល ជាអនន្តរប្បច្ច័យដល់ធម៌ ៤ ពួកនេះ ដោយមិនប្លែកគ្នា គឺវិបាកទាំង ២ ( កាមវិបាក និងរូបវិបាក ) កុសលរបស់ខ្លួន និងវិបាករបស់ខ្លួន ។ ក្នុងអធិការនេះ កាលពោលដោយពិសេស នេវសញ្ញានាសញ្ញាយតនកុសល ជាអនន្តរប្បច្ច័យដល់លោកុត្តរវិបាក ពោល គឺអនាគាមិផល ។

លោកុត្តរកុសល ជាអនន្តរប្បច្ច័យដល់លោកុត្តរវិបាកប៉ុណ្ណោះ ។

អកុសល ជាអនន្តរប្បច្ច័យដល់អកុសល កុសលវិបាក និងអកុសលវិបាក ដោយមិនប្លែកគ្នា ។ កាលពោលដោយប្លែកគ្នាក្នុងអធិការនេះ អកុសលដែលសម្បយុត្តដោយសុខវេទនា និងឧបេក្ខាវេទនា ជាអនន្តរប្បច្ច័យដល់ធម៌ ៤ គឺកុសលវិបាក អកុសលវិបាក រូបាវចរវិបាក និងអរូបាវចរវិបាក ។

កាមាវចរវិបាកដែលជាញាណសម្បយុត្តក្តី ដែលជាញាណវិប្បយុត្តក្តី ជាអនន្តរប្បច្ច័យដល់ធម៌ ៤ ពួកនេះ គឺកាមាវចរកិរិយាអាវជ្ជនចិត្ត វិបាក-

ញាណសម្បយុត្ត រូបាវចរវិបាក អរូបាវចរវិបាក ដែលកើតឡើងដោយអំណាចបដិសន្ធិ[១] ។

រូបាវចរវិបាក ជាអនន្តរប្បច្ច័យដល់ធម៌ ៤ ពួកនេះ គឺសហេតុកកាមាវចរវិបាក រូបាវចរវិបាក អរូបាវចរវិបាក និងកាមាវចរកិរិយាអាវជ្ជនចិត្ត ។

អរូបាវចរវិបាក ជាអនន្តរប្បច្ច័យដល់ធម៌ ៣ ពួកនេះ គឺតិហេតុកកាមាវចរវិបាក អរូបាវចរវិបាក និងកាមាវចរកិរិយាអាវជ្ជនចិត្ត ។

លោកុត្តរវិបាក ជាអនន្តរប្បច្ច័យដល់ធម៌ ៤ ពួកនេះ គឺតិហេតុកកាមាវចរវិបាក រូបាវចរវិបាក អរូបាវចរវិបាក និងលោកុត្តរវិបាក ។

កាមាវចរកិរិយា ជាអនន្តរប្បច្ច័យដល់ធម៌ ៩ ពួកនេះ គឺកាមាវចរកុសល អកុសល វិបាកចិត្តទាំង ៤ ភូមិ និងកិរិយាចិត្តទាំង ៣ ភូមិ ។

រូបាវចរកិរិយា ជាអនន្តរប្បច្ច័យដល់ធម៌ ៣ ពួកនេះ គឺតិហេតុកកាមាវចរវិបាក រូបាវចរវិបាក និងរូបាវចរកិរិយា ។

អរូបាវចរកិរិយា ជាអនន្តរប្បច្ច័យដល់ធម៌ ៥ ពួក គឺតិហេតុកកាមាវចរវិបាក រូបាវចរវិបាក អរូបាវចរវិបាក លោកុត្តរវិបាក និងអរូបាវចរកិរិយា ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យដោយធម៌ ដែលជាបច្ចយុប្បន្ន ក្នុងអនន្តរប្បច្ច័យនេះ យ៉ាងនេះឯង ។ល។

---

១- សេចក្តីត្រង់នេះ អត្ថមិនប្រាកដ បណ្ឌិតគប្បីកាន់យកតាមបាលីនេះ ( ថា ) កាមាវចរវិបាកស្ស ញាណសម្បយុត្តោ វា ញាណវិប្បយុត្តោ វា វិបាកោ កាមាវចរកិរិយាវជ្ជនស្ស , ញាណសម្បយុត្តវិបាកោ បនេត្ថ បដិសន្ធិវសេន ឧប្បជ្ជមានស្ស រូបាវចរ-រូបាវចរវិបាកស្សាបីតិ ឥមេសំ ចតុន្នំ រាសីនំ អនន្តរប្បច្ចយោ ហោតិ ។

# អភិធម្មបិដក

## សមនន្តរប្បច្ច័យ

[ ៦ ] ពាក្យថា សមនន្តរប្បច្ច័យ បានដល់ ចក្ខុវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយសមនន្តរប្បច្ច័យ មនោធាតុក្តី ពួកធម៌ដែលប្រកបដោយមនោធាតុនោះក្តី ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយសមនន្តរប្បច្ច័យ សោតវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយសោតវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយសមនន្តរប្បច្ច័យ មនោធាតុក្តី ពួកធម៌ដែលប្រកបដោយមនោធាតុនោះក្តី ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយសមនន្តរប្បច្ច័យ ឃានវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយឃានវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយសមនន្តរប្បច្ច័យ មនោធាតុក្តី ពួកធម៌ដែលប្រកបដោយមនោធាតុនោះក្តី ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយសមនន្តរប្បច្ច័យ ជិវ្ហាវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយសមនន្តរប្បច្ច័យ មនោធាតុក្តី ពួកធម៌ដែលប្រកបដោយមនោធាតុនោះក្តី ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុ

នោះផង ដោយសមនន្តរប្បច្ច័យ កាយវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកប ដោយកាយវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែល ប្រកបដោយមនោធាតុនោះផង ដោយសមនន្តរប្បច្ច័យ មនោធាតុក្តី ពួកធម៌ ដែលប្រកបដោយមនោធាតុនោះក្តី ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួក ធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយសមនន្តរប្បច្ច័យ ពួក កុសលធម៌មុនៗ ជាបច្ច័យនៃពួកកុសលធម៌ក្រោយៗ ដោយសមនន្តរប្បច្ច័យ ពួកកុសលធម៌មុនៗ ជាបច្ច័យនៃពួកអព្យាកតធម៌ក្រោយៗ ដោយសមនន្ត-រប្បច្ច័យ ពួកអកុសលធម៌មុនៗ ជាបច្ច័យនៃពួកអកុសលធម៌ក្រោយៗ ដោយ សមនន្តរប្បច្ច័យ ពួកអកុសលធម៌មុនៗ ជាបច្ច័យនៃពួកអព្យាកតធម៌ក្រោយៗ ដោយសមនន្តរប្បច្ច័យ ពួកអព្យាកតធម៌មុនៗ ជាបច្ច័យនៃពួកអព្យាកតធម៌ ក្រោយៗ ដោយសមនន្តរប្បច្ច័យ ពួកអព្យាកតធម៌មុនៗ ជាបច្ច័យនៃពួក កុសលធម៌ក្រោយៗ ដោយសមនន្តរប្បច្ច័យ ពួកអព្យាកតធម៌មុនៗ ជាបច្ច័យ នៃពួកអកុសលធម៌ក្រោយៗ ដោយសមនន្តរប្បច្ច័យ ពួកធម៌ណាៗ កើតឡើង ក្នុងលំដាប់ស្មើ នៃពួកធម៌ណាៗ ពួកធម៌នោះៗ គឺចិត្តចេតសិកធម៌ ជាបច្ច័យ នៃពួកធម៌នោះៗ ដោយសមនន្តរប្បច្ច័យ ។

# អធិប្បាយ

## សមនន្តរប្បច្ចយនិទ្ទេស

[ ៦ ] *សមនន្តរប្បច្ចយនិទ្ទេស ដូចគ្នានឹងអនន្តរប្បច្ច័យនេះឯង ។ តែបច្ច័យទាំង ២ នេះ ទូលំទូលាយខ្លាំង ព្រោះហេតុនោះ គប្បីកំណត់កាន់យកសេចក្តីពិស្តារនៃបច្ច័យទាំង ២ នោះ ដោយការកើតឡើងរបស់ចិត្តទាំងអស់ ។៚*

**អធិប្បាយសមនន្តរប្បច្ចយនិទ្ទេស ចប់**

# អភិធម្មបិដក

## សហជាតប្បច្ច័យ

[ ៧ ] ពាក្យថា សហជាតប្បច្ច័យ បានដល់ ពួកធម៌ ៤ ដែលមិនមានរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយសហជាតប្បច្ច័យ មហាភូតរូប ៤ ជាបច្ច័យនៃគ្នានិងគ្នា ដោយសហជាតប្បច្ច័យ នាមរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយសហជាតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកចិត្តចេតសិកធម៌ ជាបច្ច័យនៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន ដោយសហជាតប្បច្ច័យ មហាភូតរូប ជាបច្ច័យនៃឧបាទារូបទាំងឡាយ ដោយសហជាតប្បច្ច័យ ជួនកាល ពួកធម៌ដែលមានរូប ជាបច្ច័យនៃពួកធម៌ដែលមិនមានរូប ដោយសហជាតប្បច្ច័យ ជួនកាល ជាបច្ច័យដោយនសហជាតប្បច្ច័យ ។

# អធិប្បាយ

## សហជាតប្បច្ចយនិទ្ទេស

[ ៧ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងសហជាតប្បច្ចយនិទ្ទេស ដូចតទៅ

បទថា **អញ្ញមញ្ញំ** ប្រែថា នូវគ្នានិងគ្នា ។ ដោយបទនេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងថា ធម៌ទាំងនោះជាបច្ច័យ និងជាបច្ចយុប្បន្ន ក្នុងខណៈជាមួយគ្នា ។ បទថា **ឱក្កន្តិក្ខណេ** គឺក្នុងបដិសន្ធិក្ខណៈ ក្នុងបញ្ចវោការភព ។ ពិតហើយ ក្នុងខណៈនោះ នាម និងរូប កើតឡើង ដូចឈានចុះ គឺដូចស្ទុះទៅ បានដល់ ដូចមកអំពីលោកដទៃ ហើយចូលមកកាន់លោកនេះ ព្រោះហេតុនោះ ទើបខណៈនោះ ព្រះមានព្រះភាគត្រាស់ហៅថា **ឱក្កន្តិក្ខណៈ** ។ ក្នុងអធិការនេះ បទថា **រូបំ** ព្រះមានព្រះភាគ ទ្រង់បំណាងយកហទយវត្ថុប៉ុណ្ណោះ ។ ពិតហើយ ហទយវត្ថុនោះ រមែងឲ្យប្រយោជន៍ដើម្បីជាសហជាតប្បច្ច័យ ដល់គ្នានិងគ្នា ដល់នាម នាមក៏ឲ្យប្រយោជន៍ដើម្បីជាសហជាតប្បច្ច័យ ដល់គ្នានិងគ្នា ដល់ហទយវត្ថុនោះ ។ បទថា **ចិត្តចេតសិកា** គឺខន្ធ ៤ ក្នុងបវត្តិកាល ។ ក្នុងបទថា **សហជាតបច្ចយេន** នេះ រូបដែលមានចិត្តជាសមុដ្ឋាន រមែងមិនឲ្យប្រយោជន៍ដើម្បីជាបច្ច័យដល់ចិត្ត និងចេតសិក ព្រោះហេតុនោះ ទើបព្រះមានព្រះភាគមិនត្រាស់ថា **អញ្ញមញ្ញំ** ។ ឧបាទារូប មិនឲ្យប្រយោជន៍ដើម្បីជាបច្ច័យដល់មហាភូតរូបដូចគ្នា ។ បទថា **រូបិនោ ធម្មា អរូបីនំ ធម្មានំ** គឺហទយវត្ថុ ជាបច្ច័យដល់នាមក្ខន្ធ ៤ ។

បទថា **កិញ្ចិ កាលេ** គឺក្នុងកាលខ្លះ ។ បទថា **សហជាតប្បច្ចយេន** ត្រាស់សំដៅដល់បដិសន្ធិកាល ។ បទថា **ន សហជាតប្បច្ចយេន** ត្រាស់សំដៅដល់បវត្តិកាល ។

សហជាតប្បច្ច័យនេះ តាំងទុកដោយចំណែក ៦ ដូច្នេះ គឺអរូបក្ខន្ធ ៤ ជាបច្ច័យដល់គ្នានិងគ្នា ដោយអំណាចសហជាតប្បច្ច័យជាដើម ។ ក្នុង ៦ ចំណែកនោះ ៣ ចំណែក ត្រាស់ដោយអំណាចជាសហជាតប្បច្ច័យដល់គ្នានិងគ្នា ៣ ចំណែកទៀត ទ្រង់មិនត្រាស់ដោយអំណាចភាពជាសហជាតប្បច្ច័យ ដល់គ្នានិងគ្នាឡើយ ។ បណ្តាសហជាតប្បច្ច័យ ៦ ចំណែកនោះ អរូបធម៌ប៉ុណ្ណោះ ជាបច្ច័យផង ជាបច្ចយុប្បន្នផង ក្នុងចំណែកទី ១ ។ ចំពោះរូបធម៌តែម្យ៉ាងជាបច្ច័យផង ជាបច្ចយុប្បន្នផង ក្នុងចំណែកទី ២ ។ នាម និងរូប ជាបច្ច័យ និងជាបច្ចយុប្បន្ន ក្នុងចំណែកទី ៣ ។ អរូប ជាបច្ច័យ រូប ជាបច្ចយុប្បន្ន ក្នុងចំណែកទី ៤ ។ រូបប៉ុណ្ណោះ ជាបច្ច័យផង ជាបច្ចយុប្បន្នផង ក្នុងចំណែកទី ៥ ។ រូប ជាបច្ច័យ អរូប ជាបច្ចយុប្បន្ន ក្នុងចំណែកទី ៦ ។ នេះជាពាក្យអធិប្បាយព្រះបាលីក្នុងទីនេះប៉ុណ្ណោះ ។

សហជាតប្បច្ច័យនេះ ចែកដោយជាតិបាន ៥ ជាតិ គឺកុសលជាតិ អកុសលជាតិ វិបាកជាតិ កិរិយាជាតិ និងរូបជាតិ ។ ក្នុងជាតិទាំង ៥ នោះ កុសល ចាត់តាមភូមិ បាន ៤ ភូមិ អកុសល បាន ១ ភូមិ វិបាក បាន ៤ ភូមិ កិរិយា បាន ៣ ភូមិ រូប បានកាមាវចរភូមិតែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងសហជាតប្បច្ច័យនេះ ដោយការចែកជា

ប្រការផ្សេងៗ មានប្រមាណប៉ុណ្ណោះ ។

ក្នុងសហជាតប្បច្ច័យ ដែលចែកហើយនេះ យ៉ាងនេះ កុសល សូម្បីប្រព្រឹត្តទៅក្នុង ៤ ភូមិ ជាសហជាតប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តជាមួយខ្លួនប៉ុណ្ណោះ និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ។ អកុសលក៏ដូចគ្នា ។ ក្នុងសហជាតប្បច្ច័យនេះ ចិត្តណាកើតក្នុងអរូបភូមិ ចិត្តនោះ ជាសហជាតប្បច្ច័យ ដល់អរូបធម៌ប៉ុណ្ណោះ ។ កាមាវចរវិបាក រូបាវចរវិបាក ជាសហជាតប្បច្ច័យ ដល់រូបដែលមានចិត្តជាសមុដ្ឋានផង ដល់ធម៌ដែលសម្បយុត្តផង ។ ក្នុងសហជាតប្បច្ច័យនេះ ចិត្តណា ឲ្យរូបកើតមិនបាន ចិត្តនោះ ជាសហជាតប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ។ ចិត្តណាកើតឡើងក្នុងបដិសន្ធិកាល ចិត្តនោះ ជាសហជាតប្បច្ច័យ ដល់កដត្តារូបផងដែរ ។ អរូបាវចរវិបាក ជាសហជាតប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ។

លោកុត្តរវិបាក ជាសហជាតប្បច្ច័យ ដល់ធម៌ដែលសម្បយុត្ត និងដល់រូប ដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ជាបច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ក្នុងចតុវោការភព ។ កាមាវចរកិរិយា និងអរូបាវចរកិរិយា ជាសហជាតប្បច្ច័យ ដល់ធម៌ដែលសម្បយុត្ត និងដល់រូប ដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ។ ក្នុងចតុវោការភព ជាបច្ច័យចំពោះដល់អរូបធម៌ប៉ុណ្ណោះ ។ រូបាវចរកិរិយា ជាសហជាតប្បច្ច័យដោយចំណែកមួយ ដល់ធម៌ដែលសម្បយុត្ត និងដល់រូប ដែលមានចិត្តជាសមុដ្ឋាន ។ សម្រាប់

រូបដែលកើតអំពីសមុដ្ឋានទាំង ៤ ក្នុងរូបដែលមានកម្មជាសមុដ្ឋាន មហាភូតរូប ១ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ដល់មហាភូតរូប ៣ មហាភូតរូប ៣ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ដល់មហាភូតរូប ១ មហាភូតរូប ២ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ដល់មហាភូតរូប ២ មហាភូតរូប ជាបច្ច័យ ដល់ឧបាទារូប ដោយសហជាតប្បច្ច័យ ។ ក្នុងបដិសន្ធិក្ខណៈរបស់កាមាវចរ និងរូបាវចរ វត្ថុរូប ជាបច្ច័យ ដល់វិបាកក្ខន្ធ ដោយសហជាតប្បច្ច័យ ។ ឯក្នុងរូបដែលមានឧតុ ចិត្ត និងអាហារជាសមុដ្ឋាន មហាភូតរូប ជាបច្ច័យ ដល់គ្នានិងគ្នា និងដល់ឧបាទារូប ដោយសហជាតប្បច្ច័យ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងសហជាតប្បច្ច័យនេះយ៉ាងនេះឯង ។ល។

## អធិប្បាយសហជាតប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## អញ្ញមញ្ញប្បច្ច័យ

[ ៨ ] ពាក្យថា អញ្ញមញ្ញប្បច្ច័យ បានដល់ ខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ មហាភូតរូប ៤ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ នាមរូប ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។

# អធិប្បាយ

## អញ្ញមញ្ញប្បច្ចយនិទ្ទេស

[ ៨ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងអញ្ញមញ្ញប្បច្ចយនិទ្ទេស ដូចតទៅ

បាលីមកហើយ ដោយអំណាចចំណែក ៣ ខាងដើម នៃសហជាតប្បច្ចយនិទ្ទេស កិច្ចពណ៌នាបាលីនោះ ដូចគ្នាតាមដែលពោលហើយ ក្នុងសហជាតប្បច្ចយនិទ្ទេសនោះឯង ព្រោះហេតុនោះ ទើបខ្ញុំមិននាំមកពោលទៀត ។

អញ្ញមញ្ញប្បច្ច័យនេះ ពោលដោយអំណាចនៃជាតិ ចែកចេញបាន ៥ ជាតិ គឺកុសល អកុសល វិបាក កិរិយា និងរូប ។ ក្នុង ៥ ជាតិនោះ កុសល ពោលដោយភូមិ មាន ៤ យ៉ាង ។ សេចក្តីអធិប្បាយទាំងអស់ ដូចគ្នានឹងសហជាតប្បច្ច័យខាងដើមនោះឯង ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងអញ្ញមញ្ញប្បច្ចយនិទ្ទេសនេះ ដូចបានពណ៌នាមកហើយ ។

ក្នុងអញ្ញមញ្ញប្បច្ច័យនេះ ដែលចែកហើយយ៉ាងនេះ កុសលដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៤ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួន ដោយអញ្ញមញ្ញប្បច្ច័យ ។ អកុសលក៏ដូចគ្នា ។ ឯក្នុងវិបាក កាមាវចរវិបាក និងរូបាវចរវិបាក ជាអញ្ញមញ្ញប្បច្ច័យដល់វត្ថុរូប ក្នុងបដិសន្ធិកាល ជាអញ្ញមញ្ញប្បច្ច័យ ដល់សម្បយុត្តធម៌ ក្នុងបវត្តិកាល ។ អរូបាវចរវិបាក និងលោកុត្តរវិបាក ជាបច្ច័យដល់ធម៌ ដែលសម្បយុត្តនឹងខ្លួនប៉ុណ្ណោះ ដោយ

*អញ្ញមញ្ញប្បច្ច័យ ។ កិរិយាចិត្តទាំងអស់ ជាបច្ច័យដល់ធម៌ដែលសម្បយុត្ត ប៉ុណ្ណោះ ដោយអញ្ញមញ្ញប្បច្ច័យ ។ សម្រាប់រូបដែលកើតអំពីសមុដ្ឋានទាំង ៤ ក្នុងរូបដែលកើតអំពីកម្ម មហាភូតរូប ១ ជាបច្ច័យដល់មហាភូតរូប ៣ ដោយអញ្ញមញ្ញប្បច្ច័យ មហាភូតរូប ៣ ជាបច្ច័យដល់មហាភូតរូប ១ ដោយ អញ្ញមញ្ញប្បច្ច័យ មហាភូតរូប ២ ជាបច្ច័យដល់មហាភូតរូប ២ ដោយ អញ្ញមញ្ញប្បច្ច័យ ។ ក្នុងបដិសន្ធិក្ខណៈនៃកាមាវចរ និងរូបាវចរ វត្ថុរូប ជា បច្ច័យដោយវិបាកក្ខន្ធ ដោយអញ្ញមញ្ញប្បច្ច័យ ។ បណ្ដារូបដែលមានឧតុ ចិត្ត និងអាហារជាសមុដ្ឋានចំពោះមហាភូតរូបប៉ុណ្ណោះ ជាបច្ច័យដល់មហាភូតរូប ដោយអញ្ញមញ្ញប្បច្ច័យ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជា បច្ចុប្បន្ន ក្នុងអញ្ញមញ្ញប្បច្ច័យនេះ យ៉ាងនេះឯង ៕*

## អធិប្បាយអញ្ញមញ្ញប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## និស្សយប្បច្ច័យ

[ ៩ ] ពាក្យថា និស្សយប្បច្ច័យ បានដល់ ខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយនិស្សយប្បច្ច័យ មហាភូតរូប ៤ ជាបច្ច័យនៃគ្នានិងគ្នា ដោយនិស្សយប្បច្ច័យ នាមរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយនិស្សយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកចិត្តចេតសិកធម៌ ជាបច្ច័យនៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន ដោយនិស្សយប្បច្ច័យ មហាភូតរូប ជាបច្ច័យនៃឧបាទារូបទាំងឡាយ ដោយនិស្សយប្បច្ច័យ ចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ សោតាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណ-ធាតុផង នៃពួកធម៌ដែលប្រកបដោយសោតវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ ឃានាយតនៈ ជាបច្ច័យនៃឃានវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយឃានវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ ជិវ្ហាយតនៈ ជាបច្ច័យនៃជិវ្ហាវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ មនោធាតុក្តី មនោវិញ្ញាណធាតុក្តី អាស្រ័យនូវរូបណាហើយប្រព្រឹត្តទៅ រូបនោះ ជាបច្ច័យនៃមនោធាតុផង នៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយនិស្សយប្បច្ច័យ ។

# អធិប្បាយ

## និស្សយបច្ចយនិទ្ទេស

[៩] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងនិស្សយបច្ចយនិទ្ទេសដូចតទៅ ព្រះមានព្រះភាគ កាលទ្រង់សម្តែងន័យរបស់សហជាតនិស្សយបច្ច័យ ដោយអំណាចនៃចំណែកទី ៥ ខាងដើមនៃសហជាតបច្ចយនិទ្ទេសហើយ ដើម្បីសម្តែងន័យរបស់បុរេជាតនិស្សយបច្ច័យ ដោយចំណែកទី ៦ ទៀត ទើបទ្រង់ផ្តើមពាក្យថា **ចក្ខាយតនំ ចក្ខុវិញ្ញាណធាតុយា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យំ រូបំ និស្សាយ** ព្រះមានព្រះភាគ ត្រាស់សំដៅដល់វត្ថុរូប ។ ពិតហើយ ចិត្ត ៧៥ នោះ គឺមនោធាតុ ៣ មនោវិញ្ញាណធាតុ ៧២ វៀរអរូបវិបាក អាស្រ័យហទយវត្ថុនោះ ប្រព្រឹត្តទៅ ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះប៉ុណ្ណេះ ។

និស្សយបច្ច័យ ពោលដោយអំណាចជាតិ ចែកចេញជា ៥ ជាតិ ដោយជាកុសលជាដើម ។ ក្នុង ៥ យ៉ាងនោះ កុសលពោលដោយភូមិ មាន ៤ អកុសល មាន ១ ភូមិប៉ុណ្ណោះ វិបាក មាន ៤ ភូមិ កិរិយា មាន ៣ ភូមិ រូប មាន ១ ភូមិប៉ុណ្ណោះ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងនិស្សយបច្ច័យនេះ ដូចពណ៌នាមក ដូច្នេះ ។

ក្នុងនិស្សយបច្ច័យ ដែលចែកហើយយ៉ាងនេះ កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ជាបច្ច័យដល់ខន្ធដែលសម្បយុត្ត និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ដោយនិស្សយបច្ច័យ ។ អកុសលក៏ដូចគ្នា ។

ក្នុងនិស្សយបច្ច័យនេះ ចិត្តណា កើតឡើង ក្នុងអរូបភព ចិត្តនោះ ជានិស្សយបច្ច័យ ដល់អរូបធម៌ប៉ុណ្ណោះ ។

កាមាវចរវិបាក និងរូបាវចរវិបាក ជានិស្សយបច្ច័យ ដល់ធម៌ដែលសម្បយុត្ត និងដល់រូប ដែលមានចិត្តជាសមុដ្ឋាន ក្នុងបវត្តិកាល ជានិស្សយបច្ច័យ ដល់កដត្តារូប ក្នុងបដិសន្ធិកាល ។ អរូបាវចរវិបាក ជានិស្សយបច្ច័យ ដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ។ លោកុត្តរវិបាក ជានិស្សយបច្ច័យ ដល់ធម៌ដែលសម្បយុត្ត និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ជានិស្សយបច្ច័យ ដល់អរូបធម៌ប៉ុណ្ណោះ ក្នុងចតុវោការភព ។ កាមាវចរកិរិយា និងរូបាវចរកិរិយា ជានិស្សយបច្ច័យ ដល់ធម៌ដែលសម្បយុត្ត និងដល់ចិត្តសមុដ្ឋានរូប ក្នុងបញ្ចវោការភព ។ ជាបច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ក្នុងចតុវោការភព ។ រូបាវចរកិរិយា ជានិស្សយបច្ច័យដោយចំណែកមួយ ដល់ធម៌ដែលសម្បយុត្ត និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ។

សម្រាប់រូប ដែលកើតអំពីសមុដ្ឋានទាំង ៤ ក្នុងរូបដែលមានកម្មជាសមុដ្ឋាន មហាភូតរូប ១ ជានិស្សយបច្ច័យដល់មហាភូតរូប ៣ មហាភូតរូប ៣ ជានិស្សយបច្ច័យ ដល់មហាភូតរូប ១ មហាភូតរូប ២ ជានិស្សយបច្ច័យ ដល់មហាភូតរូប ២ មហាភូតរូប ជានិស្សយបច្ច័យ ដល់ឧបាទារូប ក្នុងបញ្ចវោការភព វត្ថុរូប ជានិស្សយបច្ច័យដល់ធម៌ ៤ ពួកនេះ គឺដល់កុសល ក្នុងភូមិទាំង ៤ ដល់អកុសល ដល់វិបាក ក្នុងភូមិ ៣

ដ៏សេស វៀរអរូបវិបាក និងទ្វិបញ្ចវិញ្ញាណចិត្ត និងដល់កិរិយាក្នុងភូមិ ៣ ។

អាយតនៈ ៥ មានចក្ខាយតនៈជាដើម ជានិស្សយប្បច្ច័យ ដល់វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម មួយអន្លើដោយសម្បយុត្តធម៌ ។ បណ្ដារូបដែលមានឧតុ ចិត្ត និងអាហារជាសមុដ្ឋាន មហាភូតរូប ជាបច្ច័យដល់មហាភូតរូប និងជាបច្ច័យដល់ឧបាទារូប ដោយនិស្សយប្បច្ច័យ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងនិស្សយប្បច្ច័យនេះ យ៉ាងនេះឯង ។

## អធិប្បាយនិស្សយប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## ឧបនិស្សយប្បច្ច័យ

[ ១០ ] ពាក្យថា ឧបនិស្សយប្បច្ច័យ បានដល់ ពួកកុសលធម៌មុនៗ ជាបច្ច័យនៃពួកកុសលធម៌ក្រោយៗ ដោយឧបនិស្សយប្បច្ច័យ ពួកកុសលធម៌មុនៗ ជាបច្ច័យនៃពួកអកុសលធម៌ក្រោយៗ ខ្លះ ដោយឧបនិស្សយប្បច្ច័យ ពួកកុសលធម៌មុនៗ ជាបច្ច័យនៃពួកអព្យាកតធម៌ក្រោយៗ ដោយឧបនិស្សយប្បច្ច័យ ពួកអកុសលធម៌មុនៗ ជាបច្ច័យនៃពួកអកុសលធម៌ក្រោយៗ ដោយឧបនិស្សយប្បច្ច័យ ពួកអកុសលធម៌មុនៗ ជាបច្ច័យនៃពួកកុសលធម៌ក្រោយៗ ខ្លះ ដោយឧបនិស្សយប្បច្ច័យ ពួកអកុសលធម៌មុនៗ ជាបច្ច័យនៃពួកអព្យាកតធម៌ក្រោយៗ ដោយឧបនិស្សយប្បច្ច័យ ពួកអព្យាកតធម៌មុនៗ ជាបច្ច័យនៃពួកអព្យាកតធម៌ក្រោយៗ ដោយឧបនិស្សយប្បច្ច័យ ពួកអព្យាកតធម៌មុនៗ ជាបច្ច័យនៃពួកអកុសលធម៌ក្រោយៗ ដោយឧបនិស្សយប្បច្ច័យ បុគ្គលក៏ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យដែរ សេនាសនៈ ក៏ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យដែរ ។

# អធិប្បាយ

## ឧបនិស្សយប្បច្ចយនិទ្ទេស

[ ១០ ] *អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងឧបនិស្សយប្បច្ចយនិទ្ទេស ដូចតទៅ*

*បទថា* **បុរិមា បុរិមា** *សេចក្ដីថា រមែងបាននូវធម៌ ដែលរលត់ទៅដោយលំដាប់ដោយល្អ ក្នុងអនន្តរូបនិស្សយប្បច្ច័យ ។ ធម៌ដែលកើតមុន រមែងបានដោយអំណាចនៃវីថិផ្សេងគ្នា ក្នុងអារម្មណូបនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ។ តិកៈទាំងនោះ ( គឺឧបនិស្ស័យទាំងឡាយ ) រមែងបានក្នុងកុសលបទ និងកុសលបទ ។ ឯធម៌ដែលរលត់ទៅ ក្នុងលំដាប់ដោយល្អ រមែងមិនបានក្នុងអកុសលបទ និងកុសលបទ ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា* **អកុសលានំ ធម្មានំ កេសញ្ចិ ឧបនិស្សយប្បច្ចយេន បច្ចយោ** *នៃពួកអកុសលធម៌ខ្លះ ដោយឧបនិស្សយប្បច្ច័យដូច្នេះ ។ ពិតហើយ ពាក្យនេះ ព្រះមានព្រះភាគត្រាស់សំដៅដល់ន័យនេះថា កុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ និងបកតូបនិស្ស័យ ។ អារម្មណូបនិស្ស័យ គឺ ( បុគ្គល ) ឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ធ្វើពួកកុសលដែលខ្លួនធ្លាប់សន្សំហើយ ក្នុងកាលមុនឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ( បុគ្គល ) ចេញចាកឈាន ធ្វើឈាន*

ឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើឈាន នោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ។ ឯបកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធា ហើយដំឡើងមានះ ប្រកាន់ទិដ្ឋិ សីល ... សុតៈ ... ចាគៈ ... អាស្រ័យបញ្ញា ហើយដំឡើងមានះ ប្រកាន់ទិដ្ឋិ សទ្ធា ... សីល សុតៈ ចាគៈ ... បញ្ញា ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ដូច្នេះ ។ ធម៌ពួក ៣ រមែងបានក្នុងអព្យាកតបទជាមួយកុសលបទ ។ ក្នុងអកុសលបទជាមួយអកុសលបទក៏ដូចគ្នា ។

ធម៌ដែលរលត់ទៅ ដោយមិនមានរវាងចន្លោះដោយល្អ រមែងមិនបាន ក្នុងកុសលបទជាមួយអកុសលបទ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា **កុសលានំ ធម្មានំ កេសញ្ចិ ឧបនិស្សយប្បច្ចយេន បច្ចយោ** នៃពួកកុសលធម៌ខ្លះដោយឧបនិស្សយប្បច្ច័យ ដូច្នេះ ។ ពិតហើយ ពាក្យនេះ ព្រះមានព្រះភាគ ត្រាស់សំដៅដល់បកតូបនិស្សយប្បច្ច័យប៉ុណ្ណោះ ដែលមកហើយក្នុងបញ្ហាវារៈ ដោយន័យថា អកុសលធម៌ជាបច្ច័យនៃកុសលធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យរាគៈ ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើតឡើង ធ្វើវិបស្សនាឲ្យកើតឡើង ធ្វើមគ្គឲ្យកើតឡើង ធ្វើអភិញ្ញាឲ្យកើតឡើង ធ្វើសមាបត្តិឲ្យកើតឡើង ទោសៈ ... មោហៈ មានះ ទិដ្ឋិ ... អាស្រ័យសេចក្តីប្រាថ្នា ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើតឡើង ធ្វើវិបស្សនាឲ្យកើតឡើង ធ្វើមគ្គឲ្យកើតឡើង ធ្វើអភិញ្ញាឲ្យកើតឡើង

ធ្វើសមាបត្តិឲ្យកើតឡើង ។ រាគៈ ... ទោសៈ មោហៈ មានះ ទិដ្ឋិ ... សេចក្តីប្រាថ្នាជាបច្ច័យនៃសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា ដោយឧបនិស្សយប្បច្ច័យ ។ ( បុគ្គល ) សម្លាប់សត្វ ហើយឲ្យទាន ដូច្នេះជាដើម ។ តែអកុសល រមែងមិនជាអារម្មណូបនិស្សយប្បច្ច័យដល់កុសល ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភាពដែលកុសលនោះ នឹងធ្វើអកុសលនោះឲ្យមានកម្លាំងខ្លាំងក្លា ហើយឲ្យប្រព្រឹត្តទៅមិនបាន ( កុសលធ្វើអកុសលឲ្យជាអារម្មណាធិបតីមិនបាន ) ។ ក្នុងអធិការនេះ អ្នកសិក្សាគប្បីជ្រាបថា អនន្តរូបនិស្សយប្បច្ច័យ រមែងមិនបានដូចអារម្មណូបនិស្សយប្បច្ច័យ ។ ក្នុងអព្យាកតបទជាមួយអកុសលបទ រមែងមិនបានចំពោះអារម្មណូបនិស្សយប្បច្ច័យប៉ុណ្ណោះ ព្រោះថា អព្យាកតធម៌ មិនធ្វើអកុសល ឲ្យជាអារម្មណ៍ធ្ងន់ឡើយ ព្រោះភាពជាអនន្តរប្បច្ច័យរមែងមាន ហេតុនោះ ក្នុងអធិការនេះ ព្រះមានព្រះភាគមិនត្រាស់ថា **កេសញ្ចិ** ។ តែឧបនិស្សយប្បច្ច័យទាំង ៣ រមែងបានក្នុងន័យ ៣ គឺក្នុងអព្យាកតបទ ជាមួយនឹងអព្យាកតបទ កុសលបទជាមួយនឹងអព្យាកតបទ អកុសលបទ ជាមួយនឹងអព្យាកតបទ ។ បទនេះ គឺ **បុគ្គលោបិ សេនាសនម្បិ** ព្រះមានព្រះភាគ ត្រាស់ដោយអំណាចបកតូបនិស្សយប្បច្ច័យ ។ ពិតហើយ បុគ្គល និងសេនាសនៈ ទាំង ២ នេះ ជាបច្ច័យមានកម្លាំង ដល់ការប្រព្រឹត្តទៅនៃកុសល និងអកុសល ឯភាពដែលបុគ្គល និងសេនាសនៈ ជាបច្ច័យក្នុងអធិការនេះ អ្នកសិក្សាគប្បីជ្រាបដោយអំណាចភាពជាបច្ច័យដោយអម ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទី

នេះប៉ុណ្ណោះ ។

ឈ្មោះថា ឧបនិស្សយប្បច្ច័យ បានដល់ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៤ មួយអន្លើដោយបញ្ញត្តិផងដែរ តែកាលពោលដោយវិភាគ មាន ៣ យ៉ាង ដោយអំណាចនៃអារម្មណូបនិស្សយប្បច្ច័យជាដើម ។ បណ្តាឧបនិស្សយប្បច្ច័យ ៣ យ៉ាងនោះ អារម្មណូបនិស្សយប្បច្ច័យ មិនផ្សេងអំពីអារម្មណាធិបតិប្បច្ច័យ ព្រោះហេតុនេះ អ្នកសិក្សាគប្បីកាន់យកដោយការចែក ដោយប្រការផ្សេងៗ តាមន័យដែលខ្ញុំបានពោលហើយ ខាងដើមនោះឯង ។ អនន្តរូបនិស្សយប្បច្ច័យ មិនផ្សេងអំពីអនន្តរប្បច្ច័យឡើយ ។ អនន្តរូបនិស្សយប្បច្ច័យនោះ អ្នកសិក្សាគប្បីកាន់យកដោយការចែក ដោយប្រការផ្សេងៗ តាមន័យដែលខ្ញុំបានពោលហើយ ខាងដើមដូចគ្នា ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យដោយធម៌ដែលជាបច្ចយុប្បន្ននៃបច្ច័យទាំង ២ នោះ តាមន័យដែលខ្ញុំពោលហើយ ក្នុងអធិបតិប្បច្ច័យ និងអនន្តរប្បច្ច័យទាំងនោះ ។ បើពោលដោយអំណាចនៃជាតិ បកតូបនិស្សយប្បច្ច័យ មាន ៥ យ៉ាង ដោយចែកជាកុសល អកុសល វិបាក កិរិយា និងរូប ។ បកតូបនិស្សយប្បច្ច័យ ដែលចែកដោយអំណាចនៃជាតិ មានកុសលជាដើម ពោលដោយប្រភេទនៃធម៌ ដែលកើតក្នុងភូមិផ្សេងៗ ហើយ មានច្រើន ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងឧបនិស្សយប្បច្ច័យនេះយ៉ាងនេះ ។

ក្នុងបកតូបនិស្សយប្បច្ច័យដែលចែកបាន ដូចខ្ញុំពោលមកហើយនេះ

កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ជាបកតូបនិស្សយប្បច្ច័យ ដល់ធម៌ ៤ ពួកនេះ គឺដល់កុសលក្នុងភូមិ ៤ អកុសល វិបាក និងកិរិយា ។ ក្នុងលោកុត្តរធម៌ មិនជាបកតូបនិស្សយប្បច្ច័យ ដល់អកុសលធម៌តែម្យ៉ាង តែជាបច្ច័យដល់អកុសលរបស់អ្នកដទៃបាន ដោយន័យជាដើមថា លោកុត្តរធម៌ដែលអាចារ្យរបស់ខ្ញុំឲ្យកើតឡើងហើយ ឬដោយន័យនេះថា លោកុត្តរធម៌នឹងកើតឡើង ដល់បុគ្គលណា ព្រោះញុំាងសេចក្តីប្រណែនឲ្យកើតឡើងក្នុងវិមោក្ខដ៏កំពូលរបស់បុគ្គលនោះ ។ អកុសលធម៌ទាំងអស់ ដែលជាបកតូបនិស្សយប្បច្ច័យដល់ខន្ធ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ម្យ៉ាងទៀត វិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ក៏ជាបកតូបនិស្សយប្បច្ច័យ ដល់ខន្ធដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដូចគ្នា ។ ក្នុងលោកុត្តរវិបាក ផល ៣ ខាងក្រោម មិនជាបកតូបនិស្សយប្បច្ច័យ ដល់អកុសលប៉ុណ្ណោះឡើយ ។ អគ្គផល គឺអរហត្តផល មិនជាបកតូបនិស្សយប្បច្ច័យដល់កុសលឡើយ ។ តាមន័យមុននោះឯង លោកុត្តរធម៌ដែលកើតដល់បុគ្គលឯណានីមួយ លោកុត្តរវិបាកទាំងអស់ ក្នុងសន្តានរបស់បុគ្គលនោះ ជាបកតូបនិស្សយប្បច្ច័យដល់អរូបក្ខន្ធមានកុសលទាំងអស់ជាដើម ។ បកតូបនិស្សយប្បច្ច័យ ពោល គឺកិរិយា

ជាបច្ច័យដល់ខន្ធ មានអកុសលជាដើម ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បកតូបនិស្សយប្បច្ច័យ គឺរូបក៏ដូចគ្នា ។ តែរូប មិនបានភាពជាឧបនិស្សយប្បច្ច័យ តាមន័យដែលពោលមកហើយ ក្នុងមហាបករណ៍ ឈ្មោះថាបដ្ឋាននេះឡើយ ។ នឹងពោលថា បានដោយបរិយាយដែលមកហើយ ក្នុងព្រះសូត្រក៏គួរ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្នក្នុងឧបនិស្សយប្បច្ច័យនេះ ដូចពណ៌នាមកហើយ ។៚

## អធិប្បាយឧបនិស្សយប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## បុរេជាតប្បច្ច័យ

[ ១១ ] ពាក្យថា បុរេជាតប្បច្ច័យ បានដល់ ចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុផង នៃពួកធម៌ ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ សោតាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយសោតវិញ្ញាណធាតុនោះផង ដោយបុរេជា-តប្បច្ច័យ ឃានាយតនៈ ជាបច្ច័យនៃឃានវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយឃានវិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ ជិវ្ហាយតនៈ ជាបច្ច័យនៃជិវ្ហាវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយបុរេជា-តប្បច្ច័យ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ សទ្ទាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយសោត-វិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ គន្ធាយតនៈ ជាបច្ច័យនៃឃានវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយឃានវិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ រសាយតនៈជាបច្ច័យ នៃជិវ្ហាវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ រូបាយតនៈ សទ្ទា-

យតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយបុរេជាតប្បច្ច័យ មនោ-ធាតុក្តី មនោវិញ្ញាណធាតុក្តី អាស្រ័យនូវរូបណា ហើយប្រព្រឹត្តទៅ រូបនោះ ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយបុរេជាតប្បច្ច័យ ជួនកាល ជាបច្ច័យនៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយបុរេជាតប្បច្ច័យ ជួនកាល ជាបច្ច័យ ដោយនបុរេជាតប្បច្ច័យ ។

# អធិប្បាយ

## បុរេជាតប្បច្ចយនិទ្ទេស

[ ១១ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងបុរេជាតប្បច្ចយនិទ្ទេស ដូចតទៅ

ឈ្មោះថា **បុរេជាតំ** ក្នុងពាក្យថា **បុរេជាតប្បច្ចយេន បច្ចយោ** នេះ ជាបច្ច័យដល់ធម៌ណាត្រូវកើតមុន ធម៌នោះ គឺកន្លងឧប្បាទក្ខណៈដល់ឋិតិក្ខណៈ ។

បទថា **ចក្ខាយតនំ** ជាដើម ព្រះមានព្រះភាគត្រាស់ដោយអំណាចវត្ថុបុរេជាតប្បច្ច័យ ។ បទថា **រូបាយតនំ** ជាដើម ព្រះមានព្រះភាគត្រាស់ដោយអំណាចអារម្មណបុរេជាតប្បច្ច័យ ។ បទថា **កិញ្ចិកាលេ បុរេជាតប្បច្ចយេន** ទ្រង់ត្រាស់សំដៅដល់បវត្តិកាល ។ បទថា **កិញ្ចិកាលេ ន បុរេជាតប្បច្ចយេន** ទ្រង់ត្រាស់សំដៅយកបដិសន្ធិកាល ។ បាលីនេះ មកហើយ ដោយអំណាចវត្ថុ និងអារម្មណ៍ ក្នុងបញ្ចទ្វារទាំងអស់ មិនបានមកដោយអំណាចវត្ថុក្នុងមនោទ្វារ ។ តែក្នុងបញ្ហាវារៈ បានអារម្មណបុរេជាតប្បច្ច័យ ក្នុងមនោទ្វារផងដែរ ព្រោះបាលីមកហើយថា អារម្មណបុរេជាត គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដូច្នេះ ។ ឯក្នុងទីនេះ ទ្រង់សម្តែងទេសនាដោយអំណាចធម៌ដែលមានចំណែកសេសសល់ ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះប៉ុណ្ណោះ ។

បុរេជាតប្បច្ច័យនេះ មានតែរូបសុទ្ធៗ ។ រូបនោះ បានដល់ រូបរូប ( រូបដែលបែកធ្លាយ ) ១៨ ប៉ុណ្ណោះ ដែលហួសឧប្បាទក្ខណៈ ហើយដល់ឋិតិក្ខណៈ ។ រូបទាំងអស់មាន ២ យ៉ាង គឺបុរេជាតប្បច្ច័យ និងអារម្មណ-បុរេជាតប្បច្ច័យ ។ ក្នុង ២ យ៉ាងនោះ រូបនេះ គឺចក្ខាយតនៈ ។បេ។ កាយា-យតនៈ និងវត្ថុរូប ឈ្មោះថា វត្ថុបុរេជាត ។ រូបដ៏សេស ១២ ទាំងដែលមក និងមិនបានមកក្នុងបាលី គឺពណ៌ សំឡេង ក្លិន រស ធាតុ ៤ ឥន្ទ្រិយ ៣ ( ភាវរូប ២ ជីវិតរូប ១ ) កពឡិង្ការាហារ ១ ឈ្មោះថា អារម្មណ-បុរេជាត ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងបុរេជាតប្បច្ច័យនេះ ដូចពណ៌នាមកហើយ ។

ក្នុងបុរេជាតប្បច្ច័យដែលចែកបាន ដូចខ្ញុំសម្ដែងមកហើយនេះ ចក្ខា-យតនៈជាបច្ច័យដល់ចក្ខុវិញ្ញាណចិត្ត ២ ដោយបុរេជាតប្បច្ច័យ អាយតនៈ ៤ ក្រៅអំពីនេះក៏ដូចគ្នា គឺជាបុរេជាតប្បច្ច័យដល់សោតវិញ្ញាណចិត្ត ២ ជាដើម ។ វត្ថុរូបជាបុរេជាតប្បច្ច័យដល់ចិត្ត និងចេតសិក ទាំងជាកុសល អកុសល និងអព្យាកតៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ ដ៏សេស វៀរទ្វិបញ្ចវិញ្ញាណចិត្ត និងអរូបវិបាក ៤ ។ អារម្មណ៍ ៥ មានរូបជាដើម

*ជាបុរេជាតប្បច្ច័យដោយចំណែកមួយ ដល់ទ្វិបញ្ចវិញ្ញាណចិត្តផង ដល់មនោធាតុ ៣ ផង ។ រូបរូបទាំង ១៨ យ៉ាងនោះ ជាបុរេជាតប្បច្ច័យ ដល់ធម៌ ៦ ពួកនេះ គឺកាមាវចរកុសល អភិញ្ញាកុសលដែលកើតអំពីរូបាវចរ អកុសល កាមាវចរវិបាក ដែលកើតឡើងជាតទារម្មណៈ កាមាវចរកិរិយា និងអភិញ្ញាកិរិយា ដែលកើតអំពីរូបាវចរ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងបុរេជាតប្បច្ច័យនេះ យ៉ាងនេះឯង ។៚*

## អធិប្បាយបុរេជាតប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## បច្ឆាជាតប្បច្ច័យ

[ ១២ ] ពាក្យថា បច្ឆាជាតប្បច្ច័យ បានដល់ ពួកចិត្តចេតសិកធម៌ ដែលកើតក្រោយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

# អធិប្បាយ

## បច្ឆាជាតប្បច្ចយនិទ្ទេស

[ ១២ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងបច្ឆាជាតប្បច្ចយនិទ្ទេស ដូចតទៅ

បទថា **បច្ឆាជាតា** សេចក្ដីថា ធម៌ដែលកើតខាងក្រោយ នឹងជាបច្ច័យដល់កាយណា នឹងត្រូវកើតឡើងក្នុងកាលកាយនោះ កើតឡើងហើយតាំងនៅ ។ បទថា **បុរេជាតស្ស** គឺជាបច្ច័យដល់ធម៌ដែលកើតមុន ឧប្បាទក្ខណៈនៃបច្ចយធម៌ទាំងនោះកន្លងខណៈ កើតដល់ខណៈតាំងនៅ ។ បទថា **ឥមស្ស កាយស្ស** គឺជាបច្ច័យដល់កាយនេះ ពោល គឺមហាភូតរូប និងឧបាទារូប ដែលកើតអំពីសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ។ ក្នុងសេចក្ដីនេះ ពាក្យថា កាយដែលកើតអំពីសមុដ្ឋាន ៣ អ្នកសិក្សាគប្បីជ្រាបកាយនៃព្រហ្មបារិសជ្ជាជាដើម ព្រោះមិនមានអាហារជាសមុដ្ឋាន នេះជាការអធិប្បាយបាលីក្នុងអធិការនេះ ។

ឈ្មោះថា បច្ឆាជាតប្បច្ច័យនេះ ពោលដោយសង្ខេប បានដល់អរូបក្ខន្ធក្នុង ៤ ភូមិដ៏សេស វៀរអរូបវិបាក ។ បច្ឆាជាតប្បច្ច័យនោះ ពោលដោយអំណាចនៃជាតិ មាន ៤ ជាតិ ដោយចែកជាកុសល អកុសល វិបាក និងកិរិយា អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងបច្ឆាជាតប្បច្ច័យនេះ ដូចសម្ដែងមកហើយ ។

ក្នុងបច្ឆាជាតប្បច្ច័យដែលចែកបាន ដូចខ្ញុំបានសម្ដែងមកហើយនេះ កុសលដែលកើតឡើងក្នុងភូមិ ៤ និងអកុសលក្នុងបញ្ចវោការភព ជាបច្ឆា-

ជាតប្បច្ច័យដល់រូបកាយដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ដែលកន្ទង ឧប្បាទក្ខណៈ មកដល់ឋិតិក្ខណៈ ។ ក្នុងចំណែកវិបាក កាមាវចរវិបាក និង រូបាវចរវិបាកដ៏សេស វៀរវិបាកដែលធ្វើកិច្ចបដិសន្ធិ ជាបច្ឆាជាតប្បច្ច័យ ដោយចំណែកមួយដល់រូប ដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ នោះ ឯង ។ លោកុត្តរវិបាកដែលកើតឡើង ក្នុងបញ្ចវោការភព ដែលជាបច្ឆា-ជាតប្បច្ច័យ ដល់រូបកាយនោះដូចគ្នា ។ កិរិយាចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ កើតឡើងក្នុងបញ្ចវោការភពប៉ុណ្ណោះ ជាបច្ឆាជាតប្បច្ច័យដល់កាយ មាន ប្រការដូចបានពោលហើយ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែល ជាបច្ចយុប្បន្ន ក្នុងបច្ឆាជាតប្បច្ច័យនេះ ដូចពណ៌នាមកហើយនោះឯង ។៚

## អធិប្បាយបច្ឆាជាតប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## អាសេវនប្បច្ច័យ

[ ១៣ ] ពាក្យថា អាសេវនប្បច្ច័យ បានដល់ ពួកកុសលធម៌មុនៗ ជាបច្ច័យនៃពួកកុសលធម៌ក្រោយៗ ដោយអាសេវនប្បច្ច័យ ពួកអកុសលធម៌មុនៗ ជាបច្ច័យនៃពួកអកុសលធម៌ក្រោយៗ ដោយអាសេវនប្បច្ច័យ ពួកកិរិយាព្យាកតធម៌មុនៗ ជាបច្ច័យនៃពួកកិរិយាព្យាកតធម៌ក្រោយៗ ដោយអាសេវនប្បច្ច័យ ។

# អធិប្បាយ

## អាសេវនប្បច្ចយនិទ្ទេស

[ ១៣ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងអាសេវនប្បច្ចយនិទ្ទេស ដូចតទៅ

ក្នុងន័យទាំងអស់ថា **បុរិមា បុរិមា** អ្នកសិក្សាគប្បីជ្រាបថា បានដល់ធម៌ដែលរលត់ទៅដោយលំដាប់ដោយល្អ ។

សួរថា ព្រោះហេតុអ្វី ក្នុងអធិការនេះ ព្រះមានព្រះភាគ ទ្រង់មិនធ្វើនិទ្ទេស ព្រមទាំងធម៌ដែលមានជាតិផ្សេងគ្នា ដោយន័យជាដើមថា កុសលធម៌ដែលកើតមុនៗ ជាបច្ច័យដល់អព្យាកតធម៌ដែលកើតក្រោយៗ ដូចក្នុងអនន្តរប្បច្ច័យ ឆ្លើយថា ព្រោះធម៌ទាំងឡាយ មិនអាចឲ្យធម៌ដទៃកាន់យកគតិរបស់ខ្លួនបាន ។ ពិតហើយ ធម៌ដែលមានជាតិផ្សេងគ្នា កាលនឹងឲ្យធម្មជាតដែលផ្សេងគ្នា សម្រេចភាពជាធម៌ស្ទាត់ជំនាញ និងមានកម្លាំង ដោយគុណគឺអាសេវនៈ រមែងមិនអាចឲ្យធម៌ទាំងនោះកាន់យកគតិរបស់ខ្លួន ពោល គឺភាពជាកុសលជាដើមបាន ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់មិនធ្វើនិទ្ទេស ព្រមជាមួយធម៌ដែលមានជាតិផ្សេងគ្នាទាំងនោះ ទ្រង់ធ្វើនិទ្ទេស រួមជាមួយធម៌ដែលមានជាតិដូចគ្នានឹងធម៌ ដែលអាចឲ្យធម៌ដទៃកាន់យកគតិរបស់ខ្លួន ពោល គឺភាពជាកុសលជាដើម ដែលពិសេសចេញទៅ ដោយសភាវៈដែលមានកម្លាំងច្រើនជាង ស្ទាត់ជំនាញជាង ព្រោះអាសេវនៈ ពោល គឺការសន្សំ ។

សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបទ្រង់មិនកាន់យកវិបាកាព្យាកតៈផង ឆ្លើយថា ព្រោះមិនមានអាសេវនៈ ។

ពិតហើយ វិបាក គឺការៈដែលឆ្អិនដោយអំណាចនៃកម្មជាសភាវៈ ដែលត្រូវកម្មធ្វើឲ្យប្រែប្រួលទៅ រមែងប្រព្រឹត្តទៅ ដោយមិនមានសេចក្តីព្យាយាម ( ក្នុងការឲ្យផល ) និងជាប់កម្លាំង ទើបវិបាកនេះ មិនអាចឲ្យវិបាកដទៃកាន់យក គឺទទួលយកនូវសភាវៈរបស់ខ្លួន ហើយកើតឡើងដោយគុណ គឺអាសេវនៈបាន ទាំងវិបាក ( ថ្មី ) ក៏មិនកាន់យកអានុភាពនៃវិបាកចាស់កើតឡើងឡើយ តែវិបាកត្រូវកម្លាំងកម្មបន្សាត់ទៅ រមែងកើតឡើងហាក់បីដូចជាធ្លាក់ទៅ ព្រោះហេតុនោះ ទើបក្នុងវិបាកទាំងអស់ មិនមានអាសេវនៈ ព្រោះវិបាកមិនមានអាសេវនៈ ដូចពោលមកហើយ ទើបព្រះមានព្រះភាគ មិនកាន់យកក្នុងអធិការនៃអាសេវនប្បច្ច័យនេះ ។

វិបាកនេះ នឹងកើតឡើងក្នុងលំដាប់នៃកុសល អកុសល និងកិរិយា ក៏រមែងមិនបានទទួលគុណ គឺអាសេវនៈ ព្រោះមានការប្រព្រឹត្តទៅទាក់ទងដោយកម្ម ព្រោះហេតុនោះ ធម៌ មានកុសលជាដើម ទើបមិនជាអាសេវនប្បច្ច័យដល់វិបាកនោះ ។ ម្យ៉ាងទៀត កុសលជាដើមនេះ មិនជាអាសេវនប្បច្ច័យដល់វិបាក ព្រោះមានជាតិផ្សេងគ្នាក៏បាន ។ កាលពោលដោយភូមិ ឬអារម្មណ៍ហើយ ធម៌ទាំងឡាយ ឈ្មោះថា មានជាតិផ្សេងគ្នា រមែងមិនមាន ព្រោះហេតុនោះ ទើបកាមាវចរកុសល និងកិរិយា ជាអាសេវនប្បច្ច័យដល់មហគ្គតកុសល និងមហគ្គតកិរិយា និងអនុលោមកុសល ដែលមាន

សង្ខារជាអារម្មណ៍ និងដល់គោត្រភូកុសល ដែលមាននិព្វានជាអារម្មណ៍បាន នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះប៉ុណ្ណោះ ។

អាសេវនប្បច្ច័យនេះ ដោយជាតិមាន ៣ ប៉ុណ្ណោះ គឺកុសល អកុសល កិរិយាព្យាកតៈ ។ ក្នុង ៣ យ៉ាងនោះ កុសលពោលដោយភូមិ មាន ៣ គឺ កាមាវចរ រូបាវចរ អរូបាវចរ ។ អកុសល ជាកាមាវចរប៉ុណ្ណោះ កិរិយា-ព្យាកតៈ មាន ៣ ភូមិ គឺកាមាវចរ រូបាវចរ អរូបាវចរ ។ ឈ្មោះជាអាសេវនប្បច្ច័យដែលជាលោកុត្តរ មិនមាន ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យដោយការចែកដោយប្រការផ្សេងៗ ក្នុងអាសេវនប្បច្ច័យនេះ ដូចពោលមកហើយ ។

ក្នុងអាសេវនប្បច្ច័យដែលចែកបាន ដូចពោលមកនេះ កាមាវចរ-កុសល ជាអាសេវនប្បច្ច័យដល់កាមាវចរកុសល ដែលកើតក្នុងលំដាប់នៃខ្លួន ។ ក្នុងអាសេវនប្បច្ច័យ កាមាវចរកុសលដែលជាញាណសម្បយុត្ត ជាអាសេវនប្បច្ច័យដល់ពួកធម៌ទាំងនេះ គឺរូបាវចរកុសល អរូបាវចរកុសល លោកុត្តរកុសលដែលមានវេទនាដូចគ្នានឹងខ្លួន ។ ឯរូបាវចរកុសល ជាអាសេវនប្បច្ច័យចំពោះដល់រូបាវចរកុសលប៉ុណ្ណោះ ។ អរូបាវចរកុសល ជាអាសេវនប្បច្ច័យដល់អរូបាវចរកុសលប៉ុណ្ណោះ ។

អកុសល ជាអាសេវនប្បច្ច័យ ដល់អកុសលប៉ុណ្ណោះដូចគ្នា ។

ឯកិរិយាធម៌ ពោល គឺកាមាវចរកិរិយា ជាអាសេវនប្បច្ច័យដល់កាមាវចរកិរិយាមុន ។ ធម៌ ពោល គឺកាមាវចរកិរិយាណា ជាញាណ-

សម្បយុត្ត ធម៌នោះ ជាអាសេវនប្បច្ច័យដល់ពួកធម៌ទាំងនេះ គឺរូបាវចរកិរិយា អរូបាវចរកិរិយា ដែលមានវេទនាដូចគ្នានឹងខ្លួន ។ រូបាវចរកិរិយា ជាអាសេវនប្បច្ច័យ ដល់រូបាវចរកិរិយាប៉ុណ្ណោះ ។ អរូបាវចរកិរិយា ជាអាសេវនប្បច្ច័យ ដល់អរូបាវចរកិរិយាប៉ុណ្ណោះ ។ ឯវិបាក ជាអាសេវនប្បច្ច័យ ដល់ធម៌ណាមួយ ឬធម៌ណាមួយ ជាអាសេវនប្បច្ច័យ ដល់វិបាក មិនមាន អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងអាសេវនប្បច្ច័យនេះ ដូចពោលមក ដូច្នេះ ។l៚

## អធិប្បាយអាសេវនប្បច្ច័យនិទ្ទេស ចប់

# អភិធម្មបិដក

## កម្មប្បច្ច័យ

[ ១៤ ] ពាក្យថា កម្មប្បច្ច័យ បានដល់ កុសលាកុសលកម្មក្តី កដត្តាកម្ម នៃវិបាកក្ខន្ធទាំងឡាយក្តី ជាបច្ច័យនៃរូបទាំងឡាយ ដោយកម្មប្បច្ច័យ ជាបច្ច័យនៃធម៌ទាំងឡាយ ដែលប្រកបដោយចេតនាផង នៃរូបទាំងឡាយដែលកើតអំពីធម៌នោះផង ដោយកម្មប្បច្ច័យ ។

# អធិប្បាយ

## កម្មប្បច្ចយនិទ្ទេស

[ ១៨ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងកម្មប្បច្ចយនិទ្ទេសដូចតទៅ

បទថា **កម្មំ** បានដល់ ចេតនាកម្ម ។ បទថា **កដត្តា ច រូបានំ** បានដល់ រូបដែលកើតឡើងព្រោះត្រូវកម្មធ្វើ ។ បទថា **កម្មប្បច្ចយេន** សេចក្តីថា ដោយនានាខណិកកម្មប្បច្ច័យ ដែលអាចឲ្យផលរបស់ខ្លួន កើតឡើងបានក្នុងទីបំផុតនៃកោដិកប្ប មិនមែនតិច ។ ពិតហើយ កុសលកម្ម និងអកុសលកម្ម រមែងមិនឲ្យផលក្នុងខណៈដែលខ្លួនប្រព្រឹត្តទៅ បើគប្បីឲ្យផលក្នុងខណៈនោះសោត បុគ្គលធ្វើកុសលកម្ម ដែលជាហេតុឲ្យចូលដល់ទេវលោកឯណា ក៏គប្បីក្លាយជាទេវតាក្នុងខណៈនោះឯង ដោយអានុភាពនៃកម្មនោះ ។

កម្មដែលបុគ្គលធ្វើក្នុងខណៈណា សូម្បីមិនមានក្នុងខណៈដទៃ បន្ទាប់អំពីនោះ រមែងញ៉ាំងផលឲ្យកើតឡើង ក្នុងកាលដែលបុគ្គលគប្បីចូលដល់បច្ចុប្បន្ន ឬបន្ទាប់អំពីនោះ ក្នុងកាលមានការប្រកបព្រមនៃបច្ច័យដ៏សេស ព្រោះជាសភាវៈដែលកម្មធ្វើស្រេចហើយ ប្រៀបដូចការហាត់ធ្វើសិប្បៈដំបូងទោះបីស្រេចហើយ ក៏ឲ្យកើតការធ្វើសិប្បៈក្រោយៗ ក្នុងកាលដទៃបាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា នានាខណិកកម្មប្បច្ច័យ ។

បទថា **ចេតនា សម្បយុត្តកានំ ធម្មានំ** សេចក្តីថា ចេតនាណាមួយ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួន ។ ដោយបទថា **តំ-សមុដ្ឋានានំ** នេះ ព្រះមានព្រះភាគ ទ្រង់កាន់យកកដត្តារូប ក្នុងបដិសន្ធិក្ខណៈ

ផងដែរ ។ បទថា **កម្មប្បច្ចយេន** នេះ ត្រាស់សំដៅដល់ចេតនាដែលកើតព្រមគ្នា ។ ពិតហើយ បណ្ដាធម៌ មានកុសលធម៌ជាដើម ចេតនាណាមួយជួយឧបការៈដល់ធម៌ដ៏សេស ដោយភាពជាកិរិយា ពោល គឺការព្យាយាមនៃចិត្ត ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា សហជាតកម្មប្បច្ច័យ ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះប៉ុណ្ណោះ ។

កម្មប្បច្ច័យនេះ ដោយអត្ថ បានដល់ ចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ចេតនានោះ ពោលដោយប្រភេទនៃជាតិ ចែកចេញជា ៤ ជាតិ គឺ កុសល អកុសល វិបាក និងកិរិយា ។ ក្នុង ៤ ជាតិនោះ កុសល ពោលដោយភូមិ មាន ៤ ភូមិ ដោយអំណាចកាមាវចរភូមិជាដើម ។ អកុសល មាន ១ ភូមិប៉ុណ្ណោះ វិបាក មាន ៤ ភូមិ កិរិយា មាន ៣ ភូមិ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងកម្មប្បច្ច័យដូចពោលមកហើយ ។ ក្នុងកម្មប្បច្ច័យ ដែលចែកបាន ដូចពោលមកនេះ កាមាវចរកុសលចេតនាដែលកើតព្រមគ្នា ជាកម្មប្បច្ច័យដល់ធម៌ ដែលសម្បយុត្តជាមួយខ្លួន និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ជាបច្ច័យដល់ខន្ធ ដែលសម្បយុត្តជាមួយខ្លួនតែម្យ៉ាងប៉ុណ្ណោះ ក្នុងចតុវោការភព ដោយសហជាតកម្មប្បច្ច័យ ។

ឯចេតនាដែលកើតឡើងហើយរលត់ទៅ ជាបច្ច័យដល់វិបាកក្ខន្ធរបស់ខ្លួន និងកដត្តារូប ដោយនានាខណិកកម្មប្បច្ច័យ ។ ចេតនានោះ ជាបច្ច័យក្នុងបញ្ចវោការភពប៉ុណ្ណោះ មិនជាបច្ច័យក្នុងភពដទៃឡើយ ។

រូបាវចរកុសលចេតនាដែលកើតព្រមគ្នា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួន និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ដោយសហជាតកម្មប្បច្ច័យដោយចំណែកមួយ តែរូបាវចរកុសលចេតនា ដែលកើតឡើងហើយរលត់ទៅ ជាបច្ច័យដល់វិបាករបស់ខ្លួន និងកដត្តារូប ដោយនានាខណិកកម្មប្បច្ច័យ ។

អរូបាវចរកុសលចេតនា និងលោកុត្តរកុសលចេតនា ដែលកើតព្រមគ្នា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួន និងដល់រូបដែលមានចិត្តជាសមុដ្ឋានក្នុងបញ្ចវោការភព ជាបច្ច័យដល់ខន្ធដែលសម្បយុត្តជាមួយខ្លួន តែម្យ៉ាង ក្នុងចតុវោការភព ដោយសហជាតកម្មប្បច្ច័យ ។

ចេតនាទាំង ២ នោះ ដែលកើតឡើងហើយរលត់ទៅ ជាបច្ច័យដល់វិបាកក្ខន្ធរៀងៗ ខ្លួន ដោយនានាខណិកកម្មប្បច្ច័យ ។ អកុសលចេតនាដែលកើតព្រមគ្នា ជាបច្ច័យដល់ខន្ធដែលសម្បយុត្តជាមួយខ្លួន និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ជាបច្ច័យដល់អរូបក្ខន្ធប៉ុណ្ណោះ ក្នុងចតុវោការភព ដោយសហជាតកម្មប្បច្ច័យ ។ អកុសលចេតនានោះដែលកើតឡើងហើយរលត់ទៅ ជាបច្ច័យដល់វិបាកក្ខន្ធ និងកដត្តារូប ដោយនានាខណិកកម្មប្បច្ច័យ ។

វិបាកចេតនាខាងកាមាវចរ និងរូបាវចរ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួន និងជាបច្ច័យដល់ចិត្តជរូបក្នុងបវត្តិកាល ដល់កដត្តារូបក្នុងបដិសន្ធិកាល ដោយសហជាតកម្មប្បច្ច័យ ។

*អរូបាវចរវិបាកចេតនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួនតែម្យ៉ាង ដោយសហជាតកម្មប្បច្ច័យ ។ លោកុត្តរវិបាកចេតនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួន និងដល់រូប ដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ជាបច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ក្នុងចតុវោការភព ដោយសហជាតកម្មប្បច្ច័យ ។*

*កិរិយាចេតនាដែលកើតក្នុងភូមិទាំង ៣ ជាបច្ច័យដល់ធម៌ដែលសម្បយុត្ត និងដល់រូប ដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ដោយសហជាតកម្មប្បច្ច័យ ។ កិរិយាចេតនាដែលកើតក្នុងអរូបភពនេះ ជាបច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ដោយសហជាតកម្មប្បច្ច័យ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងកម្មប្បច្ច័យនេះ ដូចពោលមកហើយនោះឯង ។ ។*

## អធិប្បាយកម្មប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## វិបាកប្បច្ច័យ

[ ១៥ ] ពាក្យថា វិបាកប្បច្ច័យ បានដល់ វិបាកក្ខន្ធ ៤ ដែលមិនមាន រូប ជាបច្ច័យនៃគ្នានិងគ្នា ដោយវិបាកប្បច្ច័យ ។

# អធិប្បាយ

## វិបាកប្បច្ចយនិទ្ទេស

[ ១៥ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងវិបាកប្បច្ចយនិទ្ទេសដូចតទៅ រូប ទោះបីកើតអំពីកម្ម ក៏មិនឈ្មោះថា វិបាក ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **វិបាកា** ហើយត្រាស់ថា **ចត្តារោ ខន្ធា** ក្នុងព្រះបាលីថា **វិបាកា ចត្តារោ ខន្ធា** ។ បាលីនេះ មកដោយអំណាចវិបាកប្បច្ច័យនៃអរូបធម៌ប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ តែក្នុងបញ្ហាវារៈ រមែងបានដល់វិបាកប្បច្ច័យផង ដល់ចិត្តជរូប និងកម្មជរូបផង ព្រោះព្រះបាលីមកហើយថា វិបាកាព្យាកតក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ។ ក្នុងខណៈនៃបដិសន្ធិ វិបាកាព្យាកតក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកកដត្តារូប ដោយវិបាកប្បច្ច័យ ដូច្នេះ តែក្នុងអធិការនេះ ព្រះមានព្រះភាគទ្រង់ធ្វើទេសនា ដោយអំណាចធម៌ដែលមានចំណែកសេសសល់ ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះប៉ុណ្ណោះ ។

វិបាកប្បច្ច័យនេះ ព្រោះជាវិបាកធម៌ ពោលដោយជាតិ មានត្រឹម ១ ជាតិ គឺវិបាកជាតិ ដោយប្រភេទនៃភូមិចែកបាន ៤ ភូមិ ដោយអំណាចកាមាវចរភូមិជាដើម ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងវិបាកប្បច្ច័យនេះ ដូចពោលមកហើយនេះ ។

ក្នុងវិបាកប្បច្ច័យដែលចែកបាន ដូចអធិប្បាយមកហើយ កាមាវចរវិបាក និងរូបាវចរវិបាក ជាវិបាកប្បច្ច័យដល់សម្បយុត្តក្ខន្ធ និងជាវិបាកប្បច្ច័យដល់ចិត្តជរូប ក្នុងបវត្តិកាល ជាវិបាកប្បច្ច័យដល់កដត្តារូប ក្នុងបដិសន្ធិ-

*កាល ។ អរូបាវចរវិបាក ជាវិបាកប្បច្ច័យដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ។ លោកុត្តរវិបាក ជាបច្ច័យដល់ធម៌ដែលសម្បយុត្ត និងចិត្តជរូប ក្នុងបញ្ច-វោការភព ជាវិបាកប្បច្ច័យចំពោះធម៌ដែលសម្បយុត្តប៉ុណ្ណោះ ក្នុងចតុវោ-ការភព ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងវិបាកប្បច្ច័យនេះ យ៉ាងនេះឯង ។*

## អធិប្បាយវិបាកប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## អាហារប្បច្ច័យ

[ ១៦ ] ពាក្យថា អាហារប្បច្ច័យ បានដល់ កពលិង្ការាហារ ជាបច្ច័យនៃកាយនេះ ដោយអាហារប្បច្ច័យ អាហារទាំងឡាយ ដែលមិនមានរូប ជាបច្ច័យនៃសម្បយុត្តធម៌ផង នៃរូបទាំងឡាយ ដែលកើតអំពីសម្បយុត្តធម៌នោះផង ដោយអាហារប្បច្ច័យ ។

# អធិប្បាយ

## អាហារប្បច្ចយនិទ្ទេស

[ ១៦ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងអាហារប្បច្ចយនិទ្ទេសដូចតទៅ ឱជាក្នុងរូបដែលកើតក្នុងសន្តតិ ៤[១] ឈ្មោះថា អាហារ ក្នុងបទថា **កពឡីការោ អាហារោ** ។ ព្រោះអាហារនោះ បុគ្គលធ្វើឲ្យជាពំនូតហើយ លេបចូលទៅប៉ុណ្ណោះ ទើបធ្វើកិច្ចនៃអាហារបាន ដែលនៅខាងក្រៅ មិនធ្វើកិច្ចនៃអាហារឡើយ ហេតុនោះ ទើបព្រះមានព្រះភាគមិនត្រាស់ថា **អាហារោ** ត្រាស់ថា **កពឡីការោ អាហារោ** ។ ម្យ៉ាងទៀត បទថា **កពឡីការោ** នេះ ត្រឹមតែជាឈ្មោះនៃអាហារប៉ុណ្ណោះ ព្រោះជាវត្ថុដែលបុគ្គលគប្បីធ្វើឲ្យជាពំនូតហើយ បរិភោគ ។ អាហារ គឺផស្សៈ ចេតនា និងវិញ្ញាណ ឈ្មោះថា **អរូបិនោ អាហារា** ។ រូបដែលមានកម្មជាសមុដ្ឋាន ព្រះមានព្រះភាគទ្រង់កាន់យកហើយ ក្នុងពាក្យនេះថា **តំ សមុដ្ឋានានំ** សមដូចព្រះមានព្រះភាគត្រាស់ក្នុងបញ្ហាវារៈថា ក្នុងខណៈនៃបដិសន្ធិ ពួកវិបាកាព្យាកតាហារ ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និងពួកកដត្តារូប ដោយអាហារប្បច្ច័យ ដូច្នេះ ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះប៉ុណ្ណោះ ។

អាហារប្បច្ច័យនេះ ដោយសង្ខេប បានដល់ ធម៌ ៤ យ៉ាងប៉ុណ្ណោះ គឺកពឡិង្ការាហារ ផស្សាហារ ចេតនាហារ និងវិញ្ញាណាហារ ។ ក្នុងអាហារ ៤ យ៉ាងនោះ នាមអាហារដ៏សេស ៣ វៀរកពឡិង្ការាហារ ពោលដោយអំណាចនៃជាតិ ចែកបាន ៤ ជាតិ ដោយជាកុសល អកុសល វិបាក

---

១- រូបដែលកើតអំពីសមុដ្ឋាន ៤ គឺកម្ម ចិត្ត ឧតុ អាហារ ។

និងកិរិយា ។

ពោលដោយប្រភេទនៃភូមិ នាមអាហារទាំងនេះ ចែកបានច្រើនយ៉ាង គឺកុសល ចែកបាន ៤ ភូមិ អកុសល ១ ភូមិ វិបាក ៤ ភូមិ កិរិយា ៣ ភូមិ ។ ឯកពឡិង្ការាហារ ដោយជាតិ ជាអព្យាកតៈ ដោយភូមិ ជាកាមាវចរតែម្យ៉ាង ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងអាហារប្បច្ច័យនេះ ដូចពោលមកហើយ ។

ក្នុងអាហារប្បច្ច័យដែលចែកបាន ដូចពោលមកហើយនេះ អាហារដែលជាកុសល ៣ យ៉ាង ទាំង ៤ ភូមិ ជាបច្ច័យដល់សម្បយុត្តធម៌ និងដល់ចិត្តសមុដ្ឋានរូប ក្នុងបញ្ចវោការភព ដោយអាហារប្បច្ច័យ អាហារដ៏សេស វៀររូបាវចរវិញ្ញាណ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះក្នុងអរូបភពដោយអាហារប្បច្ច័យ ។ ក្នុងអាហារដែលជាអកុសល ក៏ន័យនេះដូចគ្នា ។ អាហារដែលជាវិបាកទាំង ៤ ភូមិ ជាអាហារប្បច្ច័យដល់ធម៌ដែលសម្បយុត្តក្នុងទីទាំងពួង ។ ក្នុងអធិការនេះ កាមាវចរវិបាក និងរូបាវចរវិបាកដែលកើតក្នុងបញ្ចវោការភព ជាអាហារប្បច្ច័យដល់ចិត្តជរូប ក្នុងបវត្តិកាល ដល់កដត្តារូប ក្នុងបដិសន្ធិកាល ។ អាហារដែលជាលោកុត្តរវិបាក ជាអាហារប្បច្ច័យដល់ចិត្តសមុដ្ឋានរូបតែម្យ៉ាង ។ អាហារដែលកើតក្នុងអរូបភព រមែងមិនជាបច្ច័យដល់រូប ។ អាហារដែលជាកិរិយាទាំង ៣ ភូមិ ជាអាហារប្បច្ច័យដល់ធម៌ដែលសម្បយុត្ត និងចិត្តសមុដ្ឋានរូប ក្នុងបញ្ចវោការភព ។ អាហារដែលជាកាមាវចរ និងអរូបាវចរ ជាអាហារប្បច្ច័យ

*ដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ក្នុងអរូបភព ដោយអាហារប្បច្ច័យ ។ កពឡិង្ការាហារដែលកើតឡើងក្នុងសន្តតិ ៤ ព្រះមានព្រះភាគ ត្រាស់ដោយមិនប្លែកគ្នាថា ជាបច្ច័យដល់កាយនេះក៏ពិត តែកាលពោលដោយប្លែកគ្នាក្នុងអធិការនេះ កពឡិង្ការាហារនេះ ជាអ្នកឲ្យកើតរូបដែលមានអាហារជាសមុដ្ឋានផង និងតាមរក្សារូបដែលមានអាហារជាសមុដ្ឋានផង ដោយអាហា-រប្បច្ច័យ អធិប្បាយថា ជាបច្ច័យដល់សន្តតិរូបដែលមានសមុដ្ឋាន ៣ ដ៏សេសដោយអាហារប្បច្ច័យ ព្រោះចិញ្ចឹមរូប ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងអាហារប្បច្ច័យនេះ ដូចពណ៌នាមកហើយនេះ ៕*

## អធិប្បាយអាហារប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## ឥន្ទ្រិយប្បច្ច័យ

[ ១៧ ] ពាក្យថា ឥន្ទ្រិយប្បច្ច័យ បានដល់ ចក្ខុន្ទ្រិយ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយឥន្ទ្រិយប្បច្ច័យ សោតិន្ទ្រិយ ជាបច្ច័យនៃសោតវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយសោតវិញ្ញាណធាតុនោះផង ដោយឥន្ទ្រិយប្បច្ច័យ ឃានិន្ទ្រិយ ជាបច្ច័យនៃឃានវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយឃានវិញ្ញាណធាតុនោះផង ដោយឥន្ទ្រិយប្បច្ច័យ ជិវ្ហិន្ទ្រិយ ជាបច្ច័យនៃជិវ្ហាវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះផង ដោយឥន្ទ្រិយប្បច្ច័យ កាយិន្ទ្រិយ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយឥន្ទ្រិយប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃកដត្តារូបទាំងឡាយ ដោយឥន្ទ្រិយប្បច្ច័យ ពួកឥន្ទ្រិយដែលមិនមានរូប ជាបច្ច័យនៃសម្បយុត្តធម៌ផង នៃរូបទាំងឡាយដែលកើតអំពីសម្បយុត្តធម៌នោះផង ដោយឥន្ទ្រិយប្បច្ច័យ ។

# អធិប្បាយ

## ឥន្ទ្រិយប្បច្ចយនិទ្ទេស

[ ១៧ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងឥន្ទ្រិយប្បច្ចយនិទ្ទេសដូចតទៅ

បទថា **ចក្ខុន្ទ្រិយំ** បានដល់ ឥន្ទ្រិយ គឺចក្ខុ ។ បទថា **ឥន្ទ្រិយប្បច្ចយេន** សេចក្តីថា ចក្ខុន្ទ្រិយជាដើមនោះ ខ្លួនឯងកើតមុនហើយ ជាបច្ច័យដល់អរូបធម៌ តាំងអំពីកើត រហូតដល់រលត់ ដោយឥន្ទ្រិយប្បច្ច័យ ។ ក្នុងសោតិន្ទ្រិយជាដើម ក៏ន័យនេះដូចគ្នា ។ អរូបជីវិតិន្ទ្រិយ ព្រះមានព្រះភាគក៏ទ្រង់សង្គ្រោះចូលក្នុងពាក្យនេះថា ឥន្ទ្រិយដែលមិនមានរូប ។ ក្នុងបទថា **តំសមុដ្ឋានានំ** នេះ ទ្រង់សង្គ្រោះសូម្បីកដត្តារូប ដោយន័យដែលពោលហើយខាងដើម សមដូចទ្រង់ត្រាស់ក្នុងបញ្ហាវារៈថា ក្នុងខណៈនៃបដិសន្ធិ ពួកវិបាកាព្យាកតឥន្ទ្រិយ ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និងពួកកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ ដូច្នេះ ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះប៉ុណ្ណោះ ។

ឥន្ទ្រិយប្បច្ច័យនេះ គឺឥន្ទ្រិយ ២០ វៀរឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ។ ពិតហើយ ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ជាកំណើតនៃភេទស្ត្រី និងភេទបុរសក៏ពិត តែក្នុងកាលដែលជាកលលៈជាដើម កាលឥត្ថិន្ទ្រិយ និងបុរិ-សិន្ទ្រិយទាំងនោះមាន ក៏គង់មិនសម្រេចភាពជាឥន្ទ្រិយប្បច្ច័យដល់ភេទស្ត្រី និងភេទបុរសទាំងនោះ ព្រោះភេទស្រី និងភេទប្រុសមិនទាន់មានផង មិនជាឥន្ទ្រិយប្បច្ច័យដល់ធម៌ដទៃផង ។ ពិតហើយ ធម៌ដែលជាឥន្ទ្រិយប្បច្ច័យ និងឈ្មោះថា មិនសម្រេចភាពជាឥន្ទ្រិយប្បច្ច័យដល់ធម៌ដែលមិនបែកគ្នា ក្នុង

ខណៈដែលខ្លួនមាន រមែងមិនមាន ព្រោះហេតុនោះ ទើបឥត្ថិន្ទ្រិយ និង បុរិសិន្ទ្រិយទាំងនោះ មិនជាឥន្ទ្រិយប្បច្ច័យ ។

ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយទាំងនេះ ជាពូជនៃភេទស្រី និងភេទប្រុស ពួកណា ដោយបរិយាយដែលមកក្នុងព្រះសូត្រ ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ទាំងនោះ រាប់ថា ជាបកតូបនិស្សយប្បច្ច័យដល់ភេទស្រី និងភេទប្រុសទាំង នោះផងដែរ ។

ឥន្ទ្រិយប្បច្ច័យ អ្នកសិក្សាគប្បីជ្រាបថា បានដល់ ឥន្ទ្រិយ ២០ ។ ឥន្ទ្រិយប្បច្ច័យនោះ ដោយជាតិ ចែកចេញជា ៥ ជាតិ គឺកុសល អកុសល វិបាក កិរិយា និងរូប ។ ក្នុង ៥ ជាតិនោះ ចែកបានច្រើនយ៉ាងទៀត គឺ ដែលជាកុសល ចែកតាមភូមិបាន ៤ ភូមិ អកុសល ជាកាមាវចរតែម្យ៉ាង វិបាក មាន ៤ ភូមិ កិរិយា មាន ៣ ភូមិ រូបជាកាមាវចរភូមិប៉ុណ្ណោះ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងឥន្ទ្រិ-យប្បច្ច័យនេះយ៉ាងនេះ ។

ក្នុងឥន្ទ្រិយប្បច្ច័យដែលចែកហើយយ៉ាងនេះ បច្ច័យ គឺឥន្ទ្រិយដែល ជាកុសលទាំង ៤ ភូមិ ជាបច្ច័យដល់ធម៌ដែលសម្បយុត្ត និងដល់រូបដែល មានចិត្តជាសមុដ្ឋានក្នុងបញ្ចវោការភពដោយឥន្ទ្រិយប្បច្ច័យ ។ ឥន្ទ្រិយដែល ជាអកុសលក៏ដូចគ្នា ។ កុសល និងអកុសលដ៏សេស វៀររូបាវចរកុសល ជាបច្ច័យដល់ធម៌ដែលសម្បយុត្ត ក្នុងអរូបភព ដោយឥន្ទ្រិយប្បច្ច័យ ។

ឥន្ទ្រិយដែលជាវិបាកទាំង ៤ ភូមិ ជាឥន្ទ្រិយប្បច្ច័យដល់ធម៌ដែល

សម្បយុត្តដោយចំណែកមួយ ។ បណ្តាឥន្ទ្រិយដែលជាវិបាកទាំងនេះ ឥន្ទ្រិយដែលជាកាមាវចរវិបាក និងរូបាវចរវិបាក កាលកើតក្នុងបញ្ចវោការភព ជាបច្ច័យដល់ចិត្តជរូប ក្នុងបវត្តិកាល និងជាបច្ច័យដល់កដត្តារូប ក្នុងបដិសន្ធិកាល ដោយឥន្ទ្រិយប្បច្ច័យ ។ ឥន្ទ្រិយដែលជាលោកុត្តរវិបាក ជាបច្ច័យដល់ចិត្តជរូបតែម្យ៉ាង ។ ឥន្ទ្រិយដែលជាលោកុត្តរវិបាក ដែលកើតឡើងក្នុងអរូបភព រមែងមិនជាបច្ច័យដល់រូបឡើយ ។

ឥន្ទ្រិយដែលជាកិរិយាទាំង ៣ ភូមិ ជាឥន្ទ្រិយប្បច្ច័យដល់ធម៌ដែលសម្បយុត្ត និងដល់ចិត្តសមុដ្ឋានរូបក្នុងបញ្ចវោការភព ។ ឯឥន្ទ្រិយដែលជាកាមាវចរកិរិយា និងអរូបាវចរកិរិយា រមែងសម្រេចភាពជាឥន្ទ្រិយប្បច្ច័យដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ក្នុងអរូបភព ។

ក្នុងរូបឥន្ទ្រិយទាំង ៦ មានចក្ខុន្ទ្រិយជាដើម ចក្ខុន្ទ្រិយជាបច្ច័យដល់ចក្ខុវិញ្ញាណចិត្ត ២ ព្រមទាំងធម៌ដែលសម្បយុត្ត ក្នុងចំណែកកុសលវិបាក និងអកុសលវិបាក ។ សោតិន្ទ្រិយជាដើម ក៏ជាឥន្ទ្រិយប្បច្ច័យដល់សោតវិញ្ញាណជាដើម យ៉ាងនោះដូចគ្នា ។

រូបជីវិតិន្ទ្រិយជាបច្ច័យដល់រូប ដែលកើតរួមគ្នាជាមួយខ្លួនក្នុងឋិតិក្ខណៈ ដោយឥន្ទ្រិយប្បច្ច័យ ។ ភាពជាសហជាតប្បច្ច័យ រមែងមិនមានដល់រូបជីវិតិន្ទ្រិយនោះ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្នក្នុងឥន្ទ្រិយប្បច្ច័យ យ៉ាងនេះឯង ៕

## អធិប្បាយឥន្ទ្រិយប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## ឈានប្បច្ច័យ

[ ១៨ ] ពាក្យថា ឈានបច្ច័យ បានដល់ អង្គឈានទាំងឡាយ ជាបច្ច័យនៃពួកធម៌ដែលប្រកបដោយឈានផង នៃរូបទាំងឡាយដែលកើតអំពីធម៌នោះផង ដោយឈានបច្ច័យ ។

# អធិប្បាយ

## ឈានប្បច្ចយនិទ្ទេស

[ ១៨ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងឈានប្បច្ចយនិទ្ទេសដូចតទៅ បទថា **ឈានង្គានិ** បានដល់ អង្គឈាន ៧ គឺវិតក្ក វិចារ បីតិ សោមនស្ស ទោមនស្ស ឧបេក្ខា និងចិត្តេកគ្គតា ដែលកើតឡើងក្នុងចិត្តដ៏សេស វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ ព្រោះពួកនៃវិញ្ញាណ ៥ ត្រឹមតែជាការធ្លាក់ទៅ ( នៃចិត្តក្នុងអារម្មណ៍ ) ឧបេក្ខា សុខ និងទុក្ខ សូម្បីមាននៅក្នុងចិត្តទាំងនោះ ព្រះមានព្រះភាគ ទ្រង់ក៏មិនលើកឡើងសម្តែងថា ជាអង្គឈាន ព្រោះមិនមានការចូលទៅសម្ងំអារម្មណ៍ ។ បណ្តាអង្គឈានទាំងនោះ អង្គឈានក្នុងអហេតុកចិត្តដ៏សេស ព្រះមានព្រះភាគ ទ្រង់ក៏មិនលើកឡើងសម្តែង ( ថាជាអង្គឈាន ) ដូចគ្នា ព្រោះត្រូវកាត់ផ្តាច់ទៅហើយ តែក្នុងការប្រមូលធម៌ក្នុងអធិការនេះ ទ្រង់បានលើកឡើងសម្តែងផងដែរ ។

ក្នុងបទថា **តំសមុដ្ឋានានំ** នេះ អ្នកសិក្សាគប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់សង្គ្រោះយកកដត្តារូប សមដូចទ្រង់ត្រាស់ក្នុងបញ្ហាវារៈថា ក្នុងខណៈនៃបដិសន្ធិ ពួកអង្គឈានដែលជាវិបាកាព្យាកតៈ ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និងពួកកដត្តារូបដោយឈានប្បច្ច័យ ដូច្នេះ ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះប៉ុណ្ណោះ ។

ឈានប្បច្ច័យ គឺអង្គឈាន ៧ ចែកដោយប្រភេទនៃជាតិ មាន ៤ គឺ កុសល អកុសល វិបាក និងកិរិយា ។ ពោលដោយអំណាចនៃភូមិទៀត ចែកបាន ១២ ភូមិ គឺកុសល ៤ អកុសល ១ វិបាក ៤ កិរិយា ៣ ។

អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងឈានប្បច្ច័យ ដូចពោលមកហើយនេះ ។

ក្នុងឈានប្បច្ច័យ ដែលចែកចេញយ៉ាងនេះ អង្គឈានដែលជាកុសលទាំង ៤ ភូមិ ជាបច្ច័យដល់ធម៌ដែលសម្បយុត្ត និងចិត្តសមុដ្ឋានរូប ក្នុងបញ្ចវោការភព ដោយឈានប្បច្ច័យ ។ អង្គឈានដ៏សេស វៀរទីដែលជារូបាវចរ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ក្នុងអរូបភព ដោយឈានប្បច្ច័យ ។ ក្នុងអកុសលជាដើម ក៏ន័យនេះដូចគ្នា អង្គឈានដែលជាកាមាវចរវិបាក និងរូបាវចរវិបាក ជាឈានប្បច្ច័យដល់ធម៌ដែលសម្បយុត្ត និងចិត្តជរូប ក្នុងបវត្តិកាល ជាឈានប្បច្ច័យដល់ធម៌ដែលសម្បយុត្ត និងកដត្តារូប ក្នុងបដិសន្ធិកាល ។ អង្គឈានដែលជាអរូបវិបាក ជាឈានប្បច្ច័យដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ឯលោកុត្តរវិបាកដែលកើតក្នុងអរូបភពក៏ដូចគ្នា ។ តែក្នុងបញ្ចវោការភព អង្គឈានដែលជាលោកុត្តរវិបាកនោះ ជាបច្ច័យដល់ចិត្តសមុដ្ឋានរូប ដោយឈានប្បច្ច័យ អង្គឈានដែលជាកិរិយាទាំង ៣ ភូមិ ជាឈានប្បច្ច័យដល់ធម៌ដែលសម្បយុត្ត និងចិត្តសមុដ្ឋានរូប ក្នុងបញ្ចវោការភព ។ អង្គឈានដែលកើតក្នុងអរូបភព ជាបច្ច័យដល់ធម៌ដែលសម្បយុត្តប៉ុណ្ណោះ ដោយឈានប្បច្ច័យ ។ អ្នកសិក្សគប្បីជ្រាបវិនិច្ឆ័យដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងឈានប្បច្ច័យនេះ ដូចពោលមកហើយនេះឯង ៕៚

## អធិប្បាយឈានប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## មគ្គប្បច្ច័យ

[ ១៩ ] *ពាក្យថា មគ្គប្បច្ច័យ បានដល់ អង្គមគ្គទាំងឡាយ ជាបច្ច័យនៃពួកធម៌ដែលប្រកបដោយមគ្គផង នៃរូបទាំងឡាយ ដែលកើតអំពីធម៌នោះផង ដោយមគ្គប្បច្ច័យ ។*

# អធិប្បាយ

## មគ្គប្បច្ចយនិទ្ទេស

[ ១៩ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងមគ្គប្បច្ចយនិទ្ទេសដូចតទៅ បទថា **មគ្គង្គានិ** បានដល់ អង្គមគ្គ ១២ នេះ គឺបញ្ញា វិតក្ក សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ វីរិយៈ សតិ សមាធិ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្ប មិច្ឆាវាយាមៈ មិច្ឆាសមាធិ ដែលកើតឡើងក្នុងចិត្តដ៏សេស វៀរអហេតុកចិត្តុប្បាទ ។ ព្រះមានព្រះភាគ ទ្រង់មិនលើកអង្គមគ្គក្នុងអហេតុកចិត្តជាមគ្គប្បច្ច័យ ព្រោះភាពជាមគ្គ ជាធម៌កើតខាងក្រោយនៃហេតុ ។ ទ្រង់សង្គ្រោះកដត្តារូបក្នុងបទថា **តំសមុដ្ឋានានំ** នេះ ។ សមដូចទ្រង់ត្រាស់ក្នុងបញ្ហាវារៈថា ក្នុងខណៈនៃបដិសន្ធិ ពួកអង្គមគ្គដែលជាវិបាកាព្យាកតៈជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និងពួកកដត្តារូប ដោយមគ្គប្បច្ច័យ ដូច្នេះ ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះប៉ុណ្ណេះ ។

មគ្គប្បច្ច័យនេះ បានដល់ អង្គមគ្គ ១២ ចែកដោយប្រភេទនៃជាតិមាន ៤ មានកុសលជាតិជាដើម ចែកដោយភូមិ បាន ១២ ភូមិ មានកាមាវចរភូមិជាភូមិ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ដូចពោលមកហើយ ។

ក្នុងមគ្គប្បច្ច័យ ដែលចែកបានយ៉ាងនេះ អង្គមគ្គដែលជាកុសលទាំង ៤ ភូមិ ជាបច្ច័យដល់ធម៌ដែលសម្បយុត្ត និងដល់ចិត្តសមុដ្ឋានរូបក្នុងបញ្ចវោការភព ដោយមគ្គប្បច្ច័យ ។ អង្គមគ្គដ៏សេស វៀរអង្គមគ្គដែលជារូបាវចរ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តក្នុងអរូបភព ដោយមគ្គប្បច្ច័យ ។ អធិប្បាយទាំងអស់ លោកឲ្យពិស្តារហើយ ដូចក្នុងឈានប្បច្ច័យ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងមគ្គប្បច្ច័យនេះ ដូចពោលមកហើយនោះឯង ។៚

## អធិប្បាយមគ្គប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## សម្បយុត្តប្បច្ច័យ

[ ២០ ] ពាក្យថា សម្បយុត្តប្បច្ច័យ បានដល់ ខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយសម្បយុត្តប្បច្ច័យ ។

# អធិប្បាយ

## សម្បយុត្តប្បច្ចយនិទ្ទេស

[ ២០ ] បាលីក្នុងសម្បយុត្តប្បច្ចយនិទ្ទេសមានអត្ថក្លីច្បាស់ហើយ ។ ឈ្មោះថា សម្បយុត្តប្បច្ច័យនេះ ពោលដោយសង្ខេប បានដល់ អរូបក្ខន្ធទាំងអស់ ។ ដោយប្រភេទ ចែកបានច្រើនយ៉ាង គឺដោយជាតិ មានកុសល-ជាតិជាដើម ដោយភូមិ មានកាមាវចរភូមិជាដើម ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងសម្បយុត្តប្បច្ច័យនេះ ដូចពោលមកហើយ ។

ក្នុងសម្បយុត្តប្បច្ច័យ ដែលចែកហើយយ៉ាងនេះ បណ្តាកុសលក្ខន្ធទាំង ៤ ភូមិ ខន្ធ ១ ជាបច្ច័យដល់ខន្ធ ៣ ( ដោយសម្បយុត្តប្បច្ច័យ ) ខន្ធ ៣ ជាបច្ច័យដល់ខន្ធ ១ ខន្ធ ២ ជាបច្ច័យដល់ខន្ធ ២ ។ កុសលក្ខន្ធទាំងអស់ជាបច្ច័យដល់គ្នានិងគ្នា ដោយសម្បយុត្តប្បច្ច័យ ដោយប្រការដូច្នេះ ក្នុងអកុសលក្ខន្ធ វិបាកក្ខន្ធ និងកិរិយាខន្ធក៏ន័យនេះដូចគ្នា ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងសម្បយុត្តប្បច្ច័យនេះ ដូចពណ៌នាមកហើយនោះឯង ៕

**អធិប្បាយសម្បយុត្តប្បច្ចយនិទ្ទេស ចប់**

# អភិធម្មបិដក

## វិប្បយុត្តប្បច្ច័យ

[ ២១ ] ពាក្យថា វិប្បយុត្តប្បច្ច័យ បានដល់ ពួកធម៌ដែលមានរូប ជាបច្ច័យនៃពួកធម៌ដែលមិនមានរូប ដោយវិប្បយុត្តប្បច្ច័យ ពួកធម៌មិនមានរូប ជាបច្ច័យនៃពួកធម៌ដែលមានរូប ដោយវិប្បយុត្តប្បច្ច័យ ។

# អធិប្បាយ

## វិប្បយុត្តប្បច្ចយនិទ្ទេស

[ ២១ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងវិប្បយុត្តប្បច្ចយនិទ្ទេស ដូចតទៅ

បទថា **រូបិនោ ធម្មា អរូបីនំ** គប្បីជ្រាបដោយអំណាចហទយវត្ថុ និងចក្ខុន្ទ្រិយជាដើមមុនៗ ។ ពិតហើយ ក្នុងរូបធម៌ ៦ ចំណែកនេះឯងជាវិប្បយុត្តប្បច្ច័យដល់អរូបក្ខន្ធ ។ សូម្បីធម៌ដែលជាអារម្មណ៍ មានរូបាយតនៈជាដើម ជាវិប្បយុត្តគ្នា ( ជាមួយនឹងចក្ខាយតនៈជាដើម ) ក៏ពិត តែមិនចាត់ជាវិប្បយុត្តប្បច្ច័យ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនមានការទាក់ទងក្នុងរឿងសម្បយោគ ។ អរូបក្ខន្ធទាំងឡាយកើតឡើង ដូចចេញមកអំពីខាងក្នុងនៃរូបដែលជាទីអាស្រ័យ មានចក្ខុបសាទជាដើម ទើបការជាប់ជំពាក់ក្នុងចក្ខុបសាទជាដើមនេះមាន ទោះជាអរូបក្ខន្ធទាំងនោះសម្បយុត្ត ឬវិប្បយុត្តជាមួយចក្ខុបសាទជាដើមនោះក៏ដោយ ។ ឯធម៌ដែលជាអារម្មណ៍ រមែងត្រឹមតែជាអារម្មណ៍នៃចិត្តដែលកើតឡើង ព្រោះអាស្រ័យវត្ថុរូបប៉ុណ្ណោះ ព្រោះហេតុនោះ ទើបការសម្ពន្ធនៃសម្បយោគ ក្នុងចក្ខុបសាទជាដើមនោះ មិនមាន ។ រូបាយតនៈជាដើមនោះ មិនចាត់ជាវិប្បយុត្តប្បច្ច័យ ព្រោះមិនមានការជាប់ទាក់ទងក្នុងរឿងសម្បយោគ ដោយប្រការដូច្នេះ ។ អ្នកសិក្សាគប្បីជ្រាបវិប្បយុត្តប្បច្ច័យនេះ ក្នុងហទយវត្ថុជាដើមផងដែរ សមដូចព្រះមានព្រះភាគត្រាស់ក្នុងបញ្ហាវារៈថា វត្ថុជាបច្ច័យនៃពួកកុសលក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។

វត្ថុជាបច្ច័យនៃពួកអកុសលក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ ចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ សោតាយតនៈ ... ឃានាយតនៈ ... ជិវ្ហាយតនៈ ... កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ដូច្នេះ ។

បទថា **អរូបិណោ ធម្មា រូបីនំ** នេះ អ្នកសិក្សាគប្បីជ្រាបដោយអំណាចខន្ធ ៤ ។ ពិតហើយ បណ្តាអរូបធម៌ ខន្ធ ៤ ជាវិប្បយុត្តប្បច្ច័យដល់រូបធម៌ ដែលជាសហជាត និងបុរេជាត ។ ឯនិព្វាន ទោះជាអរូបធម៌ក៏មិនជាបច្ច័យដល់រូប ដោយវិប្បយុត្តប្បច្ច័យ ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ថា ការសមប្រកបដោយបទ ៤ ការប្រាសចេញចាកបទ ៤ ដូច្នេះ ។ អ្នកសិក្សាគប្បីជ្រាបថា អរូបក្ខន្ធ ៤ ប៉ុណ្ណោះ ជាវិប្បយុត្តប្បច្ច័យ ដោយប្រការដូច្នេះ ។ សមដូចព្រះមានព្រះភាគត្រាស់ក្នុងបញ្ហាវារៈថា សហជាត គឺពួកកុសលក្ខន្ធជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកកុសលក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ក្នុងខណៈនៃបដិសន្ធិ ពួកវិបាកាព្យាកតក្ខន្ធ ជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ពួកខន្ធជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដូច្នេះ ។ អ្នកសិក្សាគប្បីជ្រាបអធិប្បាយព្រះបាលីក្នុងទីនេះប៉ុណ្ណោះ ។

ឈ្មោះថា វិប្បយុត្តប្បច្ច័យនេះ ដោយសង្ខេប បានដល់ រូបធម៌ និង

អរូបធម៌ដែលកំពុងប្រព្រឹត្តទៅ ក្នុងបញ្ចវោការភព ។ បណ្តារូបធម៌ និងអរូបធម៌ទាំងនោះ រូបធម៌ចែកបាន ៦ យ៉ាង ដោយអំណាចនៃហទយវត្ថុ និងចក្ខុបសាទជាដើម ។ អរូបធម៌ដែលកើតក្នុងបញ្ចវោការភព ចែកបាន ៤ ជាតិ គឺកុសល អកុសល វិបាក និងកិរិយា ។ អរូបធម៌នោះ ដោយភូមិ ចែកបាន ១១ ភូមិ គឺកុសល ៤ អកុសល ១ វិបាក ៣ កិរិយា ៣ ដោយអំណាចនៃកាមាវចរភូមិជាដើម ។ តែអរូបវិបាក មិនជាវិប្បយុត្តប្បច្ច័យឡើយ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យដោយការចែក ដោយប្រការផ្សេងៗ ក្នុងវិប្បយុត្តប្បច្ច័យនេះ ដូចពណ៌នាមកនេះ ។

ក្នុងវិប្បយុត្តប្បច្ច័យដែលចែកហើយយ៉ាងនេះ កុសល និងអកុសលទាំង ៤ ភូមិ ដែលកើតក្នុងបញ្ចវោការភពជាបច្ច័យ ដល់ចិត្តសមុដ្ឋានរូបដែលកើតឡើងព្រមជាមួយខ្លួន ដោយសហជាតវិប្បយុត្តប្បច្ច័យ ។ ជាបច្ច័យដល់រូបកាយ ដែលមានសមុដ្ឋាន ៤ និង ៣ ដែលកើតមុន ដែលកន្លងឧប្បាទក្ខណៈ មកដល់ឋិតិក្ខណៈ ដោយបច្ឆាជាតវិប្បយុត្តប្បច្ច័យ ។ ពាក្យថា រូបកាយដែលមានសមុដ្ឋាន ៣ ក្នុងទីនេះ អ្នកសិក្សា គប្បីជ្រាបថាបានដល់ កាយនៃព្រហ្មបារិសជ្ជាជាដើម ព្រោះមិនមានអាហារជាសមុដ្ឋាន ។

កាមាវចរវិបាក និងរូបាវចរវិបាក ជាបច្ច័យដល់ចិត្តសមុដ្ឋានរូប ក្នុងបវត្តិកាល និងដល់កដត្តារូប ក្នុងបដិសន្ធិកាល ដោយសហជាតវិប្បយុត្តប្បច្ច័យ ។ លោកុត្តរវិបាក ជាបច្ច័យដល់ចិត្តសមុដ្ឋានរូបតែម្យ៉ាង ។ វិបាកទាំង ៣ ភូមិនេះ ( កាមភូមិ រូបភូមិ លោកុត្តរភូមិ ) ជាបច្ច័យដល់

កាយដែលមានសមុដ្ឋាន ៤ និង ៣ ដែលកើតមុន ដោយបច្ឆាជាតវិប្ប-យុត្តប្បច្ច័យ ។

កិរិយាទាំង ៣ ភូមិ ជាបច្ច័យដល់ចិត្តសមុដ្ឋានរូបដោយសហជាត-វិប្បយុត្តប្បច្ច័យ ។ ជាបច្ច័យដល់កាយដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ដែលកើតមុន ដោយបច្ឆាជាតវិប្បយុត្តប្បច្ច័យ ។

ឯក្នុងបិតរូប ៦ យ៉ាងនោះ ក្នុងបដិសន្ធិក្ខណៈ វត្ថុរូបជាបច្ច័យដល់កាមាវចរវិបាក និងរូបាវចរវិបាក ដោយសហជាតវិប្បយុត្តប្បច្ច័យ ។ ជាបច្ច័យដល់កុសលទាំង ៤ ភូមិ អកុសល ១ ភូមិ វិបាកទាំង ៣ ភូមិ វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ និងដល់កិរិយាចិត្តទាំង ៣ ភូមិ ដែលកើតឡើងក្នុងបវត្តិកាល ដោយបុរេជាតវិប្បយុត្តប្បច្ច័យ ។ ចក្ខាយតនៈជាដើម ជាបច្ច័យដល់ចក្ខុវិញ្ញាណជាដើម ដោយបុរេជាតវិប្បយុត្តប្បច្ច័យ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងអធិការនេះ ដូចពណ៌នាមកហើយនោះឯង ។៚

## អធិប្បាយវិប្បយុត្តប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## អត្ថិប្បច្ច័យ

[ ២២ ] ពាក្យថា អត្ថិប្បច្ច័យ បានដល់ ខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយអត្ថិប្បច្ច័យ មហាភូតរូប ៤ ជាបច្ច័យនៃគ្នានិងគ្នា ដោយអត្ថិប្បច្ច័យ នាមរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកចិត្តចេតសិកធម៌ ជាបច្ច័យនៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន ដោយអត្ថិប្បច្ច័យ មហាភូតរូប ជាបច្ច័យនៃឧបាទារូបទាំងឡាយ ដោយអត្ថិប្បច្ច័យ ចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ សោតាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយសោតវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ ឃានាយតនៈ ជាបច្ច័យនៃឃានវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយឃានវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ ជិវ្ហាយតនៈ ជាបច្ច័យនៃជិវ្ហាវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ សទ្ទាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយសោតវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ គន្ធាយតនៈ ជាបច្ច័យនៃឃានវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយឃានវិញ្ញាណធាតុនោះផង ដោយ

អត្ថិប្បច្ច័យ រសាយតនៈ ជាបច្ច័យនៃជិវ្ហាវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយអត្ថិប្បច្ច័យ មនោធាតុក្តី មនោវិញ្ញាណធាតុក្តី អាស្រ័យរូបណាហើយ ប្រព្រឹត្តទៅ រូបនោះ ជាបច្ច័យនៃមនោធាតុផង នៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយអត្ថិប្បច្ច័យ ។

# អធិប្បាយ

## អត្ថិប្បច្ចយនិទ្ទេស

[ ២២ ] *អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងអត្ថិប្បច្ចយនិទ្ទេសដូចតទៅ*

*ព្រះមានព្រះភាគ ទ្រង់សម្តែងអត្ថិប្បច្ច័យដោយអំណាចនៃសហជាត ដោយបទថា* **ចត្តារោ ខន្ធា** *ជាដើម ទ្រង់សម្តែងអត្ថិប្បច្ច័យដោយអំណាចនៃបុរេជាត ដោយបទថា* **ចក្ខាយតនំ** *ជាដើម ។ ក្នុងបទថា* **យំ រូបំ និស្សាយ** *នេះ ទ្រង់សម្តែងអត្ថិប្បច្ច័យដោយអំណាចធម៌ដែលជាសហជាត និងបុរេជាត ។ បាលីនេះមកហើយ ដោយអំណាចអត្ថិប្បច្ច័យ នៃធម៌ដែលជាសហជាតផង បុរេជាតផង ដោយប្រការដូច្នេះ ។ ក្នុងបញ្ហាវារៈ បាន អត្ថិប្បច្ច័យ ដោយអំណាចនៃអាហារ និងឥន្ទ្រិយ ដែលជាបច្ឆាជាតផង ព្រោះព្រះបាលីមកហើយ ដោយអំណាចធម៌ទាំងនេះ គឺសហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ តែក្នុងទីនេះ ព្រះមានព្រះភាគ ទ្រង់ទេសនា ដោយអំណាចនៃធម៌ដែលមានចំណែកសេសសល់ ។ នេះជាពាក្យអធិប្បាយ ព្រះបាលីក្នុងទីនេះប៉ុណ្ណេះ ។*

*ឈ្មោះថា អត្ថិប្បច្ច័យនេះ មាន ២ យ៉ាង គឺដោយអញ្ញមញ្ញៈ និងមិនមែនអញ្ញមញ្ញៈ ។ ក្នុង ២ យ៉ាងនោះ អត្ថិប្បច្ច័យដែលជាអញ្ញមញ្ញៈ មាន ៣ យ៉ាង គឺអរូបជាមួយអរូប រូបជាមួយរូប រូប និងអរូប ជាមួយរូប និងអរូប ។ ពិតហើយ ក្នុងពាក្យនេះថា ខន្ធ ៤ ជាអត្ថិប្បច្ច័យដល់អរូប ព្រះមានព្រះភាគត្រាស់ដល់អរូប ជាបច្ច័យដល់រូបក្ខន្ធ ដោយអំណាចការកើតឡើងនៃចិត្តទាំងអស់ ។ ក្នុងបទថា* **ចត្តារោ មហាភូតា** *ត្រាស់ដល់រូបជា*

*បច្ច័យដល់រូប ដោយអំណាចការបន្តនៃរូបទាំងអស់ ។ ក្នុងបទនេះថា* **ឱក្កន្តិក្ខណេ នាមរូបំ** *ត្រាស់ដល់រូប និងអរូប ជាមួយរូប និងអរូប ជាបច្ច័យដល់គ្នានិងគ្នា ដោយអំណាចនៃខន្ធដែលធ្វើបដិសន្ធិកិច្ច និងវត្ថុរូប ។ អត្ថិ-ប្បច្ច័យដែលមិនមែនអញ្ញមញ្ញៈ មាន ៣ យ៉ាង គឺអរូប ជាអត្ថិប្បច្ច័យដល់រូប រូប ជាអត្ថិប្បច្ច័យដល់រូប រូប ជាអត្ថិប្បច្ច័យដល់ អរូប ។ ពិតហើយ ក្នុងបទនេះថា* **ចិត្តចេតសិកា ធម្មា** *ព្រះមានព្រះភាគ ត្រាស់ដល់អរូប ជាបច្ច័យដល់រូប ដោយអំណាចបញ្ចុរេភាវការភព ។ ក្នុងពាក្យនេះថា* **មហាភូតា ឧបាទារូបានំ** *ត្រាស់ដល់រូបជាបច្ច័យដល់រូប ដោយអំណាចការបន្តនៃរូបទាំងអស់ ។ ក្នុងបទថា* **ចក្ខាយតនំ ចក្ខុវិញ្ញាណធាតុយា** *ជាដើម ព្រះមានព្រះភាគត្រាស់ថា រូបជាបច្ច័យដល់អរូប ដោយអត្ថិប្បច្ច័យដោយអំណាចវត្ថុ និងអារម្មណ៍ ។ម្យ៉ាងទៀត ឈ្មោះថា អត្ថិប្បច្ច័យនេះដោយសង្ខេប ទោះពោលថា បានដល់បញ្ចក្ខន្ធដែលកំពុងជារូប គឺនាមនិងរូប ដែលដល់ខណៈទាំង ៣ ក៏គួរ ។*

*អត្ថិប្បច្ច័យនោះ ដោយប្រភេទនៃជាតិចែកចេញជា ៥ ជាតិ គឺកុសលអកុសល វិបាក កិរិយា និងរូប ។ ក្នុង ៥ ជាតិនោះ អត្ថិប្បច្ច័យ ដែលជាកុសល មាន ២ គឺជាសហជាត និងបច្ឆាជាត អកុសល វិបាក និងកិរិយាក៏ដូចគ្នា ។ បណ្តាអត្ថិប្បច្ច័យ ដែលជាកុសលជាដើមនោះ កុសលចែកចេញជា ៤ ភូមិ ដោយអំណាចជាកាមាវចរជាដើម ។ អកុសលជាកាមាវចរតែម្យ៉ាង ។ វិបាក ប្រព្រឹត្តទៅទាំង ៤ ភូមិ កិរិយា ប្រព្រឹត្តទៅ*

ក្នុងភូមិ ៣ អត្ថិប្បច្ច័យ គឺរូប ជាកាមាវចរតែម្យ៉ាង ។ អត្ថិប្បច្ច័យ គឺរូប នោះ មាន ២ យ៉ាង ដោយអំណាចសហជាត និងបុរេជាត ។ ក្នុង ២ យ៉ាង នោះ វត្ថុ ៥ និងអារម្មណ៍ ៥ ជាបុរេជាតតែម្យ៉ាង ។ ហទយវត្ថុ ជាសហជាត ក៏បាន ជាបុរេជាតក៏បាន ឯអាហារ និងឥន្ទ្រិយ ដែលមកហើយក្នុងបញ្ហាវារៈ រមែងមិនបានទូវការចែក ដោយសហជាតជាដើម ។ អ្នកសិក្សាគប្បីជ្រាប វិនិច្ឆ័យ ដោយការចែកដោយប្រការផ្សេងៗ ក្នុងអធិការនេះ ដូចពណ៌នាមក ហើយ ។

ក្នុងអត្ថិប្បច្ច័យដែលចែកយ៉ាងនេះ កុសលទាំង ៤ ភូមិ ដែលកើត ព្រមគ្នាជាអត្ថិប្បច្ច័យ ។ ក្នុងបញ្ចវោការភព ជាបច្ច័យទូវគ្នានិងគ្នា ដល់ខន្ធ ទាំងឡាយ ដោយន័យជាដើមថា ខន្ធ ១ ជាបច្ច័យដល់ខន្ធ ៣ និងជា បច្ច័យដល់ចិត្តសមុដ្ឋានរូប ( ដោយអត្ថិប្បច្ច័យ ) ។ ដល់សហជាតកុសល ដ៏សេស វៀររូបាវចរកុសល ជាបច្ច័យដល់ខន្ធទាំងឡាយ ដែលសម្បយុត្ត ប៉ុណ្ណោះ ក្នុងអរូបភព ដោយអត្ថិប្បច្ច័យ ។ ដល់កុសលដែលជាបច្ឆាជាត ទាំង ៤ ភូមិ ជាបច្ច័យដល់កាយ ដែលមានសមុដ្ឋាន ៤ និង ៣ ក្នុងបញ្ច-វោការភព ដោយអត្ថិប្បច្ច័យ ។ ក្នុងអកុសលជាដើម ក៏ន័យនេះដូចគ្នា ។ ពិតហើយ អកុសលដែលជាសហជាតនោះ ជាបច្ច័យដល់ខន្ធទាំងឡាយ ដែលសម្បយុត្ត និងដល់ចិត្តសមុដ្ឋានរូប ក្នុងបញ្ចវោការភព និងជាបច្ច័យ ដល់ខន្ធទាំងឡាយ ដែលសម្បយុត្តប៉ុណ្ណោះ ក្នុងចតុវោការភព ដោយ អត្ថិប្បច្ច័យ ។ អកុសល ដែលជាបច្ឆាជាត ជាបច្ច័យដល់កាយ ដែល

មានសមុដ្ឋាន ៤ និង ៣ ក្នុងបញ្ចវោការភព ដោយអត្ថិប្បច្ច័យ ។

ដោយភាពជាវិបាក អត្ថិប្បច្ច័យដែលជាកាមាវចរវិបាក និងរូបាវចរ-វិបាក ជាបច្ច័យដល់ខន្ធទាំងឡាយ និងដល់កដត្តារូប ក្នុងបដិសន្ធិក្ខណៈ ដោយពិតប្រាកដ ដោយសហជាតត្ថិប្បច្ច័យ តែជាបច្ច័យដល់ខន្ធដែលសម្ប-យុត្ត និងដល់ចិត្តសមុដ្ឋានរូប ក្នុងបវត្តិកាល ដោយសហជាតត្ថិប្បច្ច័យ ជាបច្ច័យដល់កាយ ដែលមានសមុដ្ឋាន ៤ និង ៣ ដែលដល់ឋិតិក្ខណៈហើយ ដោយបច្ឆាជាតត្ថិប្បច្ច័យ ។

អរូបាវចរវិបាក និងលោកុត្តរវិបាក ដែលកើតក្នុងអរូបភព ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួនប៉ុណ្ណោះ ដោយសហជាតត្ថិប្បច្ច័យ ។ លោកុត្តរវិបាក ក្នុងបញ្ចវោការភព ជាបច្ច័យដល់ខន្ធដែលសម្បយុត្តជាមួយខ្លួន និងដល់ចិត្តសមុដ្ឋានរូប ដោយសហជាតត្ថិប្បច្ច័យ ជាបច្ច័យដល់កាយដែលមានសមុដ្ឋាន ៤ និង ៣ ដោយបច្ឆាជាតត្ថិប្បច្ច័យ ។

ដោយភាពជាកិរិយា អត្ថិប្បច្ច័យដែលជារូបាវចរកិរិយា ជាបច្ច័យដល់ខន្ធដែលសម្បយុត្ត និងដល់ចិត្តសមុដ្ឋានរូបដោយសហជាតត្ថិប្បច្ច័យ ។ ជាបច្ច័យដល់កាយដែលមានសមុដ្ឋាន ៤ និង ៣ ដោយបច្ឆាជាតត្ថិប្បច្ច័យ ។

កាមាវចរ និងអរូបាវចរ ជាបច្ច័យដល់ខន្ធ ដែលសម្បយុត្តប៉ុណ្ណោះ ក្នុងអរូបភព និងជាបច្ច័យដល់ចិត្តសមុដ្ឋានរូប ក្នុងបញ្ចវោការភព ដោយសហជាតត្ថិប្បច្ច័យ ។ ជាបច្ច័យដល់កាយ ដែលមានសមុដ្ឋាន ៤ និង ៣ ដោយបច្ឆាជាតត្ថិប្បច្ច័យ ។

ធម៌ គឺរូប ជាអត្ថិប្បច្ច័យ ៤ បច្ច័យ គឺសហជាត បុរេជាត អាហារ និងឥន្ទ្រិយ ។ បច្ច័យទាំង ៤ នោះ អត្ថិប្បច្ច័យ គឺរូបដែលជាសហជាត មាន ៤ យ៉ាង ដោយអំណាចនៃសមុដ្ឋាន ។ ក្នុងសមុដ្ឋាន ៤ នោះ រូបដែលមានកម្មជាសមុដ្ឋាន ជាសហជាតត្ថិប្បច្ច័យយ៉ាងនេះ គឺមហាភូតរូប ១ ជាបច្ច័យដល់មហាភូតរូប ៣ មហាភូតរូប ៣ ជាបច្ច័យដល់មហាភូតរូប ១ មហាភូតរូប ២ ជាបច្ច័យដល់មហាភូតរូប ២ មហាភូតរូបជាបច្ច័យដល់ឧបាទារូប ដោយសហជាតត្ថិប្បច្ច័យ ។ វត្ថុរូបក្នុងបដិសន្ធិក្ខណៈ ជាបច្ច័យដល់កាមាវចរវិបាកក្ខន្ធ និងរូបាវចរវិបាកក្ខន្ធ ដោយសហជាតត្ថិប្បច្ច័យ ។ រូបដែលមានសមុដ្ឋាន ៣ ដ៏សេស ជាបច្ច័យដោយសហជាតត្ថិប្បច្ច័យយ៉ាងនេះ គឺមហាភូតរូប ១ ជាបច្ច័យដល់មហាភូតរូប ៣ មហាភូតរូប ៣ ជាបច្ច័យដល់មហាភូតរូប ១ មហាភូតរូប ២ ជាបច្ច័យដល់មហាភូតរូប ២ មហាភូតរូបជាបច្ច័យដល់ឧបាទារូប ។

ឯបុរេជាតត្ថិប្បច្ច័យនេះ មាន ២ យ៉ាង គឺវត្ថុបុរេជាត និងអារម្មណ-បុរេជាត ។ ទាំង ២ យ៉ាងនោះ អ្នកសិក្សាគប្បីភ្ជាប់សេចក្ដីកាន់យកតាមន័យ ដែលខ្ញុំពោលហើយក្នុងបុរេជាតប្បច្ច័យខាងដើម ។ អាហារត្ថិប្បច្ច័យគប្បីប្រកបតាមន័យដែលប្រកបហើយ ក្នុងកពឡិង្ការាហារប្បច្ច័យខាងដើម ។ អាហារត្ថិប្បច្ច័យនេះ ព្រះមានព្រះភាគត្រាស់ហៅថា អត្ថិប្បច្ច័យ ក្នុងអធិការនេះ ដោយភាពជាបច្ច័យ ក្នុងខណៈដែលខ្លួនមិនទាន់រលត់ទៅ ។ រូបជីវិតិន្ទ្រិយ គប្បីកាន់យកតាមន័យដែលខ្ញុំពោលហើយ ក្នុងការអធិប្បាយ

*រូបជីវិតិន្ទ្រិយ ក្នុងឥន្ទ្រិយប្បច្ច័យខាងដើម ។ ក្នុងទីនេះ រូបជីវិតិន្ទ្រិយនោះ ព្រះមានព្រះភាគត្រាស់ហៅថា អត្ថិប្បច្ច័យ ដោយភាពជាបច្ច័យក្នុងខណៈ ដែលខ្លួនមិនទាន់រលត់ទៅ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយធម៌ដែល ជាបច្ចយុប្បន្ន ក្នុងអធិការនេះ ដូច្នេះឯង ។*

## អធិប្បាយអត្ថិប្បច្ចយនិទ្ទេស ចប់

# អភិធម្មបិដក

## នត្ថិប្បច្ច័យ

[ ២៣ ] ពាក្យថា នត្ថិប្បច្ច័យ បានដល់ ពួកចិត្តចេតសិកធម៌ ដែលរលត់ក្នុងលំដាប់ស្មើ ជាបច្ច័យនៃពួកចិត្តចេតសិកធម៌ ជាបច្ចុប្បន្ន ដោយនត្ថិប្បច្ច័យ ។

# អធិប្បាយ

## នត្ថិប្បច្ចយនិទ្ទេស

[ ២៣ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ក្នុងនត្ថិប្បច្ចយនិទ្ទេសដូចតទៅ បទថា **សមនន្តរនិរុទ្ធា** គឺជាធម៌ដែលមិនមានរវាងចន្លោះ ដោយចិត្តុប្បាទដទៃ រលត់ទៅដោយលំដាប់ដោយល្អ ។ បទថា **បដុប្បន្នានំ** បានដល់ កើតឡើងចំពោះមុខ ។ ដោយបទនេះ ព្រះមានព្រះភាគ រមែងញ៉ាំងភាពដែលនត្ថិប្បច្ច័យ ជានត្ថិប្បច្ច័យ ព្រោះអត្ថថា ឲ្យឱកាសដល់ធម៌ដែលកើតក្រោយប្រព្រឹត្តទៅ ។ ពិតហើយ កាលធម៌ដែលកើតមុន មិនឲ្យឱកាសដល់ធម៌ដែលកើតក្រោយប្រព្រឹត្តទៅ ដោយអំណាចការដែលខ្លួនឯងរលត់ទៅ ភាពដែលធម៌ខាងក្រោយនោះ នឹងកើតឡើងចំពោះមុខ មិនគប្បីមាន ។ នេះជាពាក្យអធិប្បាយព្រះបាលី ក្នុងទីនេះប៉ុណ្ណេះ ។ ពាក្យដ៏សេសទាំងអស់ អ្នកសិក្សាគប្បីជ្រាបតាមន័យដែលខ្ញុំពោលហើយ ក្នុងអនន្តរប្បច្ច័យនោះឯង ។

ពិតហើយ លក្ខណៈនៃបច្ច័យប៉ុណ្ណោះ ជាការប្លែកគ្នាក្នុងរវាងអនន្តរប្បច្ច័យ និងនត្ថិប្បច្ច័យនេះ តែការផ្សេងគ្នានៃបច្ច័យ និងបច្ចយុប្បន្ន មិនមានឡើយ ។ ម្យ៉ាងទៀត បច្ច័យទាំង ២ នោះ ព្រះមានព្រះភាគ ទ្រង់សម្តែងបច្ច័យ និងបច្ចយុប្បន្នដោយសរុប ដោយន័យថា ចក្ខុវិញ្ញាណធាតុក្តី ពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះក្តី ជាបច្ច័យនៃមនោធាតុផងដូច្នេះជាដើម ។ ក្នុងទីនេះ ទ្រង់សម្តែងធម៌ទាំងអស់នោះ ដោយទូទៅ ដោយអំណាចការរលត់ទៅ និងការកើតឡើងថា ពួកចិត្តចេតសិកធម៌ ដែលរលត់ក្នុងលំដាប់ស្មើ ជាបច្ច័យនៃពួកចិត្តចេតសិកធម៌ ជាបច្ចុប្បន្ន ដូច្នេះ ។៚

# អភិធម្មបិដក

## វិគតប្បច្ច័យ

[ ២៤ ] ពាក្យថា វិគតប្បច្ច័យ បានដល់ ពួកចិត្តចេតសិកធម៌ ដែលទៅប្រាសក្នុងលំដាប់ស្មើ ជាបច្ច័យនៃពួកចិត្តចេតសិកធម៌ ជាបច្ចុប្បន្នដោយវិគតប្បច្ច័យ ។

# អធិប្បាយ

## វិគតប្បច្ចយនិទ្ទេស

[ ២៤ ] ក្នុងវិគតប្បច្ចយនិទ្ទេស បទថា **សមនន្តរវិគតា** គឺប្រាសទៅដោយលំដាប់ដោយល្អ ។ ដោយបទនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងថា វិគតប្បច្ច័យ ជាបច្ច័យដោយភាវៈដែលខ្លួនឯងប្រាសទៅ ។ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យនេះ ផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ អត្ថមិនផ្សេងគ្នាឡើយ ៕

**អធិប្បាយវិគតប្បច្ចយនិទ្ទេស ចប់**

# អភិធម្មបិដក

## អវិគតប្បច្ច័យ

[ ២៥ ] ពាក្យថា អវិគតប្បច្ច័យ បានដល់ ខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយអវិគតប្បច្ច័យ មហាភូតរូប ៤ ជាបច្ច័យនៃគ្នានិងគ្នា ដោយអវិគតប្បច្ច័យ នាមរូប ជាបច្ច័យនៃគ្នានិងគ្នា ដោយអវិគតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកចិត្តចេតសិកធម៌ ជាបច្ច័យនៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន ដោយអវិគតប្បច្ច័យ មហាភូតរូប ជាបច្ច័យនៃឧបាទារូបទាំងឡាយ ដោយអវិគតប្បច្ច័យ ចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយអវិគតប្បច្ច័យ សោតាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយសោតវិញ្ញាណធាតុនោះផង ដោយអវិគតប្បច្ច័យ ឃានាយតនៈ ជាបច្ច័យនៃឃានវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយឃានវិញ្ញាណធាតុនោះផង ដោយអវិគតប្បច្ច័យ ជិវ្ហាយតនៈ ជាបច្ច័យនៃជិវ្ហាវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះផង ដោយអវិគតប្បច្ច័យ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយអវិគតប្បច្ច័យ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយអវិគតប្បច្ច័យ សទ្ទាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយសោតវិញ្ញាណធាតុនោះផង ដោយអវិគតប្បច្ច័យ គន្ធាយតនៈ ជាបច្ច័យនៃឃានវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយ

យានវិញ្ញាណធាតុនោះផង ដោយអវិគតប្បច្ច័យ រសាយតនៈ ជាបច្ច័យនៃ ជិវ្ហាវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយជិវ្ហាវិញ្ញាណធាតុនោះផង ដោយអវិគតប្បច្ច័យ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុផង នៃ ពួកធម៌ដែលប្រកបដោយកាយវិញ្ញាណធាតុនោះផង ដោយអវិគតប្បច្ច័យ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ជា បច្ច័យនៃមនោធាតុផង នៃពួកធម៌ដែលប្រកបដោយមនោធាតុនោះផង ដោយ អវិគតប្បច្ច័យ មនោធាតុក្តី មនោវិញ្ញាណធាតុក្តី អាស្រ័យនូវរូបណាហើយ ប្រព្រឹត្តទៅ រូបនោះ ជាបច្ច័យនៃមនោធាតុផង នៃមនោវិញ្ញាណធាតុផង នៃ ពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយអវិគតប្បច្ច័យ ។

## បច្ចយវិភង្គវារៈ ចប់

# អធិប្បាយ

## អវិគតប្បច្ចយនិទ្ទេស

[ ២៥ ] គប្បីជ្រាបវិនិច្ឆ័យ បទថា **ចត្តារោ ខន្ធា** ជាដើម ក្នុងអវិគតប្បច្ចយនិទ្ទេសដូចតទៅ

អ្នកសិក្សាគប្បីជ្រាបអត្ថដោយអាការទាំងពួង តាមន័យដែលខ្ញុំពោលហើយ ក្នុងអត្ថិប្បច្ចយនិទ្ទេសនោះឯង ។ ពិតហើយ បច្ច័យនេះ ជាមួយនឹងអត្ថិប្បច្ច័យ ផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ ឯអត្ថមិនផ្សេងគ្នាឡើយ ៕ ៚

**អធិប្បាយអវិគតប្បច្ចយនិទ្ទេស ចប់**

# បច្ចយនិទ្ទេសបកិណ្ណកវិនិច្ឆយកថា

ដើម្បីឲ្យជាក់ច្បាស់ក្នុងការប្រព្រឹត្តទៅនៃញាណ ក្នុងបច្ច័យ ២៤ នេះ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ទាំងដោយឧទ្ទេស និងនិទ្ទេសដូចពណ៌នាមកហើយ ឥឡូវនេះ អ្នកសិក្សា គប្បីជ្រាបបកិណ្ណកវិនិច្ឆ័យ ដោយអំណាចបទទាំង ១០ នេះ គឺដោយភាវៈដែលធម៌ច្រើនយ៉ាង ជាបច្ច័យតែមួយ ១ ដោយភាវៈដែលធម៌តែមួយ ជាបច្ច័យច្រើនយ៉ាង ១ ដោយភាវៈដែលបច្ច័យតែមួយ ជាបច្ច័យបានច្រើនយ៉ាង ១ ដោយបច្ច័យដែលជាសភាគៈ ១ ដោយបច្ច័យដែលជាវិសភាគៈ ១ ដោយបច្ច័យដែលជាគូ ១ ដោយជាជនកប្បច្ច័យ និងអជនកប្បច្ច័យ ១ ដោយបច្ច័យដែលចូលជាមួយធម៌បានទាំងអស់ និងមិនបានទាំងអស់ ១ ដោយការកំណត់ជាដើមថា រូបជាបច្ច័យដល់រូបជាដើម ១ ដោយការចែកដោយកត ១ ។

ក្នុង ១០ យ៉ាងនោះ ពាក្យថា ដោយភាវៈដែលធម៌ច្រើនយ៉ាង ជាបច្ច័យតែមួយ សេចក្តីថា ធម៌ច្រើនយ៉ាង ជាបច្ច័យដោយភាពតែមួយ ក្នុងបច្ច័យ ២៣ ដ៏សេសនេះ វៀរកម្មប្បច្ច័យទាំងនេះ ។ ឯកម្មប្បច្ច័យ ជាចេតនាធម៌ប៉ុណ្ណោះ ។ អ្នកសិក្សា គប្បីជ្រាបវិនិច្ឆ័យ ដោយភាវៈដែលធម៌ច្រើនយ៉ាង ជាបច្ច័យតែមួយ ក្នុងអធិការនេះប៉ុណ្ណោះ ។

ពាក្យថា ដោយភាវៈដែលធម៌តែមួយ ជាបច្ច័យច្រើនយ៉ាង សេចក្តីថា ក្នុងហេតុប្បច្ច័យ ធម៌ ១ គឺអមោហៈ មិនត្រឹមតែជាបុរេជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ ឈានប្បច្ច័យប៉ុណ្ណោះទេ តែជាបច្ច័យដោយអំណាចបច្ច័យ ២០ ដ៏សេសផងដែរ ។ អលោភៈ និងអទោសៈ មិនជា

ឥន្ទ្រិយប្បច្ច័យ និងមគ្គប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ១៨ ដ៏សេស ។ លោភៈ មោហៈ មិនជាវិបាកប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ១៧ ដ៏សេស ។ ទោសៈ មិនជាអធិបតិប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ១៦ ដ៏សេស ។

ក្នុងអារម្មណប្បច្ច័យ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុ ដោយបច្ច័យ ៤ យ៉ាង គឺអារម្មណប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ជាបច្ច័យដល់មនោធាតុ និងអហេតុកមនោវិញ្ញាណធាតុ ទាំងជាបច្ច័យ ដោយអារម្មណាធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យ ដល់សហេតុកមនោវិញ្ញាណធាតុ ។ អ្នកសិក្សា គប្បីជ្រាបភាពដែលធម៌ គឺអារម្មណប្បច្ច័យទាំងអស់ ជាបច្ច័យច្រើនយ៉ាងដោយន័យនេះ ។

ក្នុងអធិបតិប្បច្ច័យ អ្នកសិក្សា គប្បីជ្រាបភាពដែលអារម្មណាធិបតិប្បច្ច័យច្រើនយ៉ាង តាមន័យដែលពោលហើយ ក្នុងអារម្មណប្បច្ច័យ ។ ក្នុងធម៌ដែលជាសហជាតាធិបតី វីមំសាធិបតី ជាបច្ច័យ ២០ យ៉ាង ដូចអមោហហេតុ ។ ឆន្ទៈ មិនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យឡើយ តែជាបច្ច័យ ដោយអំណាចបច្ច័យ ១៧ ដ៏សេស ។ ចិត្ត មិនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ១៩ ដ៏សេស ។ វីរិយៈ មិនជាហេតុប្បច្ច័យ បុរេ-

ជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ និងឈានប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ១៩ ដ៏សេស ។

ក្នុងអនន្តរប្បច្ច័យ បណ្ដាខន្ធ ៤ ដែលព្រះមានព្រះភាគត្រាស់ដោយន័យថា **ចក្ខុវិញ្ញាណធាតុ** ជាដើម ។

វេទនាខន្ធ មិនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ និងមគ្គប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ១៩ ដ៏សេស ។ សញ្ញាខន្ធ មិនជាឥន្ទ្រិយប្បច្ច័យ និងឈានប្បច្ច័យ តែជាបច្ច័យ ដោយអំណាចបច្ច័យ ១៧ ដ៏សេស ។ ក្នុងសង្ខារក្ខន្ធ ហេតុ ជាបច្ច័យតាមន័យដែលពោលហើយ ក្នុងហេតុប្បច្ច័យ ឆន្ទៈ និងវីរិយៈ ជាបច្ច័យតាមន័យដែលពោលហើយ ក្នុងអធិបតិប្បច្ច័យ ។

ផស្សៈ មិនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យឡើយ តែជាបច្ច័យដោយអំណាចបច្ច័យ ១៨ ដ៏សេស ។

ចេតនា មិនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ១៩ ដ៏សេស ។

វិតក្ក មិនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ១៩ ដ៏សេស ។ វិចារ មិនជាមគ្គប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ១៨ ដ៏សេស ។ បីតិ

ជាបច្ច័យដោយអំណាចបច្ច័យ ១៨ នោះដូចគ្នា ។

ចិត្តេកគ្គតា មិនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ និង អាហារប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ២០ ដ៏សេស ។

សទ្ធា មិនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ១៨ ដ៏សេស ។ សតិ ជាបច្ច័យដោយអំណាចបច្ច័យ ១៩ គឺបច្ច័យ ១៨ នោះ និងមគ្គប្បច្ច័យ ។

ជីវិតិន្ទ្រិយ ជាបច្ច័យដោយអំណាចបច្ច័យ ១៨ ដែលពោលហើយក្នុង សទ្ធា ។ ហិរិ និងឱត្តប្បៈ ជាបច្ច័យដោយអំណាចបច្ច័យ ១៧ ដ៏សេស ដោយដកឥន្ទ្រិយប្បច្ច័យចេញ ។ ចេតសិកដែលជាគូគ្នា មានកាយបស្សទ្ធិ ជាដើម និងបណ្ដាយេវាបនកចេតសិក គឺអធិមោក្ខ មនសិការ តត្រ-មជ្ឈត្តតា ករុណា និងមុទិតា ក៏ដូចគ្នា គឺជាបច្ច័យដោយអំណាចបច្ច័យ ១៧ បុណ្ណោះ ។ ឯវិរតិចេតសិក ជាបច្ច័យ ១៨ យ៉ាង គឺបច្ច័យ ១៧ នោះ និងមគ្គប្បច្ច័យ ។ មិច្ឆាទិដ្ឋិ ជាបច្ច័យ ១៧ យ៉ាង ដោយដកវិបាកប្បច្ច័យ ចេញ ។ មិច្ឆាវាចា មិច្ឆាកម្មន្តៈ និងមិច្ឆាអាជីវៈ ជាបច្ច័យ ១៩ គឺបច្ច័យ ១៧ នោះ ថែមកម្មប្បច្ច័យ និងអាហារប្បច្ច័យ ។ ចេតសិកធម៌ទាំងនេះ គឺ អហិរិកៈ អនោត្តប្បៈ មានះ ថីនៈ មិទ្ធៈ ឧទ្ធច្ចៈ មិនជាហេតុប្បច្ច័យ បុរេ-ជាតប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ តែជាបច្ច័យដោយអំណាចបច្ច័យ ១៦

ដ៏សេស ។ វិចិកិច្ឆា ឥស្សា មច្ឆរិយៈ និងកុក្កុច្ចៈ ជាបច្ច័យ ១៥ យ៉ាង ដោយដកអធិបតិប្បច្ច័យចេញ ។

គប្បីជ្រាបភាពដែលវិញ្ញាណក្ខន្ធ ជាបច្ច័យច្រើនយ៉ាង តាមន័យដែលបានពោលមកហើយ ក្នុងអធិបតិប្បច្ច័យ ។ ក្នុងសមនន្តរប្បច្ច័យ ក៏មានន័យនេះដូចគ្នា ។

ក្នុងសហជាតប្បច្ច័យ បណ្តាខន្ធ ៤ គប្បីជ្រាបភាពដែលធម៌នីមួយៗ ជាបច្ច័យច្រើនយ៉ាង តាមន័យដែលពោលហើយនោះឯង ។ មហាភូតរូប ៤ ជាបច្ច័យ ៩ យ៉ាង គឺអារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ហទយវត្ថុ ជាបច្ច័យ ១០ យ៉ាង គឺបច្ច័យទាំង ៩ នោះ និងវិប្បយុត្តប្បច្ច័យ ។ ក្នុងអញ្ញមញ្ញប្បច្ច័យ មិនមានធម៌ដែលមិនធ្លាប់មានមកអំពីមុន ( គឺមិនមានធម៌ថ្មីបន្ថែមមក ) ។

ក្នុងនិស្សយប្បច្ច័យ ចក្ខាយតនៈជាដើម ជាបច្ច័យ ៩ យ៉ាង គឺ អារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

ក្នុងឧបនិស្សយប្បច្ច័យ មិនមានធម៌ដែលមិនធ្លាប់ពោលមកអំពីមុន ។

ក្នុងបុរេជាតប្បច្ច័យ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ និងរសាយតនៈ ជាបច្ច័យ ៦ យ៉ាង គឺអារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ

ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ក្នុងបុរេជាតប្បច្ច័យនេះ ។ ពាក្យដែលមិនទាន់បានអធិប្បាយមានត្រឹមប៉ុណ្ណោះ ។

ក្នុងបច្ឆាជាតប្បច្ច័យជាដើម មិនមានធម៌ដែលមិនធ្លាប់មានមកអំពីមុន ។

ក្នុងអាហារប្បច្ច័យ កពឡិង្ការាហារ ជាបច្ច័យ ៦ យ៉ាង គឺអារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ ឧបនិស្សយប្បច្ច័យ អាហារប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

ក្នុងឥន្ទ្រិយប្បច្ច័យជាដើម មិនមានធម៌ដែលមិនធ្លាប់មានមក ។ អ្នកសិក្សា គប្បីជ្រាបវិនិច្ឆ័យដោយភាវៈដែលធម៌តែមួយ ជាបច្ច័យច្រើនយ៉ាងក្នុងអធិការនេះ ដូចពណ៌នាមកហើយនោះឯង ។

ពាក្យថា ដោយភាវៈដែលបច្ច័យតែមួយ ជាបច្ច័យបានច្រើនយ៉ាង សេចក្ដីថា ធម៌ណា ជាបច្ច័យនៃបច្ចយុប្បន្ន ប្រភេទណាមួយ បណ្ដាហេតុប្បច្ច័យជាដើម ដោយអាការណា ដោយអត្ថណា ធម៌នោះ មិនលះអាការនោះ អត្ថនោះ ដល់នូវភាពជាបច្ច័យច្រើនយ៉ាងដល់ធម៌ទាំងនោះ ក្នុងខណៈនោះឯង ដោយអាការណា ដោយអត្ថណា ម្យ៉ាងទៀត អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យធម៌នោះ ដោយភាវៈដែលជាបច្ច័យច្រើនយ៉ាង ដោយអាការនោះ ដោយអត្ថនោះ

គឺអមោហៈ ជាហេតុប្បច្ច័យ អមោហៈនោះ មិនលះភាពជាហេតុប្បច្ច័យនោះឡើយ ដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ១១ គឺអធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ

វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ អលោភៈ និងអទោសៈ ដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអំណាចបច្ច័យដ៏សេសអំពីបច្ច័យ ១១ នោះ ដោយដកបច្ច័យ ៣ គឺអធិបតិប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ និងមគ្គប្បច្ច័យចេញ ។ អលោភៈ និងអទោសៈ ទាំង ២ នេះ រមែងបានក្នុងហេតុប្បច្ច័យ និងវិបាកប្បច្ច័យផងដែរ ។ ឯកុសល និងកិរិយា ដាច់ ( មិនមាន ) វិបាកប្បច្ច័យ ។ លោភៈ ទោសៈ និងមោហៈ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអំណាចបច្ច័យដ៏សេស វៀរបច្ច័យ ៤ គឺ ៣ បច្ច័យនោះ មួយអន្លើដោយវិបាកប្បច្ច័យ ។

អារម្មណប្បច្ច័យ មិនលះភាពជាអារម្មណប្បច្ច័យឡើយ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ៧ ទៀត គឺអារម្មណាធិបតិប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ នេះជាការកំណត់យ៉ាងឧក្រិដ្ឋ ក្នុងអារម្មណប្បច្ច័យនេះ កាលអរូបធម៌ ឬរូបធម៌ដែលជាអតីត និងអនាគត ជាអារម្មណប្បច្ច័យមាន រមែងបានបច្ច័យបន្ថែមឡើង ត្រឹមអារម្មណាធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យប៉ុណ្ណោះ ។

វីមំសាក្នុងអធិបតិប្បច្ច័យ ដូចគ្នានឹងអមោហៈ ។ ឆន្ទៈមិនលះភាពជាអធិបតិប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ៨ ទៀត គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ

សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ វីរិយៈ ដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ១០ ដោយអំណាចបច្ច័យទាំងនេះ គឺបច្ច័យទាំង ៨ នោះ បន្ថែមឥន្ទ្រិយប្បច្ច័យ និងមគ្គប្បច្ច័យ ។ ចិត្តដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ១០ ក្រៅអំពីអធិបតិប្បច្ច័យ ដោយអំណាចការដកមគ្គប្បច្ច័យនោះចេញ ហើយបន្ថែមអាហារប្បច្ច័យចូលទៅ ឯអារម្មណាធិបតិប្បច្ច័យ អ្នកសិក្សា គប្បីជ្រាបថា ជាបច្ច័យច្រើនយ៉ាង តាមន័យដែលបានពោលមកហើយ ក្នុងអារម្មណប្បច្ច័យខាងដើម ។

អនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ មិនលះភាពជាអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ៥ គឺឧបនិស្សយប្បច្ច័យ កម្មប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។ ចេតនាក្នុងអរិយមគ្គប៉ុណ្ណោះ រមែងបាននូវភាពជាកម្មប្បច្ច័យក្នុងអនន្តរប្បច្ច័យនេះ ធម៌ដ៏សេស រកមិនបានឡើយ ។

សហជាតប្បច្ច័យ មិនលះភាពជាសហជាតប្បច្ច័យឡើយ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ១៤ គឺហេតុប្បច្ច័យ អធិបតិប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ នេះជាកំណត់យ៉ាងឧក្រិដ្ឋ តែប្រសិនបើពោលដោយអំណាចវត្ថុសហជាតជាដើម គប្បីជ្រាបថា មិនមាន

ហេតុប្បច្ច័យជាដើម ក្នុងវត្ថុសហជាតនេះ ។ ក្នុងអញ្ញមញ្ញប្បច្ច័យ ក៏ន័យនេះដូចគ្នា ។

និស្សយប្បច្ច័យ មិនលះភាពជានិស្សយប្បច្ច័យឡើយ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ១៧ ដទៃទៀត គឺកាត់ភាពជានិស្សយប្បច្ច័យរបស់ខ្លួនចេញ និងកាត់បច្ច័យ ៦ ចេញទៀត គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងបាកបច្ច័យ ២៤ ។ នេះជាការកំណត់យ៉ាងឧក្រិដ្ឋ កាលពោលដោយអំណាចនៃវត្ថុ និងធម៌ដែលអាស្រ័យជាដើម គប្បីជ្រាបថា មិនមានហេតុប្បច្ច័យជាដើម ក្នុងនិស្សយប្បច្ច័យនេះ ។

ក្នុងឧបនិស្សយប្បច្ច័យ អារម្មណូបនិស្សយប្បច្ច័យ ដូចគ្នានឹងអារម្មណាធិបតិប្បច្ច័យ ។ អនន្តរូបនិស្សយប្បច្ច័យ មិនលះភាពជាអនន្តរូបនិស្សយប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ៦ ទៀត គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ កម្មប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។ អរិយមគ្គចេតនាប៉ុណ្ណោះ រមែងបានភាពជាកម្មប្បច្ច័យ ក្នុងអនន្តរូបនិស្សយប្បច្ច័យនេះ មិនបានធម៌ដ៏សេសឡើយ ។ បកតូបនិស្សយៈ គឺបកតូបនិស្សយប្បច្ច័យនោះឯង ។

បុរេជាតប្បច្ច័យ មិនលះភាពជាបុរេជាតប្បច្ច័យរបស់ខ្លួនឡើយ តែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ៨ ទៀត គឺអារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ

វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ នេះជាការសម្ដែងបច្ច័យដែលច្រើនបំផុត តែក្នុងអារម្មណបុរេជាតប្បច្ច័យ រមែងមិនបាននិស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ និងវិប្បយុត្តប្បច្ច័យ គប្បីជ្រាបបច្ច័យដែលបាន ឬមិនបានក្រៃលែងជាងនេះ ដូច្នេះ ។

បច្ឆាជាតប្បច្ច័យ មិនលះភាពជាបច្ឆាជាតប្បច្ច័យរបស់ខ្លួន រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ៣ ទៀត គឺវិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

អាសេវនប្បច្ច័យ មិនលះភាពជាអាសេវនប្បច្ច័យឡើយ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាងទៀត ដោយអាការ ៥ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។

កម្មប្បច្ច័យ មិនលះភាពជាកម្មប្បច្ច័យ ដែលជាកម្មប្បច្ច័យក្នុងខណៈតែមួយ ( ឯកខណិកកម្មប្បច្ច័យ គឺសហជាតកម្មប្បច្ច័យ ) រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាងទៀត ដោយអាការ ៩ គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

នានាខណិកកម្មប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាងទៀត ដោយអាការ ៥ គឺឧបនិស្សយប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។

វិបាកប្បច្ច័យ មិនលះភាពជាវិបាកប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យ

ច្រើនយ៉ាង ដោយអាការ ១៤ គឺហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

ក្នុងអាហារប្បច្ច័យ កពឡិង្ការាហារ មិនលះភាពជាអាហារប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ២ យ៉ាង គឺអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ អាហារដ៏សេស ៣ មិនលះភាពជាអាហារប្បច្ច័យ រមែងដល់ភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ១១ គឺអធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ តាមសមគួរ ។

ក្នុងឥន្ទ្រិយប្បច្ច័យ រូបជីវិតិន្ទ្រិយ ៥ មិនលះភាពជាឥន្ទ្រិយប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ៥ គឺនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ។ រូបជីវិតិន្ទ្រិយ ក៏មិនលះភាពជាឥន្ទ្រិយប្បច្ច័យដូចគ្នា រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ២ គឺអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ អរូបឥន្ទ្រិយ មិនលះភាពជាឥន្ទ្រិយប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាងទៀត ដោយអាការ ១៣ គឺហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឈានប្បច្ច័យ

មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគ-តប្បច្ច័យ តាមសមគួរ ។

ឈានប្បច្ច័យ មិនលះភាពជាឈានប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាងទៀត ដោយអាការ ១០ គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្ប-យុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យតាមសមគួរ ។

មគ្គប្បច្ច័យ មិនលះភាពជាមគ្គប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាងទៀត ដោយអាការ ១២ គឺបច្ច័យ ១០ ដែលពោលហើយ ក្នុងឈានប្បច្ច័យ និងហេតុប្បច្ច័យ មួយអន្លើដោយអធិបតិប្បច្ច័យ តាមសមគួរ ។

សម្បយុត្តប្បច្ច័យ មិនលះភាពជាសម្បយុត្តប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាងទៀត ដោយអាការ ១៣ គឺហេតុប្បច្ច័យ អធិប-តិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ តាមសមគួរ ។

វិប្បយុត្តប្បច្ច័យ មិនលះភាពជាវិប្បយុត្តប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាងទៀត ដោយអាការ ១៧ តាមសមគួរ គឺបច្ច័យដ៏សេសដោយដកបច្ច័យ ៦ ចេញ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវ-នប្បច្ច័យ សម្បយុត្តប្បច្ច័យ នត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ គប្បីជ្រាប

វិភាគនៃបច្ច័យរបស់រូប និងអរូប ក្នុងវិប្បយុត្តប្បច្ច័យនោះ ។

អត្ថិប្បច្ច័យ មិនលះភាពជាអត្ថិប្បច្ច័យ រមែងដល់នូវភាពជាបច្ច័យច្រើនយ៉ាងទៀត ដោយអាការ ១៨ តាមសមគួរ ដោយអំណាចបច្ច័យដ៏សេស ដោយដកបច្ច័យ ៥ ចេញ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។

នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ដូចគ្នានឹងអនន្តរប្បច្ច័យនោះឯង ។

អវិគតប្បច្ច័យ ដូចគ្នានឹងអត្ថិប្បច្ច័យ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការៈដែលបច្ច័យតែមួយ ជាបច្ច័យបានច្រើនយ៉ាង ក្នុងអធិការនេះ ដូចពណ៌នាមកហើយ ។

ពាក្យថា ដោយបច្ច័យដែលជាសភាគៈ សេចក្ដីថា ពិតហើយ ក្នុងបច្ច័យ ២៤ នេះ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អនន្តរូបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ជាសភាគៈគ្នា ។ម្យ៉ាងទៀត អារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យ ក៏ជាសភាគៈគ្នានោះឯង ។ គប្បីជ្រាបវិនិច្ឆ័យ ដោយបច្ច័យដែលជាសភាគៈ ក្នុងអធិការនេះ ដោយឧបាយនេះ ។

ពាក្យថា ដោយបច្ច័យដែលជាវិសភាគៈ សេចក្ដីថា បណ្ដាបច្ច័យទាំងនេះ បុរេជាតប្បច្ច័យ ជាវិសភាគៈជាមួយបច្ឆាជាតប្បច្ច័យ សម្បយុត្តប្បច្ច័យ ជាវិសភាគៈជាមួយវិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ជាវិសភាគៈជាមួយ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ជាវិសភាគៈជាមួយអវិគតប្បច្ច័យ ។ គប្បីជ្រាប

វិនិច្ឆ័យដោយបច្ច័យដែលជាវិសភាគៈ ក្នុងអធិការនេះ ដោយឧបាយនេះ ។

ពាក្យថា ដោយបច្ច័យដែលជាគូ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយបច្ច័យដែលជាគូគ្នាក្នុងបច្ច័យទាំងនេះ ដោយហេតុទាំងនេះ គឺដោយភាពដែលមានអត្ថដូចគ្នា មានសព្ទដូចគ្នា មានកាលដែលខុសគ្នា ជាហេតុ និងជាផលគ្នា និងជាបដិបក្ខចំពោះគ្នានិងគ្នា ។

ពិតហើយ អនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យជាគូមួយ ព្រោះមានអត្ថដូចគ្នា ។

និស្សយប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ចាត់ជាគូមួយ ព្រោះមានសព្ទដូចគ្នា ។

បុរេជាតប្បច្ច័យ និងបច្ឆាជាតប្បច្ច័យ ចាត់ជាគូមួយ ព្រោះមានកាលផ្ទុយគ្នា ។

កម្មប្បច្ច័យ និងវិបាកប្បច្ច័យ ចាត់ជាគូមួយ ព្រោះជាហេតុ និងជាផលគ្នានិងគ្នា ។

សម្បយុត្តប្បច្ច័យ និងវិប្បយុត្តប្បច្ច័យ ចាត់ជាគូមួយ ព្រោះជាបដិបក្ខដល់គ្នានិងគ្នា ។

អត្ថិប្បច្ច័យ និងនត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ក៏ដូចគ្នា អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយបច្ច័យដែលជាគូ ក្នុងអធិការនេះ ដូចពោលមកហើយនេះ ។

ពាក្យថា ដោយជាជនកប្បច្ច័យ និងអជនកប្បច្ច័យ សេចក្តីថា បណ្តា

បច្ច័យទាំងនេះ បច្ច័យ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អនន្តរូបនិស្ស្រ-យប្បច្ច័យ បកតូបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នានាខណិកកម្មប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ចាត់ជាជនកប្បច្ច័យតែម្យ៉ាង មិនជាអជនកប្បច្ច័យឡើយ ។ បច្ឆាជាតប្បច្ច័យ ជាចំណែកឧបត្ថម្ភប៉ុណ្ណោះ មិនជាជនកប្បច្ច័យឡើយ បច្ច័យដ៏សេស ជាជនកប្បច្ច័យ អជនកប្បច្ច័យ និងឧបត្ថម្ភ-កប្បច្ច័យ គប្បីជ្រាបវិនិច្ឆ័យ ដោយជនកប្បច្ច័យ និងអជនកប្បច្ច័យ ក្នុងអធិការនេះ ដូចពណ៌នាមកហើយនេះ ។

ពាក្យថា ដោយបច្ច័យដែលចូលជាមួយធម៌បានទាំងអស់ និងមិនបានទាំងអស់ សេចក្តីថា ក្នុងបច្ច័យទាំងនេះ សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ឈ្មោះថា ចូលជាមួយធម៌បានទាំងអស់ អធិប្បាយថា ជាទីតាំង ជាហេតុនៃរូបធម៌ និងអរូបធម៌ ដែលជាសង្ខត: ទាំងអស់ សេចក្តីថា ធម៌ណាមួយ កាលកើតឡើង វៀរចាកបច្ច័យទាំងនេះរមែងមិនមាន ។ អារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អនន្តរូបនិស្សយប្បច្ច័យ បកតូបនិស្សយប្បច្ច័យ បុរេជា-តប្បច្ច័យ អាសេវនប្បច្ច័យ សម្បយុត្តប្បច្ច័យ នត្ថិប្បច្ច័យ និងអវិគ-តប្បច្ច័យ ឈ្មោះថា បច្ច័យដែលចូលជាមួយធម៌មិនបានទាំងអស់ គឺមិនជាទីតាំងនៃរូបធម៌ និងអរូបធម៌ទាំងអស់ អធិប្បាយថា ជាទីតាំង ជាហេតុនៃអរូបក្ខន្ធទាំងឡាយប៉ុណ្ណោះ ។ ពិតហើយ អរូបធម៌ប៉ុណ្ណោះ រមែងកើតព្រោះបច្ច័យទាំងនេះ រូបធម៌មិនកើតឡើងឡើយ បុរេជាតប្បច្ច័យ និងបច្ឆា-

ជាតប្បច្ច័យ ឈ្មោះថា បច្ច័យដែលចូលជាមួយធម៌មិនបានទាំងអស់ ព្រោះ ជាបច្ច័យដល់អរូបក្ខន្ធ និងរូបក្ខន្ធប៉ុណ្ណោះតាមលំដាប់ ។ បច្ច័យដែលសល់ អំពីពោលមកហើយ ក៏ឈ្មោះថា ប្រកបមិនបានសព្វអន្លើ ព្រោះជាហេតុនៃ ការកើតឡើងរបស់រូបធម៌ និងអរូបធម៌ពួកខ្លះ ។ គប្បីជ្រាបវិនិច្ឆ័យ ដោយ បច្ច័យដែលចូលជាមួយធម៌បានទាំងអស់ និងមិនបានទាំងអស់ ក្នុងអធិការ នេះ ដូចពណ៌នាមកហើយនេះ ។

ពាក្យថា ដោយការកំណត់ជាដើមថា រូបជាបច្ច័យដល់រូបជាដើម សេចក្តីថា ក្នុងបច្ច័យ ២៤ នេះ បច្ច័យណាមួយដែលជារូបតែម្យ៉ាង ឈ្មោះ ថា ជាបច្ច័យដល់រូបប៉ុណ្ណោះមិនមាន ។ តែដែលជារូបដោយចំណែកមួយ ជាបច្ច័យដល់អរូបប៉ុណ្ណោះមាន ។ សួរថា បច្ច័យយ៉ាងនោះ គឺបច្ច័យអ្វី ឆ្លើយថា បុរេជាតប្បច្ច័យ ។ ពិតហើយ បុរេជាតប្បច្ច័យ ជារូបដោយពិត ប្រាកដ ជាបច្ច័យដល់អរូបប៉ុណ្ណោះ ។ បច្ច័យដែលជារូបតែម្យ៉ាង ឈ្មោះថា ជាបច្ច័យដល់រូប និងអរូបមិនមាន តែដែលជាអរូបតែម្យ៉ាង ជាបច្ច័យដល់ អរូបប៉ុណ្ណោះមាន សួរថា បានដល់ បច្ច័យអ្វី ឆ្លើយថា បានដល់ បច្ច័យ ៦ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ សម្បយុត្តប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។ ពិតហើយ បច្ច័យទាំង ៦ នោះ ជាអរូប តែម្យ៉ាង ជាបច្ច័យដល់អរូបប៉ុណ្ណោះ ។

បច្ច័យដែលជាអរូបតែម្យ៉ាង ជាបច្ច័យដល់រូបប៉ុណ្ណោះមាន ។ សួរថា បានដល់ បច្ច័យអ្វី ឆ្លើយថា បានដល់ បច្ឆាជាតប្បច្ច័យ ។ ពិតហើយ

បច្ឆាជាតប្បច្ច័យនោះ ជាអរូបតែម្យ៉ាង ជាបច្ច័យដល់រូបប៉ុណ្ណោះ ។ ឯបច្ច័យដែលជាអរូបធម៌តែម្យ៉ាង ជាបច្ច័យដល់រូបផង អរូបផងមាន ។ សួរថា បានដល់ បច្ច័យអ្វី ឆ្លើយថា បានដល់ បច្ច័យ ៥ គឺហេតុប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ ។ ពិតហើយ បច្ច័យទាំង ៥ នោះ ជាអរូបតែម្យ៉ាង ជាបច្ច័យដល់រូបធម៌ក៏បាន អរូបធម៌ក៏បាន ។ តែបច្ច័យដែលជារូប និងអរូប ដោយពិតប្រាកដ ឈ្មោះថា ជាបច្ច័យដល់រូបប៉ុណ្ណោះមិនមាន តែជាបច្ច័យដល់អរូបមាន ។ សួរថា បានដល់ បច្ច័យអ្វី ឆ្លើយថា បានដល់ អារម្មណប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។ ពិតហើយ បច្ច័យទាំង ២ នេះ ជារូប និងអរូបពិតប្រាកដ តែជាបច្ច័យដល់អរូបប៉ុណ្ណោះ ។

ម្យ៉ាងទៀត បច្ច័យដែលជារូប និងអរូប ដោយពិតប្រាកដ ជាបច្ច័យដល់រូប និងអរូបមាន សួរថា បានដល់ បច្ច័យអ្វី ឆ្លើយថា បានដល់ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ពិតហើយ បច្ច័យទាំងអស់នោះ ជារូប និងអរូប ហើយជាបច្ច័យដល់រូបផង អរូបផង ។ គប្បីជ្រាបវិនិច្ឆ័យ ដោយការកំណត់ជាដើមថា រូបជាបច្ច័យដល់រូបជាដើម ក្នុងអធិការនេះ ដូចពោលមកហើយនេះ ។

ពាក្យថា ដោយការចែកដោយភព សេចក្ដីថា បណ្ដាបច្ច័យ ២៤ នេះ ក្នុងបញ្ចវោការភព បច្ច័យណាមួយដែលឈ្មោះថា មានមិនបាន រមែងមិន

*មាន ។ ឯក្នុងចតុវោការភព បច្ច័យដ៏សេស ២១ រមែងមាន ដោយដក បច្ច័យ ៣ចេញ គឺបុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ និងវិប្បយុត្តប្បច្ច័យ ។ ក្នុងឯកវោការភព រមែងបានបច្ច័យ ៧ គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគ-តប្បច្ច័យ ។ ឯក្នុងរូបដែលមិនទាក់ទងដោយឥន្ទ្រិយខាងក្រៅ រមែងបាន បច្ច័យ ៥ ប៉ុណ្ណោះ គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។*

*គប្បីជ្រាបវិនិច្ឆ័យ ដោយការចែកដោយភព ក្នុងអធិការនេះ ដូច ពោលមកហើយ ដូច្នេះ ៕*

## បច្ចយនិទ្ទេសបកិណ្ណកវិនិច្ឆយកថា ចប់

# អភិធម្មបិដក
# អនុលោមត្តិកប្បដ្ឋាន

## កុសលត្តិកៈ
### បដិច្ចវារៈ

[ ២៦ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។

[ ២៧ ] អកុសលធម៌ អាស្រ័យអកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន កុសលធម៌ អាស្រ័យអកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អព្យាកតធម៌ អាស្រ័យអកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអកុ-

សលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អាស្រ័យអកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។

[ ២៨ ] អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ អាស្រ័យអព្យាកតធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ អាស្រ័យអព្យាកតធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអព្យាកតធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអព្យាកតធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អាស្រ័យអព្យាកតធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអព្យាកតធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។

[ ២៩ ] កុសលធម៌ អាស្រ័យកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ អាស្រ័យកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌

ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អាស្រ័យកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។

[ ៣០ ] កុសលធម៌ អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អព្យាកតធម៌ អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។

[ ៣១ ] កុសលធម៌ អាស្រ័យកុសលធម៌ផង អកុសលធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ អាស្រ័យកុសលធម៌

ផង អកុសលធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ផង អកុសលធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ផង អកុសលធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ផង អកុសលធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អាស្រ័យកុសលធម៌ផង អកុសលធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ផង អកុសលធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។

[ ៣២ ] កុសលធម៌ អាស្រ័យកុសលធម៌ផង អកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ អាស្រ័យកុសលធម៌ផង អកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ផង អកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ផង អកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ផង អកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អាស្រ័យកុសលធម៌ផង អកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើត

ឡើង ព្រោះហេតុប្បច្ច័យក៏មាន ។ កុសលធម៌ក្តី អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ផង អកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មាន ។

[ ៣៣ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះអារម្មណប្បច្ច័យក៏មាន ។ ហេតុប្បច្ច័យ ដែលលោកឲ្យពិស្តារហើយ យ៉ាងណា ឯអារម្មណប្បច្ច័យ បណ្ឌិតគប្បីឲ្យពិស្តារ តាមបែបផែននៃការបង្រៀនក៏យ៉ាងនោះដែរ ។

[ ៣៤ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះអធិបតិប្បច្ច័យក៏មាន ។ ព្រោះអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។

[ ៣៥ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះអវិគតប្បច្ច័យក៏មាន ។ អាស្រ័យអកុសលធម៌ក៏មាន ។ អាស្រ័យអព្យាកតធម៌ ។ អាស្រ័យកុសលធម៌ផង អព្យាកតធម៌ផង ។ អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង ។ អាស្រ័យកុសលធម៌ផង អកុសលធម៌ផង ។ កុសលធម៌ អាស្រ័យកុសលធម៌ផង អកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង អកុសលធម៌ គប្បីកើតឡើង អព្យាកតធម៌ គប្បីកើតឡើង

កុសលធម៌ក្តី អព្យាកតធម៌ក្តី គប្បីកើតឡើង អកុសលធម៌ក្តី អព្យាកតធម៌ក្តី គប្បីកើតឡើង កុសលធម៌ក្តី អកុសលធម៌ក្តី គប្បីកើតឡើង កុសលធម៌ក្តី អកុសលធម៌ក្តី អព្យាកតធម៌ក្តី គប្បីកើតឡើង ព្រោះអវិគតប្បច្ច័យ ។ ហេតុប្បច្ច័យ ដែលលោកឲ្យពិស្តារហើយ យ៉ាងណា ឯអវិគតប្បច្ច័យ បណ្ឌិតគប្បីឲ្យពិស្តារ តាមបែបផែននៃការបង្រៀន ក៏យ៉ាងនោះដែរ ។

ឯកមូលកៈ ចប់

[ ៣៦ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យក៏មាន ។បេ។ កុសលធម៌ក្តី អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ផង អកុសលធម៌ផង អព្យាកតធម៌ផង គប្បីកើតឡើង ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យក៏មាន ។

[ ៣៧ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យ អធិបតិប្បច្ច័យក៏មាន ។បេ។ ព្រោះហេតុប្បច្ច័យ អនន្តរប្បច្ច័យ ។ ព្រោះហេតុប្បច្ច័យ សមនន្តរប្បច្ច័យ ។បេ។ ព្រោះហេតុប្បច្ច័យ អវិគតប្បច្ច័យ ។

ទុមូលកៈ ចប់

[ ៣៨ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យក៏មាន ។ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អនន្តរប្បច្ច័យ ។បេ។ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អវិគតប្បច្ច័យ ។

តិមូលកៈ ចប់

[ ៣៩ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យក៏មាន ។បេ។ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អវិគតប្បច្ច័យ ។

ចតុម្មូលកៈ ចប់

[ ៤០ ] ពួកមូលកៈ មានបញ្ចមូលកៈជាដើម លោកបានបង្រួញហើយ ។ ឯកមូលកៈ ទុមូលកៈ តិមូលកៈ ចតុម្មូលកៈ បញ្ចមូលកៈ សព្វមូលកៈ បុគ្គលអ្នកមិនវង្វេង គប្បីឲ្យពិស្តារផងចុះ ។

ហេតុមូលកៈ ចប់

[ ៤១ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះអារម្មណប្បច្ច័យ ហេតុប្បច្ច័យក៏មាន ។ ព្រោះអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ ។បេ។ ព្រោះអារម្មណប្បច្ច័យ អវិគតប្បច្ច័យ ។ កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះអធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យក៏មាន ... ។ ព្រោះអវិគតប្បច្ច័យ ហេតុប្បច្ច័យ ។ ព្រោះអវិគតប្បច្ច័យ អារម្មណប្បច្ច័យ ។ ព្រោះអវិគតប្បច្ច័យ អធិបតិប្បច្ច័យ ។ ព្រោះអវិគតប្បច្ច័យ វិគតប្បច្ច័យ ។

[ ៤២ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះអវិគតប្បច្ច័យ ហេតុប្បច្ច័យ អារម្មណប្បច្ច័យក៏មាន ។ ព្រោះអវិគតប្បច្ច័យ ហេតុប្បច្ច័យ អធិបតិប្បច្ច័យ ។ ព្រោះអវិគតប្បច្ច័យ ហេតុប្បច្ច័យ អនន្តរប្បច្ច័យ ។ ព្រោះអវិគតប្បច្ច័យ ហេតុប្បច្ច័យ វិគតប្បច្ច័យ ។

[ ៤៣ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះអវិគតប្បច្ច័យ ហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យក៏មាន ។ ព្រោះអវិគតប្បច្ច័យ ហេតុប្បច្ច័យ អារម្មណប្បច្ច័យ អនន្តរប្បច្ច័យ ... ។ ព្រោះវិគតប្បច្ច័យ ។

[ ៤៤ ] ឯកមូលកៈ ទុមូលកៈ តិមូលកៈ ចតុមូលកៈ បញ្ចមូលកៈ សព្វមូលកៈ នៃបទមួយៗ បុគ្គលអ្នកមិនវង្វេង គប្បីឲ្យពិស្តារចុះ ។

ន័យទាំង ៦ គឺតិកប្បដ្ឋាន ដ៏ប្រសើរ ១ ទុកប្បដ្ឋាន ដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន តិកត្តិកប្បដ្ឋាន ១ ទុកទុកប្បដ្ឋាន ១ ជាន័យដ៏ជ្រៅ ក្នុងអនុលោម ។

[ ៤៥ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះនហេតុប្បច្ច័យក៏មាន ហេតុប្បច្ច័យ ក្នុងអនុលោម លោកឲ្យពិស្តារហើយយ៉ាងណា ឯនហេតុប្បច្ច័យ ក្នុងបច្ចនីយប្បដ្ឋាន បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះដែរ ។

[ ៤៦ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះនអារម្មណប្បច្ច័យក៏មាន ។ ព្រោះនអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នសហជាតប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ ននិស្សយប្បច្ច័យ នឧបនិស្សយប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ នកម្មប្បច្ច័យ នវិបាកប្បច្ច័យ នអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ

នឈានប្បច្ច័យ នមគ្គប្បច្ច័យ នសម្បយុត្តប្បច្ច័យ នវិប្បយុត្តប្បច្ច័យ នោអត្ថិប្បច្ច័យ នោនត្ថិប្បច្ច័យ នោវិគតប្បច្ច័យ និងនោអវិគតប្បច្ច័យ ។

[ ៤៧ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះនហេតុប្បច្ច័យ នអារម្មណប្បច្ច័យក៏មាន ។ ឯកមូលកៈ ទុមូលកៈ តិមូលកៈ ចតុម្មូលកៈ ដរាបដល់មូលកៈ ២៣ នៃបទមួយៗ ក្នុងអនុលោម ដែលលោកឲ្យពិស្តារហើយ យ៉ាងណា ឯក្នុងបច្ចនីយៈ បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

ន័យទាំង ៦ គឺតិកប្បដ្ឋានដ៏ប្រសើរ ១ ទុកប្បដ្ឋានដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន ១ តិកត្តិកប្បដ្ឋាន ១ ទុកទុកប្បដ្ឋាន ១ ជាន័យដ៏ជ្រៅ ក្នុងបច្ចនីយៈ ។

[ ៤៨ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យ នអារម្មណប្បច្ច័យក៏មាន ។ អកុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យ នអារម្មណប្បច្ច័យក៏មាន ។ ហេតុប្បច្ច័យ ក្នុងអនុលោម លោកឲ្យពិស្តារហើយ យ៉ាងណា ឯបទក្នុងអនុលោមប្បច្ចនីយៈ បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

[ ៤៩ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យ នអធិបតិប្បច្ច័យក៏មាន ។ ព្រោះហេតុប្បច្ច័យ នអនន្តរប្បច្ច័យ ។បេ។ ព្រោះហេតុប្បច្ច័យ នោអវិគតប្បច្ច័យ ។

[ ៥០ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះ

ហេតុប្បច្ច័យ អារម្មណប្បច្ច័យ នអធិបតិប្បច្ច័យក៏មាន ។ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ នអនន្តរប្បច្ច័យ ។បេ។ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ នោអវិគតប្បច្ច័យ ។ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ ។ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ នោអវិគតប្បច្ច័យ ។ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ ។ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ នោអវិគតប្បច្ច័យ ។ ព្រោះ ហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ... សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ... និងនោអវិគតប្បច្ច័យ ។

[ ៥១ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ ។បេ។ អវិគតប្បច្ច័យ និង នហេតុប្បច្ច័យក៏មាន ។ ព្រោះអវិគតប្បច្ច័យ នអារម្មណប្បច្ច័យ ។បេ។ ព្រោះអវិគតប្បច្ច័យ និងនោវិគតប្បច្ច័យ ។ ព្រោះអវិគតប្បច្ច័យ ហេតុប្បច្ច័យ នអារម្មណប្បច្ច័យ អវិគតប្បច្ច័យ ហេតុប្បច្ច័យ និងនោវិគតប្បច្ច័យ ។ ព្រោះ អវិគតប្បច្ច័យ ហេតុប្បច្ច័យ អារម្មណប្បច្ច័យ នអធិបតិប្បច្ច័យ អវិគតប្បច្ច័យ

ហេតុប្បច្ច័យ អារម្មណប្បច្ច័យ និងនោវិគតប្បច្ច័យ ។ ព្រោះអវិគតប្បច្ច័យ ហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ ។បេ។ ... និងនោវិគតប្បច្ច័យ ។

ន័យទាំង ៦ គឺតិកប្បដ្ឋានដ៏ប្រសើរ ១ ទុកប្បដ្ឋានដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន ១ តិកត្តិកប្បដ្ឋាន ១ ទុកទុកប្បដ្ឋាន ១ ជាន័យដ៏ជ្រៅ ក្នុងអនុលោមបច្ចនីយៈ ។

[ ៥២ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះនហេតុប្បច្ច័យ និងអារម្មណប្បច្ច័យក៏មាន ។ កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះនហេតុប្បច្ច័យ និងអធិបតិប្បច្ច័យក៏មាន ។បេ។ ព្រោះនហេតុប្បច្ច័យ និងអវិគតប្បច្ច័យក៏មាន ។

[ ៥៣ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះនហេតុប្បច្ច័យ នអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ ។បេ។ ព្រោះនហេតុប្បច្ច័យ នអារម្មណប្បច្ច័យ និងអវិគតប្បច្ច័យក៏មាន ។ ព្រោះនហេតុប្បច្ច័យ នអារម្មណប្បច្ច័យ នអធិបតិប្បច្ច័យ ... នអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ។បេ។ នោអត្ថិប្បច្ច័យ នោនត្ថិប្បច្ច័យ នោវិគតប្បច្ច័យ ... និងអវិគតប្បច្ច័យ ។

[ ៥៤ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះនអារម្មណប្បច្ច័យ និងហេតុប្បច្ច័យក៏មាន ។

[ ៥៥ ] កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះនអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ ។បេ។ ព្រោះនអារម្មណប្បច្ច័យ អវិគ-

តប្បច្ច័យ ។បេ។ ព្រោះនោអវិគតប្បច្ច័យ និងហេតុប្បច្ច័យក៏មាន ។ ព្រោះនោអវិគតប្បច្ច័យ អារម្មណប្បច្ច័យ ។បេ។ ព្រោះនោអវិគតប្បច្ច័យ និងវិគតប្បច្ច័យ ។ ព្រោះនោអវិគតប្បច្ច័យ នហេតុប្បច្ច័យ អារម្មណប្បច្ច័យ នោអវិគតប្បច្ច័យ នហេតុប្បច្ច័យ និងវិគតប្បច្ច័យ ។ ព្រោះនោអវិគតប្បច្ច័យ នហេតុប្បច្ច័យ នអារម្មណប្បច្ច័យ ... ព្រោះនអធិបតិប្បច្ច័យ ។បេ។ ព្រោះនោអត្ថិប្បច្ច័យ នោនត្ថិប្បច្ច័យ ... និងវិគតប្បច្ច័យ ។

នយ័ទាំង ៦ គឺតិកប្បដ្ឋានដ៏ប្រសើរ ១ ទុកប្បដ្ឋានដ៏ឧត្តម ១
ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន ១ តិកត្តិកប្បដ្ឋាន ១
ទុកទុកប្បដ្ឋាន ១ ជានយ័ដ៏ជ្រៅ ក្នុងបច្ចនីយានុលោម ។

បណ្ណត្តិវារៈ ចប់

# អដ្ឋកថា

# បុច្ឆាវារៈ

## បច្ចយានុលោម

[ ២៦-៣៥ ] ពាក្យថា **តិកប្បដ្ឋានំ ទុកប្បដ្ឋានំ ។បេ។ ទុកទុកប្បដ្ឋានំ** នេះ ព្រះមានព្រះភាគ ត្រាស់ក្នុងបដ្ឋានមហាបករណ៍ ដែលជាទីរួមនៃសមន្តប្បដ្ឋាន ២៤ ដោយអំណាចតិកប្បដ្ឋានជាដើម បណ្ដាបដ្ឋានទាំងឡាយមានអនុលោមប្បដ្ឋានជាដើម ដូចពោលមកហើយ ដោយទ្រង់អាស្រ័យតិកប្បដ្ឋានជាដើមទាំងឡាយណា ពង្រីកសេចក្ដីតិកប្បដ្ឋានជាដើមទាំងឡាយនោះ ទ្រង់ចែកបដ្ឋានទាំងនោះ មានតិកប្បដ្ឋានជាដើម ដោយអំណាចបច្ច័យទាំងឡាយណា កាលទ្រង់សម្ដែងចំពោះបច្ច័យទាំងនោះ មិនពឹងផ្អែកដល់តិកប្បដ្ឋានជាដើមនោះ ទាំងដោយឧទ្ទេស និងនិទ្ទេស ដោយវារៈ ពោលគឺការចែកបច្ច័យ ដោយការតាំងមាតិកាមុនហើយ ព្រោះព្រះអង្គទ្រង់អាស្រ័យតិកប្បដ្ឋានជាដើមទាំងឡាយណា ទើបត្រាស់ពាក្យថា តិកប្បដ្ឋាន ទុកប្បដ្ឋាន ។បេ។ ទុកទុកប្បដ្ឋាន ដូច្នេះ ឥឡូវនេះ ដើម្បីសម្ដែងតិកប្បដ្ឋានជាដើមនោះឲ្យពិស្ដារ ដោយអំណាចបច្ច័យទាំងឡាយនេះ ទើបទ្រង់អាស្រ័យតិកៈនិងទុកៈនីមួយៗ ចងទេសនាដោយមហាវារៈ ៧ ។ ឈ្មោះនៃមហាវារៈទាំង ៧ នោះ គឺបដិច្ចវារៈ សហជាតវារៈ បច្ចយវារៈ និស្សយវារៈ សំសដ្ឋវារៈ សម្បយុត្តវារៈ និងបញ្ហាវារៈ ។ បណ្ដាវារៈ ៧ នោះ វារៈ

ដែលព្រះមានព្រះភាគត្រាស់ដោយព្រះតម្រាស់ថា **បដិច្ច** ដូចពាក្យថា **កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ** ជាដើម ឈ្មោះថា បដិច្ចវារៈ ។

បើទ្រង់ត្រាស់ដោយអំណាចព្រះតម្រាស់ថា **សហជាតោ** ដូចពាក្យនេះថា **កុសលំ ធម្មំ សហជាតោ កុសលោ ធម្មោ**[១] ជាដើម ឈ្មោះថា សហជាតវារៈ ។ សហជាតវារៈនោះ ពោលដោយអត្ថហើយ មិនផ្សេងអំពីបដិច្ចវារៈ ដែលពោលមកមុន តែវារៈទី ១ ទ្រង់ត្រាស់ដោយអំណាចវេនេយ្យសត្វ ដែលអាចត្រាស់ដឹងដោយពាក្យថា **បដិច្ច** ( អាស្រ័យ ) ។ វារៈទី ២ ទ្រង់ត្រាស់ដោយអំណាចវេនេយ្យសត្វ ដែលអាចត្រាស់ដឹងដោយពាក្យថា **សហជាតោ** ( កើតជាមួយ ) ។ ក្នុងវារៈទាំង ២ នេះ អ្នកសិក្សាគប្បីជ្រាបបច្ច័យទាំងឡាយដោយចំពោះ និងបច្ចយុប្បន្នធម៌ ដោយអំណាចរូបធម៌ និងអរូបធម៌ ។ ឯបច្ច័យ និងបច្ចយុប្បន្នធម៌ទាំងនោះ បានចំពោះដែលកើតព្រមគ្នាប៉ុណ្ណោះ ដែលកើតមុន ឬកើតក្រោយ រមែងមិនបាន ។

វារៈដែលត្រាស់ដោយអំណាចព្រះតម្រាស់ថា **បច្ចយា** យ៉ាងនេះថា **កុសលំ ធម្មំ បច្ចយា កុសលោ ធម្មោ**[២] ជាដើម ឈ្មោះថា បច្ចយវារៈ ។ បច្ចយវារៈនោះ អ្នកសិក្សាគប្បីជ្រាបដោយអំណាចនៃរូបធម៌ និងអរូបធម៌ ដូច ២ វារៈមុន ។ ម្យ៉ាងទៀត បុរេជាតបច្ច័យ ក៏រមែងបានក្នុងអធិការនេះ ។ នេះជាការប្លែកគ្នានៃបច្ចយវារៈជាមួយ ២ វារៈមុន ។

---

១- បិដកខ្មែរ លេខឃ្នាប ២៣៦ ។ ២ -បិដកខ្មែរ លេខឃ្នាប ២៤៦ ។

វារៈបន្ទាប់អំពីនោះ ដែលព្រះមានព្រះភាគ ត្រាស់ដោយអំណាចព្រះតម្រាស់ថា **និស្សាយ** យ៉ាងនេះថា **កុសលំ ធម្មំ និស្សាយ កុសលោ ធម្មោ**[១] ឈ្មោះថា និស្សយវារៈ ។ និស្សយវារៈនោះ ដោយអត្ថមិនផ្សេងអំពីបច្ចយវារៈដែលពោលមកអំពីមុន តែវារៈទី ១ ត្រាស់ដោយអំណាចសត្វដែលអាចត្រាស់ដឹង ដោយពាក្យថា **បច្ចយា** ( ពឹងផ្អែក ) បទទី ២ ត្រាស់ដោយអំណាចសត្វដែលអាចត្រាស់ដឹង ដោយពាក្យថា **និស្សាយ** ( អាស្រ័យ ) ។

បន្ទាប់អំពីនោះ ទ្រង់ត្រាស់ដោយអំណាចព្រះតម្រាស់ថា **សំសដ្ឋោ** យ៉ាងនេះថា **កុសលំ ធម្មំ សំសដ្ឋោ កុសលោ ធម្មោ**[២] ជាដើម ឈ្មោះថា សំសដ្ឋវារៈ ។

វារៈដែលត្រាស់ដោយអំណាចព្រះតម្រាស់ថា **សម្បយុត្តោ** យ៉ាងនេះថា **កុសលំ ធម្មំ សម្បយុត្តោ កុសលោ ធម្មោ**[៣] ឈ្មោះថា សម្បយុត្តវារៈ ។ សម្បយុត្តវារៈនោះ ដោយអត្ថ មិនផ្សេងអំពីសំសដ្ឋវារៈ ។ តែវារៈទី ១ ត្រាស់ដោយអំណាចវេនេយ្យសត្វ ដែលអាចត្រាស់ដឹងដោយពាក្យថា **សំសដ្ឋ** ( ច្រឡំ ) វារៈទី ២ ត្រាស់ដោយអំណាចវេនេយ្យសត្វដែលអាចត្រាស់ដឹង ដោយពាក្យថា **សម្បយុត្ត** ( ប្រកប ) ។ ក្នុង ២ វារៈនេះ អ្នកសិក្សាគប្បីជ្រាបបច្ច័យ និងបច្ចយុប្បន្ន ដោយអំណាចនៃអរូបធម៌

---

១- បិដកខ្មែរលេខឃ្នាប ៣៨០ ។ ២- បិដកខ្មែរលេខឃ្នាប ៣៩០ ។ ៣- បិដកខ្មែរលេខឃ្នាប ៤៧៥ ។

ប៉ុណ្ណោះ ។

ឯក្នុងវារៈទី ៧ ព្រោះព្រះមានព្រះភាគ ទ្រង់លើកឡើងនូវបញ្ហានោះដោយន័យថា **កុសលោ ធម្មោ កុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ**[១] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយហេតុប្បច្ច័យ ដូច្នេះជាដើម ហើយទ្រង់ចែកបញ្ហាទាំងនោះ មិនឲ្យសាំញ៉ាំ មិនឲ្យច្រឡូកច្រឡំដោយន័យថា **កុសលា ហេតូ សម្បយុត្តកានំ ខន្ធានំ** ពួកកុសលហេតុជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ ដូច្នេះជាដើម ទើបវារៈនោះ ឈ្មោះថាបញ្ហាវារៈ ព្រោះទ្រង់ចែកបញ្ហាទាំងឡាយល្អហើយ ។ ក្នុងអធិការនេះ គប្បីជ្រាបបច្ច័យ និងបច្ចយុប្បន្ន ដោយអំណាចនៃរូបធម៌ និងអរូបធម៌ ។

បណ្ដាវារៈទាំងនោះ វារៈទី ១ ឈ្មោះថា បដិច្ចវារៈ វារៈនោះមាន ២ យ៉ាង គឺដោយឧទ្ទេស និងនិទ្ទេស ។ ក្នុង ២ យ៉ាងនោះ ឧទ្ទេសវារៈទី ១ ហៅថា បុច្ឆាវារៈ ក៏បាន ។

ពាក្យថា បណ្ណត្តិវារៈ ក៏ជាឈ្មោះនៃឧទ្ទេសវារៈនោះឯង ។ ពិតហើយ វារៈនោះ ឈ្មោះថា ឧទ្ទេសវារៈ ព្រោះព្រះមានព្រះភាគទ្រង់អាស្រ័យកុសលជាដើម ដោយលើកកុសលជាដើមនោះ សម្ដែងដោយអំណាចនៃហេតុប្បច្ច័យជាដើម ។ ឈ្មោះថា បុច្ឆាវារៈ ព្រោះទ្រង់អាស្រ័យកុសលជាដើម ត្រាស់សួរដល់ការកើតឡើងនៃកុសលជាដើម ដោយអំណាចហេតុប្បច្ច័យជាដើម ។ វារៈនោះ ទោះហៅថា បណ្ណត្តិវារៈក៏បាន ព្រោះព្រះមានព្រះភាគទ្រង់អាស្រ័យ

---

១- បិដកខ្មែរ លេខឃ្នាប ៤៨៤ ។

កុសលជាដើម ហើយឲ្យដឹងដល់ការកើតឡើងនៃកុសលជាដើម ដោយអំណាចនៃហេតុប្បច្ច័យជាដើម ។ ក្នុងសេចក្តីនោះ មានបរិកប្បបុច្ឆាថា **សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា** កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យក៏មានដូច្នេះ ។

ក្នុងបរិកប្បបុច្ឆានេះ មានសេចក្តីដូច្នេះថា កុសលធម៌ណា គប្បីកើតឡើង ព្រោះហេតុប្បច្ច័យ កុសលធម៌នោះ ត្រូវអាស្រ័យកុសលធម៌ឬ ។ ម្យ៉ាងទៀត ក្នុងអធិការនេះ មានសេចក្តីដូច្នេះថា កុសលធម៌ណា គប្បីអាស្រ័យកុសលធម៌ កើតឡើង កុសលធម៌នោះ គប្បីមាន ព្រោះហេតុប្បច្ច័យឬ ។

សព្ទថា **បដិ** ក្នុងពាក្យថា **បដិច្ច** នោះ ប្រព្រឹត្តទៅក្នុងអត្ថថា ដូចគ្នា ដូចបុគ្គលដូចគ្នា ហៅថា បដិបុគ្គល ចំណែកស្មើគ្នា ហៅថា បដិភាគ ។ ពាក្យថា **ឥច្ច** នោះ ពោលដល់ការខ្វល់ខ្វាយក្នុងការទៅ ។ កាលពោលរួមគ្នាទាំង ២ សព្ទ ទើបមានអធិប្បាយថា បទថា **បដិច្ច** សេចក្តីថា ប្រព្រឹត្តទៅប្រហាក់ប្រហែលគ្នា គឺដំណើរទៅដោយភាពជាធម៌ ដែលប្រហាក់ប្រហែលគ្នា ពោល គឺកើតឡើងព្រមគ្នា អធិប្បាយថា ចូលដល់ការៈ គឺការកើតឡើងព្រមជាមួយបច្ច័យនោះ ។ បទថា **កុសលោ ធម្មោ** ព្រះមានព្រះភាគត្រាស់សួរថា កុសលធម៌គប្បីអាស្រ័យកុសលធម៌ កើតឡើង ព្រោះហេតុប្បច្ច័យ ដោយការៈ គឺការកើតឡើងព្រមគ្នាយ៉ាងនោះឬ ។ ម្យ៉ាង

ទៀត បទថា **បដិច្ច** សេចក្ដីថា ធ្វើឲ្យជាបច្ច័យ ។ ការធ្វើឲ្យជាបច្ច័យនោះ រមែងបានទាំងក្នុងបុរេជាតប្បច្ច័យ និងសហជាតប្បច្ច័យ ក្នុងទីនេះ បំណង យកសហជាតប្បច្ច័យ ។ ក្នុងបទថា **សិយា កុសលំ ធម្មំ បដិច្ច អកុសលោ** ជាដើម ក៏ន័យនេះដូចគ្នា ។ អកុសលធម៌ អាស្រ័យកុសលធម៌ កើតឡើង ដោយអំណាចសហជាតប្បច្ច័យ មិនមានក៏ពិត តែបច្ច័យណា ដែលទ្រង់ វិសជ្ជនា រមែងបានដោយអត្ថ និងមិនបានដោយអត្ថ ក្នុងបុច្ឆាវារៈនេះ បច្ច័យ ទាំងអស់នោះ ទ្រង់លើកឡើងដោយអំណាចបុច្ឆា ។ ឯក្នុងការវិសជ្ជនាខាង មុខ បច្ច័យណា មិនបានវិសជ្ជនា ទ្រង់លះបច្ច័យនោះចេញ បច្ច័យណា ដែលបាននូវវិសជ្ជនា ទ្រង់វិសជ្ជនាចំពោះបច្ច័យនោះប៉ុណ្ណោះ ។

អ្នកសិក្សាគប្បីជ្រាបអត្ថនៃបុច្ឆា និងគន្លងនៃបុច្ឆាក្នុងអធិការនេះ ដូច ពោលមកហើយ ។ ឥឡូវនេះ គប្បីជ្រាបការកំណត់បុច្ឆា ដោយអំណាច ការគណនាដូចតទៅ

ក្នុងបទថា **កុសលំ ធម្មំ បដិច្ច** នេះ បុច្ឆាមាន ៣ គឺដែលមាន កុសលបទជាបទដើម មានកុសល អកុសល និងអព្យាកតៈ ជាបទចុង បុច្ឆា ៣ ទៀត មានកុសលបទនោះឯងជាបទដើម មានការចែកដោយទុកៈ ដោយអំណាចនៃកុសល និងអព្យាកតៈជាដើម ជាបទចុងបុច្ឆា មួយទៀត គឺមានកុសលបទនោះឯងជាបទដើម មានតិកៈជាបទចុង ។ ហេតុនោះ បុច្ឆា ដែលមានកុសលបទជាបទដើម ក្នុងបទថា **កុសលំ ធម្មំ បដិច្ច** នេះ ទើបមាន ៧ បុច្ឆា ។ បុច្ឆាដែលមានអកុសលបទជាបទដើម មានអព្យា-

កតបទជាបទដើម មានកុសលាព្យាកតបទជាបទដើម មានអកុសលាព្យាកតបទជាបទដើម មានកុសលាកុសលបទជាបទដើម មានកុសលាកុសលាព្យាកតបទជាបទដើម ក៏ដូចគ្នា ( គឺមួយពួកៗ មាន ៧ បុច្ឆា ) ។

ហេតុនោះ អាស្រ័យកុសលត្តិកៈ ទើបមានបុច្ឆា ( សំណួរ ) ទាំងអស់ ក្នុងហេតុប្បច្ច័យមាន ៤៩[១] គឺ ៧ ពួក ៧ ដង ។

ក្នុងអធិការនេះ គប្បីជ្រាបបុច្ឆាទាំងនោះដោយអំណាចនៃមូល ( ពាក្យខាងដើម ) និងអវសាន ( ពាក្យខាងចុង ) បន្ថែមចូលមកយ៉ាងនេះ គឺ

បុច្ឆាដែលមានពាក្យខាងដើម ១ ពាក្យខាងចុង ១ មាន ៩ បុច្ឆា ដែលមានពាក្យខាងដើម ១ ពាក្យខាងចុង ២ មាន ៩ បុច្ឆា ដែលមានពាក្យខាងដើម ១ ពាក្យខាងចុង ៣ មាន ៣ បុច្ឆា ដែលមានពាក្យខាងដើម ២ ពាក្យខាងចុង ១ មាន ៩ បុច្ឆា ដែលមានពាក្យខាងដើម ២ ពាក្យខាងចុង ២ មាន ៩ បុច្ឆា ដែលមានពាក្យខាងដើម ២ ពាក្យខាងចុង ៣ មាន ៣ បុច្ឆា ដែលមានពាក្យខាងដើម ៣ ពាក្យខាងចុង ១ មាន ៣ បុច្ឆា ដែលមានពាក្យខាងដើម ៣ ពាក្យខាងចុង ២ មាន ៣ បុច្ឆា ដែលមានពាក្យខាងដើម ៣ ពាក្យខាងចុង ៣ មាន ១ ។ ក្នុងអារម្មណប្បច្ច័យជាដើម ក៏មានបុច្ឆា ៤៩ ដូចគ្នានឹងហេតុប្បច្ច័យនោះឯង ។ ក្នុងបច្ច័យទាំង

---

១- ចាប់ពីលេខឃ្នាប ២៦ ដល់លេខឃ្នាប ៣២ ក្នុង ១ ឃ្នាបៗ មាន ៧ សំណួរ ទើបរួមជា ៤៩ សំណួរ ក្នុងហេតុប្បច្ច័យ បណ្ឌិតគប្បីថែមពាក្យថា ឬ ដើម្បីឲ្យក្លាយជាសំណួរ ព្រោះក្នុងទីនេះជាបុច្ឆាភាវៈ ។

២៤ នោះ មានបុច្ឆាច្លាស់គ្នាទៅមក ១១៧៦ ក្នុងឯកមូលកន័យ ។

[ ៣៦-៣៧ ] បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ទ្រង់ផ្តើមទុកមូល-កន័យថា **ហេតុប្បច្ចយា អារម្មណប្បច្ចយា** ជាដើម ។ ក្នុងន័យដែលមានមូល ២ នោះ មានទុកៈ ២៣ ដែលមានហេតុប្បច្ច័យជាគោល គឺហេតា-រម្មណទុកៈ ។បេ។ ហេតាវិគតទុកៈ ។ ក្នុងហេតារម្មណទុកៈ ក៏មានបុច្ឆា ៤៩ ដូចហេតុប្បច្ច័យដែរ ។ បណ្តាបុច្ឆាទាំងនោះ ទ្រង់សម្តែងក្នុងបាលី ២ មាតិកាប៉ុណ្ណោះ ។ ក្នុងហេតាធិបតិទុកៈជាដើម ក៏មានបុច្ឆា ៤៩ ដូចក្នុងហេតារម្មណទុកៈដែរ ។ បណ្តាទុកៈទាំងនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងទុកៈ ៣ តាមលំដាប់ គឺហេតាធិបតិទុកៈ ហេតានន្តរទុកៈ ហេតុ-សមនន្តរទុកៈ ដោយអំណាចនៃបុច្ឆាទី ១ ហើយទ្រង់សម្តែងហេតាវិគតទុកៈជាទីបំផុត ពាក្យដ៏សេស ទ្រង់សង្ខេប ។ អ្នកសិក្សាគប្បីជ្រាបការរាប់ចំនួនបុច្ឆា ក្នុងអធិការនេះ យ៉ាងនេះ គឺ

ក្នុងទុកមូលកន័យ ក្នុងចំនួនទុកៈ ២៣ មានបុច្ឆា ១១២៧ ។

[ ៣៨ ] បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ទ្រង់ផ្តើមតិមូលកន័យថា **ហេតុប្បច្ចយា អារម្មណប្បច្ចយា អធិបតិប្បច្ចយា** ជាដើម ។ ក្នុងតិមូលកន័យនោះ មានតិកៈ ២២ ដោយអំណាចការបន្ថែមបច្ច័យនីមួយៗក្នុងបច្ច័យ ២២ មានអធិបតិប្បច្ច័យជាដើម ចូលជាមួយហេតារម្មណទុកៈ ។ បណ្តាតិកៈទាំងនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងតិកៈទី ១ និងតិកៈទី ២ ដោយអំណាចនៃបុច្ឆាទី ១ ហើយ ទើបទ្រង់សម្តែងតិកៈចុងក្រោយ ។

ពាក្យដ៏សេស ទ្រង់សង្ខេបក្នុងទុកៈ យ៉ាងណា ក្នុងតិកៈ ក៏យ៉ាងនោះ ទ្រង់ចាត់បុច្ឆា ៤៩ ចូលក្នុងតិកៈនីមួយៗ ។

ក្នុងតិមូលកន័យ ក្នុងតិកៈទាំង ២២ មានបុច្ឆាចំនួន ១០៧៨ ។

[ ៣៩ ] បន្ទាប់អំពីនោះ ទ្រង់ផ្តើមចតុមូលកន័យថា **ហេតុប្បច្ចយា អារម្មណប្បច្ចយា អធិបតិប្បច្ចយា អនន្តរប្បច្ចយា** ជាដើម ។ ក្នុងន័យដែលមានមូល ៤ នោះ មានចតុក្កៈ ២១ ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ២១ មានអនន្តរប្បច្ច័យជាដើម ចូលជាមួយនឹងតិកៈទី ១ ។ បណ្តាចតុក្កៈទាំងនោះ ព្រះមានព្រះភាគទ្រង់សម្តែងចតុក្កៈ ២ ហើយសង្ខេបចតុក្កៈដ៏សេស ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងចតុក្កៈនីមួយៗ ។

ក្នុងអធិការនេះ

ក្នុងចតុមូលកន័យ ក្នុងចតុក្កៈទាំង ២១ មានបុច្ឆាចំនួន ១០២៩ ។

[ ៤០-៤៤ ] បន្ទាប់អំពីនោះ ព្រះមានព្រះភាគទ្រង់ទេសនា ផ្តើមអំពីបញ្ចមូលកន័យជាដើម រហូតដល់សព្វមូលកន័យ ។ ន័យដែលទ្រង់សង្ខេបដែលត្រាស់ហើយខាងដើម និងត្រាស់ទៅខាងមុខ ទាំងអស់នោះ ទ្រង់ធ្វើឲ្យជាបែបតែមួយ ហើយសម្តែងក្នុងបាលីថា ឯកមូលកៈ ទុមូលកៈ តិមូលកៈ ចតុមូលកៈ បញ្ចមូលកៈ សព្វមូលកៈ បុគ្គលអ្នកមិនវង្វេង គប្បីឲ្យពិស្តារផងចុះ ដូច្នេះ ។ ក្នុងឯកមូលកន័យជាដើមនោះ ពាក្យដែលគួរពោល ខ្ញុំបានពោលហើយ ។ ឯក្នុងបញ្ចមូលកន័យ មានបច្ច័យ ១ ពួក ៥ រួមជាបញ្ចកៈ ២០ ពួក ដោយអំណាចការបន្ថែមបច្ច័យនីមួយៗ ក្នុងបច្ច័យ ២០ មាន

សមនន្តរប្បច្ច័យជាដើម ចូលជាមួយចតុក្កៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងបញ្ចកៈនីមួយៗ ក្នុងបញ្ចកៈទាំងនោះ

ក្នុងបញ្ចមូលកន័យ មានបុច្ឆាចំនួន ៩៨០ ។

ក្នុងឆមូលកន័យ មានបច្ច័យ ១ ពួក ៦ រួមជា ១៩ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ១៩ មានសហជាតប្បច្ច័យជាដើម ចូលជាមួយនឹងបញ្ចកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងឆក្កៈនីមួយៗ ក្នុងឆក្កៈទាំងនោះ

ក្នុងឆមូលកន័យ មានបុច្ឆាចំនួន ៩៣១ ។

ក្នុងសត្តមូលកន័យ មានបច្ច័យ ១ ពួក ៧ រួមជា ១៨ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ១៨ មានអញ្ញមញ្ញប្បច្ច័យជាដើម ចូលជាមួយនឹងឆក្កៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងសត្តកៈនីមួយៗ ក្នុងសត្តកៈទាំងនោះ

ក្នុងសត្តមូលកន័យ មានបុច្ឆាចំនួន ៨៨២ ។

ក្នុងអដ្ឋមូលកន័យ មានបច្ច័យ ១ ពួក ៨ រួមជា ១៧ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ១៧ មាននិស្សយប្បច្ច័យជាដើម ចូលជាមួយសត្តកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងអដ្ឋកៈនីមួយៗ ក្នុងអដ្ឋកៈទាំងនោះ

ក្នុងអដ្ឋមូលកន័យ មានបុច្ឆាចំនួន ៨៣៣ ។

ក្នុងនវមូលកន័យ មានបច្ច័យ ១ ពួក ៩ រួមជា ១៦ ពួក ដោយ

អំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ១៦ មានឧបនិស្សយប្បច្ច័យជាដើម ចូលជាមួយអដ្ឋកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងនវកៈនីមួយៗ ក្នុងនវកៈទាំងនោះ

ក្នុងនវមូលកន័យ មានបុច្ឆាចំនួន ៧៨៤ ។

ក្នុងទសមូលកន័យ មានបច្ច័យ ១ ពួក ១០ រួមជា ១៥ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ១៥ មានបុរេជាតប្បច្ច័យជាដើម ចូលជាមួយនវកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងទសកៈនីមួយៗ ក្នុងទសកៈទាំងនោះ

ក្នុងទសមូលកន័យ មានបុច្ឆាចំនួន ៧៣៥ ។

ក្នុងឯកាទសមូលកន័យ មានបច្ច័យ ១ ពួក ១១ រួមជា ១៤ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ១៤ មានបច្ឆាជាតប្បច្ច័យជាដើម ចូលជាមួយនឹងទសកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងឯកាទសកៈនីមួយៗ ក្នុងឯកាទសកៈទាំងនោះ

ក្នុងឯកាទសកមូលកន័យ មានបុច្ឆាចំនួន ៦៨៦ ។

ក្នុងទ្វាទសមូលកន័យ មានបច្ច័យ ១ ពួក ១២ រួមជា ១៣ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ១៣ មានអាសេវនប្បច្ច័យជាដើម ចូលជាមួយនឹងឯកាទសកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងទ្វាទសកៈនីមួយៗ ក្នុងទ្វាទសកៈទាំងនោះ

ក្នុងទ្វាទសមូលកន័យ មានបុច្ឆាចំនួន ៦៣៧ ។

ក្នុងតេរសមូលកន័យ មានបច្ច័យ ១ ពួក ១៣ រួមជា ១២ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ១២ មានកម្មប្បច្ច័យជាដើម ចូលជាមួយនឹងទ្វាទសកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងតេរសកៈនីមួយៗ ក្នុងតេរសកៈទាំងនោះ

ក្នុងតេរសមូលកន័យ មានបុច្ឆាចំនួន ៥៨៨ ។

ក្នុងចុទ្ទសមូលកន័យ មានបច្ច័យ ១ ពួក ១៤ រួមជា ១១ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ១១ មានវិបាកប្បច្ច័យជាដើម ចូលជាមួយនឹងតេរសកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងចុទ្ទសកៈនីមួយៗ ក្នុងចុទ្ទសកៈទាំងនោះ

ក្នុងចុទ្ទសមូលកន័យ មានបុច្ឆាចំនួន ៥៣៩ ។

ក្នុងបណ្ណរសមូលកន័យ មានបច្ច័យ ១ ពួក ១៥ រួមជា ១០ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ១០ មានអាហារប្បច្ច័យជាដើម ចូលជាមួយនឹងចុទ្ទសកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងបណ្ណរសកៈនីមួយៗ ក្នុងបណ្ណរសកៈទាំងនោះ

ក្នុងបណ្ណរសមូលកន័យ មានបុច្ឆាចំនួន ៤៩០ ។

ក្នុងសោឡសមូលកន័យ មានបច្ច័យ ១ ពួក ១៦ រួមជា ៩ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ៩ មានឥន្ទ្រិយប្បច្ច័យជាដើម ចូលជាមួយបណ្ណរសកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងសោឡសកៈនីមួយៗ ក្នុងសោឡសកៈទាំងនោះ

ក្នុងសោឡសមូលកន័យ មានបុច្ឆាចំនួន ៤៤១ ។

ក្នុងសត្តរសមូលកន័យ មានបច្ច័យ ១ ពួក ១៧ រួមជា ៨ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ៨ មានឈានប្បច្ច័យជាដើម ចូលជាមួយសោឡសកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងសត្តរសកៈនីមួយៗ ក្នុងសត្តរសកៈទាំងនោះ

ក្នុងសត្តរសមូលកន័យ មានបុច្ឆាចំនួន ៣៩២ ។

ក្នុងអដ្ឋារសមូលកន័យ មានបច្ច័យ ១ ពួក ១៨ រួមជា ៧ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ៧ មានមគ្គប្បច្ច័យជាដើម ចូលជាមួយនឹងបច្ចយសត្តរសកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងអដ្ឋារសកៈនីមួយៗ ក្នុងអដ្ឋារសកៈទាំងនោះ

ក្នុងអដ្ឋារសមូលកន័យ មានបុច្ឆាចំនួន ៣៤៣ ។

ក្នុងឯកូនវីសតិមូលកន័យ មានបច្ច័យ ១ ពួក ១៩ រួមជា ៦ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ៦ មានសម្បយុត្តប្បច្ច័យជាដើម ចូលជាមួយនឹងអដ្ឋារសកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងឯកូនវីសតិកៈនីមួយៗ ក្នុងឯកូនវីសតិកៈទាំងនោះ

ក្នុងឯកូនវីសតិមូលកន័យ មានបុច្ឆាចំនួន ២៩៤ ។

ក្នុងវីសតិមូលកន័យ មានបច្ច័យ ១ ពួក ២០ រួមជា ៥ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ៥ មានវិប្បយុត្តប្បច្ច័យជាដើម ចូលជាមួយនឹងឯកូនវីសតិកៈទី ១ ព្រោះចាត់បុច្ឆា ៤៩ ចូលក្នុងវីសតិកៈ

ទីមួយៗ ក្នុងវីសតិកៈទាំងនោះ

ក្នុងវីសតិមូលកន័យ មានបុច្ឆាចំនួន ២៤៥ ។

ក្នុងឯកវីសតិមូលកន័យ មានបច្ច័យ ១ ពួក ២១ រួមជា ៤ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ៤ មានអត្ថិប្បច្ច័យជាដើម ចូលជាមួយនឹងវីសតិកៈទី ១ ព្រោះបាត់បុច្ឆា ៤៩ ចូលក្នុងឯកវីសតិកៈ ទីមួយៗ ក្នុងឯកវីសតិកៈទាំងនោះ

ក្នុងឯកវីសតិមូលកន័យ អ្នកដឹងលក្ខណៈរាប់បុច្ឆាបាន ១៩៦ ។

ក្នុងទ្វាវីសតិមូលកន័យ មានបច្ច័យ ១ ពួក ២២ រួមជា ៣ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងបច្ច័យ ៣ មាននត្ថិប្បច្ច័យជាដើម ចូលជាមួយនឹងឯកវីសតិកៈទី ១ ព្រោះបាត់បុច្ឆា ៤៩ ចូលក្នុងទ្វាវីសតិកៈ ទីមួយៗ ក្នុងទ្វាវីសតិកៈទាំងនោះ

ក្នុងទ្វាវីសតិមូលកន័យ មានបុច្ឆាចំនួន ១៤៧ ។

ក្នុងតេវីសតិមូលកន័យ មានបច្ច័យ ១ ពួក ២៣ រួមជា ២ ពួក ដោយអំណាចការបន្ថែមបច្ច័យ ១ ក្នុងវិគតប្បច្ច័យ និងអវិគតប្បច្ច័យទាំង ២ ចូលជាមួយនឹងទ្វាវីសតិកៈទី ១ ព្រោះបាត់បុច្ឆា ៤៩ ចូលក្នុង តេវីសតិកៈទីមួយៗ ក្នុងតេវីសតិកៈទាំងនោះ

ក្នុងតេវីសតិមូលកន័យដែលជាគម្រប់ ២៣ នេះ មានបុច្ឆាចំនួន ៩៨ ។

ឯចតុវីសតិមូលកន័យ អ្នកសិក្សាគប្បីជ្រាបដោយអំណាចការប្រជុំនៃ បច្ច័យទាំងអស់ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា សព្វ-

*មូលកៈ ( មានបច្ច័យទាំងអស់ជាមូល ) ។ ក្នុងន័យដែលមានមូល ២៤ នោះ មានបុច្ឆា ៤៩ ប៉ុណ្ណោះ ដូច្នេះ ។ បុច្ឆាទាំងអស់ ព្រះសាស្តា ទ្រង់កាន់យកចំពោះបទថា ហេតុប្បច្ច័យប៉ុណ្ណោះ ចែកដោយពិស្តារក្រៃលែងក្នុងទេវបរិស័ទ ដោយអំណាចន័យដែលមានមូល ១ ជាដើម បញ្ចប់ដោយន័យដែលមានបច្ច័យទាំងអស់ជាមូល ។ ក្នុងអធិការនេះ ទ្រង់សម្តែងបុច្ឆាដោយសង្ខេប ។ ការប្រមូលរាប់បុច្ឆាទាំងអស់នោះ ដោយប្រការដូច្នេះឯង ។*

*ពិតហើយ ក្នុងន័យដែលមានមូល ១ មានបុច្ឆា ១១៧៦ បណ្តាបុច្ឆាទាំងនោះ ក្នុងន័យរបស់ហេតុប្បច្ច័យ អ្នកសិក្សាគប្បីចងបុច្ឆា ៤៩ ជាមួយនឹងបច្ច័យដែលជាមូលនោះឯង ហើយគប្បីកាន់យកក្នុងទីដែលមានហេតុប្បច្ច័យជាមូលនេះ ។ បុច្ឆាដ៏សេស អ្នកសិក្សាគប្បីដាក់ក្នុងន័យដែលមានបច្ច័យដ៏សេសជាមូល ។ ក្នុងន័យដែលមានមូល ២ មានបុច្ឆា ១១២៧ ដែលមានមូល ៣ មានបុច្ឆា ១០៧៨ ដែលមានមូល ៤ មានបុច្ឆា ១០២៩ ដែលមានមូល ៥ មានបុច្ឆា ៩៨០ ដែលមានមូល ៦ មានបុច្ឆា ៩៣១ ដែលមានមូល ៧ មានបុច្ឆា ៨៨២ ដែលមានមូល ៨ មានបុច្ឆា ៨៣៣ ដែលមានមូល ៩ មានបុច្ឆា ៧៨៤ ដែលមានមូល ១០ មានបុច្ឆា ៧៣៥ ដែលមានមូល ១១ មានបុច្ឆា ៦៨៦ ដែលមានមូល ១២ មានបុច្ឆា ៦៣៧ ដែលមានមូល ១៣ មានបុច្ឆា ៥៨៨ ដែលមានមូល ១៤ មានបុច្ឆា ៥៣៩ ដែលមានមូល ១៥ មានបុច្ឆា ៤៩០ ដែលមានមូល ១៦ មានបុច្ឆា ៤៤១ ដែលមានមូល ១៧ មានបុច្ឆា ៣៩២ ដែលមានមូល ១៨ មានបុច្ឆា ៣៤៣*

*ដែលមានមូល ១៩ មានបុច្ឆា ២៩៤ ដែលមានមូល ២០ មានបុច្ឆា ២៤៥ ដែលមានមូល ២១ មានបុច្ឆា ១៩៦ ដែលមានមូល ២២ មានបុច្ឆា ១៤៧ ដែលមានមូល ២៣ មានបុច្ឆា ៩៨ ដែលមានបច្ច័យទាំងអស់ជាមូល មានបុច្ឆា ៤៩ ក្នុងន័យដែលមានមូល ១ ជាដើម ដែលចែកចេញទៅ ដោយលើកហេតុបទឡើងដូចពោលមកហើយ ។*

*ចំពោះហេតុបទប៉ុណ្ណោះ ពោលដោយប្រភេទនៃមូល ១ ជាដើម ក៏ មានបុច្ឆា ១៤៧០០ ។*

*ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រភេទនៃបុច្ឆា តាំងអំពីន័យដែល មានមូល ១ រហូតដល់ន័យដែលមានបច្ច័យទាំងអស់ជាមូល ដោយលើក ហេតុប្បច្ច័យឡើង ដូចពោលមកហើយ ឥឡូវនេះ ដើម្បីនឹងលើកអារម្ម-ណប្បច្ច័យសម្តែងជាដើម ទើបត្រាស់ពាក្យថា* **សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ អារម្មណប្បច្ចយា ហេតុប្បច្ចយា** *ជាដើម ។*

*បណ្តាបទទាំងនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងន័យដែលមានមូល ១ ដែលមានអារម្មណប្បច្ច័យជាដើម មានហេតុប្បច្ច័យជាទីបំផុត ដោយ ពាក្យមានប្រមាណប៉ុណ្ណេះថា* **អារម្មណប្បច្ចយា ហេតុប្បច្ចយា** *ដូច្នេះ ។ បន្ទាប់អំពីនោះ ទ្រង់ផ្តើមន័យដែលមានមូល ២ ថា* **អារម្មណប្បច្ចយា អធិបតិប្បច្ចយា** *ដូច្នេះ ។ ក្នុងន័យដែលមានមូល ២ នោះ ព្រះមានព្រះភាគ ទ្រង់សម្តែងទុកៈទី ១ នេះ និងអារម្មណាទិគតទុកៈហើយ ទ្រង់សង្ខេបពាក្យ ដ៏សេស ។ ទុកៈចុងក្រោយនេះថា* **អារម្មណប្បច្ចយា ហេតុប្បច្ចយា** *ដូច្នេះ*

*ទ្រង់មិនសម្តែង ។ បើទុកៈទីបំផុតនោះប្រាកដក្នុងវគ្គណា អ្នកសិក្សាគប្បីកាន់យកវគ្គនោះឯង ។ បន្ទាប់អំពីនោះ ដើម្បីមិនសម្តែងតិមូលកន័យជាដើម ដោយអំណាចអារម្មណប្បច្ច័យ ហើយសម្តែងបច្ច័យនីមួយៗ ជាដើម ដោយលើកអធិបតិប្បច្ច័យជាដើម ទើបត្រាស់ពាក្យមានប្រមាណប៉ុណ្ណេះថា* **អធិបតិប្បច្ចយា អនន្តរប្បច្ចយា សមនន្តរប្បច្ចយា សហជាតប្បច្ចយា អញ្ញមញ្ញប្បច្ចយា** *ដូច្នេះ ។ ពាក្យនោះ អ្នកសិក្សាគប្បីជ្រាបដោយន័យដែលមានមូល ១ ឬដែលមានបច្ច័យទាំងអស់ជាមូល ។*

*បន្ទាប់អំពីនោះ ដើម្បីសម្តែងចំពោះទុមូលកន័យប៉ុណ្ណោះ ដោយលើកអវិគតប្បច្ច័យឡើងសម្តែង ទើបផ្តើមពាក្យថា* **អវិគតប្បច្ចយា ហេតុប្បច្ចយា** *ជាដើម ។ ក្នុងទុមូលកន័យនោះ កាលត្រាស់ទុកៈ ៣ តាមលំដាប់ គឺអវិគតហេតុទុកៈ អវិគតារម្មណទុកៈ អវិគតាធិបតិទុកៈហើយទើបទ្រង់សម្តែងទុកៈ ១ គឺអវិគតវិគតទុកៈ ក្នុងទីបំផុត ។*

*លំដាប់នោះ ដើម្បីទ្រង់សម្តែងន័យដែលមានមូល ៣ ដោយអំណាចអវិគតប្បច្ច័យ កាលត្រាស់តិកៈ ៣ តាមលំដាប់យ៉ាងនេះ គឺ* **អវិគតប្បច្ចយា ហេតុប្បច្ចយា អារម្មណប្បច្ចយា , អវិគតប្បច្ចយា ហេតុប្បច្ចយា អធិបតិប្បច្ចយា , អវិគតប្បច្ចយា ហេតុប្បច្ចយា អនន្តរប្បច្ចយា** *ហើយទើបទ្រង់ត្រាស់តិកៈចុងក្រោយថា* **អវិគតប្បច្ចយា ហេតុប្បច្ចយា វិគតប្បច្ចយា** *ដូច្នេះ ។*

*លំដាប់នោះ ដើម្បីទ្រង់សម្តែងន័យដែលមានមូល ៤ ដោយអំណាច*

អវិគតប្បច្ច័យនោះឯង កាលត្រាស់ពួកបួន ២ ពួក គឺ **អវិគតប្បច្ចយា ហេតុប្បច្ចយា អារម្មណប្បច្ចយា អធិបតិប្បច្ចយា , អវិគតប្បច្ចយា ហេតុប្បច្ចយា អារម្មណប្បច្ចយា អនន្តរប្បច្ចយា** ដូច្នេះហើយ ទ្រង់លើកបទថា **វិគតប្បច្ចយា** មកតាំង ។ ពាក្យដ៏សេសទាំងពួងទ្រង់សង្ខេប ។ ដើម្បីទ្រង់សម្តែងថា ពាក្យទាំងអស់នោះ ទ្រង់សង្ខេប ទើបត្រាស់ថា ឯក-មូលកៈ ទុមូលកៈ តិមូលកៈ ចតុមូលកៈ បញ្ចមូលកៈ សព្វមូលកៈនៃបទមួយៗ បុគ្គលអ្នកមិនវង្វេង គប្បីឲ្យពិស្តារចុះ ដូច្នេះ ។

ព្រោះហេតុនោះ ក្នុងឯកមូលកន័យ មានបុច្ឆា ១១៧៦ ។បេ។ ក្នុងសព្វមូលកន័យ មានបុច្ឆា ៤៩ ដោយអំណាចនៃបទថា **ហេតុ** ជាដើម ដោយលើកហេតុប្បច្ច័យជាគោល យ៉ាងណា ក្នុងឯកមូលកន័យ បទនីមួយៗ ក៏មានបុច្ឆា ១១៧៦ ។បេ។ ក្នុងសព្វមូលកន័យ មានបុច្ឆា ៤៩ ដោយអំណាចនៃបទថា **អារម្មណ** ជាដើម ដោយលើកបច្ច័យនីមួយៗ មានអារម្មណប្បច្ច័យជាគោលជាដើម ក៏យ៉ាងនោះ ក្នុងការចែកន័យនីមួយៗ ក្នុងឯកមូលកន័យជាដើម ទើបបទនីមួយៗ មានបុច្ឆា ១៤៧០០ ដូចពោលមកហើយ ។ ការរាប់ចំនួនបុច្ឆាទាំងនោះ ក្នុងបច្ច័យ ២៤ ទាំងអស់មានដូច្នេះ គឺ

ក្នុងអនុលោមន័យ ទ្រង់ចែកបុច្ឆានៃកុសលត្តិកៈ ៣៥២៨០០ ។

កុសលត្តិកៈ យ៉ាងណា វេទនាតិកៈជាដើម ក៏យ៉ាងនោះ ។ ក្នុងតិកៈ ២២ តិកៈទាំងអស់

ដោយការចែកប្រភេទនៃតិកៈហើយ មានបុច្ឆា ៧៧៦១៦០០ ។

*គន្ធនៃពាក្យពោល ( វចនាមគ្គ ) ព្រះមានព្រះភាគ ទ្រង់សង្ខេប ។*

*ក្នុងបណ្ដាទុកៈទាំងឡាយ ព្រះបាលីថា* **សិយា ហេតុំ ធម្មំ បដិច្ច ហេតុធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា** *ដូច្នេះ រមែងបានបុច្ឆា ៩ ក្នុងបច្ច័យទីមួយៗ មានហេតុប្បច្ច័យជាដើម ក្នុងទុកៈទីមួយៗ យ៉ាងនេះ គឺ ហេតុអាស្រ័យហេតុ នហេតុអាស្រ័យហេតុ ហេតុ និងនហេតុ អាស្រ័យហេតុ នហេតុ អាស្រ័យនហេតុ ហេតុអាស្រ័យនហេតុ ហេតុ និងនហេតុ អាស្រ័យនហេតុ ហេតុ អាស្រ័យហេតុ និងនហេតុ នហេតុ អាស្រ័យហេតុ និងនហេតុ ហេតុ និងនហេតុ អាស្រ័យហេតុ និងនហេតុ ។*

*បណ្ដាបុច្ឆាទាំងនោះ ក្នុងឯកមូលកន័យ លើកហេតុប្បច្ច័យជាប្រធាន មានបុច្ឆា ២១៦ ។ បណ្ដាបុច្ឆា ២១៦ នោះ សម្រាប់ហេតុប្បច្ច័យតែម្យ៉ាង អ្នកសិក្សាគប្បីកាន់យកបុច្ឆា ៩ ដែលមិនលាយឡំនឹងបច្ច័យដទៃ ។ ( បុច្ឆា ) ដ៏សេស លោកកាន់យកដោយវារៈនៃអធិប្បាយបុច្ឆាទាំងនោះ ។*

*មានការរាប់ចំនួនក្នុងវារៈ ២៣ ផ្ដើមអំពីទុមូលកន័យ រហូតដល់សព្វមូលកន័យ ដោយដកនវកៈទីមួយៗ ចេញ ដូច្នេះ ។*

*ក្នុងទុមូលកន័យ បណ្ដាបុច្ឆា ២១៦ ដែលសម្ដែងក្នុងឯកមូលកន័យ ដកបុច្ឆាចេញ ៩ ទើបមានបុច្ឆា ២០៧ ។ បន្ទាប់អំពីនោះ ក្នុងតិមូលកន័យ ដកបុច្ឆាចេញ ៩ នៅសល់ ១៩៨ ។ ដកបុច្ឆាចេញអំពីមូលខាងដើមទីមួយៗ ៩ ដូចពោលមកហើយ ទើបក្នុងចតុមូលកន័យ មានបុច្ឆា ១៨៩ ។ ក្នុងបញ្ចមូលកន័យ មាន ១៨០ ក្នុងឆមូលកន័យ មាន ១៧១ ក្នុង*

សត្តមូលកន័យមាន ១៦២ ក្នុងអដ្ឋមូលកន័យមាន ១៥៣ ក្នុងនវមូលកន័យមាន ១៤៤ ក្នុងទសមូលកន័យ មាន ១៣៥ ក្នុងឯកាទសមូលកន័យមាន ១២៦ ក្នុងទ្វាទសមូលកន័យមាន ១១៧ ក្នុងតេរសមូលកន័យមាន ១០៨ ក្នុងចុទ្ទសមូលកន័យមាន ៩៩ ក្នុងបណ្ណរសមូលកន័យមាន ៩០ ក្នុងសោឡសមូលកន័យមាន ៨១ ក្នុងសត្តរសមូលកន័យមាន ៧២ ក្នុងអដ្ឋារសមូលកន័យមាន ៦៣ ក្នុងឯកូនវីសតិមូលកន័យមាន ៥៤ ក្នុងវីសតិមូលកន័យមាន ៤៥ ក្នុងឯកវីសតិមូលកន័យមាន ៣៦ ក្នុងទ្វាវីសតិ-មូលកន័យមាន ២៧ ក្នុង តេវីសតិមូលកន័យមាន ១៨ និងក្នុងសព្វមូល-កន័យមាន ៩ ។

ក្នុងឯកមូលកន័យមានបុច្ឆា ២១៦ ។បេ។ ក្នុងសព្វមូលកន័យមានបុច្ឆា ៩ ដោយអំណាចនៃហេតុប្បច្ច័យ យ៉ាងណា ពោលដោយអំណាចនៃបទ មានអារម្មណ៍ជាដើម ធ្វើនូវបច្ច័យនីមួយៗ មានអារម្មណប្បច្ច័យជាដើមជាប្រធាន ក្នុងឯកមូលកន័យ បទនីមួយៗ ក៏មានបុច្ឆា ២១៦ ។បេ។ ក្នុងសព្វមូលកន័យមាន ៩ យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ក្នុងការចែកបទនីមួយៗ ដោយឯកមូលកន័យជាដើម ទើបមានបុច្ឆា ២៧០០ ។ មានការរាប់ចំនួនបុច្ឆាទាំងនោះ ក្នុងបច្ច័យ ២៤ ទាំងអស់ដូចតទៅនេះ

ក្នុងអនុលោមន័យនៃហេតុទុកៈ មានបុច្ឆា ៦៤៨០០ ។

ក្នុងសហេតុកទុកៈជាដើម ក៏មានន័យដូចគ្នានឹងហេតុទុកៈនោះឯង ។

ក្នុងទុកៈ ១០០ អ្នកប្រាជ្ញពោលបុច្ឆាក្នុងទុកៈ ១០០ ដែលមាន ៦៨០០០០០ ។

នេះជាការរាប់ចំនួនបុច្ឆាក្នុងតិកប្បដ្ឋាន និងទុកប្បដ្ឋានសុទ្ធៗ ។

ឯដែលឈ្មោះថា ទុកត្តិកប្បដ្ឋានណា ដែលព្រះមានព្រះភាគ ទ្រង់កាន់យកតិកៈ ២២ ចូលក្នុងទុកៈ ១០០ សម្តែងបន្ទាប់អំពីនោះ ក្នុងទុកត្តិកប្បដ្ឋាននោះ អ្នកសិក្សាគប្បីជ្រាបការរាប់ចំនួនបុច្ឆាដែលគប្បីសម្តែងប្រកបតិកៈនីមួយៗ ក្នុងតិកៈ ២២ ចូលជាមួយទុកៈ ១០០ ដោយអំណាចរបស់ន័យដែលមានមូល ១ ជាដើម តាមន័យដែលព្រះមានព្រះភាគត្រាស់ហើយខាងដើមយ៉ាងនេះថា កុសលធម៌ជាហេតុ អាស្រ័យនូវកុសលធម៌ជាហេតុ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យឬ ដូច្នេះ ។

បន្ទាប់អំពីនោះ ព្រះមានព្រះភាគទ្រង់កាន់យកទុកៈ ១០០ បន្ថែមចូលក្នុងតិកៈ ២២ ហើយសម្តែងបដ្ឋានឈ្មោះតិកទុកប្បដ្ឋានណា ក្នុងតិក-ទុកប្បដ្ឋាននោះ អ្នកសិក្សាគប្បីជ្រាបការរាប់ចំនួនបុច្ឆា ដែលគប្បីសម្តែងប្រកបទុកៈនីមួយៗ ក្នុង ១០០ ទុកៈ ចូលជាមួយតិកៈ ២២ ដោយអំណាចន័យដែលមានមូល ១ ជាដើម តាមន័យដែលព្រះមានព្រះភាគត្រាស់ហើយខាងដើមយ៉ាងនេះថា ហេតុធម៌ជាកុសល អាស្រ័យនូវហេតុធម៌ជាកុសល គប្បីកើតឡើង ព្រោះហេតុប្បច្ច័យឬ ដូច្នេះ ។

បន្ទាប់អំពីនោះ ទ្រង់បន្ថែមតិកៈទាំងឡាយ ចូលក្នុងតិកៈនោះឯង រួចសម្តែងបដ្ឋានឈ្មោះតិកត្តិកប្បដ្ឋានឯណា តិកត្តិកប្បដ្ឋាននោះ អ្នកសិក្សា

គប្បីជ្រាបការរាប់ចំនួនបុច្ឆា ដែលគប្បីសំដែងប្រកបតិកៈនីមួយៗ បណ្តាតិកៈ ២២ ចូលជាមួយតិកៈ ២១ ដ៏សេស ដោយអំណាចរបស់ន័យដែលមានមូល ១ ជាដើម តាមន័យដែលព្រះមានព្រះភាគ ត្រាស់ហើយខាងដើមយ៉ាងនេះថា ធម៌ជាកុសល ប្រកបដោយសុខវេទនា អាស្រ័យនូវធម៌ជាកុសលធម៌ ប្រកបដោយសុខវេទនា គប្បីកើតឡើង ព្រោះហេតុប្បច្ច័យឬ ដូច្នេះ ។

បន្ទាប់អំពីនោះ ទ្រង់បន្ថែមទុកៈចូលក្នុងទុកៈនោះឯង ហើយសំដែងបដ្ឋានឈ្មោះថា ទុកទុកប្បដ្ឋានឯណា ក្នុងទុកទុកប្បដ្ឋាននោះ អ្នកសិក្សាគប្បីជ្រាបការរាប់បុច្ឆាដែលគប្បីសំដែងប្រកបទុកៈនីមួយៗ ក្នុង ១០០ ទុកៈជាមួយទុកៈ ៩៩ ដ៏សេស ដោយអំណាចរបស់ន័យដែលមានមូល ១ ជាដើម តាមន័យដែលព្រះមានព្រះភាគ ត្រាស់ហើយខាងដើមយ៉ាងនេះថា ធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ គប្បីកើតឡើង ព្រោះហេតុប្បច្ច័យឬ ដូច្នេះ ។

ពិតហើយ ព្រះតថាគត កាលទ្រង់សំដែងប្រភេទទាំងអស់ហើយទើបទ្រង់សំដែងធម៌ក្នុងទេវបរិស័ទ ។ តែព្រះធម្មសេនាបតីសង្ខេបថា ធម៌នេះ ទ្រង់សំដែងក្នុងថ្ងៃនេះ ហើយពោលក្នុងទេសនា ដោយគ្រាន់តែសំដែងន័យនោះប៉ុណ្ណោះ ព្រះថេរៈសំដែងគន្លងនៃពាក្យពោលដោយសង្ខេប ។ គន្លងនៃពាក្យពោលនោះ ព្រះធម្មសង្គាហកាចារ្យ លើកឡើងកាន់សង្គាយនា ក្នុងសង្គីតិកាល តាមន័យដែលព្រះថេរៈសំដែងហើយនោះឯង ។ ដើម្បីសំដែង

គន្ថនៃពាក្យពោលដោយសង្ខេបនោះ ទើបខ្ញុំតាំងគាថានេះថា **តិកញ្ច បដ្ឋានវរំ** ជាដើម ។

គាថានោះ មានអត្ថថា ពាក្យថា **តិកញ្ច បដ្ឋានវរំ** បានដល់ តិកបដ្ឋានដ៏ប្រសើរ គឺដ៏បវរ ។ បទថា **ទុកុត្តមំ** បានដល់ ទុកបដ្ឋាន ដ៏ឧត្តម គឺប្រសើរបំផុត ។ បទថា **ទុកតិកញ្ចេវ** គឺទុកតិកបដ្ឋាន ។ បទថា **តិកទុកញ្ច** គឺតិកទុកបដ្ឋាន ។ បទថា **តិកតិកញ្ចេវ** គឺតិកតិកបដ្ឋាន ។ បទថា **ទុកទុកញ្ច** គឺទុកទុកបដ្ឋាន ។ បទថា **ឆ អនុលោមម្ហិ នយា សុគម្ភីរា** សេចក្តីថា អ្នកសិក្សាគប្បីជ្រាបន័យ ៦ ដ៏ជ្រៅដោយល្អ មាន តិកបដ្ឋានជាដើមនេះ ក្នុងអនុលោម ។

បណ្តាន័យទាំងនោះ អនុលោម មាន ២ គឺធម្មានុលោម និងបច្ច-យានុលោម ក្នុងអនុលោម ២ នេះ បដ្ឋានដែលប្រព្រឹត្តទៅដោយអំណាច ទេសនា ដែលជាអនុលោមដល់ធម៌ ដែលលោកបង្រួមបង្រួមដោយបទ អភិធម្មមាតិកា យ៉ាងនេះថា **កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ** ឈ្មោះ ថា ធម្មានុលោម ។ បដ្ឋានដែលប្រព្រឹត្តទៅដោយអំណាចទេសនា ដែលជា អនុលោមដល់បច្ច័យ ២៤ យ៉ាងនេះថា **ហេតុប្បច្ចយា អារម្មណប្បច្ចយា** ឈ្មោះថា បច្ចយានុលោម ។

បណ្តាពាក្យដែលជាគាថាទាំងនោះ គាថានេះថា **តិកញ្ច បដ្ឋានវរំ ។បេ។ ឆ អនុលោមម្ហិ នយា សុគម្ភីរា** លោកពោលក្នុងអដ្ឋកថា បន្ទាប់ មក សំដៅដល់ធម្មានុលោម ។ ក្នុងអធិការនេះ គាថានេះ លោកពោល

សំដៅដល់បច្ចយានុលោម ក្នុងធម្មានុលោមនោះ ។ ព្រោះហេតុនោះ បទថា **ឆ អនុលោមម្ហិ ឆយា សុគម្ភីរា** អ្នកសិក្សាគប្បីជ្រាបអត្ថនៃគាថា ក្នុងអដ្ឋកថាយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើម ក្នុងធម្មានុលោម ជ្រាលជ្រៅក្រៃលែង ។ តែក្នុងឱកាសនេះ អ្នកសិក្សាគប្បីជ្រាបអត្ថយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើម ក្នុងធម្មានុលោម ក្នុងបច្ចយានុលោម ដែលប្រព្រឹត្តទៅយ៉ាងនេះថា **ហេតុប្បច្ចយា អារម្មណប្បច្ចយា** ជ្រាលជ្រៅក្រៃលែង ។ បណ្តាន័យទាំង ៦ នោះ ប្រភេទនៃបុច្ឆានេះ ព្រះមានព្រះភាគ ទ្រង់សម្តែងសង្ខេបក្នុងបណ្ណត្តិវារៈនេះនៃបដិច្ចវារៈ ដោយអំណាចកុសលត្តិកៈប៉ុណ្ណោះ ក្នុងតិកប្បដ្ឋានដែលជាអនុលោម ។ ឯក្នុងតិកៈ និងទុកៈដ៏សេស និងក្នុងបដ្ឋានដ៏សេស ទ្រង់មិនសម្តែងបុច្ឆា សូម្បីតែ ១ ។

ក្នុងសហជាតវារៈជាដើម បន្ទាប់អំពីនោះ ព្រះមានព្រះភាគ មិនលើកឡើងនូវបុច្ឆាដោយអំណាចកុសលត្តិកៈ ទ្រង់សម្តែងចំពោះវិសជ្ជនាដោយអំណាចវារៈដែលមានប៉ុណ្ណោះ ។ ព្រោះពាក្យថា **ឆ អនុលោមម្ហិ ឆយា សុគម្ភីរា** អ្នកសិក្សាគប្បីលើកឡើងសម្តែងនូវបដ្ឋានន័យទាំង ៦ នេះ ក្នុងបច្ចយានុលោមនេះ ដោយអំណាចនៃបុច្ឆាទាំងឡាយ ព្រោះថា នុ៎ះជាភារៈរបស់អាចារ្យដែលអធិប្បាយបដ្ឋាន ។

# បច្ចយបច្ចនីយៈ

[ ៤៥ ] ឥឡូវនេះ ដើម្បីសម្ដែងបច្ចនីយប្បដ្ឋាន ទើបព្រះមានព្រះភាគទ្រង់ផ្ដើមបទថា **សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ ន ហេតុប្បច្ចយា** ដូច្នេះ ។ ក្នុងបច្ចនីយប្បដ្ឋាននោះ មានការរាប់ចំនួនបុច្ឆា ស្មើគ្នានឹងអនុលោមបុច្ឆា ព្រោះហេតុនោះ ក្នុងបច្ចនីយប្បដ្ឋាននេះ ទើបព្រះមានព្រះភាគត្រាស់ថា អ្នកសិក្សាគប្បីអធិប្បាយនហេតុប្បច្ច័យ ក្នុងបច្ចនីយប្បដ្ឋាន ដូចអធិប្បាយហេតុប្បច្ច័យ ក្នុងអនុលោមប្បដ្ឋាន ហើយត្រាស់ក្នុងទីបំផុតទៀតថា គប្បីអធិប្បាយ ឯកមូលកៈ ទុមូលកៈ តិមូលកៈ ចតុម្មូលកៈ រហូតដល់តេវីសតិមូលកៈនៃបទនីមួយៗ ក្នុងបច្ចនីយប្បដ្ឋាន ដូចក្នុងអនុលោមប្បដ្ឋាន ។

ពាក្យនេះថា តេវីសតិមូលកៈ ក្នុងអធិការនេះ ត្រាស់សំដៅដល់ទុមូលកប្បដ្ឋានប៉ុណ្ណោះ ឯសព្វមូលកន័យក្នុងទីបំផុត បានដល់ ចតុវីសតិមូលកន័យនោះឯង ។ ន័យទាំងនោះ ទ្រង់សង្ខេប ដូច្នេះ ។

ព្រះបាលីនេះថា **តិកញ្ច បដ្ឋានវរំ ។បេ។ ឆ បច្ចនីយម្ហិ នយា សុគម្ភីរា** ដូច្នេះ បានដល់ បច្ចនីយៈ ២ យ៉ាង គឺធម្មបច្ចនីយៈ និងបច្ចយបច្ចនីយៈ ។ ក្នុង ២ យ៉ាងនោះ បច្ចនីយៈដែលឲ្យប្រព្រឹត្តទៅហើយ ដោយអំណាចការសម្ដែងធម៌ ដែលសង្គ្រោះដោយបទអភិធម្មមាតិកា យ៉ាងនេះថា **កុសលា ធម្មា** ដោយសម្ដែងជាបច្ចនីយៈថា **ន កុសលំ ធម្មំ បដិច្ច ន កុសលោ ធម្មោ** ឈ្មោះថា ធម្មបច្ចនីយៈ ។ បច្ចនីយៈដែលឲ្យប្រព្រឹត្តទៅ ដោយអំណាចការសម្ដែងបច្ច័យ ២៤ ដោយជាបច្ច័យយ៉ាងនេះថា

**នហេតុប្បច្ចយា នារម្មណប្បច្ចយា** *ឈ្មោះថា បច្ចយបច្ចនីយៈ ។ ក្នុង ២ យ៉ាងនោះ គាថានេះថា* **តិកញ្ច បដ្ឋានវរំ ។បេ។ ឆ បច្ចនីយម្ហិ នយា សុគម្ភីរា** *ក្នុងអដ្ឋកថាបន្ទាប់មក លោកពោលសំដៅដល់ធម្មបច្ចនីយៈ តែក្នុងអធិការនេះ គាថានេះ លោកពោលសំដៅដល់បច្ចយបច្ចនីយៈ ក្នុងធម្មានុលោមប៉ុណ្ណោះ ។ ព្រោះហេតុនោះ ក្នុងគាថានៃអដ្ឋកថាថា* **ឆ បច្ចនីយម្ហិ នយា សុគម្ភីរា** *អ្នកសិក្សាគប្បីជ្រាបអត្ថយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើម ក្នុងធម្មបច្ចនីយៈ ជ្រាលជ្រៅក្រៃលែង ។ តែក្នុងបច្ចនីយៈ ដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា* **នហេតុប្បច្ចយា នអារម្មណប្បច្ចយា** *ក្នុងឱកាសនេះ អ្នកសិក្សាគប្បីជ្រាបអត្ថយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើម ចំពោះក្នុងធម្មានុលោមប៉ុណ្ណោះ ជ្រាលជ្រៅ ។*

*បណ្តាន័យទាំង ៦ នោះ ប្រភេទនៃបុច្ឆានេះ ព្រះមានព្រះភាគទ្រង់រមែងសម្តែងក្នុងបណ្ណត្តិវារៈនេះនៃបដិច្ចវារៈ ដោយអំណាចធម៌ត្រឹមតែកុសលត្តិកៈ ក្នុងអនុលោមតិកប្បដ្ឋានប៉ុណ្ណោះ សូម្បីក្នុងតិកៈ និងទុកៈដ៏សេស និងក្នុងបដ្ឋានដ៏សេស ទ្រង់ក៏មិនសម្តែងបុច្ឆាត្រឹមតែ ១ ។ ក្នុងសហជាតវារៈជាដើម បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ទ្រង់មិនលើកឡើងនូវបុច្ឆាដោយអំណាចកុសលត្តិកៈ ទ្រង់សម្តែងចំពោះវិសជ្ជនា ដោយអំណាចវារៈដែលបានប៉ុណ្ណោះ ។ ព្រោះព្រះបាលីថា* **ឆ បច្ចនីយម្ហិ នយា សុគម្ភីរា** *គប្បីលើកឡើងនូវបដ្ឋានន័យ ៦ នេះ សម្តែងក្នុងបច្ចយបច្ចនីយៈនេះ ដោយអំណាចនៃបុច្ឆា ព្រោះថា នុ៎ះជាភារៈនៃអាចារ្យដែលអធិប្បាយបដ្ឋាន ។*

# អនុលោមបច្ចនីយៈ

[ ៤៨ ] ឥឡូវនេះ ដើម្បីសម្ដែងអនុលោមប្បច្ចនីយប្បដ្ឋាន ទើបព្រះមានព្រះភាគផ្ដើមបទថា **សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា នអារម្មណប្បច្ចយា** ជាដើម ក្នុងអនុលោមប្បច្ចនីយប្បដ្ឋាននោះ ក្នុងន័យដែលមានមូល ១ ផ្ដើមដោយហេតុបទ មានអនុលោមប្បច្ចនីយប្បដ្ឋាន ២៣ ដោយការបន្ថែមហេតុបទចូលជាមួយនឹងបច្ច័យនីមួយៗ ក្នុងបច្ច័យ ២៣ ដ៏សេសថា **ហេតុប្បច្ចយា នអារម្មណប្បច្ចយា ។បេ។ ហេតុប្បច្ចយា នអវិគតប្បច្ចយា** ក្នុងអនុលោមប្បច្ចនីយប្បដ្ឋាននោះ មានបុច្ឆា ១១២៧ ព្រោះបទនីមួយៗ ចែកបាន ៤៩ ។ ឯក្នុងទុមូលកន័យ អ្នកសិក្សាគប្បីជ្រាបការរាប់ចំនួនបុច្ឆា ដោយអំណាចបទដ៏សេស ដោយបន្ថយមួយបទៗ ក្នុងឯកមូលកន័យទាំងអស់ជាដើម ដែលពោលក្នុងអនុលោមយ៉ាងនេះថា អនុលោមប្បច្ចនីយប្បដ្ឋាន មាន ២២ ដោយការបន្ថែមហេតារម្មណបទ ជាមួយនឹងបច្ច័យនីមួយៗ ក្នុងបច្ច័យដ៏សេស ២២ ។

ម្យ៉ាងទៀត ក្នុងឯកមូលកន័យជាដើម ក្នុងអធិការនេះ បុច្ឆាណាមកហើយ និងមិនទាន់មកក្នុងព្រះបាលី បុច្ឆាទាំងនោះ អ្នកសិក្សាគប្បីជ្រាបតាមគន្លងន័យដែលខ្ញុំពោលហើយខាងដើមនោះឯង ។

ក្នុងបទនេះថា **តិកញ្ច បដ្ឋានវរំ ។បេ។ ធ អនុលោមប្បច្ចនីយម្ហិ នយា សុគម្ភីរា** មានអនុលោមប្បច្ចនីយប្បដ្ឋាន ២ យ៉ាង គឺធម្មានុលោមប្បច្ចនីយៈ និងបច្ចយានុលោមប្បច្ចនីយៈ តាមន័យដែលពោលហើយខាង

ដើមនោះឯង ។ ក្នុង ២ យ៉ាងនោះ បដ្ឋានដែលប្រព្រឹត្តទៅ ដោយអំណាចការសម្តែងធម៌ដែលសង្គ្រោះដោយបទអភិធម្មមាតិកាយ៉ាងនេះថា **កុសលោ ធម្មា** ដោយអនុលោមប្បច្ចនីយន័យថា **កុសលំ ធម្មំ បដិច្ច ន កុសលោ ធម្មា** ឈ្មោះថា ធម្មានុលោមប្បច្ចនីយប្បដ្ឋាន ។ បដ្ឋានដែលប្រព្រឹត្តទៅ ដោយអំណាចការសម្តែងបទដែលបានក្នុងបច្ច័យ ២៤ យ៉ាងនេះថា **ហេតុប្បច្ចយា នអារម្មណប្បច្ចយា** ដោយអនុលោមប្បច្ចនីយន័យ ឈ្មោះថា បច្ចយានុលោមប្បច្ចនីយប្បដ្ឋាន ។ ក្នុង ២ យ៉ាងនោះ គាថានេះថា **តិកញ្ច បដ្ឋានវរំ ។បេ។ ន អនុលោមប្បច្ចនីយម្ហិ នយា សុគម្ភីរា** ក្នុងអដ្ឋកថាបន្ទាប់មក លោកពោលសំដៅដល់តែក្នុងអធិការនេះ ។ គាថានេះលោកពោលសំដៅដល់បច្ចយានុលោមប្បច្ចនីយប្បដ្ឋាន ក្នុងធម្មានុលោមនោះឯង ព្រោះហេតុនោះ ក្នុងគាថានៃអដ្ឋកថាថា **ន អនុលោមប្បច្ចនីយម្ហិ នយា សុគម្ភីរា** គប្បីជ្រាបអត្ថយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើម ក្នុងធម្មានុលោមប្បច្ចនីយន័យដ៏ជ្រាលជ្រៅ ។ ឯក្នុងបច្ចយានុ-លោមប្បច្ចនីយប្បដ្ឋាន ដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា **ហេតុប្បច្ចយា នអារម្មណប្បច្ចយា** ក្នុងឱកាសនេះ អ្នកសិក្សាគប្បីជ្រាបអត្ថយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើមនេះ ក្នុងធម្មានុលោមប៉ុណ្ណោះ ជ្រាលជ្រៅក្រៃលែង ។

បណ្តាន័យ ៦ នោះ ប្រភេទនៃបុច្ឆានេះ ទ្រង់សង្ខេបក្នុងបណ្ណត្តិវារៈនេះនៃបដិច្ចវារៈ ដោយអំណាចនៃធម៌ត្រឹមតែកុសលត្តិកៈ ចំពោះក្នុងអនុ-

*លោមតិកប្បដ្ឋានប៉ុណ្ណោះ ឯក្នុងតិកៈ និងទុកៈដ៏សេស និងក្នុងបដ្ឋានដ៏សេស មិនបានសម្ដែងបុច្ឆាត្រឹមតែ ១ ឡើយ ។ ក្នុងសហជាតវារៈជាដើម បន្ទាប់អំពីនោះ ទ្រង់មិនលើកឡើងនូវបុច្ឆា ដោយអំណាចកុសលត្តិកៈ ទ្រង់សម្ដែងចំពោះវិសជ្ជនាដោយអំណាចវារៈដែលបាន ។ ចំពោះព្រះបាលីថា* **ឆ អនុលោមប្បច្ចនីយម្ហិ នយា សុគន្ថិកា** *គប្បីលើកឡើងនូវបដ្ឋាននយទាំង ៦ នេះ សម្ដែងដោយអំណាចបុច្ឆា ក្នុងបច្ចយានុលោមប្បច្ចនីយប្បដ្ឋាននេះ ព្រោះថា នុះជាភារៈនៃអាចារ្យដែលអធិប្បាយបដ្ឋាន ។*

## បច្ចនីយានុលោម

*[ ៥២ ] ឥឡូវនេះ ដើម្បីសម្ដែងបច្ចនីយានុលោមប្បដ្ឋាន ទើបព្រះមានព្រះភាគផ្ដើមបទថា* **សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ នហេតុប្បច្ចយា អារម្មណប្បច្ចយា** *ជាដើម ក្នុងបច្ចយានុលោមប្បដ្ឋាននោះ មានកំណត់បុច្ឆាចំនួនស្មើគ្នានឹងអនុលោមប្បច្ចនីយបុច្ឆា ។ ក្នុងន័យដែលមានមូល ១ ជាដើម ក្នុងអធិការនេះ បុច្ឆាណាដែលមកហើយ និងបុច្ឆាណាដែលមិនទាន់បានមកក្នុងព្រះបាលី បុច្ឆាទាំងអស់នោះ អ្នកសិក្សាគប្បីជ្រាបតាមគន្លងន័យដែលខ្ញុំពោលខាងដើមហើយ ។*

*ក្នុងបទនេះថា* **តិកញ្ច បដ្ឋានវរំ ។បេ។ ឆ បច្ចនីយានុលោមម្ហិ នយា សុគន្ថិកា** *អ្នកសិក្សាគប្បីជ្រាបបច្ចនីយានុលោម ២ យ៉ាង គឺធម្មប្បច្ចនីយានុលោម និងបច្ចយប្បច្ចនីយានុលោម តាមន័យដែលខ្ញុំពោលហើយ*

ខាងដើម ។ ក្នុង ២ យ៉ាងនោះ បដ្ឋានដែលប្រព្រឹត្តទៅដោយអំណាចការសម្តែងធម៌ ដែលសង្គ្រោះដោយបទអភិធម្មមាតិកាយ៉ាងនេះថា **កុសលោ ធម្មោ** ដោយបច្ចនីយានុលោមថា **នកុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ** ឈ្មោះថា ធម្មប្បច្ចនីយានុលោមប្បដ្ឋាន ។ បដ្ឋានដែលប្រព្រឹត្តទៅដោយអំណាចនៃការសម្តែងបទ ដែលបានក្នុងបច្ច័យ ២៤ យ៉ាងនេះថា **នហេតុប្បច្ចយា អារម្មណប្បច្ចយា** ដោយបច្ចយប្បច្ចនីយានុលោម ឈ្មោះថា បច្ចយប្បច្ចនីយានុលោមប្បដ្ឋាន ។ ក្នុង ២ យ៉ាងនោះ គាថានេះថា **តិកញ្ច បដ្ឋានវរំ ។បេ។ ច បច្ចនីយានុលោមម្ហិ នយា សុគម្ភីរា** ក្នុងអដ្ឋកថាខាងដើម លោកពោលសំដៅដល់ ធម្មប្បច្ចនីយានុលោមប្បដ្ឋាន ។ តែក្នុងអធិការនេះ គាថានេះ លោកពោលសំដៅដល់ បច្ចយប្បច្ចនីយានុ-លោមប្បដ្ឋាន ក្នុងធម្មានុលោមប៉ុណ្ណោះ ព្រោះហេតុនោះ ក្នុងគាថានៃអដ្ឋកថាថា **ច បច្ចនីយានុលោមម្ហិ នយា សុគម្ភីរា** ។ អ្នកសិក្សាគប្បីជ្រាបអត្ថយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើម ក្នុងធម្មប្បច្ចនីយានុលោមដ៏ជ្រាលជ្រៅ ។ ឯក្នុងបច្ចយប្បច្ចនីយានុលោម ដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា **នហេតុប្បច្ចយា អារម្មណប្បច្ចយា** ក្នុងឱកាសនេះ អ្នកសិក្សាគប្បីជ្រាបអត្ថយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើមនេះ ក្នុងធម្មា-នុលោមប៉ុណ្ណោះដ៏ជ្រាលជ្រៅ ។ បណ្តាន័យ ៦ នោះ ប្រភេទនៃបុច្ឆានេះ ព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេបក្នុងបណ្ណត្តិវារៈនេះ នៃបដិច្ចវារៈដោយអំណាចធម៌ត្រឹមតែកុសលត្តិកៈ ក្នុងអនុលោមប្បដ្ឋានប៉ុណ្ណោះ ។ តែក្នុង

តិកៈ និងទុកៈដ៏សេស និងក្នុងបដ្ឋានដ៏សេស ទ្រង់មិនបានសម្ដែងបុច្ឆាសូម្បីត្រឹមតែ ១ ឡើយ ។ ក្នុងសហជាតវារៈជាដើម បន្ទាប់អំពីនោះ ទ្រង់មិនលើកឡើងនូវបុច្ឆាដោយអំណាចកុសលត្តិកៈ ទ្រង់សម្ដែងចំពោះវិសជ្ជនាដោយអំណាចវារៈដែលបាន ព្រោះព្រះបាលីថា **ឆ បច្ចនីយានុលោមម្ហិ ឆយា សុគម្ភីរា** អ្នកសិក្សាគប្បីលើកឡើងនូវបដ្ឋាននយ័ទាំង ៦ នេះសម្ដែងដោយអំណាចបុច្ឆា ក្នុងបច្ចនីយានុលោមបដ្ឋាននេះ ព្រោះថា នុ៎ះជាភារៈរបស់អាចារ្យដែលអធិប្បាយបដ្ឋាននោះឯង ។៚

## អដ្ឋកថាបុច្ឆាវារៈ ចប់

# អភិធម្មបិដក

## អនុលោម

[ ៥៦ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យកុសលក្ខន្ធទាំងឡាយ ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។ អកុសលធម៌ អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យអកុសលក្ខន្ធទាំងឡាយ ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិបាកាព្យាកតៈ និងកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី

កដត្តារូបក្តី អាស្រ័យវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈបដិសន្ធិ ខន្ធ ១ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ វត្ថុ អាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយ អាស្រ័យវត្ថុ មហាភូតរូប ៣ អាស្រ័យ មហាភូតរូប ១ មហាភូតរូប ១ អាស្រ័យមហាភូតរូប ៣ មហាភូតរូប ២ អាស្រ័យមហាភូតរូប ២ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យ មហាភូតរូបទាំងឡាយ ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ផង អព្យាកត-ធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យ កុសលក្ខន្ធទាំងឡាយផង មហាភូតរូបទាំងឡាយផង ។ អព្យាកតធម៌ អាស្រ័យ អកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យអកុសលក្ខន្ធទាំងឡាយផង មហាភូតរូបទាំងឡាយ ផង ។

[ ៥៧ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះ អារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យ ខន្ធ ២ ។ អកុសលធម៌ អាស្រ័យអកុសលធម៌ ទើប កើតឡើងព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យ អព្យាកតធម៌ ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យ វិបាកាព្យាកតៈ និងកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ

ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធទាំងឡាយ អាស្រ័យវត្ថុ ។

[ ៥៨ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យកុសលក្ខន្ធទាំងឡាយ ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។ អកុសលធម៌ អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យអកុសលក្ខន្ធទាំងឡាយ ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ

ខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ មហាភូតរូប ១ អាស្រ័យមហាភូតរូប ៣ មហាភូតរូប ២ អាស្រ័យមហាភូតរូប ២ ចិត្តសមុដ្ឋានរូប និងឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យកុសលក្ខន្ធទាំងឡាយផង មហាភូតរូបទាំងឡាយផង ។ អព្យាកតធម៌ អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យអកុសលក្ខន្ធទាំងឡាយផង មហាភូតរូបទាំងឡាយផង ។

[ ៥៩ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ។ អនន្តរប្បច្ច័យក្តី សមនន្តរប្បច្ច័យក្តី ប្រហែលគ្នានឹងអារម្មណប្បច្ច័យ ។

[ ៦០ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះសហជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យកុសលក្ខន្ធទាំងឡាយ ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូប

ក្តី អាស្រ័យខន្ធ ២ ។ អកុសលធម៌ អាស្រ័យអកុសលធម៌ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យ ខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះសហជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យអកុសលក្ខន្ធទាំងឡាយ ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ ទើបកើតឡើងព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ វត្ថុ អាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយអាស្រ័យវត្ថុ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ មហាភូតរូប ១ អាស្រ័យមហាភូតរូប ៣ មហាភូតរូប ២ អាស្រ័យមហាភូតរូប ២ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប ពាហិររូប អាស្រ័យមហាភូតរូបទាំងឡាយ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ មហាភូតរូប ១ អាស្រ័យមហាភូតរូប ៣ មហាភូតរូប ២ អាស្រ័យមហាភូតរូប ២ ឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ មហាភូតរូប ៣

អាស្រ័យមហាភូតរូប ១ ដែលមានអាហារជាសមុដ្ឋាន មហាភូតរូប ១ អាស្រ័យមហាភូតរូប ៣ មហាភូតរូប ២ អាស្រ័យមហាភូតរូប ២ ឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ ដែលមានឧតុជាសមុដ្ឋាន មហាភូតរូប ១ អាស្រ័យមហាភូតរូប ៣ មហាភូតរូប ២ អាស្រ័យមហាភូតរូប ២ ឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ របស់ពួកអសញ្ញសត្វ មហាភូតរូប ១ អាស្រ័យមហាភូតរូប ៣ មហាភូតរូប ២ អាស្រ័យមហាភូតរូប ២ កដត្តារូប ឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះសហជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យកុសលក្ខន្ធទាំងឡាយផង មហាភូតរូបទាំងឡាយផង ។ អព្យាកតធម៌ អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះសហជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យអកុសលក្ខន្ធទាំងឡាយផង មហាភូតរូបទាំងឡាយផង ។

[ ៦១ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អកុសលធម៌ អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ ទើបកើតឡើងព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យ

វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី វត្ថុក្តី អាស្រ័យវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ ក្តី វត្ថុក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី វត្ថុក្តី អាស្រ័យខន្ធ ២ វត្ថុ អាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយអាស្រ័យវត្ថុ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ មហាភូតរូប ១ អាស្រ័យមហាភូតរូប ៣ មហាភូតរូប ២ អាស្រ័យមហាភូតរូប ២ ។ ពាហិររូប ។ អាហារសមុដ្ឋានរូប ។ ឧតុ-សមុដ្ឋានរូប ។ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ របស់ពួកអសញ្ញសត្វ មហាភូតរូប ១ អាស្រ័យមហាភូតរូប ៣ មហាភូតរូប ២ អាស្រ័យមហារូប ២ ។

[ ៦២ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះនិស្សយប្បច្ច័យ គឺអាស្រ័យកុសលក្ខន្ធ ១ និស្សយប្បច្ច័យ ប្រហែលគ្នានឹងសហជាតប្បច្ច័យដែរ ។

[ ៦៣ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះឧប-និស្សយប្បច្ច័យ គឺអាស្រ័យកុសលក្ខន្ធ ១ ។ ឧបនិស្សយប្បច្ច័យ ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។

[ ៦៤ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ( ខន្ធទាំងឡាយអាស្រ័យ ) វត្ថុ ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ ។ អកុសលធម៌ អាស្រ័យអកុសលធម៌ ទើបកើត

ឡើងព្រោះបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ( ខន្ធទាំងឡាយ អាស្រ័យវត្ថុ ) ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ ។ អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកាព្យាកត-កិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ( ខន្ធទាំងឡាយ អាស្រ័យវត្ថុ ) ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ ។

[ ៦៥ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អកុសលធម៌ អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ ទើបកើតឡើងព្រោះអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។

[ ៦៦ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះកម្មប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ។ ខន្ធ ៣ អាស្រ័យអកុសល-ធម៌ ។ អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ ទើបកើតឡើងព្រោះកម្មប្បច្ច័យ គឺ ( ខន្ធទាំងឡាយ ) អាស្រ័យវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ មហាភូតរូប ៣ អាស្រ័យមហា-

ភូតរូប ១ របស់ពួកអសញ្ញសត្វ កដត្តារូប ឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះកម្មប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យកុសលក្ខន្ធទាំងឡាយផង មហាភូតរូបទាំងឡាយផង ។ អព្យាកតធម៌ អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះកម្មប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យអកុសលក្ខន្ធទាំងឡាយផង មហាភូតរូបទាំងឡាយផង ។

[ ៦៧ ] អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ ទើបកើតឡើងព្រោះវិបាកប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិបាកាព្យាកតក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ វត្ថុ អាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយ អាស្រ័យវត្ថុ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ មហាភូតរូប ១ អាស្រ័យមហាភូតរូប ៣ មហាភូតរូប ២ អាស្រ័យមហាភូតរូប ២ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ ។

[ ៦៨ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះអាហារប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ។ អកុសលធម៌ អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះអាហារប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអកុសលក្ខន្ធ ១ ។ អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ ទើបកើតឡើងព្រោះ

អាហារប្បច្ច័យ គឺ ( ខន្ធទាំងឡាយ ) អាស្រ័យវិបាកាព្យាកតកិរិយា-ព្យាកតក្ខន្ធ ១ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ ( មហាភូតរូបទាំងឡាយ ) អាស្រ័យមហាភូតរូប ១ ដែលមានអាហារជាសមុដ្ឋាន ឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ ។ ( អព្យាកតធម៌ ) អាស្រ័យកុសលធម៌ផង អព្យាកតធម៌ផង ។ អព្យាកតធម៌ អាស្រ័យអកុ-សលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះអាហារប្បច្ច័យ គឺចិត្ត-សមុដ្ឋានរូប អាស្រ័យអកុសលក្ខន្ធទាំងឡាយផង មហាភូតរូបទាំងឡាយផង ។

[ ៦៩ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះឥន្ទ្រិយប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ។ ខន្ធ ៣ អាស្រ័យអកុសលធម៌ ។ អាស្រ័យអព្យាកតធម៌ ។បេ។ អាស្រ័យមហាភូតរូប ១ របស់ពួកអសញ្ញសត្វ ។ ឥន្ទ្រិយប្បច្ច័យ ប្រហែលគ្នានឹងកម្មប្បច្ច័យដែរ ។

[ ៧០ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះឈានប្បច្ច័យ ... ព្រោះមគ្គប្បច្ច័យ ។ ឈានប្បច្ច័យក្តី មគ្គប្បច្ច័យក្តី ប្រហែលគ្នានឹងហេតុប្បច្ច័យដែរ ។

[ ៧១ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះសម្បយុត្តប្បច្ច័យ គឺអាស្រ័យកុសលក្ខន្ធ ១ ។ សម្បយុត្តប្បច្ច័យ ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។

[ ៧២ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះ

វិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ( ខន្ធទាំងឡាយអាស្រ័យ ) វត្ថុ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ ។ អព្យាកតធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យកុសលក្ខន្ធទាំងឡាយ ( ចិត្តសមុដ្ឋានរូបអាស្រ័យ ) ខន្ធទាំងឡាយ ទើបកើតឡើងព្រោះវិប្ប-យុត្តប្បច្ច័យ ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធទាំងឡាយ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ ។ អកុសលធម៌ អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ( ខន្ធទាំងឡាយអាស្រ័យ ) វត្ថុ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ ។ អព្យាកតធម៌ អាស្រ័យអកុ-សលធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យអកុសលក្ខន្ធទាំងឡាយ ( ចិត្តសមុដ្ឋានរូប អាស្រ័យ ) ខន្ធទាំងឡាយ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី អាស្រ័យអកុសលធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្ត-សមុដ្ឋានរូបក្តី អាស្រ័យអកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី

អាស្រ័យខន្ធ ៣ ខន្ធ ២ ក្ដី ចិត្តសមុដ្ឋានរូបក្ដី អាស្រ័យខន្ធ ២ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធទាំងឡាយ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ ។ អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្ដី ចិត្តសមុដ្ឋានរូបក្ដី អាស្រ័យវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ ក្ដី ចិត្តសមុដ្ឋានរូបក្ដី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្ដី ចិត្តសមុដ្ឋានរូបក្ដី អាស្រ័យខន្ធ ២ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធទាំងឡាយ ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធ ៣ ក្ដី កដត្តារូបក្ដី អាស្រ័យវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ ក្ដី កដត្តារូបក្ដី អាស្រ័យខន្ធ ៣ ខន្ធ ២ ក្ដី កដត្តារូបក្ដី អាស្រ័យខន្ធ ២ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ វត្ថុ អាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយអាស្រ័យវត្ថុ ខន្ធទាំងឡាយ អាស្រ័យវត្ថុ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ វត្ថុ ( អាស្រ័យ ) ខន្ធទាំងឡាយ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ មហាភូតរូប ១ អាស្រ័យមហាភូតរូប ៣ មហាភូតរូប ២ អាស្រ័យមហាភូតរូប ២ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ ( ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យ ) ខន្ធទាំងឡាយ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ ។ អព្យាកតធម៌ អាស្រ័យ

កុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យកុសលក្ខន្ធទាំងឡាយផង មហាភូតរូបទាំងឡាយផង ( ចិត្តសមុដ្ឋានរូបអាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ អព្យាកតធម៌ អាស្រ័យអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យអកុសលក្ខន្ធទាំងឡាយផង មហាភូតរូបទាំងឡាយផង ( ចិត្តសមុដ្ឋានរូបអាស្រ័យ ) ខន្ធទាំងឡាយ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៧៣ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះអត្ថិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ។ សេចក្ដីបង្រួញ ។ អត្ថិប្បច្ច័យ ប្រហែលគ្នានឹងសហជាតប្បច្ច័យដែរ ។

[ ៧៤ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះនត្ថិប្បច្ច័យ គឺ ... ព្រោះវិគតប្បច្ច័យ ។ នត្ថិប្បច្ច័យក្ដី វិគតប្បច្ច័យក្ដី ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។

[ ៧៥ ] កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះអវិគតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ។ អវិគតប្បច្ច័យ ប្រហែលគ្នានឹងសហជាតប្បច្ច័យដែរ ។

បច្ច័យ ២៣ នេះ បុគ្គលអ្នកស្វាធ្យាយ គប្បីឲ្យពិស្ដារចុះ ។

[ ៧៦ ] វារៈ ៩ ក្នុងហេតុប្បច្ច័យ វារៈ ៣ ក្នុងអារម្មណប្បច្ច័យ វារៈ ៩ ក្នុងអធិបតិប្បច្ច័យ វារៈ ៣ ក្នុងអនន្តរប្បច្ច័យ វារៈ ៣ ក្នុងសមនន្ត-

វប្បច្ច័យ វារៈ ៩ ក្នុងសហជាតប្បច្ច័យ វារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ វារៈ ៩ ក្នុងនិស្សយប្បច្ច័យ វារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ វារៈ ៣ ក្នុងបុរេជាតប្បច្ច័យ វារៈ ៣ ក្នុងអាសេវនប្បច្ច័យ វារៈ ៩ ក្នុងកម្មប្បច្ច័យ វារៈ ១ ក្នុងវិបាកប្បច្ច័យ វារៈ ៩ ក្នុងអាហារប្បច្ច័យ វារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ វារៈ ៩ ក្នុងឈានប្បច្ច័យ វារៈ ៩ ក្នុងមគ្គប្បច្ច័យ វារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ វារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ វារៈ ៩ ក្នុងអត្ថិប្បច្ច័យ វារៈ ៣ ក្នុងនត្ថិប្បច្ច័យ វារៈ ៣ ក្នុងវិគតប្បច្ច័យ វារៈ ៩ ក្នុងអវិគតប្បច្ច័យ ។

[ ១៩២-២៣៥ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់ផ្តើមពាក្យថា **នហេតុប្បច្ចយា អារម្មណេ ទ្វេ** ជាដើម ដើម្បីសម្តែងការរាប់ក្នុងបច្ចនីយានុលោម ។ ក្នុងបច្ចនីយានុលោមនោះ បច្ច័យដ៏សេស វៀរអធិបតិប្បច្ច័យ រមែងបានដោយអនុលោម ក្នុងហេតុប្បច្ច័យ ដែលតាំងនៅដោយភាពជាបច្ចនិកៈ ។ ចំណែកបច្ឆាជាតប្បច្ច័យ រមែងមិនបានដោយអនុលោមក្នុងបច្ច័យទាំងអស់នោះឯង ។ បច្ច័យទាំង ៩ ណា ដែលលោកពោលថា ជាអរូបប៉ុណ្ណោះ បច្ច័យដែលតាំងនៅក្នុងឋានៈនៃនាមដ៏សេស រមែងមិនបានដោយអនុលោមក្នុងបច្ច័យ ៧ ដ៏សេសនោះ វៀរបុរេជាតប្បច្ច័យ និងអាសេវនប្បច្ច័យ ដែលតាំងនៅដោយភាពជាបច្ចនិកៈ ។ ពិតហើយ ធម៌ដែលមិនកើតអំពីអារម្មណប្បច្ច័យជាដើម រមែងមិនបានអនន្តរប្បច្ច័យជាដើម ។ បដិសន្ធិវិបាក និងវិបាកទាំងអស់ចាកបុរេជាតប្បច្ច័យ សូម្បីមិនកើតអំពីអាសេវនៈ និងកិរិយាមនោធាតុ ក៏រមែងបានអនន្តរប្បច្ច័យជាដើម ព្រោះហេតុនោះ ទើបខ្ញុំពោលថា វៀរបុរេជាតប្បច្ច័យ និងអាសេវនប្បច្ច័យ ដូច្នេះ ។

បច្ច័យដ៏សេស វៀរអវិគតប្បច្ច័យ រមែងបានដោយអនុលោម ក្នុងបុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ ដែលតាំងនៅដោយភាពជាបច្ចនិកៈ ។ វៀរវិបាកប្បច្ច័យ បច្ច័យដ៏សេស រមែងបានដោយអនុលោម ក្នុងកម្មប្បច្ច័យ ដែលតាំងនៅដោយបច្ចនិកៈ ។ វៀរបច្ច័យដែលឧបការៈក្នុងទីទាំងពួង និងអញ្ញមញ្ញប្បច្ច័យ

កម្មប្បច្ច័យ អាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ ដែលសេសសល់ រមែងមិនបានដោយអនុលោម ក្នុងអាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ ដែលតាំងនៅដោយភាពជាបច្ចនិកៈ ។ បច្ច័យក្រៅអំពីនេះ រមែងបានដោយអំណាចដែលសមគួរ ។ ហេតុប្បច្ច័យ អធិបតិប្បច្ច័យ អាសេវនប្បច្ច័យ និងមគ្គប្បច្ច័យ រមែងមិនបាន ដោយអនុលោមក្នុងឈានប្បច្ច័យ ដែលតាំងនៅដោយភាពជាបច្ចនិកៈ ។ ក្នុងមគ្គប្បច្ច័យដែលតាំងនៅដោយភាពជាបច្ចនិកៈ រមែងមិនបានហេតុប្បច្ច័យ និងអធិបតិប្បច្ច័យដោយភាពជាអនុលោម ។ ក្នុងវិប្បយុត្តប្បច្ច័យដែលតាំងនៅដោយភាពជាបច្ចនិកៈ វៀរបុរេជាតប្បច្ច័យ រមែងបានបច្ច័យដ៏សេសដោយអនុលោម ។ បណ្ឌិតកាលជ្រាបបច្ច័យដែលមិនបានដោយភាពជាអនុលោមក្នុងបច្ច័យទាំងនោះ ដែលតាំងនៅដោយភាពជាបច្ចនិកៈយ៉ាងនេះហើយ គប្បីជ្រាបការរាប់ដោយអំណាចបច្ច័យដែលរាប់បានតិចជាង ក្នុងការប្រៀបធៀបជាមួយបច្ច័យទាំងនោះ ។

មាតិកាទាំងឡាយ មានទុកមាតិកាឯណាជាដើម ដែលលោកសម្ដែងផ្ដើមអំពីបច្ច័យណាមួយ ក្នុងន័យទាំងឡាយ មានទុមូលកន័យជាដើម ទុក-មាតិកាទាំងនោះ លោកសម្ដែងហើយដោយវិធីណាៗ ដោយអំណាចបច្ច័យដែលរកបាន និងរកមិនបាន បណ្ឌិតគប្បីកំណត់ទុកមាតិកាជាដើមនោះឲ្យល្អដោយវិធីនោះៗ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះ ដែលព្រះមានព្រះភាគកាលសម្ដែងន័យ មានទុមូលកន័យជាដើម ដោយអំណាចនហេតុប្បច្ច័យត្រាស់ថា **នហេតុប្បច្ចយា នារម្មណប្បច្ចយា ។បេ។ នាសេវនប្បច្ចយា**

ដូច្នេះហើយ ត្រាស់ពាក្យណាថា ពាក្យអធិប្បាយទាំងអស់ ដូចគ្នារហូតដល់អាសេវនប្បច្ច័យ គប្បីជ្រាបការដូចគ្នានៃពាក្យនោះ និងពាក្យថា **ឆអញ្ញមញ្ញប្បច្ចយា សហជាតេ ឯកំ ។** ពាក្យណា ដែលលោករចនាក្នុងសីហឡភាសាថា អាចារ្យរមែងសង្គ្រោះយកនូវបច្ច័យ ៥ ក្នុងនកម្មប្បច្ច័យ ដែលគណនាហើយ គប្បីជ្រាបសេចក្ដីនៃពាក្យនោះដូចតទៅ បច្ច័យ ៥ ផ្ដើមអំពីនហេតុប្បច្ច័យ ដែលលោកសម្ដែងយ៉ាងនេះថា បណ្ឌិតរមែងបានវិសជ្ជនា ១ ក្នុងសហជាតប្បច្ច័យ ដែលតជាមួយនកម្មប្បច្ច័យយ៉ាងនេះថា **ឆកម្មប្បច្ចយា** ដូច្នេះ រមែងមិនបានដោយអនុលោមប្បច្ច័យដទៃឡើយ ។ ក្នុងឋានៈដទៃបែបនេះ បណ្ឌិតមិនគួរកាន់យកព្យញ្ជនៈ គួរកាន់យកអត្ថដែលបំណងប៉ុណ្ណោះ ។ ពិតហើយ ព្យញ្ជនៈបែបនោះ បុរាណាចារ្យរចនាជាភាសាមគធៈ ដើម្បីចងក្រងតាមការចេះចាំរបស់ខ្លួន ។

ម្យ៉ាងទៀត បណ្ដាបច្ចយុប្បន្នធម៌ ក្នុងបច្ចនីយានុលោមនេះ អត្ថិធម៌ ( អត្ថិប្បច្ច័យ ) រមែងបានកម្មប្បច្ច័យ តែមិនបានឥន្ទ្រិយប្បច្ច័យ ។ អត្ថិធម៌នោះ គប្បីជ្រាបដោយអំណាចរូបជីវិតិន្ទ្រិយ ក្នុងអសញ្ញសត្វ និងក្នុងបវត្តិកាលក្នុងបញ្ចវោការភព អត្ថិធម៌ រមែងបានមគ្គប្បច្ច័យ តែមិនបានហេតុប្បច្ច័យ អត្ថិធម៌នោះ គប្បីជ្រាបដោយអំណាចមោហៈ ដែលសហគតៈដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ។ អត្ថិធម៌ រមែងបានឈានប្បច្ច័យ តែមិនបានមគ្គប្បច្ច័យ អត្ថិធម៌នោះ គប្បីជ្រាបដោយអំណាចមនោធាតុ និងអហេតុកមនោវិញ្ញាណធាតុ ។ បណ្ដាការបាន និងការមិនបាន ក្នុងអត្ថិប្បច្ច័យនោះ កដត្តារូប រមែងបាន

កម្មប្បច្ច័យដោយអំណាចនៃកម្ម ដែលប្រព្រឹត្តទៅក្នុងខណៈផ្សេងៗ ប៉ុណ្ណោះ ។ ក្នុងបច្ច័យទាំងនោះ រូបធម៌ រមែងមិនបានហេតុប្បច្ច័យ អធិបតិប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ ។ បច្ច័យដែលចូលបានគ្រប់អន្ទើ មិនមានបច្ចនីយៈ ក្នុងអហេតុកចិត្ត មិនមានអធិបតិប្បច្ច័យ ។ ក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាបវារៈនៃការគណនាដោយអំណាចបកិណ្ណកៈទាំងនេះ ដោយការមិនវង្វេង ។

ក្នុងសេចក្ដីនោះ មានន័យដូចតទៅ អហេតុកមោហៈ និងអហេតុកវិបាក និងកិរិយាប៉ុណ្ណោះ ជាបច្ចុប្បន្នធម៌ ក្នុងព្រះបាលីនេះថា **នហេតុយា អារម្មណេ ទ្វេ** ដូច្នេះ ព្រោះហេតុនោះ បទថា **ទ្វេ** ក្នុងអធិការនេះ លោកសំដៅយកអកុសល និងអកុសល អព្យាកតៈ និងអព្យាកតៈ ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ឯក្នុងអាសេវនប្បច្ច័យ រមែងមិនបានវិបាក និងកិរិយាមនោធាតុ ព្រោះហេតុនោះ ក្នុងទីនេះ បទថា **អព្យាកតេន អព្យាកតំ** បណ្ឌិតគប្បីជ្រាបដោយអំណាចអហេតុកមនោវិញ្ញាណធាតុខាងកិរិយា ។ បទថា **វិបាកេ ឯកំ** គឺអព្យាកតៈ និងអព្យាកតៈនោះឯង ។ បទថា **មគ្គេ ឯកំ** គឺអកុសល និងអកុសល ។

បទថា **ហេតុយា បញ្ច** ក្នុងនអារម្មណមូលកន័យ លោកពោលសំដៅយករូបប៉ុណ្ណោះ ។ ពិតហើយ រូបនោះ រមែងកើតព្រោះអាស្រ័យចំណែក ៥ គឺកុសល អកុសល អព្យាកតៈ កុសល និងអព្យាកតៈ និងអកុសល និងអព្យាកតៈ ។ ក្នុងបញ្ចកៈទាំងពួង ក៏មានន័យនេះដូចគ្នា ។

បទថា **អញ្ញមញ្ញោ ឯកំ** លោកពោលសំដៅយកមហាភូតរូប និងវត្ថុរូប ។ ពិតហើយ រូបទាំងនោះ រមែងកើតដោយអំណាចនអារម្មណប្បច្ច័យ ព្រោះអញ្ញមញ្ញប្បច្ច័យ ។ ក្នុងតិមូលកន័យ ក៏មាននន័យនេះដូចគ្នា ។ បទថា **ហេតុយា ឆរ** ក្នុងនាធិបតិមូលកន័យ លោកពោលហើយ ក្នុងហេតុប្បច្ចយអនុលោមន័យ ។ បទថា **តីណិ** ជាដើម ក៏ដូចគ្នានឹងពាក្យដែលពោលហើយ ក្នុងអនុលោមន័យខាងដើមនោះឯង ។ ក្នុងតិមូលកន័យ បទថា **ទ្វេ** ដូចគ្នានឹងពាក្យដែលពោលហើយ ក្នុងអារម្មណប្បច្ច័យ ព្រោះនហេតុប្បច្ច័យខាងដើម ។

ក្នុងនបុរេជាតមូលកន័យ បទថា **ហេតុយា សត្ត** ជាដើម ព្រះមានព្រះភាគ ទ្រង់សម្តែងក្នុងនបុរេជាតប្បច្ច័យខាងដើម ដោយន័យថា **អារុប្បេ កុសលំ ឯកំ ខន្ធំ បដិច្ច** ជាដើម ។ ក្នុងសត្តកៈទាំងពួងក៏ន័យនេះ ។ ក្នុងនកម្មមូលកន័យ ក្នុងបទថា **ហេតុយា តីណិ** ជាដើម ចេតនាប៉ុណ្ណោះ ជាបច្ចយុប្បន្ន ព្រោះហេតុនោះ បទថា **តីណិ** ទើបលោកសំដៅយកការកើតឡើង ព្រោះអាស្រ័យកុសល អកុសល និងអព្យាកតៈ ។ ដោយន័យនេះ បណ្ឌិតគប្បីជ្រាបការរាប់ចំនួនវារៈ ក្នុងអាគតដ្ឋានថា ១-២-៣-៥-៧-៩ ចំណែកការរាប់ចំនួន ៣ ទៀតថា ៤-៦-៨ មិនមានឡើយ ។៚

## អដ្ឋកថាបច្ចយបច្ចនីយានុលោម ចប់

## ពណ៌នាអត្ថបដិច្ចវារៈ ចប់

# អភិធម្មបិដក

## សហជាតវារៈ

[ ២៣៦ ] កុសលធម៌ កើតជាមួយនឹងកុសលធម៌ រមែងកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ កើតជាមួយនឹងកុសលក្ខន្ធ ១ ខន្ធ ១ កើតជាមួយនឹងខន្ធ ៣ ខន្ធ ២ កើតជាមួយនឹងខន្ធ ២ ។ អព្យាកតធម៌ កើតជាមួយនឹងកុសលធម៌ រមែងកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប កើតជាមួយនឹងកុសលក្ខន្ធទាំងឡាយ ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី កើតជាមួយនឹងកុសលធម៌ រមែងកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងខន្ធ ២ ។

[ ២៣៧ ] អកុសលធម៌ កើតជាមួយនឹងអកុសលធម៌ រមែងកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ កើតជាមួយនឹងអកុសលក្ខន្ធ ១ ខន្ធ ១ កើតជាមួយនឹងខន្ធ ៣ ខន្ធ ២ កើតជាមួយនឹងខន្ធ ២ ។ អព្យាកតធម៌ កើតជាមួយនឹងអកុសលធម៌ រមែងកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប កើតជាមួយនឹងអកុសលក្ខន្ធទាំងឡាយ ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី កើតជាមួយនឹងអកុសលធម៌ រមែងកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងអកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងខន្ធ ២ ។

[ ២៣៨ ] អព្យាកតធម៌ កើតជាមួយនឹងអព្យាកតធម៌ រមែងកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងវិបាកា-

ព្យាកតកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបក្តី កើតជាមួយនឹងវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ ក្តី កដត្តារូបក្តី កើតជាមួយនឹងខន្ធ ៣ ខន្ធ ២ ក្តី កដត្តារូបក្តី កើតជាមួយនឹងខន្ធ ២ វត្ថុ កើតជាមួយនឹងខន្ធទាំងឡាយ ខន្ធទាំងឡាយ កើតជាមួយនឹងវត្ថុ មហាភូត ៣ កើតជាមួយនឹងមហាភូត ១ មហាភូត ១ កើតជាមួយនឹងមហាភូត ៣ មហាភូត ២ កើតជាមួយនឹងមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប កើតជាមួយនឹងមហាភូតទាំងឡាយ ។

[ ២៣៩ ] អព្យាកតធម៌ កើតជាមួយនឹងកុសលធម៌ផង អព្យាកតធម៌ផង រមែងកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប កើតជាមួយនឹងកុសលក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។ អព្យាកតធម៌ កើតជាមួយនឹងអកុសលធម៌ផង អព្យាកតធម៌ផង រមែងកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប កើតជាមួយនឹងអកុសលក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

បណ្ឌិតគប្បីឲ្យពិស្តារ ដូចជាក្នុងបដិច្ចវារៈដែរ ។

[ ២៤០ ] វារៈ ៩ ក្នុងហេតុប្បច្ច័យ វារៈ ៣ ក្នុងអារម្មណប្បច្ច័យ ... វារៈ ៩ ក្នុងអធិបតិប្បច្ច័យ វារៈ ៣ ក្នុងអនន្តរប្បច្ច័យ វារៈ ៣ ក្នុងសមនន្តរប្បច្ច័យ វារៈ ៩ ក្នុងសហជាតប្បច្ច័យ វារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ វារៈ ៩ ក្នុងនិស្សយប្បច្ច័យ វារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ វារៈ ៣ ក្នុង

បុរេជាតប្បច្ច័យ វារៈ ៣ ក្នុងអាសេវនប្បច្ច័យ វារៈ ៩ ក្នុងកម្មប្បច្ច័យ វារៈ ១ ក្នុងវិបាកប្បច្ច័យ វារៈ ៩ ក្នុងអាហារប្បច្ច័យ វារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ វារៈ ៩ ក្នុងឈានប្បច្ច័យ វារៈ ៩ ក្នុងមគ្គប្បច្ច័យ វារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ វារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ វារៈ ៩ ក្នុងអត្ថិប្បច្ច័យ វារៈ ៣ ក្នុងនត្ថិប្បច្ច័យ វារៈ ៣ ក្នុងវិគតប្បច្ច័យ វារៈ ៩ ក្នុងអវិគតប្បច្ច័យ ។

**អនុលោម ចប់**

បណ្ឌិតគប្បីរាប់ ដូចជាការរាប់ក្នុងបដិច្ចវារៈដែរ ។

[ ២៤១ ] អកុសលធម៌ កើតជាមួយនឹងអកុសលធម៌ រមែងកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ កើតជាមួយនឹងខន្ធទាំងឡាយ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។

[ ២៤២ ] អព្យាកតធម៌ កើតជាមួយនឹងអព្យាកតធម៌ រមែងកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងអហេតុកវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី កើតជាមួយនឹងខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបក្តី កើតជាមួយនឹងវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈនៃអហេតុកបដិសន្ធិ ខន្ធ ១ ក្តី កដត្តារូបក្តី កើតជាមួយនឹងខន្ធ ៣ ខន្ធ ២ ក្តី កដត្តារូបក្តី កើតជាមួយនឹងខន្ធ ២ វត្ថុ កើតជាមួយនឹងខន្ធទាំងឡាយ ខន្ធទាំងឡាយ កើតជាមួយនឹងវត្ថុ មហាភូត ៣ កើតជាមួយនឹងមហាភូត ១ មហាភូត ១ កើតជាមួយនឹងមហាភូត ៣ មហាភូត ២ កើតជាមួយនឹង

មហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប កើតជាមួយនឹងមហាភូតទាំងឡាយ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ កើតជាមួយនឹងមហាភូត ១ របស់ពួកអសញ្ញសត្វ ។បេ។ កដត្តារូប ឧបាទារូប កើតជាមួយនឹងមហាភូតទាំងឡាយ ។

បណ្ឌិតគប្បីឲ្យពិស្តារ ដូចជាបដិច្ចវារៈដែរ ។

[ ២៨៣ ] វារៈ ២ ក្នុងនហេតុប្បច្ច័យ វារៈ ៥ ក្នុងនអារម្មណប្បច្ច័យ ... វារៈ ៩ ក្នុងនអធិបតិប្បច្ច័យ វារៈ ៥ ក្នុងនអនន្តរប្បច្ច័យ វារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ វារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ វារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ វារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ វារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ វារៈ ៩ ក្នុងនអាសេវនប្បច្ច័យ វារៈ ៣ ក្នុងនកម្មប្បច្ច័យ វារៈ ៩ ក្នុងនវិបាកប្បច្ច័យ វារៈ ១ ក្នុងនអាហារប្បច្ច័យ វារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ វារៈ ១ ក្នុងនឈានប្បច្ច័យ វារៈ ១ ក្នុងនមគ្គប្បច្ច័យ វារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ វារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ វារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ វារៈ ៥ ក្នុងនោវិគតប្បច្ច័យ ។

## បច្ចនីយៈ ចប់

[ ២៨៤ ] វារៈ ៥ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... វារៈ ៩ ក្នុងនអធិបតិប្បច្ច័យ វារៈ ៥ ក្នុងនអនន្តរប្បច្ច័យ វារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ វារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ វារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ វារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ វារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ វារៈ ៩ ក្នុង

នអាសេវនប្បច្ច័យ វារៈ ៣ ក្នុងនកម្មប្បច្ច័យ វារៈ ៩ ក្នុងនវិបាកប្បច្ច័យ វារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ វារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ វារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ វារៈ ៥ ក្នុងនោវិគតប្បច្ច័យ ។

អនុលោមបច្ចនីយៈ ចប់

[ ២៨៥ ] វារៈ ២ ក្នុងអារម្មណប្បច្ច័យ ព្រោះនហេតុប្បច្ច័យ ... វារៈ ២ ក្នុងអនន្តរប្បច្ច័យ វារៈ ២ ក្នុងសមនន្តរប្បច្ច័យ វារៈ ២ ក្នុងសហជា-តប្បច្ច័យ វារៈ ២ ក្នុងអញ្ញមញ្ញប្បច្ច័យ វារៈ ២ ក្នុងនិស្សយប្បច្ច័យ វារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ វារៈ ២ ក្នុងបុរេជាតប្បច្ច័យ វារៈ ២ ក្នុងអាសេវនប្បច្ច័យ វារៈ ២ ក្នុងកម្មប្បច្ច័យ វារៈ ១ ក្នុងវិបាកប្បច្ច័យ វារៈ ២ ក្នុងអាហារប្បច្ច័យ វារៈ ២ ក្នុងឥន្ទ្រិយប្បច្ច័យ វារៈ ២ ក្នុងឈានប្បច្ច័យ វារៈ ១ ក្នុងមគ្គប្បច្ច័យ វារៈ ២ ក្នុងសម្បយុត្តប្បច្ច័យ វារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ វារៈ ២ ក្នុងអត្ថិប្បច្ច័យ វារៈ ២ ក្នុងនត្ថិប្បច្ច័យ វារៈ ២ ក្នុងវិគតប្បច្ច័យ វារៈ ២ ក្នុងអវិគតប្បច្ច័យ ។

បច្ចនីយានុលោម ចប់

សហជាតវារៈ ចប់

អត្ថរបស់សហជាតវារៈ ឈ្មោះថា អត្ថរបស់បដិច្ចវារៈ អត្ថរបស់បដិច្ចវារៈ ឈ្មោះថា អត្ថរបស់សហជាតវារៈ ។

# អដ្ឋកថា

## សហជាតវារៈ

[ ២៣៦-២៤៥ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងសហជាតវារៈដូចតទៅ

បទថា **កុសលំ ធម្មំ សហជាតោ** គឺព្រោះអាស្រ័យកុសលធម៌ ទើបកើតរួមជាមួយកុសលធម៌នោះ ។ ពាក្យដ៏សេស ក្នុងសហជាតវារៈនេះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងបដិច្ចវារៈ ។ ក្នុងអវសាននៃសហ-ជាតវារៈ លោកពោលពាក្យនេះថា អត្ថរបស់សហជាតវារៈ ឈ្មោះថា អត្ថរបស់បដិច្ចវារៈ អត្ថរបស់បដិច្ចវារៈ ឈ្មោះថា អត្ថរបស់សហជាតវារៈ ដូច្នេះ ដើម្បីសម្ដែងថា វារៈទាំង ២ នេះ ពោលដោយអត្ថហើយ មិនមានការផ្សេងគ្នាឡើយ ។ ពិតហើយ ដោយអត្ថហើយ វារៈទាំង ២ នេះ មិនមានការប្លែកគ្នាឡើយ តែលោកពោលដើម្បីកំណត់អត្ថនៃគ្នានិងគ្នា ។ ពិតហើយ ក្នុងបទថា **ចក្ខុញ្ច បដិច្ច រូបេ ច** ជាដើម លោកពោលថា បច្ចុប្បន្នធម៌ រមែងកើតព្រោះអាស្រ័យចក្ខុ និងរូប សូម្បីមិនកើតព្រមគ្នា ។ ឧបាទារូប សូម្បីកើតព្រមគ្នា ក៏មិនជាបច្ច័យដល់មហាភូតរូបឡើយ ហេតុនោះ វារៈទាំង ២ នេះ លោកពោលដើម្បីកំណត់ភាពជាសហជាតប្បច្ច័យដោយបដិច្ចវារៈ និងភាពជាសហជាតរបស់បច្ច័យ ដែលលោកប្រើពាក្យថា **បដិច្ច** ដោយសហជាតវារៈ ។

ម្យ៉ាងទៀត វារៈទាំង ២ នេះ លោកពោលដោយអំណាចទេសនា-វិលាស តាមអធ្យាស្រ័យនៃពួកសត្វដែលឈមចុះដោយប្រការនោះ និងដោយអំណាចការបែកធ្លាយក្នុងនិរុត្តិប្បដិសម្ភិទា ៕

# អភិធម្មបិដក

## បច្ចយវារៈ

### អនុលោម

[ ២៤៦ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ។ អព្យាកតធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងកុសលក្ខន្ធទាំងឡាយ ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ២ ។

[ ២៤៧ ] អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងអកុសលក្ខន្ធទាំងឡាយ ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ២ ។

[ ២៤៨ ] អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើង

ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងវិបាកាព្យា-កតកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ខន្ធ ៣ ក្តី កដត្តារូបក្តី ពឹងផ្អែកនឹងវិបាកាព្យាកតក្ខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ ក្តី កដត្តារូបក្តី ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ក្តី កដត្តារូបក្តី ពឹងផ្អែកនឹងខន្ធ ២ វត្ថុ ពឹងផ្អែកនឹងខន្ធទាំងឡាយ ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ មហាភូត ១ ពឹងផ្អែកនឹងមហាភូត ៣ មហាភូតរូប ២ ពឹងផ្អែកនឹងមហាភូតរូប ២ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ កុស-លធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺកុស-លក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ អកុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺអកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺអកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ។

[ ២៤៩ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ផង

វត្ថុផង ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។ អព្យាកតធម៌ ពឹងផ្អែកនឹងកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងកុសលក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ផង វត្ថុផង ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងកុសលក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

[ ២៥០ ] អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ផង វត្ថុផង ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។ អព្យាកតធម៌ ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងអកុសលក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ផង វត្ថុផង ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងអកុសលក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

[ ២៥១ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះ

អារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ។

[ ២៥២ ] អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ខន្ធ ៣ ពឹងផ្អែកនឹងវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ខន្ធទាំងឡាយពឹងផ្អែកនឹងវត្ថុ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ សោតវិញ្ញាណ ពឹងផ្អែកនឹងសោតាយតនៈ ឃានវិញ្ញាណ ពឹងផ្អែកនឹងឃានាយតនៈ ជិវ្ហាវិញ្ញាណពឹងផ្អែកនឹងជិវ្ហាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។

[ ២៥៣ ] កុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ អកុសលធម៌ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺអកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។

[ ២៥៤ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១

ផង វត្ថុផង ។បេ។ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។

[ ២៥៥ ] អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ផង វត្ថុផង ។បេ។ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។

[ ២៥៦ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។ អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ ចិត្តសមុដ្ឋានរូប ឧបាទារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ កុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយពឹងផ្អែកនឹងវត្ថុ ។ បណ្ឌិតគប្បីឲ្យពិស្តារ ដូចជាហេតុប្បច្ច័យដែរ ។

[ ២៥៧ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះអនន្តរប្បច្ច័យ ... ព្រោះសមនន្តរប្បច្ច័យ ... ។ បណ្ឌិតគប្បីឲ្យពិស្តារ ដូចជាអារម្មណប្បច្ច័យដែរ ។

[ ២៥៨ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។ ខន្ធ ៣ ពឹងផ្អែកនឹង

អកុសលធម៌ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ ពាហិររូប ពឹងផ្អែកនឹងមហាភូត ១ ក្នុងខណៈនៃបដិសន្ធិ ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... ពឹងផ្អែកនឹងមហាភូត ១ របស់ពួកអសញ្ញសត្វ ។បេ។ កដត្តារូប ឧបាទារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ កុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះសហជាតប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ បណ្ឌិតគប្បីឲ្យពិស្តារដូចជាហេតុប្បច្ច័យដែរ ។

[ ២៥៩ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះអញ្ញមញ្ញប្បច្ច័យ គឺ ( ខន្ធ ៣ ពឹងផ្អែក ) នឹងខន្ធ ១ ។ អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះអញ្ញមញ្ញប្បច្ច័យ គឺ ( ខន្ធ ៣ ពឹងផ្អែក ) នឹងខន្ធ ១ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ ។បេ។ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ខន្ធ ៣ ក្តី វត្ថុក្តី ពឹងផ្អែកនឹងវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ខន្ធ ២ ក្តី វត្ថុក្តី ពឹងផ្អែកនឹងខន្ធ ២ វត្ថុ ពឹងផ្អែកនឹងខន្ធទាំងឡាយ ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ ។បេ។ មហាភូត ២ ពឹងផ្អែកនឹងមហាភូត ២

ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ របស់ពួកអសញ្ញសត្វ ។បេ។ មហាភូត ២ ពឹងផ្អែកនឹងមហាភូត ២ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណពឹងផ្អែកនឹងកាយាយតនៈ វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ កុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះអញ្ញមញ្ញប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ បណ្ឌិតគប្បីឲ្យពិស្តារ ដូចជាអារម្មណប្បច្ច័យដែរ ។

[ ២៦០ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះនិស្សយប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។ បណ្ឌិតគប្បីឲ្យពិស្តារ ដូចជាសហជាតប្បច្ច័យដែរ ។

[ ២៦១ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះឧបនិស្សយប្បច្ច័យ គឺ ( ខន្ធ ៣ ) ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។ ( ឧបនិស្សយប្បច្ច័យ ) ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។

[ ២៦២ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។បេ។ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ( ខន្ធទាំងឡាយពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះបុរេជាតប្បច្ច័យ ។ អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ។បេ។ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ( ខន្ធទាំងឡាយពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង )

ព្រោះបុរេជាតប្បច្ច័យ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ ។បេ។ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ( ខន្ធទាំងឡាយ ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះបុរេជាតប្បច្ច័យ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ ។ កុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ( ខន្ធទាំងឡាយ ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះបុរេជាតប្បច្ច័យ ។ អកុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ គឺអកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ( ខន្ធទាំងឡាយ ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះបុរេជាតប្បច្ច័យ ។ កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ផង វត្ថុផង ។បេ។ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ( ខន្ធទាំងឡាយពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះបុរេជាតប្បច្ច័យ ។ អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះបុរេជាតប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ផង វត្ថុផង ។បេ។ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ( ខន្ធទាំងឡាយពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះ

បុរេជាតប្បច្ច័យ ។

[ ២៦៣ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើង ព្រោះអាសេវនប្បច្ច័យ គឺពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។បេ។ អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះអាសេវនប្បច្ច័យ គឺពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ។បេ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះអាសេវនប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកិរិយាព្យាកតក្ខន្ធ ១ ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ កិរិយាព្យាកតក្ខន្ធទាំងឡាយពឹងផ្អែកនឹងវត្ថុ ។ កុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះអាសេវនប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ អកុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះអាសេវនប្បច្ច័យ គឺអកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ ពឹងផ្អែកនឹងកុសលធម៌ផង អព្យាកតធម៌ផង ។បេ។ អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះអាសេវនប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ផង វត្ថុផង ។បេ។

[ ២៦៤ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះកម្មប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។ អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះកម្មប្បច្ច័យ គឺខន្ធ ៣ ( ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ) ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះកម្មប្បច្ច័យ គឺពឹងផ្អែកនឹងវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ ។បេ។ ពឹង

ផ្អែកនឹងមហាភូត ១ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ពឹងផ្អែកនឹងមហាភូត ១ របស់ពួកអសញ្ញសត្វ ។បេ។ កដត្តារូប ឧបាទារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ កុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះកម្មប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ អកុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះកម្មប្បច្ច័យ គឺអកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះកម្មប្បច្ច័យ ។បេ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះកម្មប្បច្ច័យ គឺពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ផង វត្ថុផង ។បេ។ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងអកុសលក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

[ ២៦៥ ] អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះវិបាកប្បច្ច័យ គឺពឹងផ្អែកនឹងវិបាកាព្យាកតក្ខន្ធ ១ ។បេ។ ពឹងផ្អែកនឹងមហាភូត ១ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ វិបាកាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។

[ ២៦៦ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះអាហារប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។ ខន្ធ ៣ ពឹងផ្អែកនឹង

អកុសលធម៌ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើង ព្រោះអាហារប្បច្ច័យ ។បេ។ ក្នុងខណៈនៃបដិសន្ធិ ។បេ។ អាហារសមុដ្ឋានរូប មហាភូត ១ ។បេ។ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយ-វិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ បរិបូណ៌ ។

[ ២៦៧ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះឥន្ទ្រិយប្បច្ច័យ ។បេ។ ពឹងផ្អែកនឹងមហាភូត ១ របស់ពួកអសញ្ញសត្វ ។បេ។ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ( ទើបកើតឡើង ) ព្រោះឥន្ទ្រិយប្បច្ច័យ ។ បណ្ឌិតគប្បីឲ្យពិស្តារ ដូចជាកម្មប្បច្ច័យដែរ ។

[ ២៦៨ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះឈានប្បច្ច័យ និងមគ្គប្បច្ច័យ ។ ព្រោះឈានប្បច្ច័យផង ព្រោះមគ្គប្បច្ច័យផង ។ បណ្ឌិតគប្បីឲ្យពិស្តារ ដូចជាហេតុប្បច្ច័យដែរ ។

[ ២៦៩ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះសម្បយុត្តប្បច្ច័យ ។ ( សម្បយុត្តប្បច្ច័យ ) ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។

[ ២៧០ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។បេ។ ខន្ធ ២ ពឹង

ផ្អែកនឹងខន្ធ ២ ( ខន្ធទាំងឡាយពឹងផ្អែក ) នឹងវត្ថុ ព្រោះវិប្បយុត្តប្បច្ច័យ ។ អព្យាកតធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងកុសលក្ខន្ធទាំងឡាយ ( ចិត្តសមុដ្ឋានរូប ) ពឹងផ្អែកនឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។បេ។ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ២ ខន្ធទាំងឡាយ ( ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ ។ អកុ-សលធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ។បេ។ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ( ខន្ធទាំងឡាយពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងអកុសលក្ខន្ធទាំងឡាយ ( ចិត្តសមុដ្ឋានរូប ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ។បេ។ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ២ ខន្ធទាំងឡាយ ( ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប

( ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធ ១ ។បេ។ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ២ ខន្ធទាំងឡាយ ( ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធ ៣ ក្តី កដត្តារូបក្តី ពឹងផ្អែកនឹងវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ខន្ធ ២ ក្តី កដត្តារូបក្តី ពឹងផ្អែកនឹងខន្ធ ២ ខន្ធទាំងឡាយ ( ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ វត្ថុ ( ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ខន្ធទាំងឡាយ ( ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ វត្ថុ ( ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ ពឹងផ្អែកនឹងមហាភូត ១ ។បេ។ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ( ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ( ខន្ធទាំងឡាយពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ កុសលធម៌

ពីងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ( កុសលក្ខន្ធទាំងឡាយពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ អកុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺអកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ( អកុសលក្ខន្ធទាំងឡាយ ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ខន្ធទាំងឡាយ ( ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺអកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ខន្ធទាំងឡាយ ( ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ផង វត្ថុផង ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ( ខន្ធ ២ ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

អព្យាកតធម៌ ពឹងផ្អែកនឹងកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងកុសលក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ( ចិត្តសមុដ្ឋានរូបពឹងផ្អែក ) នឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ កុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ផង វត្ថុផង ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹង ខន្ធ ២ ផង វត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងកុសលក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ខន្ធទាំងឡាយ ( ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ផង វត្ថុផង ។បេ។ ខន្ធ ២ ពឹងផ្អែកនឹង ខន្ធ ២ ផង វត្ថុផង ( ខន្ធ ២ ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងអកុសលក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ( ចិត្តសមុដ្ឋានរូប ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ អកុសលធម៌ក្តី អព្យាកតធម៌ក្តី ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះ

វិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអកុសលក្ខន្ធ ១ ផង វត្ថុផង ។បេ។ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងអកុសលក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ខន្ធទាំងឡាយ ( ពឹងផ្អែក ) នឹងវត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( ពឹងផ្អែក ) នឹងខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ២៧១ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះអត្ថិប្បច្ច័យ ។បេ។ អត្ថិប្បច្ច័យ បណ្ឌិតគប្បីធ្វើឲ្យប្រហែលគ្នានឹងសហជាតប្បច្ច័យដែរ ។ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ប្រហែលគ្នានឹងអារម្មណប្បច្ច័យ ។ អវិគតប្បច្ច័យ ប្រហែលគ្នានឹងសហជាតប្បច្ច័យ ។

[ ២៧២ ] វារៈ ១៧ ក្នុងហេតុប្បច្ច័យ វារៈ ៧ ក្នុងអារម្មណប្បច្ច័យ វារៈ ១៧ ក្នុងអធិបតិប្បច្ច័យ វារៈ ៧ ក្នុងអនន្តរប្បច្ច័យ វារៈ ៧ ក្នុងសមនន្តរប្បច្ច័យ វារៈ ១៧ ក្នុងសហជាតប្បច្ច័យ វារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ វារៈ ១៧ ក្នុងនិស្សយប្បច្ច័យ វារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ វារៈ ៧ ក្នុងបុរេជាតប្បច្ច័យ វារៈ ៧ ក្នុងអាសេវនប្បច្ច័យ វារៈ ១៧ ក្នុងកម្មប្បច្ច័យ វារៈ ១ ក្នុងវិបាកប្បច្ច័យ វារៈ ១៧ ក្នុងអាហារប្បច្ច័យ វារៈ ១៧ ក្នុងឥន្ទ្រិយប្បច្ច័យ វារៈ ១៧ ក្នុងឈានប្បច្ច័យ វារៈ ១៧ ក្នុងមគ្គប្បច្ច័យ វារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ វារៈ ១៧ ក្នុងវិប្បយុត្តប្បច្ច័យ វារៈ ១៧ ក្នុងអត្ថិប្បច្ច័យ វារៈ ៧ ក្នុងនត្ថិប្បច្ច័យ វារៈ ៧ ក្នុងវិគតប្បច្ច័យ វារៈ ១៧ ក្នុងអវិគតប្បច្ច័យ ។

[ ២៧៣ ] វារៈ ៧ ក្នុងអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... វារៈ ១៧ ក្នុងអធិបតិប្បច្ច័យ វារៈ ៧ ក្នុងអនន្តរប្បច្ច័យ វារៈ ៧ ក្នុងសមនន្តរប្បច្ច័យ វារៈ ១៧ ក្នុងសហជាតប្បច្ច័យ ។បេ។ វារៈ ១៧ ក្នុងអវិគតប្បច្ច័យ ។

[ ២៧៤ ] វារៈ ៧ ក្នុងអធិបតិប្បច្ច័យ ព្រោះហេតុប្បច្ច័យ និងអារម្មណប្បច្ច័យ ( វារៈ ៧ ក្នុងបច្ច័យទាំងអស់ ) ... វារៈ ១ ក្នុងវិបាកប្បច្ច័យ វារៈ ៧ ក្នុងអវិគតប្បច្ច័យ ។

[ ២៧៥ ] វារៈ ៧ ក្នុងកម្មប្បច្ច័យ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ និង អាសេវនប្បច្ច័យ ... វារៈ ៧ ក្នុងអាហារប្បច្ច័យ វារៈ ៧ ក្នុងអវិគតប្បច្ច័យ ។

[ ២៧៦ ] វារៈ ៧ ក្នុងអវិគតប្បច្ច័យ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ បុរេជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ និងវិគតប្បច្ច័យ ។

[ ២៧៧ ] វារៈ ១ ក្នុងអាហារប្បច្ច័យ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ និងវិបាកប្បច្ច័យ ... វារៈ ១ ក្នុង អវិគតប្បច្ច័យ ។

[ ២៧៨ ] វារៈ ១ ក្នុងអវិគតប្បច្ច័យ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ និង

វិគតប្បច្ច័យ ។

## ហេតុមូលកៈ ចប់

[ ២៧៩ ] វារៈ ៧ ក្នុងហេតុប្បច្ច័យ ព្រោះអារម្មណប្បច្ច័យ ... វារៈ ៧ ក្នុងអធិបតិប្បច្ច័យ ។បេ។ អារម្មណមូលកៈ បណ្ឌិតគប្បីឲ្យពិស្តារ ដូចជាហេតុមូលកៈដែរ ។

[ ២៨០ ] វារៈ ១៧ ក្នុងហេតុប្បច្ច័យ ព្រោះអធិបតិប្បច្ច័យ ។ ព្រោះអនន្តរប្បច្ច័យ ... វារៈ ៧ ក្នុងហេតុប្បច្ច័យ ព្រោះសមនន្តរប្បច្ច័យ ។ ព្រោះសហជាតប្បច្ច័យ ... អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ និងបុរេជាតប្បច្ច័យ ... វារៈ ៧ ក្នុងហេតុប្បច្ច័យ ព្រោះអាសេវនប្បច្ច័យ ... វារៈ ៧ ក្នុងអារម្មណប្បច្ច័យ វារៈ ៧ ក្នុងអធិបតិប្បច្ច័យ វារៈ ៧ ក្នុងអនន្តរប្បច្ច័យ វារៈ ៧ ក្នុងសមនន្តរប្បច្ច័យ វារៈ ៧ ក្នុងសហជាតប្បច្ច័យ វារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ វារៈ ៧ ក្នុងនិស្សយប្បច្ច័យ វារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ វារៈ ៧ ក្នុងបុរេជាតប្បច្ច័យ វារៈ ៧ ក្នុងកម្មប្បច្ច័យ វារៈ ៧ ក្នុងអាហារប្បច្ច័យ វារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ វារៈ ៧ ក្នុងឈានប្បច្ច័យ វារៈ ៧ ក្នុងមគ្គប្បច្ច័យ វារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ វារៈ ៧ ក្នុងវិប្បយុត្តប្បច្ច័យ វារៈ ៧ ក្នុងអត្ថិប្បច្ច័យ វារៈ ៧ ក្នុងនត្ថិប្បច្ច័យ វារៈ ៧ ក្នុងវិគតប្បច្ច័យ វារៈ ៧ ក្នុងអវិគតប្បច្ច័យ ។

[ ២៨១ ] ព្រោះកម្មប្បច្ច័យ វារៈ ១ ក្នុងហេតុប្បច្ច័យ ព្រោះវិបាកប្បច្ច័យ ... វារៈ ១ ក្នុងអារម្មណប្បច្ច័យ វារៈ ១ ក្នុងអធិបតិប្បច្ច័យ

វារៈ ១ ក្នុងអនន្តរប្បច្ច័យ វារៈ ១ ក្នុងសមនន្តរប្បច្ច័យ វារៈ ១ ក្នុងសហជាតប្បច្ច័យ វារៈ ១ ក្នុងអញ្ញមញ្ញប្បច្ច័យ វារៈ ១ ក្នុងនិស្សយប្បច្ច័យ វារៈ ១ ក្នុងឧបនិស្សយប្បច្ច័យ វារៈ ១ ក្នុងបុរេជាតប្បច្ច័យ វារៈ ១ ក្នុងកម្មប្បច្ច័យ វារៈ ១ ក្នុងអាហារប្បច្ច័យ វារៈ ១ ក្នុងឥន្ទ្រិយប្បច្ច័យ វារៈ ១ ក្នុងឈានប្បច្ច័យ វារៈ ១ ក្នុងមគ្គប្បច្ច័យ វារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ វារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ វារៈ ១ ក្នុងអត្ថិប្បច្ច័យ វារៈ ១ ក្នុងនត្ថិប្បច្ច័យ វារៈ ១ ក្នុងវិគតប្បច្ច័យ វារៈ ១ ក្នុងអវិគតប្បច្ច័យ ។

[ ២៨២ ] ព្រោះអាហារប្បច្ច័យ ... ព្រោះឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ... វារៈ ១៧ ក្នុងហេតុប្បច្ច័យ ព្រោះអវិគតប្បច្ច័យ ... វារៈ ៧ ក្នុងអារម្មណប្បច្ច័យ វារៈ ៧ ក្នុងវិគតប្បច្ច័យ ។

## អនុលោមក្នុងបច្ចយវារៈ ចប់

# អដ្ឋកថា

## បច្ចយវារៈ

### អនុលោម

*[ ២៤៦-២៨២ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងបច្ចយវារៈដូចតទៅ*

*បទថា* **កុសលំ ធម្មំ បច្ចយា** *គឺជាសភាវៈតាំងនៅក្នុងកុសលធម៌ អធិប្បាយថា ធ្វើកុសលធម៌ឲ្យជាបច្ច័យ ព្រោះអត្ថថា ជាទីអាស្រ័យ ។ បទថា* **កុសលំ ឯកំ ខន្ធំ បច្ចយា** *មានពាក្យអធិប្បាយថា ខន្ធ ៣ ធ្វើកុសលក្ខន្ធ ១ ឲ្យជាទីអាស្រ័យ កើតឡើងព្រោះហេតុប្បច្ច័យ ។ ក្នុងគ្រប់បទ បណ្ឌិតគប្បីជ្រាបអត្ថដោយឧបាយនេះឯង ។ បទនេះថា* **វត្ថុំ បច្ចយា វិបាកាព្យាកតា កិរិយាព្យាកតា ខន្ធា** *ព្រះមានព្រះភាគ ត្រាស់ដោយអំណាចបវត្តិកាល ក្នុងបញ្ចវោការភព ។ ពិតហើយ ក្នុងបវត្តិកាល ក្នុងបញ្ចវោការភព ហទយវត្ថុដែលជាបុរេជាត ជានិស្សយប្បច្ច័យដល់ខន្ធទាំងឡាយ តែព្រោះ* **បដិច្ច** *សព្ទ មានអត្ថស្មើគ្នានឹង* **សហជាត** *សព្ទ ក្នុងបដិច្ចវារៈ មិនបានន័យបែបនេះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា* **វត្ថុំ បដិច្ច ខន្ធា** *ដូច្នេះ សំដៅយកវត្ថុដែលជាសហជាតប៉ុណ្ណោះ ក្នុងបដិសន្ធិ-កាល ។ ក្នុងបទថា* **កុសលំ ឯកំ ខន្ធញ្ច វត្ថុញ្ច បច្ចយា តយោ ខន្ធា** *ជាដើម បណ្ឌិតគប្បីជ្រាបអត្ថដោយន័យនេះដូចគ្នា ។ បទថា* **អព្យាកតំ ធម្មំ បច្ចយា កុសលោ ច អព្យាកតោ ច** *លោកពោលសំដៅយកការកើតព្រមគ្នានៃកុសល និងអព្យាកតៈ ដោយអំណាចហេតុប្បច្ច័យ ។ ពិតហើយ ក្នុងខណៈកុសលចិត្តកើតឡើង កុសលក្ខន្ធទាំងឡាយ អាស្រ័យ*

ហទយវត្ថុ និងឧបាទារូបដែលមានចិត្តជាសមុដ្ឋាន អាស្រ័យមហាភូតរូបដែលមានចិត្តជាសមុដ្ឋាន កើតឡើងដោយអំណាចហេតុប្បច្ច័យ ។ សូម្បីអព្យាកតធម៌ដែលជាបច្ច័យផ្សេងគ្នា បណ្ឌិតគប្បីជ្រាបថា ពាក្យនេះ លោកពោលសំដៅដល់ការកើតព្រមគ្នានៃបច្ចយុប្បន្ន ដោយអំណាចហេតុប្បច្ច័យក្នុងឋានៈដទៃដែលមានសភាពយ៉ាងនេះ ក៏ន័យនេះដូចគ្នា ។

ក្នុងហេតុប្បច្ច័យនេះ លោកវិសជ្ជនាបញ្ហា ១៧ ព្រោះធ្វើសហជាតនិងបុរេជាតឲ្យជាបច្ច័យ ដោយអត្ថថា ជាទីអាស្រ័យ ដោយប្រការដូច្នេះ ។ ក្នុងសេចក្តីនោះ លោកកាន់យកខន្ធទាំងឡាយ និងមហាភូតរូប ដោយអំណាចសហជាតប្បច្ច័យ កាន់យកហទយវត្ថុ ដោយអំណាចសហជាតប្បច្ច័យនិងបុរេជាតប្បច្ច័យ ។ ឯក្នុងបដិច្ចវារៈ រមែងបានបច្ច័យ ដោយអំណាចសហជាត ព្រោះហេតុនោះ ទើបក្នុងទីនោះ លោកវិសជ្ជនា ៩ បញ្ហាប៉ុណ្ណោះ ។

ក្នុងបច្ចយវារៈនោះ ធម៌ទាំងឡាយណា មានបញ្ហា ១៧ ដែលព្រះមានព្រះភាគទ្រង់វិសជ្ជនាហើយ ក្នុងធម៌ទាំងនោះ មានកុសលជាដើម ក្នុងការវិសជ្ជនាដែលមានបទដើម ១ បទ បទចុងក៏ ១ បទ បានបច្ចយុប្បន្នតែម្យ៉ាងអំពីបច្ច័យដែលដូចគ្នា ។ ក្នុងការវិសជ្ជនាដែលមានបទដើម ១ បទ បទចុង ២ បទ បានបច្ចយុប្បន្នផ្សេងគ្នា តែជាបច្ច័យដូចគ្នាតែមួយ ។ ក្នុងការវិសជ្ជនាបច្ច័យដែលមានបទដើម ២ បទ បទចុង ១ បទ បានបច្ចយុប្បន្នតែមួយដូចគ្នា អំពីបច្ច័យផ្សេងគ្នា ។ ក្នុងការវិសជ្ជនា ដែលមានបទដើម ២

បទ បទចុង ២ បទ បានបច្ចយុប្បន្នផ្សេងគ្នា អំពីបច្ច័យផ្សេងគ្នា ។ ក្នុងអារម្មណប្បច្ច័យជាដើម គប្បីជ្រាបការចែកបញ្ហា និងវិសជ្ជនា ដោយឧបាយនេះឯង ។

ពាក្យណា ដែលព្រះមានព្រះភាគត្រាស់ក្នុងអារម្មណប្បច្ច័យថា **វត្ថុំ បច្ចយា ១ខ្នា** ពាក្យនោះ លោកសំដៅយកព្រោះវិបាកក្ខន្ធក្នុងបដិសន្ធិកាលប៉ុណ្ណោះ ចក្ខុវិញ្ញាណជាដើម លោកពោលដើម្បីសម្តែងប្រភេទនៃធម៌ទាំងឡាយ ដែលអាស្រ័យអព្យាកតៈ កើតឡើងព្រោះអារម្មណប្បច្ច័យ ។ បទថា **វត្ថុំ បច្ចយា** ទ្រង់ត្រាស់ទៀត ក៏ដើម្បីសម្តែងការកើតឡើងនៃវិបាកាព្យាកតៈ និងកិរិយាព្យាកតៈក្នុងបវត្តិកាល ពាក្យដ៏សេស គប្បីជ្រាបដោយន័យមុននោះឯង ។

ក្នុងអារម្មណប្បច្ច័យនេះ លោកវិសជ្ជនា ៧ សំណួរ ព្រោះលើកឡើងនូវសហជាតប្បច្ច័យ និងបុរេជាតប្បច្ច័យឲ្យជាបច្ច័យ ដោយប្រការដូច្នេះ ។ ក្នុងបញ្ហាទាំងនោះ ខន្ធទាំងឡាយ លោកកាន់យកដោយអំណាចសហជាត ។ ហទយវត្ថុ កាន់យកដោយអំណាចសហជាត និងបុរេជាតចក្ខាយតនៈជាដើម កាន់យកដោយអំណាចបុរេជាត ។ ឯក្នុងបដិច្ចវារៈ បានបច្ច័យ ដោយអំណាចសហជាតប៉ុណ្ណោះ ព្រោះហេតុនោះ ទើបក្នុងវារៈនោះវិសជ្ជនា ៣ សំណួរប៉ុណ្ណោះ ។

ក្នុងអធិបតិប្បច្ច័យ គប្បីជ្រាបថា បានដល់ វិបាកាព្យាកតៈដែលជាលោកុត្តរប៉ុណ្ណោះ ។ អនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ ដូចគ្នានឹងអារម្ម-

ណបច្ច័យ ព្រោះមិនមានរូប ។ ក្នុងអាសេវនបច្ច័យ អត្ថិបច្ច័យ និង វិគតបច្ច័យខាងមុខ ក៏ន័យនេះដូចគ្នា ។

ក្នុងសហជាតបច្ច័យ បទថា **កដត្តារូបំ ឧបាទារូបំ** បានដល់ កដត្តារូប ពោល គឺឧបាទារូប ។ ពាក្យនេះ លោកកាន់យករូបនៃអសញ្ញ-សត្វមួយពួក ។ ចក្ខាយតនៈជាដើម ពោលដោយអំណាចបញ្ចវោការភព ។ ក្នុងអញ្ញមញ្ញបច្ច័យ លោកពោលសំដៅយកបញ្ហាដែលមានវិសជ្ជនាស្មើគ្នា ថា ដូចជាអារម្មណបច្ច័យដែរ ។ ក្នុងបច្ចយុប្បន្នធម៌ មានការផ្សេងគ្នា ។

បទថា **អារម្មណបច្ចយសទិសំ** ក្នុងឧបនិស្សយបច្ច័យ លោក ពោល ព្រោះមានវិសជ្ជនាស្មើគ្នាដោយការមិនមានរូបខ្វះ ។ បទថា **វត្ថុំ បុរេជាតបច្ចយា** ជាដើម គប្បីកាន់យកអត្ថតាមន័យដែលពោលហើយ ក្នុងបដិច្ចវារៈ ។

ក្នុងកម្មបច្ច័យ បទថា **តីណិ** បណ្ឌិតគប្បីជ្រាបវិសជ្ជនា ៣ យ៉ាង នេះ គឺកុសលកើតព្រោះអាស្រ័យកុសល ១ អព្យាកតៈកើតព្រោះអាស្រ័យ កុសល ១ កុសល និងអព្យាកតៈកើតព្រោះអាស្រ័យកុសល ១ ។ ក្នុង អកុសលជាដើម ក៏មានន័យនេះដូចគ្នា ។

ក្នុងវិប្បយុត្តបច្ច័យ បទថា **ខន្ធេ វិប្បយុត្តបច្ចយា** សេចក្តីថា ធម៌ ទាំងឡាយ អាស្រ័យខន្ធទាំងឡាយ កើតឡើងព្រោះវិប្បយុត្តបច្ច័យ ។ បទ ថា **ខន្ធា វត្ថុំ វិប្បយុត្តបច្ចយា** សេចក្តីថា ខន្ធទាំងឡាយ អាស្រ័យ ហទយវត្ថុ កើតឡើងព្រោះវិប្បយុត្តបច្ច័យ ។ ពាក្យដ៏សេស គប្បីជ្រាបតាម

ន័យដែលពោលហើយខាងដើមនោះឯង ។

ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ថា **ហេតុយា សត្តរស** ជាដើម ដើម្បីសម្ដែងវិសជ្ជនាតាមដែលរកបាន ដោយអំណាចការគណនា ។ បណ្ដាបទទាំងនោះ បទថា **ហេតុយា សត្តរស** សេចក្ដីថា ព្រះមានព្រះភាគត្រាស់វិសជ្ជនា ៣ ប្រការ គឺបទដើម ១ បទ បទចុង ១ បទ មាន ២ វារៈ បទដើម ២ បទ និងបទចុង ១ បទ មាន ១ វារៈ ដោយអំណាចកុសលយ៉ាងនេះ គឺកុសលជាមួយកុសល អព្យាកតៈជាមួយកុសល កុសលនិងអព្យាកតៈជាមួយកុសល ។ វិសជ្ជនាដោយអកុសល ក៏ដូចគ្នានឹងកុសលនោះឯង ។ អព្យាកតៈជាមួយអព្យាកតៈ អកុសល អព្យាកតៈជាមួយអព្យាកតៈ កុសលជាមួយកុសលអព្យាកតៈ អព្យាកតៈជាមួយកុសលអព្យាកតៈ កុសល អព្យាកតៈជាមួយកុសល អព្យាកតៈ អកុសលជាមួយអកុសល អព្យាកតៈ អព្យាកតៈជាមួយអកុសល អព្យាកតៈ អកុសលអព្យាកតៈជាមួយអកុសល អព្យាកតៈ បណ្ឌិតគប្បីជ្រាបថា ក្នុងហេតុប្បច្ច័យមាន ១៧ វារៈយ៉ាងនេះ ។

ក្នុងបទថា **អារម្មណោ សត្ត** សេចក្ដីថា មានវិសជ្ជនា ៧ វារៈយ៉ាងនេះ គឺកុសលជាមួយកុសល អកុសលជាមួយអកុសល អព្យាកតៈជាមួយអព្យាកតៈ កុសលជាមួយអព្យាកតៈ អកុសលជាមួយអព្យាកតៈ កុសលជាមួយកុសល អព្យាកតៈ អកុសលជាមួយអកុសល អព្យាកតៈ ។ បទថា **ឯកំ** ក្នុងវិបាកប្បច្ច័យ គឺអព្យាកតៈជាមួយនឹងអព្យាកតៈនោះឯង ។

ការកំណត់វារៈ ៣ គឺ ១៧ វារៈ ៧ វារៈ និង ១ វារៈ ក្នុងអនុលោមន័យ បច្ចយវារៈ មានដោយប្រការដូច្នេះ ។ ក្នុងវារៈទាំងនោះ បណ្ឌិតកំណត់វារៈទាំងអស់នោះ គឺពួក ១៧ វារៈ មាន ១២ បច្ច័យ ពួក ៧ វារៈ មាន ១១ បច្ច័យ ពួក ១ វារៈ មាន ១ បច្ច័យ ឲ្យល្អហើយ គប្បីជ្រាបចំនួនដោយអំណាចចំនួនដែលតិចជាង ក្នុងការប្រៀបធៀបបច្ច័យ ដោយអំណាចទុកត្តិកប្បដ្ឋានខាងមុខជាដើមខាងមុខ ។ ពិតហើយ ដោយវិធីគណនានេះ បណ្ឌិតអាចជ្រាបការកំណត់វារៈក្នុងន័យទាំងឡាយ មានទុមូលកន័យជាដើមបាន ព្រោះហេតុនោះ ដើម្បីសម្ដែងការកំណត់វារៈ ដោយអំណាចការគណនាប៉ុណ្ណោះ មិនប៉ះពាល់ ( ធ្លុះបញ្ចាំង ) ដល់វិសជ្ជនាថា កុសលធម៌កើតឡើងព្រោះអាស្រ័យកុសលធម៌ទៀត ទើបទ្រង់ផ្ដើមពាក្យថា **ហេតុប្បច្ចយា អារម្មណេ សត្ត** ជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយថា កុសលធម៌រមែងកើតព្រោះអាស្រ័យកុសលធម៌ ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ ។ បណ្ឌិតគប្បីអធិប្បាយវិសជ្ជនា ដែលបានក្នុងអារម្មណប្បច្ច័យ ឲ្យពិស្ដារទូលំទូលាយទៅ ដោយន័យនេះថា ខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ កើតឡើង ។៚

## នេះជាន័យក្នុងអនុលោមមានប្រមាណប៉ុណ្ណោះ

# អភិធម្មបិដក

## បច្ចនីយៈ

[ ២៨៣ ] អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងអហេតុកវិបាកាព្យាកតកិរិយា-ព្យាកតក្ខន្ធ ១ ។បេ។ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបក្តី ពឹងផ្អែកនឹងវិបាកាព្យាកតក្ខន្ធ ១ ក្នុងខណៈនៃអហេតុក-បដិសន្ធិ ។បេ។ ខន្ធ ២ ក្តី កដត្តារូបក្តី ពឹងផ្អែកនឹងខន្ធ ២ វត្ថុ ពឹងផ្អែកនឹងខន្ធទាំងឡាយ ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ ។បេ។ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ របស់ពួកអសញ្ញសត្វ ។បេ។ កដត្តារូប ឧបាទារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ អហេតុកវិបាកាព្យាកតកិរិយាព្យា-កតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ អកុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។ អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកប

ដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលប្រទូស្ត ដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈផង វត្ថុផង ។

[ ២៨៤ ] អព្យាកតធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងកុសលក្ខន្ធទាំងឡាយ ។ បណ្ឌិតគប្បីឲ្យពិស្តារ ដូចជានអារម្មណប្បច្ច័យ ក្នុងបដិច្ចវារៈផងចុះ ។

[ ២៨៥ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។ ខន្ធ ៣ ពឹងផ្អែកនឹងអកុសលធម៌ ។ ពឹងផ្អែកនឹងអព្យាកតធម៌ ក្នុងខណៈនៃបដិសន្ធិ ។បេ។ បណ្ឌិតគប្បីសម្តែងអព្យាកតធម៌ ឲ្យបរិបូណ៌ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... ( មហាភូត ៣ ) ពឹងផ្អែកនឹងមហាភូត ១ របស់ពួកអសញ្ញសត្វ ។បេ។ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ វិបាកាព្យាកតកិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ កុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះនអធិបតិប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។បេ។ បណ្ឌិតគប្បីរាប់ដូចជាសហជាតប្បច្ច័យ ក្នុងអនុលោមដែរ ។

[ ២៨៦ ] អព្យាកតធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះនអនន្តរប្បច្ច័យ ... ព្រោះនសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ នឧបនិស្សយប្បច្ច័យ និងនបុរេជាតប្បច្ច័យ ... ។ បណ្ឌិតគប្បីសម្តែងឲ្យពិស្តារ ដូចជាក្នុងបដិច្ចវារៈដែរ ។

[ ២៨៧ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះនបច្ឆាជាតប្បច្ច័យ ... ព្រោះនអាសេវនប្បច្ច័យ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ នបច្ឆាជាតប្បច្ច័យក្តី នអាសេវនប្បច្ច័យក្តី បណ្ឌិតគប្បីសម្តែងឲ្យបរិបូណ៌ សុទ្ធតែមានវារៈ ១៧ ។ បណ្ឌិតគប្បីសម្តែងឲ្យពិស្តារដូចជាសហជាតប្បច្ច័យ ក្នុងអនុលោមដែរ ។

[ ២៨៨ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះនកម្មប្បច្ច័យ គឺកុសលចេតនា ពឹងផ្អែកនឹងកុសលក្ខន្ធទាំងឡាយ ។ អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ ទើបកើតឡើងព្រោះនកម្មប្បច្ច័យ គឺអកុសលចេតនា ពឹងផ្អែកនឹងអកុសលក្ខន្ធទាំងឡាយ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះនកម្មប្បច្ច័យ គឺកិរិយាព្យាកតចេតនា ពឹងផ្អែកនឹងកិរិយាព្យាកតក្ខន្ធទាំងឡាយ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... ( មហាភូត ៣ ) ពឹងផ្អែកនឹងមហាភូត ១ ។បេ។ ឧបាទារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ កិរិយាព្យាកតចេតនា ពឹងផ្អែកនឹងវត្ថុ ។ កុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះនកម្មប្បច្ច័យ គឺកុសលចេតនា ពឹងផ្អែកនឹងវត្ថុ ។ អកុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះនកម្មប្បច្ច័យ គឺអកុសលចេតនា ពឹងផ្អែកនឹងវត្ថុ ។ កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើងព្រោះនកម្មប្បច្ច័យ គឺកុសលចេតនា ពឹងផ្អែកនឹងកុសលធម៌ផង វត្ថុផង ។ អកុសលធម៌ ពឹងផ្អែកនឹងអកុសលធម៌ផង អព្យាកតធម៌ផង ទើបកើតឡើង

ព្រោះនកម្មប្បច្ច័យ គឺអកុសលចេតនា ពឹងផ្អែកនឹងអកុសលក្ខន្ធទាំងឡាយ ផង វត្ថុផង ។

[ ២៨៩ ] កុសលធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើងព្រោះនវិបាកប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងកុសលក្ខន្ធ ១ ។ ខន្ធ ៣ ពឹងផ្អែកនឹងអកុសលធម៌ ។ អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះនវិបាកប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងកិរិយាព្យាកតក្ខន្ធ ១ ។បេ។ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ២ មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ ។បេ។ ចិត្តសមុដ្ឋានរូប និងឧបាទារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ របស់ពួកអសញ្ញសត្វ ។បេ។ កដត្តារូប និងឧបាទារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ កិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ កុសលធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះនវិបាកប្បច្ច័យ គឺកុសលក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ បណ្ឌិតគប្បីសម្តែងឲ្យពិស្តារ ក្នុងបច្ច័យទាំងពួងចុះ វៀរលែងតែវិបាកប្បច្ច័យចេញ ។

[ ២៩០ ] អព្យាកតធម៌ ពឹងផ្អែកនឹងអព្យាកតធម៌ ទើបកើតឡើងព្រោះនអាហារប្បច្ច័យ ... ព្រោះនឥន្ទ្រិយប្បច្ច័យ ... ព្រោះនឈានប្បច្ច័យ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ការធ្វើឲ្យផ្សេងៗ គ្នានេះ ក្នុងនឈានប្បច្ច័យ ។ ... ព្រោះ

នមគ្គប្បច្ច័យ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ អហេតុកវិបាកាព្យាកតកិរិយាព្យាកតក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ការធ្វើឲ្យផ្សេងៗ គ្នានេះ ក្នុងនមគ្គប្បច្ច័យ ។ ពាក្យដ៏សេសសល់ បណ្ឌិតគប្បីឲ្យពិស្តារ ដូចជាបច្ចនីយៈ ក្នុងបដិច្ចវារៈដែរ ។ ព្រោះនសម្បយុត្តប្បច្ច័យ នវិប្បយុត្តប្បច្ច័យ និងនោនត្ថិប្បច្ច័យ ។ អព្យាកតធម៌ ពឹងផ្អែកនឹងកុសលធម៌ ទើបកើតឡើង ព្រោះនោវិគតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងកុសលក្ខន្ធទាំងឡាយ ។ បណ្ឌិតគប្បីសម្តែងឲ្យពិស្តារ ដូចជាក្នុងបដិច្ចវារៈដែរ ។

[ ២៩១ ] វារៈ ៤ ក្នុងនហេតុប្បច្ច័យ វារៈ ៥ ក្នុងនអារម្មណប្បច្ច័យ វារៈ ១៧ ក្នុងនអធិបតិប្បច្ច័យ វារៈ ៥ ក្នុងនអនន្តរប្បច្ច័យ វារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ វារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ វារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ វារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ វារៈ ១៧ ក្នុងនបច្ឆាជាតប្បច្ច័យ វារៈ ១៧ ក្នុងនអាសេវនប្បច្ច័យ វារៈ ៧ ក្នុងនកម្មប្បច្ច័យ វារៈ ១៧ ក្នុងនវិបាកប្បច្ច័យ វារៈ ១ ក្នុងនអាហារប្បច្ច័យ វារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ វារៈ ១ ក្នុងនឈានប្បច្ច័យ វារៈ ១ ក្នុងនមគ្គប្បច្ច័យ វារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ វារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ វារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ វារៈ ៥ ក្នុងនោវិគតប្បច្ច័យ ។

[ ២៩២ ] វារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះនហេតុប្បច្ច័យ ... វារៈ ៤ ក្នុងនអធិបតិប្បច្ច័យ វារៈ ១ ក្នុងនអនន្តរប្បច្ច័យ វារៈ ១ ក្នុងនសមនន្ត-

វប្បច្ច័យ វារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ វារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ វារៈ ២ ក្នុងនបុរេជាតប្បច្ច័យ វារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ វារៈ ៤ ក្នុងនអាសេវនប្បច្ច័យ វារៈ ១ ក្នុងនកម្មប្បច្ច័យ វារៈ ៤ ក្នុងនវិបាកប្បច្ច័យ វារៈ ១ ក្នុងនអាហារប្បច្ច័យ វារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ វារៈ ១ ក្នុងនឈានប្បច្ច័យ វារៈ ១ ក្នុងនមគ្គប្បច្ច័យ វារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ វារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ វារៈ ១ ក្នុងនោនត្ថិប្បច្ច័យ វារៈ ១ ក្នុងនោវិគតប្បច្ច័យ ។

[ ២៩៣ ] វារៈ ១ ក្នុងនអធិបតិប្បច្ច័យ ព្រោះនហេតុប្បច្ច័យ និងនអារម្មណប្បច្ច័យ ... វារៈ ១ ក្នុងនអនន្តរប្បច្ច័យ វារៈ ១ ក្នុងនសមនន្តរប្បច្ច័យ ( វារៈ ១ ក្នុងបច្ច័យទាំងអស់ ) វារៈ ១ ក្នុងនោនត្ថិប្បច្ច័យ វារៈ ១ ក្នុងនោវិគតប្បច្ច័យ ។

[ ២៩៤ ] វារៈ ១ ក្នុងនហេតុប្បច្ច័យ ព្រោះនអារម្មណប្បច្ច័យ... វារៈ ៥ ក្នុងនអធិបតិប្បច្ច័យ វារៈ ៥ ក្នុងនអនន្តរប្បច្ច័យ វារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ វារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ វារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ វារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ វារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ វារៈ ៥ ក្នុងនអាសេវនប្បច្ច័យ វារៈ ១ ក្នុងនកម្មប្បច្ច័យ វារៈ ៥ ក្នុងនវិបាកប្បច្ច័យ វារៈ ១ ក្នុងនអាហារប្បច្ច័យ វារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ វារៈ ១ ក្នុងនឈានប្បច្ច័យ វារៈ ១ ក្នុងនមគ្គប្បច្ច័យ វារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ វារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ វារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ វារៈ ៥ ក្នុង

នោវិគតប្បច្ច័យ ។

[ ២៩៥ ] វារៈ ១ ក្នុងនអធិបតិប្បច្ច័យ ព្រោះនអារម្មណប្បច្ច័យ និង នហេតុប្បច្ច័យ ... វារៈ ១ ក្នុងនោវិគតប្បច្ច័យ ។

[ ២៩៦ ] វារៈ ៤ ក្នុងនហេតុប្បច្ច័យ ព្រោះនអធិបតិប្បច្ច័យ ... វារៈ ៥ ក្នុងនអារម្មណប្បច្ច័យ វារៈ ៥ ក្នុងនអនន្តរប្បច្ច័យ វារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ វារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ វារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ វារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ វារៈ ១៧ ក្នុងនបច្ឆាជាតប្បច្ច័យ វារៈ ១៧ ក្នុងនអាសេវនប្បច្ច័យ វារៈ ៧ ក្នុងនកម្មប្បច្ច័យ វារៈ ១៧ ក្នុងនវិបាកប្បច្ច័យ វារៈ ១ ក្នុងនអាហារប្បច្ច័យ វារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ វារៈ ១ ក្នុងនឈានប្បច្ច័យ វារៈ ១ ក្នុងនមគ្គប្បច្ច័យ វារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ វារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ វារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ វារៈ ៥ ក្នុងនោវិគតប្បច្ច័យ ។

[ ២៩៧ ] វារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះនអធិបតិប្បច្ច័យ និង នហេតុប្បច្ច័យ ... វារៈ ១ ក្នុងនអនន្តរប្បច្ច័យ វារៈ ១ ក្នុងនសមនន្តរប្បច្ច័យ វារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ វារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ វារៈ ២ ក្នុងនបុរេជាតប្បច្ច័យ វារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ វារៈ ៤ ក្នុងនអាសេវនប្បច្ច័យ វារៈ ១ ក្នុងនកម្មប្បច្ច័យ វារៈ ៤ ក្នុងនវិបាកប្បច្ច័យ វារៈ ១ ក្នុងនអាហារប្បច្ច័យ វារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ វារៈ ១ ក្នុងនឈានប្បច្ច័យ វារៈ ១ ក្នុងនមគ្គប្បច្ច័យ វារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ វារៈ ២ ក្នុង

នវិប្បយុត្តប្បច្ច័យ វារៈ ១ ក្នុងនោនត្ថិប្បច្ច័យ វារៈ ១ ក្នុងនោវិគតប្បច្ច័យ ។

[ ៤៩៨ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺព្រះអរហន្តចេញចាកមគ្គ ធ្វើមគ្គឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ។ ឯសហជាតាធិបតិ គឺកុសលាធិបតិធម៌ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ កុសលធម៌ ជាបច្ច័យនៃកុសលធម៌ និងពួកអព្យាកតធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺកុសលាធិបតិធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។

[ ៤៩៩ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ

( បុគ្គល ) ធ្វើរាគៈឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈកើតឡើងព្រោះធ្វើរាគៈនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ( បុគ្គល ) ធ្វើទិដ្ឋិឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើទិដ្ឋិនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺអកុសលាធិបតិធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៥០០ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអកុសលាធិបតិធម៌ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។

[ ៥០១ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ និងអព្យាកតធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអកុសលាធិបតិធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។

[ ៥០២ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺព្រះអរហន្ត ធ្វើផលឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ធ្វើព្រះនិព្វានឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ព្រះនិព្វាន ជាបច្ច័យនៃផល ដោយអធិបតិប្បច្ច័យ ។ ឯសហជាតាធិបតិ គឺវិបាកាព្យាកតាធិបតិក្តី កិរិយាព្យាកតាធិបតិក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។

[ ៥០៣ ] អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអធិបតិប្បច្ច័យ

បានដល់ អារម្មណាធិបតិ គឺពួកសេក្ខបុគ្គល ធ្វើផលឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ធ្វើព្រះនិព្វានឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទាន: និងមគ្គ ដោយអធិបតិប្បច្ច័យ ។

[ ៥០៤ ] អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលធ្វើចក្ខុឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើចក្ខុនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ( បុគ្គលធ្វើ ) សោតៈ ... ឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ វត្ថុ ... ធ្វើនូវវិបាកាព្យាកតក្ខន្ធ និងកិរិយាព្យាកតក្ខន្ធទាំងឡាយឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើវត្ថុនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ។

[ ៥០៥ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអនន្តរប្បច្ច័យ គឺពួកកុសលក្ខន្ធមុនៗ ជាបច្ច័យនៃពួកកុសលក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈ ជាបច្ច័យនៃមគ្គ ដោយអនន្តរប្បច្ច័យ ។

[ ៥០៦ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអនន្តរប្បច្ច័យ គឺកុសល ( ជាបច្ច័យ ) នៃវុដ្ឋានៈ មគ្គ ( ជាបច្ច័យ ) នៃផល អនុលោម របស់ពួកសេក្ខបុគ្គល ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនកុសលរបស់បុគ្គល កាលចេញចាកនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[ ៥០៧ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអនន្តរប្បច្ច័យ គឺពួកអកុសលក្ខន្ធមុនៗ ជាបច្ច័យនៃពួកអកុសលក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។

[ ៥០៨ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអនន្តរប្បច្ច័យ គឺអកុសល ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។

[ ៥០៩ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអនន្តរប្បច្ច័យ គឺពួកវិបាកាព្យាកតក្ខន្ធក្តី ពួកកិរិយាព្យាកតក្ខន្ធក្តី មុនៗ ជាបច្ច័យនៃពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ភវង្គ ( ជាបច្ច័យ ) នៃអាវជ្ជនា កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋានៈ អនុលោមរបស់ព្រះអរហន្ត ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនកិរិយារបស់បុគ្គល កាលចេញចាកនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[ ៥១០ ] អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអនន្តរប្បច្ច័យ គឺអាវជ្ជនា ជាបច្ច័យនៃពួកកុសលក្ខន្ធ ដោយអនន្តរប្បច្ច័យ ។

[ ៥១១ ] អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអនន្តរប្បច្ច័យ គឺអាវជ្ជនា ជាបច្ច័យនៃពួកអកុសលក្ខន្ធ ដោយអនន្តរប្បច្ច័យ ។

[ ៥១២ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយសមនន្តរប្បច្ច័យ គឺពួកកុសលក្ខន្ធមុនៗ ជាបច្ច័យនៃពួកកុសលក្ខន្ធក្រោយៗ ដោយសមនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ )

នៃវោទាន: គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទាន: ជាបច្ច័យនៃមគ្គ ដោយសមនន្តរប្បច្ច័យ ។

[ ៥១៣ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយសមនន្តរប្បច្ច័យ គឺកុសល ( ជាបច្ច័យ ) នៃវុដ្ឋាន: មគ្គ ( ជាបច្ច័យ ) នៃផល អនុលោម របស់ពួកសេក្ខបុគ្គល ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញា-យតនកុសលរបស់បុគ្គល កាលចេញចាកនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយសមនន្តរប្បច្ច័យ ។

[ ៥១៤ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយសមនន្ត-រប្បច្ច័យ គឺពួកអកុសលក្ខន្ធមុនៗ ជាបច្ច័យនៃពួកអកុសលក្ខន្ធក្រោយៗ ដោយសមនន្តរប្បច្ច័យ ។

[ ៥១៥ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយសមនន្ត-រប្បច្ច័យ គឺអកុសល ជាបច្ច័យនៃវុដ្ឋាន: ដោយសមនន្តរប្បច្ច័យ ។

[ ៥១៦ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយសមនន្ត-រប្បច្ច័យ គឺពួកវិបាកាព្យាកតក្ខន្ធក្តី ពួកកិរិយាព្យាកតក្ខន្ធក្តី មុនៗ ជាបច្ច័យ នៃពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធក្រោយៗ ដោយសមនន្ត-រប្បច្ច័យ ភវង្គ ( ជាបច្ច័យ ) នៃអាវជ្ជនា កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋាន: អនុលោម របស់ព្រះអរហន្ត ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញា-នាសញ្ញាយតនកិរិយារបស់បុគ្គល កាលចេញចាកនិរោធ ជាបច្ច័យនៃ ផលសមាបត្តិ ដោយសមនន្តរប្បច្ច័យ ។

[ ៥១៧ ] អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយសមនន្តរបច្ច័យ គឺអាវជ្ជនា ជាបច្ច័យនៃពួកកុសលក្ខន្ធ ដោយសមនន្តរបច្ច័យ ។

[ ៥១៨ ] អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយសមនន្តរបច្ច័យ គឺអាវជ្ជនា ជាបច្ច័យនៃពួកកុសលក្ខន្ធ ដោយសមនន្តរបច្ច័យ ។

[ ៥១៩ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយសហជាតបច្ច័យ គឺកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយសហជាតបច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយសហជាតបច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយសហជាតបច្ច័យ ។

[ ៥២០ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយសហជាតបច្ច័យ គឺពួកកុសលក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយសហជាតបច្ច័យ ។

[ ៥២១ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ និងអព្យាកតធម៌ ដោយសហជាតបច្ច័យ គឺកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយសហជាតបច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកចិត្តសមុដ្ឋានរូប ដោយសហជាតបច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកចិត្តសមុដ្ឋានរូប ដោយសហជាតបច្ច័យ ។

[ ៥២២ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយសហជាតបច្ច័យ គឺអកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយសហជាតបច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយសហជាតបច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយសហជាតបច្ច័យ ។

[ ៥២៣ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយសហជាតប្បច្ច័យ គឺពួកអកុសលក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ។

[ ៥២៤ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ និងអព្យាកតធម៌ ដោយសហជាតប្បច្ច័យ គឺអកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ។

[ ៥២៥ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយសហជាតប្បច្ច័យ គឺវិបាកាព្យាកតក្ខន្ធ ១ ក្តី កិរិយាព្យាកតក្ខន្ធ ១ ក្តី ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វិបាកាព្យាកតក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកកដត្តារូប ដោយសហជាតប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកកដត្តារូប ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកកដត្តារូប ដោយសហជាតប្បច្ច័យ ពួកខន្ធ ជាបច្ច័យនៃវត្ថុ ដោយសហជាតប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកខន្ធ ដោយសហជាតប្បច្ច័យ មហាភូត ១ ជាបច្ច័យនៃមហាភូត ៣ ដោយសហជាតប្បច្ច័យ មហាភូត ៣ ជាបច្ច័យនៃមហាភូត ១ ដោយសហជា-

តប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយសហជាតប្បច្ច័យ ពួកមហាភូត ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ពួកកដត្តារូប និងពួកឧបាទារូប ដោយសហជាតប្បច្ច័យ មហាភូត ១ ជាខាងក្រៅ ជាបច្ច័យនៃមហាភូត ៣ ដោយសហជាតប្បច្ច័យ មហាភូត ៣ ជាបច្ច័យនៃមហាភូត ១ ដោយសហជាតប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយសហជា-តប្បច្ច័យ ពួកមហាភូត ជាបច្ច័យនៃពួកឧបាទារូប ដោយសហជាតប្បច្ច័យ មហាភូត ១ ដែលជាអាហារសមុដ្ឋាន ជាបច្ច័យនៃពួកមហាភូត ៣ ដោយសហជាតប្បច្ច័យ មហាភូត ៣ ជាបច្ច័យនៃមហាភូត ១ ដោយសហជា-តប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយសហជាតប្បច្ច័យ ពួកមហាភូត ជាបច្ច័យនៃពួកឧបាទារូប ដោយសហជាតប្បច្ច័យ មហាភូត ១ ដែលជាឧតុសមុដ្ឋាន ជាបច្ច័យនៃមហាភូត ៣ ដោយសហជាតប្បច្ច័យ មហាភូត ៣ ជាបច្ច័យនៃមហាភូត ១ ដោយសហជាតប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយសហជាតប្បច្ច័យ ពួកមហាភូត ជាបច្ច័យនៃពួកឧបាទារូប ដោយសហជាតប្បច្ច័យ មហាភូត ១ របស់ពួកអសញ្ញសត្វ ជាបច្ច័យនៃមហាភូត ៣ ដោយសហជាតប្បច្ច័យ មហាភូត ៣ ជាបច្ច័យនៃមហាភូត ១ ដោយសហជាតប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយសហជាតប្បច្ច័យ ពួកមហាភូត ជាបច្ច័យនៃពួកកដត្តារូប និងពួកឧបាទារូប ដោយសហជាតប្បច្ច័យ ។

[ ៥២៦ ] កុសលធម៌ក្តី អព្យាកតធម៌ក្តី ជាបច្ច័យនៃអព្យាកតធម៌

ដោយសហជាតប្បច្ច័យ គឺពួកកុសលក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ។

[ ៥២៧ ] អកុសលធម៌ក្តី អព្យាកតធម៌ក្តី ជាបច្ច័យនៃអព្យាកតធម៌ ដោយសហជាតប្បច្ច័យ គឺពួកអកុសលក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ។

[ ៥២៨ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ៥២៩ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺអកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ៥៣០ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺវិបាកាព្យាកតក្ខន្ធ ១ ក្តី កិរិយាព្យាកតក្ខន្ធ ១ ក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វិបាកាព្យាកតក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងវត្ថុ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងវត្ថុ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃ

ខន្ធ ២ និងវត្ថុ ដោយអញ្ញមញ្ញប្បច្ច័យ ពួកខន្ធ ជាបច្ច័យនៃវត្ថុ ដោយអញ្ញមញ្ញប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកខន្ធ ដោយអញ្ញមញ្ញប្បច្ច័យ មហាភូត ១ ជាបច្ច័យនៃមហាភូត ៣ ដោយអញ្ញមញ្ញប្បច្ច័យ មហាភូត ៣ ជាបច្ច័យនៃមហាភូត ១ ដោយអញ្ញមញ្ញប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយអញ្ញមញ្ញប្បច្ច័យ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ១ របស់ពួកអសញ្ញសត្វ ជាបច្ច័យនៃមហាភូត ៣ ដោយអញ្ញមញ្ញប្បច្ច័យ មហាភូត ៣ ជាបច្ច័យនៃមហាភូត ១ ដោយអញ្ញមញ្ញប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ៥៣១ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយនិស្សយប្បច្ច័យ គឺកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយនិស្សយប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយនិស្សយប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយនិស្សយប្បច្ច័យ ។

[ ៥៣២ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយនិស្សយប្បច្ច័យ គឺពួកកុសលក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ។

[ ៥៣៣ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ និងអព្យាកតធម៌ ដោយនិស្សយប្បច្ច័យ គឺកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ។

[ ៥៣៤ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយនិស្សយប្បច្ច័យ គឺអកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយនិស្សយប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយនិស្សយប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយនិស្សយប្បច្ច័យ ។

[ ៥៣៥ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយនិស្សយប្បច្ច័យ គឺពួកអកុសលក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ។

[ ៥៣៦ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ និងអព្យាកតធម៌ ដោយនិស្សយប្បច្ច័យ គឺអកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ។

[ ៥៣៧ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយនិស្សយប្បច្ច័យ គឺវិបាកាព្យាកតក្ខន្ធ ១ ក្តី កិរិយាព្យាកតក្ខន្ធ ១ ក្តី ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វិបាកាព្យាកតក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកកដត្តារូប ដោយនិស្សយប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកកដត្តារូប ដោយនិស្សយប្បច្ច័យ

ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកកដត្តារូប ដោយនិស្សយប្បច្ច័យ ពួកខន្ធ ជាបច្ច័យនៃវត្ថុ ដោយនិស្សយប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកខន្ធ ដោយនិស្សយប្បច្ច័យ មហាភូត ១ ជាបច្ច័យនៃមហាភូត ៣ ដោយនិស្សយប្បច្ច័យ មហាភូត ៣ ជាបច្ច័យនៃមហាភូត ១ ដោយនិស្សយប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយនិស្សយប្បច្ច័យ ពួកមហាភូត ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ពួកកដត្តារូប និងពួកឧបាទារូប ដោយនិស្សយប្បច្ច័យ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ១ របស់ពួកអសញ្ញសត្វ ជាបច្ច័យនៃមហាភូត ៣ ដោយនិស្សយប្បច្ច័យ មហាភូត ៣ ជាបច្ច័យនៃមហាភូត ១ ដោយនិស្សយប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយនិស្សយប្បច្ច័យ ពួកមហាភូត ជាបច្ច័យនៃពួកកដត្តារូប និងពួកឧបាទារូប ដោយនិស្សយប្បច្ច័យ ចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយនិស្សយប្បច្ច័យ សោតាយតនៈ ... ឃានាយតនៈ ... ជិវ្ហាយតនៈ ... កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយនិស្សយប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធ ដោយនិស្សយប្បច្ច័យ ។

[ ៥៣៨ ] អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយនិស្សយប្បច្ច័យ គឺវត្ថុ ជាបច្ច័យនៃពួកកុសលក្ខន្ធ ដោយនិស្សយប្បច្ច័យ ។

[ ៥៣៩ ] អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយនិស្សយប្បច្ច័យ គឺវត្ថុ ជាបច្ច័យនៃពួកអកុសលក្ខន្ធ ដោយនិស្សយប្បច្ច័យ ។

[ ៥៤០ ] កុសលធម៌ក្តី អព្យាកតធម៌ក្តី ជាបច្ច័យនៃកុសលធម៌ ដោយ

និស្សយប្បច្ច័យ គឺកុសលក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយនិស្សយប្បច្ច័យ ខន្ធ ៣ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ១ ដោយនិស្សយប្បច្ច័យ ខន្ធ ២ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ដោយនិស្សយប្បច្ច័យ ។

[ ៥៤១ ] កុសលធម៌ក្តី អព្យាកតធម៌ក្តី ជាបច្ច័យនៃអព្យាកតធម៌ ដោយនិស្សយប្បច្ច័យ គឺពួកកុសលក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ។

[ ៥៤២ ] អកុសលធម៌ក្តី អព្យាកតធម៌ក្តី ជាបច្ច័យនៃអកុសលធម៌ ដោយនិស្សយប្បច្ច័យ គឺអកុសលក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយនិស្សយប្បច្ច័យ ខន្ធ ៣ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ១ ដោយនិស្សយប្បច្ច័យ ខន្ធ ២ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ដោយនិស្សយប្បច្ច័យ ។

[ ៥៤៣ ] អកុសលធម៌ក្តី អព្យាកតធម៌ក្តី ជាបច្ច័យនៃអព្យាកតធម៌ ដោយនិស្សយប្បច្ច័យ គឺពួកអកុសលក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ។

[ ៥៤៤ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ អារម្មណូបនិស្ស័យ គឺ ( បុគ្គល ) ឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ធ្វើពួកកុសលដែលខ្លួនធ្លាប់សន្សំហើយក្នុងកាលមុន ហើយពិចារណា ចេញចាកឈាន ធ្វើឈានឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ពួកសេក្ខបុគ្គល ធ្វើគោត្រភូ ឲ្យធ្ងន់ ( ក្នុង

ចិត្ត ) ហើយពិចារណា ធ្វើវោទានៈឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ពួកសេក្ខបុគ្គល ចេញចាកមគ្គ ធ្វើមគ្គឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ។ អនន្តរូបនិស្ស័យ គឺពួកកុសលក្ខន្ធមុនៗ ជាបច្ច័យនៃពួកកុសលក្ខន្ធក្រោយៗ ដោយឧបនិស្សយប្បច្ច័យ អនុលោម ជាបច្ច័យនៃគោត្រភូ អនុលោម ជាបច្ច័យនៃវោទានៈ គោត្រភូ ជាបច្ច័យនៃមគ្គ វោទានៈ ជាបច្ច័យនៃមគ្គ ដោយឧបនិស្សយប្បច្ច័យ ។ ឯបកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធា ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើត ធ្វើវិបស្សនាឲ្យកើត ធ្វើមគ្គឲ្យកើត ធ្វើអភិញ្ញាឲ្យកើត ធ្វើសមាបត្តិឲ្យកើត សីល ... សុតៈ ... ចាគៈ ... អាស្រ័យបញ្ញា ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើត ធ្វើវិបស្សនាឲ្យកើត ធ្វើមគ្គឲ្យកើត ធ្វើអភិញ្ញាឲ្យកើត ធ្វើសមាបត្តិឲ្យកើត សទ្ធា ... សីល សុតៈ ចាគៈ ... បញ្ញា ជាបច្ច័យនៃសទ្ធា សីល សុតៈ ចាគៈ និងបញ្ញា ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃបឋមជ្ឈាន ជាបច្ច័យនៃបឋមជ្ឈាន ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃទុតិយជ្ឈាន ជាបច្ច័យនៃទុតិយជ្ឈាន ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃតតិយជ្ឈាន ជាបច្ច័យនៃតតិយជ្ឈាន ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃចតុត្ថជ្ឈាន ជាបច្ច័យនៃចតុត្ថជ្ឈាន ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃអាកាសានញ្ចា-យតនជ្ឈាន ជាបច្ច័យនៃអាកាសានញ្ចាយតនជ្ឈាន ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃវិញ្ញាណញ្ចាយតនជ្ឈាន ជាបច្ច័យនៃវិញ្ញាណញ្ចាយតនជ្ឈាន ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃអាកិញ្ចញ្ញាយតនជ្ឈាន ជាបច្ច័យនៃអាកិញ្ចញ្ញា-

យតនជ្ឈាន ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃនេវសញ្ញានាសញ្ញាយត-
នជ្ឈាន ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយឧបនិស្សយប្បច្ច័យ
បឋមជ្ឈាន ជាបច្ច័យនៃទុតិយជ្ឈាន ដោយឧបនិស្សយប្បច្ច័យ ។បេ។
ចតុត្ថជ្ឈាន ( ជាបច្ច័យ ) នៃអាកាសានញ្ចាយតនជ្ឈាន អាកាសានញ្ចា-
យតនជ្ឈាន ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយតនជ្ឈាន
( ជាបច្ច័យ ) នៃអាកិញ្ចញ្ញាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន ជាបច្ច័យ
នៃនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃទិព្វចក្ខុ
ជាបច្ច័យនៃទិព្វចក្ខុ ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃទិព្វសោតធាតុ ជា
បច្ច័យនៃទិព្វសោតធាតុ ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃឥទ្ធិវិធញ្ញាណ
ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃចេតោបរិ-
យញ្ញាណ ជាបច្ច័យនៃចេតោបរិយញ្ញាណ ដោយឧបនិស្សយប្បច្ច័យ បរិកម្ម
នៃបុព្វេនិវាសានុស្សតិញ្ញាណ ជាបច្ច័យនៃបុព្វេនិវាសានុស្សតិញ្ញាណ ដោយ
ឧបនិស្សយប្បច្ច័យ បរិកម្មនៃយថាកម្មូបគញ្ញាណ ជាបច្ច័យនៃយថាកម្មូប-
គញ្ញាណ ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃអនាគតំសញ្ញាណ ជាបច្ច័យ
នៃអនាគតំសញ្ញាណ ដោយឧបនិស្សយប្បច្ច័យ ទិព្វចក្ខុ ជាបច្ច័យនៃទិព្វ-
សោតធាតុ ដោយឧបនិស្សយប្បច្ច័យ ទិព្វសោតធាតុ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ
ដោយឧបនិស្សយប្បច្ច័យ ឥទ្ធិវិធញ្ញាណ ជាបច្ច័យនៃចេតោបរិយញ្ញាណ ដោយ
ឧបនិស្សយប្បច្ច័យ ចេតោបរិយញ្ញាណ ជាបច្ច័យនៃបុព្វេនិវាសានុស្សតិញ្ញាណ
ដោយឧបនិស្សយប្បច្ច័យ បុព្វេនិវាសានុស្សតិញ្ញាណ ជាបច្ច័យនៃយថាកម្មូ-

បគញ្ញាណ ដោយឧបនិស្សយប្បច្ច័យ យថាកម្មូបគញ្ញាណ ជាបច្ច័យនៃអនាគតំសញ្ញាណ ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃបឋមមគ្គ ជាបច្ច័យនៃបឋមមគ្គ ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃទុតិយមគ្គ ជាបច្ច័យនៃទុតិយមគ្គ ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃតតិយមគ្គ ជាបច្ច័យនៃតតិយមគ្គ ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃចតុត្ថមគ្គ ជាបច្ច័យនៃចតុត្ថមគ្គ ដោយឧបនិស្សយប្បច្ច័យ បឋមមគ្គ ជាបច្ច័យនៃទុតិយមគ្គ ដោយឧបនិស្សយប្បច្ច័យ ទុតិយមគ្គ ជាបច្ច័យនៃតតិយមគ្គ ដោយឧបនិស្សយប្បច្ច័យ តតិយមគ្គ ជាបច្ច័យនៃចតុត្ថមគ្គ ដោយឧបនិស្សយប្បច្ច័យ ពួកសេក្ខបុគ្គល អាស្រ័យមគ្គ ធ្វើសមាបត្តិដែលមិនទាន់កើត ឲ្យកើតឡើង ចូលកាន់សមាបត្តិ ដែលកើតឡើងហើយ ពិចារណាឃើញច្បាស់នូវពួកសង្ខារ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន មគ្គរបស់ពួកសេក្ខបុគ្គល ជាបច្ច័យនៃអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា និងឋានាឋានកោសល្ល ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៥ ] កុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ និងបកតូបនិស្ស័យ ។ អារម្មណូបនិស្ស័យ គឺ ( បុគ្គល ) ឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ធ្វើពួកកុសលដែលខ្លួនធ្លាប់សន្សំហើយ ក្នុងកាលមុនឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈ

កើតឡើង ព្រោះធ្វើកុសលនោះ ឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ( បុគ្គល ) ចេញចាកឈាន ធ្វើឈានឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើឈាននោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ។ ឯ បកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធា ហើយដំឡើងមានះ ប្រកាន់ទិដ្ឋិ សីល ... សុតៈ ... ចាគៈ ... អាស្រ័យបញ្ញា ហើយដំឡើងមានះ ប្រកាន់ទិដ្ឋិ សទ្ធា ... សីល សុតៈ ចាគៈ ... បញ្ញា ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៦ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ អារម្មណូបនិស្ស័យ គឺព្រះអរហន្តចេញចាកមគ្គ ធ្វើមគ្គឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ។ អនន្តរូបនិស្ស័យ គឺកុសល ជាបច្ច័យនៃវុដ្ឋានៈ មគ្គ ជាបច្ច័យនៃផល អនុលោមរបស់ពួកសេក្ខបុគ្គល ជាបច្ច័យនៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនកុសលរបស់បុគ្គល កាលចេញចាកនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ ឯបកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធា ហើយធ្វើខ្លួនឯងឲ្យក្តៅ ឲ្យក្តៅសព្វ ទទួលទុក្ខដែលមានការស្វែងរកជាមូល សីល ... សុតៈ ... ចាគៈ ... អាស្រ័យបញ្ញា ហើយធ្វើខ្លួនឯងឲ្យក្តៅ ឲ្យក្តៅសព្វ ទទួលទុក្ខ ដែលមានការស្វែងរកជាមូល សទ្ធា ... សីល សុតៈ ចាគៈ ... បញ្ញា ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ កុសលកម្ម ជាបច្ច័យនៃវិបាក

ដោយឧបនិស្សយប្បច្ច័យ ព្រះអរហន្តអាស្រ័យមគ្គ ធ្វើកិរិយាសមាបត្តិដែលមិនទាន់កើតឲ្យកើតឡើង ចូលកាន់កិរិយាសមាបត្តិ ដែលកើតឡើងហើយ ឃើញច្បាស់នូវពួកសង្ខារ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន មគ្គរបស់ព្រះអរហន្ត ជាបច្ច័យនៃអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា និងឋានាឋានកោសល្ល ដោយឧបនិស្សយប្បច្ច័យ មគ្គជាបច្ច័យនៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៧ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ អារម្មណូបនិស្ស័យ គឺ ( បុគ្គល ) ធ្វើរាគៈឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរីករាយ រាគៈកើតឡើង ព្រោះធ្វើរាគៈនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ( បុគ្គល ) ធ្វើទិដ្ឋិឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរីករាយ រាគៈកើតឡើង ព្រោះធ្វើទិដ្ឋិនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ។ អនន្តរូបនិស្ស័យ គឺពួកអកុសលក្ខន្ធមុនៗ ជាបច្ច័យនៃពួកអកុសលក្ខន្ធក្រោយៗ ដោយឧបនិស្សយប្បច្ច័យ ។ ឯបកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យរាគៈ ហើយសម្លាប់សត្វ យកទ្រព្យដែលគេមិនបានឲ្យ និយាយកុហក និយាយញុះញង់ និយាយពាក្យអាក្រក់ និយាយពាក្យរោយរាយ កាត់ទី-ត លបធក់ទ្រព្យគេ ប្លន់យកទ្រព្យក្នុងផ្ទះ ១ ឈរចាំដណ្តើមទ្រព្យគេក្បែរផ្លូវ លួចភរិយាបុគ្គលដទៃ សម្លាប់អ្នកស្រុក សម្លាប់អ្នកនិគម ផ្តាច់បង់ជីវិតមាតា ផ្តាច់បង់ជីវិតបិតា ផ្តាច់បង់ជីវិតព្រះអរហន្ត ធ្វើព្រះលោហិតនៃព្រះតថាគត

ឲ្យពុះពង់ដោយទោសចិត្ត បំបែកសង្ឃ អាស្រ័យទោសៈ ... អាស្រ័យមោហៈ អាស្រ័យមានះ អាស្រ័យទិដ្ឋិ ... អាស្រ័យសេចក្តីប្រាថ្នា ហើយសម្លាប់សត្វ ។បេ។ បំបែកសង្ឃ រាគៈ ... ទោសៈ មោហៈ មានះ ទិដ្ឋិ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៨ ] បាណាតិបាត ជាបច្ច័យនៃបាណាតិបាត ដោយឧបនិស្សយប្បច្ច័យ បាណាតិបាត ( ជាបច្ច័យ ) នៃអទិន្នាទាន ... កាមេសុមិច្ឆាចារ មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាបៈ អភិជ្ឈា ព្យាបាទ ... ជាបច្ច័យនៃមិច្ឆាទិដ្ឋិ ដោយឧបនិស្សយប្បច្ច័យ ។ អទិន្នាទាន ( ជាបច្ច័យ ) នៃអទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ ។ សេចក្តីបង្រួញ ។ ( ជាបច្ច័យ ) នៃមិច្ឆាទិដ្ឋិ និងបាណាតិបាត ដោយឧបនិស្សយប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈផងចុះ ។

[ ៥៤៩ ] កាមេសុមិច្ឆាចារ មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាបៈ អភិជ្ឈា ព្យាបាទ ។ មិច្ឆាទិដ្ឋិ ជាបច្ច័យនៃមិច្ឆាទិដ្ឋិ ដោយឧបនិស្សយប្បច្ច័យ មិច្ឆាទិដ្ឋិ ជាបច្ច័យនៃបាណាតិបាត ... ជាបច្ច័យនៃអទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាបៈ អភិជ្ឈា ព្យាបាទ ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៥០ ] មាតុឃាតកម្ម ជាបច្ច័យនៃមាតុឃាតកម្ម ដោយឧបនិស្សយប្បច្ច័យ បិតុឃាតកម្ម ( ជាបច្ច័យ ) នៃបិតុឃាតកម្ម ... នៃអរហន្តឃាត

កម្ម រុហិរុប្បាទកម្ម និងសង្ឃភេទកម្ម ... ជាបច្ច័យនៃនិយតមិច្ឆាទិដ្ឋិ ដោយឧបនិស្សយប្បច្ច័យ ។ បិតុឃាតកម្ម ( ជាបច្ច័យ ) នៃបិតុឃាតកម្ម ... នៃអរហន្តឃាតកម្ម រុហិរុប្បាទកម្ម សង្ឃភេទកម្ម និងនិយតមិច្ឆាទិដ្ឋិ ... ជាបច្ច័យនៃមាតុឃាតកម្ម ដោយឧបនិស្សយប្បច្ច័យ ។ អរហន្តឃាតកម្ម ... រុហិ-រុប្បាទកម្ម ... សង្ឃភេទកម្ម ... និយតមិច្ឆាទិដ្ឋិ ... ជាបច្ច័យនៃនិយតមិច្ឆាទិដ្ឋិ ដោយឧបនិស្សយប្បច្ច័យ និយតមិច្ឆាទិដ្ឋិ ជាបច្ច័យនៃមាតុឃាតកម្ម ដោយឧបនិស្សយប្បច្ច័យ នៃបិតុឃាតកម្ម ... អរហន្តឃាតកម្ម ... រុហិរុប្បាទកម្ម ... ជាបច្ច័យនៃសង្ឃភេទកម្ម ដោយឧបនិស្សយប្បច្ច័យ ។ បណ្ឌិតគប្បីធ្វើជាចក្កៈផងចុះ ។

[ ៥៥១ ] អកុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យរាគៈ ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើតឡើង ធ្វើវិបស្សនាឲ្យកើតឡើង ធ្វើមគ្គឲ្យកើតឡើង ធ្វើអភិញ្ញាឲ្យកើតឡើង ធ្វើសមាបត្តិឲ្យកើតឡើង ទោសៈ ... មោហៈ មានះ ទិដ្ឋិ ... អាស្រ័យសេចក្តីប្រាថ្នា ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើតឡើង ធ្វើវិបស្សនាឲ្យកើតឡើង ធ្វើមគ្គឲ្យកើតឡើង ធ្វើអភិញ្ញាឲ្យកើតឡើង ធ្វើសមាបត្តិឲ្យកើតឡើង ។ រាគៈ ... ទោសៈ មោហៈ មានះ ទិដ្ឋិ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃសទ្ធា សីល សុតៈ ចាគៈ និងបញ្ញា ដោយឧបនិស្សយប្បច្ច័យ ។ ( បុគ្គល ) សម្លាប់សត្វ ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើ

ឈានឲ្យកើតឡើង ធ្វើវិបស្សនាឲ្យកើតឡើង ធ្វើមគ្គឲ្យកើតឡើង ធ្វើអភិញ្ញាឲ្យកើតឡើង ធ្វើសមាបត្តិឲ្យកើតឡើង ដើម្បីប្រយោជន៍ដល់ការឃាត់នូវផលនៃកម្មនោះ ។ ( បុគ្គល ) យកទ្រព្យដែលគេមិនបានឲ្យ ... និយាយកុហក និយាយញុះញង់ និយាយពាក្យអាក្រក់ និយាយពាក្យរោយរាយ កាត់ទី-ត លបធក់ទ្រព្យគេ ប្លន់យកទ្រព្យគេក្នុងផ្ទះ ១ ឈរចាំដណ្តើមយកទ្រព្យគេក្បែរផ្លូវ លួចភរិយាអ្នកដទៃ សម្លាប់អ្នកស្រុក ... សម្លាប់អ្នកនិគម ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើតឡើង ធ្វើវិបស្សនាឲ្យកើតឡើង ធ្វើមគ្គឲ្យកើតឡើង ធ្វើអភិញ្ញាឲ្យកើតឡើង ធ្វើសមាបត្តិឲ្យកើតឡើង ដើម្បីប្រយោជន៍ដល់ការឃាត់នូវផលនៃកម្មនោះ ។ ( បុគ្គល ) ផ្តាច់បង់ជីវិតមាតា ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ដើម្បីប្រយោជន៍ដល់ការឃាត់នូវផលនៃកម្មនោះ ។ ( បុគ្គល ) ផ្តាច់បង់ជីវិតបិតា ... ផ្តាច់បង់ជីវិតព្រះអរហន្ត ... ធ្វើព្រះលោហិតរបស់ព្រះតថាគត ឲ្យពុរពងឡើងដោយទោសចិត្ត ... បំបែកសង្ឃ ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ដើម្បីប្រយោជន៍ដល់ការឃាត់នូវផលនៃកម្មនោះ ។

[ ៥៥២ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយឧបនិស្ស-យប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ អនន្តរូបនិស្ស័យ គឺអកុសល ជាបច្ច័យនៃវុដ្ឋានៈ ដោយឧបនិស្សយប្បច្ច័យ ។ ឯបកតូប-និស្ស័យ គឺ ( បុគ្គល ) អាស្រ័យរាគៈ ហើយធ្វើខ្លួនឯងឲ្យក្តៅ ឲ្យក្តៅសព្វ ទទួលទុក្ខ ដែលមានការស្វែងរកជាមូល ទោសៈ ... មោហៈ មានះ ទិដ្ឋិ ...

អាស្រ័យសេចក្ដីប្រាថ្នា ហើយធ្វើខ្លួនឯងឲ្យក្ដៅ ឲ្យក្ដៅសព្វ ទទួលទុក្ខដែលមានការស្វែងរកជាមូល ។ រាគៈ ... ទោសៈ មោហៈ មានះ ទិដ្ឋិ ... សេចក្ដីប្រាថ្នា ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ អកុសលកម្ម ជាបច្ច័យនៃវិបាក ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៥៣ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ អារម្មណូបនិស្ស័យ គឺព្រះអរហន្ត ធ្វើផលឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ធ្វើព្រះនិព្វានឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណាព្រះនិព្វាន ជាបច្ច័យនៃផល ដោយឧបនិស្សយប្បច្ច័យ ។ អនន្តរូបនិស្ស័យ គឺពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធមុនៗ ជាបច្ច័យនៃពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធក្រោយៗ ដោយឧបនិស្សយប្បច្ច័យ ភវង្គ ជាបច្ច័យនៃអាវជ្ជនា កិរិយា ជាបច្ច័យនៃវុដ្ឋានៈ អនុលោមរបស់ព្រះអរហន្ត ជាបច្ច័យនៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនកិរិយា របស់បុគ្គលកាលចេញចាកនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ ឯបកតូបនិស្ស័យ គឺកាយិកសុខ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ កាយិកទុក្ខ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ រដូវ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ភោជន ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្ស-

យប្បច្ច័យ សេនាសនៈ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ កាយិកសុខ ... កាយិកទុក្ខ ... រដូវ ភោជន ... សេនាសនៈ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ផលសមាបត្តិ ជាបច្ច័យនៃកាយិកសុខ ដោយឧបនិស្សយប្បច្ច័យ ព្រះអរហន្ត អាស្រ័យកាយិកសុខ ហើយធ្វើកិរិយាសមាបត្តិ ដែលមិនទាន់កើត ឲ្យកើតឡើង ចូលកាន់កិរិយាសមាបត្តិ ដែលកើតឡើងហើយ ឃើញច្បាស់នូវពួកសង្ខារ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន កាយិកទុក្ខ ... រដូវ ភោជន ... ព្រះអរហន្ត អាស្រ័យសេនាសនៈ ធ្វើកិរិយាសមាបត្តិ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ចូលកាន់កិរិយាសមាបត្តិ ដែលកើតឡើងហើយ ឃើញច្បាស់នូវពួកសង្ខារ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ។

[ ៥៥៤ ] អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ អារម្មណូបនិស្ស័យ គឺពួកសេក្ខបុគ្គល ធ្វើផលឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ធ្វើព្រះនិព្វានឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទាន និងមគ្គ ដោយឧបនិស្សយប្បច្ច័យ ។ អនន្តរូបនិស្ស័យ គឺអាវជ្ជនា ជាបច្ច័យនៃពួកកុសលក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ ។ ឯបកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យកាយិកសុខ ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើតឡើង ធ្វើវិបស្សនាឲ្យ

កើតឡើង ធ្វើមគ្គឲ្យកើតឡើង ធ្វើអភិញ្ញាឲ្យកើតឡើង ធ្វើសមាបត្តិឲ្យកើតឡើង កាយិកទុក្ខ ... រដូវ ... ភោជន ... ( បុគ្គល ) អាស្រ័យសេនាសនៈ ហើយឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើតឡើង ធ្វើវិបស្សនាឲ្យកើតឡើង ធ្វើមគ្គឲ្យកើតឡើង ធ្វើអភិញ្ញាឲ្យកើតឡើង ធ្វើសមាបត្តិឲ្យកើតឡើង កាយិកសុខ ... កាយិកទុក្ខ រដូវ ភោជន ... សេនាសនៈ ជាបច្ច័យនៃសទ្ធា សីល សុតៈ ចាគៈ និងបញ្ញា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៥៥ ] អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ អារម្មណូបនិស្ស័យ គឺ ( បុគ្គល ) ធ្វើចក្ខុឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើចក្ខុនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង សោតៈ ... ឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ ... វត្ថុ ធ្វើពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើខន្ធនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ។ អនន្តរូបនិស្ស័យ គឺអាវជ្ជនា ជាបច្ច័យនៃពួកអកុសលក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ ។ ឯបកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យកាយិកសុខ ហើយសម្លាប់សត្វ យកទ្រព្យដែលគេមិនបានឲ្យ និយាយកុហក និយាយញុះញង់ និយាយពាក្យអាក្រក់ និយាយពាក្យរោយរាយ កាត់ទី-ត លបចក់ទ្រព្យគេ ប្លន់យកទ្រព្យគេក្នុងផ្ទះមួយ ឈរចាំដណ្តើមទ្រព្យគេក្បែរផ្លូវ លួចភរិយាអ្នកដទៃ សម្លាប់អ្នកស្រុក សម្លាប់

អ្នកនិគម ផ្តាច់បង់ជីវិតមាតា ផ្តាច់បង់ជីវិតបិតា ផ្តាច់បង់ជីវិតព្រះអរហន្ត ធ្វើព្រះលោហិតនៃព្រះតថាគត ឲ្យពុរពង ដោយទោសចិត្ត បំបែកសង្ឃ កាយិកទុក្ខ ... រដូវ ... ភោជន ... អាស្រ័យសេនាសនៈ ហើយសម្លាប់សត្វ ។ សេចក្តីបន្ទ្រញ ។ បំបែកសង្ឃ ។ កាយិកសុខ ... កាយិកទុក្ខ រដូវ ភោជន ... សេនាសនៈ ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៥៦ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺព្រះអរហន្ត ឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន សោតៈ ... ឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ ... ឃើញច្បាស់នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ ។ រូបាយតនៈ ជាបច្ច័យនៃចក្ខុ-វិញ្ញាណ ដោយបុរេជាតប្បច្ច័យ សទ្ទាយតនៈ ( ជាបច្ច័យ ) នៃសោត-វិញ្ញាណ គន្ធាយតនៈ ( ជាបច្ច័យ ) នៃឃានវិញ្ញាណ រសាយតនៈ ( ជាបច្ច័យ ) នៃជិវ្ហាវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយបុរេជាតប្បច្ច័យ សោតាយតនៈ ( ជាបច្ច័យ ) នៃសោតវិញ្ញាណ ឃានាយតនៈ ( ជាបច្ច័យ ) នៃឃានវិញ្ញាណ ជិវ្ហាយតនៈ ( ជាបច្ច័យ ) នៃជិវ្ហាវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ

វត្ថុ ជាបច្ច័យនៃពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។

[ ៥៥៧ ] អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន សោតៈ ... ឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ ... ឃើញច្បាស់នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកកុសលក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។

[ ៥៥៨ ] អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) ត្រេកអរ រីករាយ នឹងចក្ខុ រាគៈកើតឡើង ព្រោះប្រារព្ធចក្ខុនោះ ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង សោតៈ ... ឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ ... ( បុគ្គល ) ត្រេកអរ រីករាយនឹងវត្ថុ រាគៈកើតឡើង ព្រោះប្រារព្ធវត្ថុនោះ ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកអកុសលក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។

[ ៥៥៩ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយបច្ឆាជាតប្បច្ច័យ

បានដល់ បច្ឆាជាត គឺពួកកុសលក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៥៦០ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកអកុសលក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៥៦១ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៥៦២ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអាសេវនប្បច្ច័យ គឺពួកកុសលក្ខន្ធមុនៗ ជាបច្ច័យនៃពួកកុសលក្ខន្ធក្រោយៗ ដោយអាសេវនប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈ ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ៥៦៣ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអាសេវនប្បច្ច័យ គឺពួកអកុសលក្ខន្ធមុនៗ ជាបច្ច័យនៃពួកអកុសលក្ខន្ធក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ៥៦៤ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអាសេវនប្បច្ច័យ គឺពួកកិរិយាព្យាកតក្ខន្ធមុនៗ ជាបច្ច័យនៃពួកកិរិយាព្យាកតក្ខន្ធក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ៥៦៥ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយកម្មប្បច្ច័យ គឺកុសលចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

[ ៥៦៦ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺកុសលចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺកុសលចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ និងពួកកដត្តារូប ដោយកម្មប្បច្ច័យ ។

[ ៥៦៧ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ និងអព្យាកតធម៌ ដោយកម្មប្បច្ច័យ គឺកុសលចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។

[ ៥៦៨ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយកម្មប្បច្ច័យ គឺអកុសលចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

[ ៥៦៩ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺអកុសលចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺអកុសលចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ និងពួកកដត្តារូប ដោយកម្មប្បច្ច័យ ។

[ ៥៧០ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ និងអព្យាកតធម៌ ដោយកម្មប្បច្ច័យ គឺអកុសលចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។

[ ៥៧១ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយកម្មប្បច្ច័យ

គឺវិបាកាព្យាកតចេតនា និងកិរិយាព្យាកតចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វិបាកាព្យាកតចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកកដត្តារូប ដោយកម្មប្បច្ច័យ ចេតនា ជាបច្ច័យនៃវត្ថុ ដោយកម្មប្បច្ច័យ ។

[ ៥៧២ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយវិបាកប្បច្ច័យ គឺវិបាកាព្យាកតក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វិបាកាព្យាកតក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកកដត្តារូប ដោយវិបាកប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកកដត្តារូប ដោយវិបាកប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកកដត្តារូប ដោយវិបាកប្បច្ច័យ ពួកខន្ធ ជាបច្ច័យនៃវត្ថុ ដោយវិបាកប្បច្ច័យ ។

[ ៥៧៣ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអាហារប្បច្ច័យ គឺពួកកុសលាហារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអាហារប្បច្ច័យ ។

[ ៥៧៤ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអាហារប្បច្ច័យ គឺពួកកុសលាហារ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអាហារប្បច្ច័យ ។

[ ៥៧៥ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ និងអព្យាកតធម៌ ដោយអាហារប្បច្ច័យ គឺពួកកុសលាហារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយអាហារប្បច្ច័យ ។

[ ៥៧៦ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអាហារប្បច្ច័យ គឺពួកអកុសលាហារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអាហារប្បច្ច័យ ។

[ ៥៧៧ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអាហារប្បច្ច័យ គឺពួកអកុសលាហារ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអាហារប្បច្ច័យ ។

[ ៥៧៨ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ និងអព្យាកតធម៌ ដោយអាហារប្បច្ច័យ គឺពួកអកុសលាហារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយអាហារប្បច្ច័យ ។

[ ៥៧៩ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអាហារប្បច្ច័យ គឺពួកវិបាកាព្យាកតាហារ និងពួកកិរិយាព្យាកតាហារ ជាបច្ច័យនៃពួកសម្ប-យុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកវិបាកាព្យាកតាហារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកកដត្តារូប ដោយអាហារប្បច្ច័យ កពឡីការាហារ ជាបច្ច័យនៃកាយនេះ ដោយអាហារប្បច្ច័យ ។

[ ៥៨០ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកកុសលិន្ទ្រិយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៥៨១ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកកុសលិន្ទ្រិយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៥៨២ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ និងអព្យាកតធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកកុសលិន្ទ្រិយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួក

ចិត្តសមុដ្ឋានរូប ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៥៨៣ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកអកុសលិន្ទ្រិយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៥៨៤ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកអកុសលិន្ទ្រិយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៥៨៥ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ និងអព្យាកតធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកអកុសលិន្ទ្រិយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៥៨៦ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកវិបាកាព្យាកតឥន្ទ្រិយ និងពួកកិរិយាព្យាកតឥន្ទ្រិយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកវិបាកាព្យាកតឥន្ទ្រិយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ សោតិន្ទ្រិយ ជាបច្ច័យនៃសោតវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ឃានិន្ទ្រិយ ជាបច្ច័យនៃឃានវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ជិវ្ហិន្ទ្រិយ ជាបច្ច័យនៃជិវ្ហាវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ កាយិន្ទ្រិយ ជាបច្ច័យនៃកាយ-វិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៥៨៧ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយឈានប្បច្ច័យ

គឺពួកអង្គឈាន ដែលជាកុសល ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឈានប្បច្ច័យ ។

[ ៥៨៨ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយឈានប្បច្ច័យ គឺពួកអង្គឈានដែលជាកុសល ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយឈានប្បច្ច័យ ។

[ ៥៨៩ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ និងអព្យាកតធម៌ដោយឈានប្បច្ច័យ គឺពួកអង្គឈានដែលជាកុសល ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយឈានប្បច្ច័យ ។

[ ៥៩០ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយឈានប្បច្ច័យ គឺពួកអង្គឈានដែលជាអកុសល ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឈានប្បច្ច័យ ។

[ ៥៩១ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយឈានប្បច្ច័យ គឺពួកអង្គឈានដែលជាអកុសល ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយឈានប្បច្ច័យ ។

[ ៥៩២ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ និងអព្យាកតធម៌ ដោយឈានប្បច្ច័យ គឺពួកអង្គឈានដែលជាអកុសល ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយឈានប្បច្ច័យ ។

[ ៥៩៣ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយឈានប្បច្ច័យ គឺពួកអង្គឈានដែលជាវិបាកាព្យាកតៈ និងកិរិយាព្យាកតៈ ជាបច្ច័យនៃពួក

សម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយឈានប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកអង្គឈានដែលជាវិបាកាព្យាកតៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកកដត្តារូប ដោយឈានប្បច្ច័យ ។

[ ៥៩៤ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយមគ្គប្បច្ច័យ គឺពួកអង្គមគ្គដែលជាកុសល ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយមគ្គប្បច្ច័យ ។

[ ៥៩៥ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយមគ្គប្បច្ច័យ គឺពួកមគ្គដែលជាកុសល ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយមគ្គប្បច្ច័យ ពួកអង្គមគ្គដែលជាកុសល ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយមគ្គប្បច្ច័យ ។

[ ៥៩៦ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ និងអព្យាកតធម៌ ដោយមគ្គប្បច្ច័យ គឺពួកអង្គមគ្គដែលជាកុសល ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយមគ្គប្បច្ច័យ ។

[ ៥៩៧ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយមគ្គប្បច្ច័យ គឺពួកអង្គមគ្គដែលជាកុសល ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយមគ្គប្បច្ច័យ ។

[ ៥៩៨ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយមគ្គប្បច្ច័យ គឺពួកអង្គមគ្គដែលជាអកុសល ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយមគ្គប្បច្ច័យ ។

[ ៥៩៩ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ និងអព្យាកតធម៌ ដោយមគ្គប្បច្ច័យ គឺពួកអង្គមគ្គដែលជាអកុសល ជាបច្ច័យនៃពួកសម្ប-

យុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយមគ្គប្បច្ច័យ ។

[ ៦០០ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយមគ្គប្បច្ច័យ គឺពួកអង្គមគ្គដែលជាវិបាកាព្យាកតៈ និងកិរិយាព្យាកតៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយមគ្គប្បច្ច័យ ក្នុងខណៈនៃបដិ-សន្ធិ ពួកអង្គមគ្គដែលជាវិបាកាព្យាកតៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកកដត្តារូប ដោយមគ្គប្បច្ច័យ ។

[ ៦០១ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយសម្បយុត្តប្បច្ច័យ គឺកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយសម្បយុត្តប្បច្ច័យ ។

[ ៦០២ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយសម្បយុត្តប្បច្ច័យ គឺអកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយសម្បយុត្តប្បច្ច័យ ។

[ ៦០៣ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយសម្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលជាវិបាកាព្យាកតៈ និងកិរិយាព្យាកតៈ ជាបច្ច័យនៃខន្ធ ៣ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វិបាកាព្យាកតក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយសម្ប-

យុត្តប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយសម្បយុត្តប្បច្ច័យ ។

[ ៦០៤ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកកុសលក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកកុសលក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៦០៥ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកអកុសលក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកអកុសលក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៦០៦ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកវិបាកាព្យាកតក្ខន្ធ ជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ពួកខន្ធ ជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ សោតាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ ឃានាយតនៈ ជាបច្ច័យ

នៃឃានវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ ជិវ្ហាយតនៈ ជាបច្ច័យនៃជិវ្ហាវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៦០៧ ] អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃពួកកុសលក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។

[ ៦០៨ ] អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកអកុសលក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។

[ ៦០៩ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអត្ថិប្បច្ច័យ គឺ កុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។

[ ៦១០ ] កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកកុសលក្ខន្ធ ជាបច្ច័យនៃចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកកុសលក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ៦១១ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ និងអព្យាកតធម៌ ដោយ

អត្ថិប្បច្ច័យ គឺកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។

[ ៦១២ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអត្ថិប្បច្ច័យ គឺអកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។

[ ៦១៣ ] អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកអកុសលក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកអកុសលក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ៦១៤ ] អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ និងអព្យាកតធម៌ ដោយអត្ថិប្បច្ច័យ គឺអកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។

[ ៦១៥ ] អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺវិបាកាព្យាកតក្ខន្ធ និងកិរិយាព្យាកតក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកចិត្ត-

សមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកចិត្ត-សមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកចិត្ត-សមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វិបាកាព្យាកតក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ពួកខន្ធ ជាបច្ច័យនៃវត្ថុ ដោយអត្ថិប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកខន្ធ ដោយអត្ថិប្បច្ច័យ មហាភូត ១ ជាបច្ច័យនៃមហាភូត ៣ ដោយអត្ថិប្បច្ច័យ មហាភូត ៣ ជាបច្ច័យនៃមហាភូត ១ ដោយអត្ថិប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយអត្ថិប្បច្ច័យ ពួកមហាភូត ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ពួកកដត្តារូប និងពួកឧបាទារូប ដោយអត្ថិប្បច្ច័យ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ១ របស់ពួកអសញ្ញសត្វ ជាបច្ច័យនៃមហាភូត ៣ ដោយអត្ថិប្បច្ច័យ មហាភូត ៣ ជាបច្ច័យនៃមហាភូត ១ ដោយអត្ថិប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយអត្ថិប្បច្ច័យ ពួកមហាភូត ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ពួកកដត្តារូប និងពួកឧបាទារូប ដោយអត្ថិប្បច្ច័យ ។ បុរេជាត គឺព្រះអរហន្ត ឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន សោតៈ ... ឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ ... ឃើញច្បាស់នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វ-សោតធាតុ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយអត្ថិប្បច្ច័យ សទ្ទា-

យតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ ចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយអត្ថិប្បច្ច័យ សោតាយតនៈ ( ជាបច្ច័យ ) នៃសោតវិញ្ញាណ ឃានាយតនៈ ( ជាបច្ច័យ ) នៃឃានវិញ្ញាណ ជិវ្ហាយតនៈ ( ជាបច្ច័យ ) នៃជិវ្ហាវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកវិបាកាព្យាកតក្ខន្ធ និងពួកកិរិយាព្យាកតក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡីការាហារ ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៦១៦ ] អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន សោតៈ ... ឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ ... ឃើញច្បាស់នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ ។ វត្ថុ ជាបច្ច័យនៃពួកកុសលក្ខន្ធ ដោយអត្ថិប្បច្ច័យ ។

[ ៦១៧ ] អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺ ( បុគ្គល ) ត្រេកអរ រីករាយនឹងចក្ខុ រាគៈកើតឡើង ព្រោះប្រារព្ធចក្ខុនោះ ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង សោតៈ ... ឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង

ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ ... ត្រេកអរ រីករាយនឹងវត្ថុ រាគៈកើតឡើង ព្រោះប្រារព្ធវត្ថុនោះ ។បេ។ ទោមនស្សកើតឡើង ។ វត្ថុ ជាបច្ច័យនៃពួកអកុសលក្ខន្ធ ដោយអត្ថិប្បច្ច័យ ។

[ ៦១៨ ] កុសលធម៌ក្តី អព្យាកតធម៌ក្តី ជាបច្ច័យនៃកុសលធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺកុសលក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ។បេ។ ខន្ធ ២ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។

[ ៦១៩ ] កុសលធម៌ក្តី អព្យាកតធម៌ក្តី ជាបច្ច័យនៃអព្យាកតធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺពួកកុសលក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកកុសលក្ខន្ធក្តី កពឡីការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកកុសលក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៦២០ ] អកុសលធម៌ក្តី អព្យាកតធម៌ក្តី ជាបច្ច័យនៃអកុសលធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺអកុសលក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ៣ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ១ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។

[ ៦២១ ] អកុសលធម៌ក្តី អព្យាកតធម៌ក្តី ជាបច្ច័យនៃអព្យាកតធម៌

ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺពួកអកុសលក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកអកុសលក្ខន្ធក្តី កពឡីការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកអកុសលក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៦២២ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយនត្ថិប្បច្ច័យ គឺពួកកុសលក្ខន្ធមុនៗ ជាបច្ច័យនៃពួកកុសលក្ខន្ធក្រោយៗ ដោយនត្ថិប្បច្ច័យ ។ សេចក្តីបង្រួញ ។ អនន្តរប្បច្ច័យ យ៉ាងណា ( នត្ថិប្បច្ច័យ ) បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះដែរ ។

[ ៦២៣ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយវិគតប្បច្ច័យ គឺពួកកុសលក្ខន្ធមុនៗ ជាបច្ច័យនៃពួកកុសលក្ខន្ធក្រោយៗ ដោយវិគតប្បច្ច័យ ។ សេចក្តីបង្រួញ ។ អនន្តរប្បច្ច័យ យ៉ាងណា ( វិគតប្បច្ច័យ ) បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះដែរ ។

[ ៦២៤ ] កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអវិគតប្បច្ច័យ គឺកុសលក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយអវិគតប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយអវិគតប្បច្ច័យ ។ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអវិគតប្បច្ច័យ ។ សេចក្តីបង្រួញ ។ អត្ថិប្បច្ច័យយ៉ាងណា ( អវិគតប្បច្ច័យ ) បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះដែរ ។

**ការចែកបញ្ហាវារៈ ( តែប៉ុណ្ណោះ ) ចប់**

# អដ្ឋកថា

## បញ្ហាវារវិភង្គ

[ ៤៨៤-៤៨៦ ] ក្នុងវារៈ ៦ នេះ បណ្ឌិតគប្បីជ្រាបបកិណ្ណកៈដូចតទៅ បច្ច័យឯណានីមួយ មិនតាំងនៅដោយភាពជាអនុលោម តាំងនៅដោយភាពជាបច្ចនិកៈប៉ុណ្ណោះក៏មាន បច្ច័យខ្លះ មិនតាំងនៅដោយភាពជាបច្ចនិកៈ តាំងនៅដោយភាពជាអនុលោមប៉ុណ្ណោះក៏មាន បច្ច័យខ្លះ តាំងនៅដោយភាពជាអនុលោមផង ជាបច្ចនិកៈផង មិនពិតប្រាកដទាំង ២ ផ្នែក ។ បណ្ដាបកិណ្ណកៈទាំងនោះ បញ្ហាទី ១ គប្បីជ្រាបដោយអំណាចបច្ឆាជាតប្បច្ច័យ បញ្ហាទី ២ គប្បីជ្រាបដោយអំណាចចតុក្កប្បដ្ឋាន បញ្ហាទី ៣ គប្បីជ្រាបដោយអំណាចបច្ច័យដ៏សេសដែលសមគ្នា ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបញ្ហាវារៈដូចតទៅ

បទថា **កុសលោ ធម្មោ កុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ** ដូច្នេះជាដើម ព្រះមានព្រះភាគ ត្រាស់ដើម្បីសម្ដែងវិសជ្ជនាបុច្ឆាដែលគប្បីលើកឡើងក្នុងកុសលត្តិកៈ ដោយអំណាចបច្ច័យដែលបាន មានពាក្យថា **សិយា កុសលោ ធម្មោ កុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ** ដូច្នេះជាដើម ជាធម្មតា កុសលធម៌នេះ កាលកើតឡើងឯង កើតឡើងព្រោះបច្ច័យ ២២ ដ៏សេស វៀរបច្ឆាជាតប្បច្ច័យ និងវិបាកប្បច្ច័យ ។ កុសលធម៌ កាលជាបច្ច័យដល់កុសល ក៏ជាបច្ច័យដោយអំណាចបច្ច័យ ២០ ដ៏សេស វៀរបុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ វិបាកប្បច្ច័យ និងវិប្បយុត្តប្បច្ច័យ ព្រោះហេតុនោះ កុសលធម៌ ជាបច្ច័យដល់កុសលធម៌ ដោយ

បច្ច័យឯណា ដើម្បីសម្ដែងបច្ច័យទាំងនោះតាមលំដាប់ ទើបព្រះមានព្រះភាគ ផ្ដើមពាក្យថា **ហេតុបច្ចយេន** ជាដើម ។ គប្បីជ្រាបអធិប្បាយ ក្នុងពាក្យនោះដូចតទៅ ទេសនាឯណា ដែលព្រះមានព្រះភាគមិនត្រាស់ថា **ហេតុ-សម្បយុត្តកានំ ធម្មានំ** ហេតុជាបច្ច័យដល់ធម៌ទាំងឡាយ ដែលសម្បយុត្តដូចក្នុងបច្ចយវិភង្គវារៈឡើយ តែទ្រង់ត្រាស់ថា **ហេតូ សម្បយុត្តកានំ ខន្ធានំ** ហេតុជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដូច្នេះ ក្នុងការដែលព្រះសម្ពុទ្ធត្រាស់ទេសនាយ៉ាងនោះ មានប្រយោជន៍ក្នុងការដែលទ្រង់ធ្វើយ៉ាងនោះ ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ថា **ធម្មានំ** ដូច្នេះ ដើម្បីសម្ដែងអត្ថថា ទទេក្នុងបច្ចយវិភង្គវារៈនោះ ធម៌ទាំងឡាយ កាលកើតអំពីបច្ច័យ រមែងកើតដោយភាពជាគំនរធម៌ មិនកើតតែឯងឡើយ ព្រោះហេតុនោះ ដើម្បីសម្ដែងអត្ថថា ជាគំនរក្នុងបញ្ហាវារវិភង្គនេះ ទើបព្រះមានព្រះភាគត្រាស់ថា **ខន្ធានំ** ។ មួយប្រការទៀត ការសម្ដែងបច្ចយុប្បន្ន ដែលព្រះមានព្រះភាគទ្រង់លើកឡើងហើយ ដោយអំណាចនៃខន្ធក្នុងបដិច្ចវារៈជាដើម ព្រោះហេតុនោះ ទើបទ្រង់លើកឡើងសម្ដែងក្នុងបញ្ហាវារវិភង្គនេះទៀត ដោយលំដាប់នោះឯង ។ សួរថា ព្រោះហេតុអ្វី ទើបក្នុងវារៈទាំងនេះ ទ្រង់លើកឡើងដើម្បីសម្ដែងយ៉ាងនោះ ឆ្លើយថា ដើម្បីសម្ដែងការចែកដោយមិនលាយឡំគ្នា ។ ពិតហើយ កាលទ្រង់ត្រាស់ដោយន័យជាដើមថា ធម៌ដ៏សេស កើតឡើង ព្រោះអាស្រ័យធម៌ឯណានីមួយ ដូច្នេះ អ្នកសិក្សា ក៏មិនអាចជ្រាបបច្ច័យ និងបច្ច-យុប្បន្ន ដោយមិនលាយឡំគ្នាបានថា ធម៌នោះ កើតឡើង ព្រោះអាស្រ័យ

ធម៌ឈ្មោះនោះ កាលបើយ៉ាងនោះ ឧទ្ទេស និងនិទ្ទេស ក៏មិនមានសេចក្តីប្លែកគ្នា ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបថា ព្រះសម្មាសម្ពុទ្ធទ្រង់លើកឡើងនូវទេសនាយ៉ាងនេះ ក៏ដើម្បីសម្តែងការចែកដោយមិនលាយឡំគ្នា ។

បទថា **ចិត្តសមុដ្ឋានានំ** នេះ ត្រាស់ដើម្បីសម្តែងកុសលថា ជាបច្ច័យដល់អព្យាកតៈ ដោយហេតុប្បច្ច័យ ។ តែក្នុងបច្ចយវិភង្គ ព្រះមានព្រះភាគ ទ្រង់មិនធ្វើការចែកដោយអំណាចកុសលជាដើម មិនត្រាស់ថា មានចិត្តជាសមុដ្ឋាន តែត្រាស់ថា មានហេតុនោះជាសមុដ្ឋាន ដើម្បីសម្តែងរូបដែលកើតឡើងដោយអំណាចនៃហេតុទាំងអស់ដោយសាមញ្ញ ព្រោះហេតុនោះ រូបដែលមានអព្យាកតហេតុជាសមុដ្ឋាន ក្នុងបច្ចយវិភង្គនោះ ក៏សង្គ្រោះដល់កដត្តារូប ក្នុងបដិសន្ធិផងដែរ ។ ក្នុងវិសជ្ជនាដ៏សេស ដែលដូចគ្នា អ្នកសិក្សាគប្បីជ្រាបអត្ថ ដោយទំនងនេះឯង ។

[ ៤៨៧-៤៩៥ ] បទថា **ទានំ ទត្វា** គឺលះបង់ទ្រព្យដែលគួរឲ្យម៉្យាងទៀត បានដល់ ចេតនាដែលជាហេតុឲ្យ ។ បទថា **ទត្វា** គឺជម្រះចេតនាឲ្យផូរផង់ គឺឲ្យបរិសុទ្ធ ។

បទថា **សីលំ សមាទិយិត្វា** គឺសមាទាននិច្ចសីល ដោយអំណាចសីល មានអង្គ ៥ ឬអង្គ ១០ ជាដើម ។ សមាទានវិរតិ ទ្រង់សម្តែងដោយពាក្យនេះ ឯសម្បត្តវិរតិ និងសមុច្ឆេទវិរតិ ទ្រង់មិនបានត្រាស់ ព្រោះមិនប្រាកដថា ជាសីលក្នុងលោក ។ ទោះបីមិនត្រាស់ក៏ពិត តែក៏ជាអារម្មណប្បច្ច័យបានដូចគ្នា បណ្តាវិរតិទាំង ២ នោះ សមុច្ឆេទវិរតិ ជាអារម្មណ៍

នៃកុសលរបស់ព្រះសេក្ខៈតែមួយពួក មិនជាអារម្មណ៍ដល់បុគ្គលដទៃឡើយ ។

បទថា **ឧបោសថកម្មំ កត្វា** គឺធ្វើឧបោសថកិរិយាដែលមានអង្គ ៨ ក្នុងថ្ងៃឧបោសថ ដែលលោកពោល ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) យ៉ាងនេះថា មិនសម្លាប់សត្វ មិនកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ ដូច្នេះជាដើម ។

បទថា **តំ បច្ចវេក្ខតិ** សេចក្តីថា ព្រះសេក្ខៈក្តី បុថុជ្ជនក្តី រមែងពិចារណាកុសលនោះ ម្យ៉ាងទៀត សូម្បីព្រះអរហន្ត ក៏ពិចារណាផងដែរ ។ ពិតហើយ សម្រាប់ព្រះអរហន្ត កុសលដែលធ្វើក្នុងកាលមុន ក៏ឈ្មោះថាជាកុសលដូចគ្នា លោករមែងពិចារណាដោយចិត្តណា ចិត្តនោះ ឈ្មោះថាកិរិយាចិត្ត ព្រោះហេតុនោះ ទើបកិរិយាចិត្តនោះ មិនបានក្នុងអធិការនេះថា **ឯតំ កុសលោ ធម្មោ កុសលស្ស ធម្មស្ស** ដូច្នេះ ។ ពិតហើយ កម្មដែលធ្វើជិតៗ គ្នា ទ្រង់ត្រាស់ថា ឲ្យហើយ សមាទានហើយ ធ្វើហើយ ក្នុងពាក្យថា **បុញ្ញេ សុចិណ្ណានិ** ដូច្នេះ ។ កម្មទាំងនេះ គប្បីជ្រាបថា មិនបានធ្វើជិតៗ គ្នា ។ ម្យ៉ាងទៀត ពាក្យនេះ ត្រាស់ដើម្បីសម្តែងកាមាវចរកុសលដ៏សេស ដោយបុញ្ញកិរិយា មានទានជាដើម ។

បទថា **ឈានា វុដ្ឋហិត្វា** ប្រែថា ចេញហើយអំពីឈាន ។ ម្យ៉ាងទៀត ពាក្យបាលីយ៉ាងនេះក៏មាន ។ បទថា **សេក្ខា គោត្រភុំ** សំដៅដល់ព្រះសោតាបន្ន ។ ពិតហើយ ព្រះសោតាបន្ននោះ រមែងពិចារណាគោត្រភូ ឯបទថា **វោទានំ** នេះ ត្រាស់សំដៅដល់ព្រះសកទាគាមី និងព្រះអនាគាមី

ព្រោះថា ចិត្តរបស់លោកទាំងនោះ ជាធម្មជាតផូរផង់ហើយ ។ បទថា **សេក្ខា** គឺព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី ។

បទថា **មគ្គា វុដ្ឋហិត្វា** គឺចេញចាកមគ្គដែលខ្លួនបានហើយដោយអំណាចការឈោនកន្លងកវត្តនៃមគ្គ និងផល ឯការចេញចាកមគ្គស្មុទ្ធៗ នោះហើយពិចារណា មិនមាន ។

ក្នុងបទនេះថា **កុសលំ អនិច្ចតោ** អ្នកសិក្សាគប្បីជ្រាបថា កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលចូលដល់វិបស្សនានោះឯង តែកុសលថ្នាក់វិបស្សនា ជាកាមាវចរតែម្យ៉ាង ។ ព្រះមានព្រះភាគ ទ្រង់សម្តែងរូបាវចរកុសល ដោយពាក្យនេះថា **ចេតោបរិយញ្ញាណេន** ។ សម្តែងចំពោះអរូបាវចរកុសលដែលកំពុងកើតឡើង ដោយអំណាចជាអារម្មណ៍នៃអរូបាវចរកុសល ដោយបទថា **អាកាសានញ្ចាយតនំ** ជាដើម ។ ទ្រង់សម្តែងដោយអំណាចធម៌ប៉ុណ្ណោះ មិនទាក់ទងដល់បុគ្គល ដោយបទថា **កុសលាខន្ធា ឥទ្ធិវិធញ្ញាណស្ស** ជាដើម ព្រោះហេតុនោះឯង ចេតោបរិយញ្ញាណទោះបីលោកកាន់យកខាងដើមហើយ ក៏គង់ត្រាស់ក្នុងអធិការនេះទៀត ។

បទថា **អស្សាទេតិ** គឺសោយ និងត្រេកអរដោយចិត្តដែលសម្បយុត្តដោយលោភៈដែលសហគតៈដោយសោមនស្ស ។ បទថា **អភិនន្ទតិ** បានដល់ ត្រេកអរ គឺជាអ្នកសប្បាយរីករាយ ដោយអំណាចតណ្ហា មានបីតិ ឬត្រេកអរក្រៃលែង ដោយអំណាចការត្រេកអរក្នុងធម៌ ដែលខ្លួនឃើញហើយ ។ បទថា **រាគោ ឧប្បជ្ជតិ** សេចក្តីថា រាគៈរមែងកើតឡើង ដល់បុគ្គលដែល

ត្រេកអរ ។ ពាក្យនេះ ត្រាស់សំដៅដល់ចិត្តដែលសហគតៈដោយលោភៈ ទាំង ៨ ដួង ។ បទថា **ទិដ្ឋិ ឧប្បជ្ជតិ** សេចក្តីថា ទិដ្ឋិដែលសម្បយុត្តដោយចិត្ត ៤ ដួង ដោយអំណាចទិដ្ឋិ ថាខ្លួនមានក្នុងខ្លួនជាដើម រមែងកើតដល់បុគ្គលដែលត្រេកអរក្រៃលែង ។ ក្នុងករណីនេះ វិចិកិច្ឆា រមែងកើតដល់បុគ្គលដែលមិនមានការសម្រេចចិត្ត គឺសង្ស័យ ។ ឧទ្ធច្ចៈ រមែងកើតដល់បុគ្គលដែលមានចិត្តរាយមាយ ទោសៈ រមែងកើតដល់បុគ្គលដែលក្តៅក្រហាយថា កម្មល្អ អាត្មាអញមិនបានធ្វើហ្ន៎ជាដើម ។ បទថា **តំ អារព្ភ** សេចក្តីថា ធ្វើកម្មទាំងនោះ ដែលខ្លួនសន្សំហើយក្នុងកាលមុនឲ្យជាអារម្មណ៍ ។ ពិតហើយ សត្វនេះ លោកផ្លាស់ពហុវចនៈ ជាឯកវចនៈ ។ ម្យ៉ាងទៀត ពាក្យនេះ ជាឯកវចនៈ ដោយអំណាចជាតិ ( កំណើតរបស់សត្វ ) ។

បទថា **អរហា មគ្គា វុដ្ឋហិត្វា** សេចក្តីថា ចេញហើយដោយអំណាចការឈានកន្លងភវង្គ ក្នុងលំដាប់នៃផល ក្នុងមគ្គវិថី បច្ចវេក្ខណចិត្តរបស់ព្រះអរហន្តនោះ ជាកិរិយាព្យាកតៈ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអារម្មណប្បច្ច័យនៃកិរិយាព្យាកតៈយ៉ាងនេះហើយ ដើម្បីទ្រង់សម្តែងអារម្មណប្បច្ច័យនៃវិបាកាព្យាកតៈទៀត ទើបត្រាស់បទថា **សេក្ខា វា** ជាដើម ។ បទថា **កុសលេ និរុទ្ធេ** គឺកាលវិបស្សនាជវនវិថីដាច់ទៅ ។ បទថា **វិបាកោ** បានដល់ កាមាវចរវិបាក ។ បទថា **តទារម្មណតា** គឺដោយជាតទារម្មណៈ អធិប្បាយថា ចិត្តនោះ ( តទារម្មណចិត្ត ) ធ្វើកុសលដែលឃើញច្បាស់ហើយ ដែលជាអារម្មណ៍នៃកុសលជវន ឲ្យជាអារម្មណ៍កើតឡើង ។ កើត

ដោយអំណាចតទារម្មណៈតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន គង់កើតដោយអំណាច បដិសន្ធិ ភវង្គ និងចុតិផងដែរ ។ ពិតហើយ វិបាក រមែងមានកុសលជាអារម្មណ៍បានដូចគ្នា សម្រាប់បុគ្គលដែលធ្វើកម្មឲ្យជាអារម្មណ៍ ហើយបដិ-សន្ធិ ។ វិបាកនោះ មិនបានសម្តែងក្នុងទីនេះ ព្រោះយល់បានលំបាក ។

បទថា **កុសលំ អស្សាទេតិ** ជាដើម ត្រាស់ដើម្បីសម្តែងវិបាកដែលមានកុសលជាអារម្មណ៍ ក្នុងទីបំផុតនៃអកុសលជវន ។

បទថា **វិញ្ញាណញ្ចាយតនវិបាកស្ស** ទោះបីជាធម៌យល់បានលំបាកទ្រង់ក៏ត្រាស់ដោយអំណាចវិបាកដែលមានព្រោះមហគ្គតវិបាក មិនកើតដោយភាពជាតទារម្មណៈ ។ បទថា **កិរិយស្ស** គឺអាកាសានញ្ចាយតនកុសលជាបច្ច័យដោយអារម្មណប្បច្ច័យ ដល់កិរិយាចិត្តរបស់បុគ្គលដែលសម្រេចអរហត្ត ហើយចូលសមាបត្តិដោយបដិលោម ឬដោយមានឈាន ១ ជាចន្លោះ ក្នុងអារម្មណ៍ដែលជាអាកាសានញ្ចាយតនៈដែលមិនធ្លាប់ចូល ។ បទថា **ចេតោបរិយញ្ញាណស្ស** ជាដើម គប្បីភ្ជាប់ជាមួយអាវជ្ជនៈខាងមុខ ក្នុងសេចក្តីនេះមានអធិប្បាយដូច្នេះថា ខន្ធទាំងឡាយដែលជាកុសល ជាបច្ច័យដល់អាវជ្ជនៈនៃចិត្តទាំងនោះ ដោយអារម្មណប្បច្ច័យ ។

បទថា **រាគំ** គឺរាគៈរបស់ខ្លួន ឬរបស់អ្នកដទៃ តែក្នុងអធិការនេះការអធិប្បាយប្រាកដហើយ ដោយអំណាចនៃរាគៈរបស់ខ្លួន ។ បទថា **អស្សាទេតិ** ជាដើម មានអត្ថដូចបានពោលហើយ តែក្នុងធម៌ ៣ មានវិចិកិច្ឆាជាដើម មិនត្រាស់ថា **អស្សាទេតិ** ដែលប្រែថា ត្រេកអរ ព្រោះមិន

*មានភាវៈដែលគួរត្រេកអរ ទិដ្ឋិរមែងកើតឡើងក្នុងឋានៈនេះ ។ ទិដ្ឋិ ព្រះមានព្រះភាគមិនត្រាស់មុនតាមលំដាប់ដែលមកដល់ ព្រោះបទថា* **អស្សាទេតិ** *ជាក់ទៅ ទិដ្ឋិនោះ ដែលព្រះមានព្រះភាគត្រាស់ធម៌នោះៗ បណ្ដាធម៌ មានវិចិកិច្ឆាជាដើម ដែលជាសភាគគ្នា ហើយត្រាស់ក្នុងលំដាប់នៃធម៌នោះៗ ។ បណ្ដាធម៌ មានរាគៈជាដើមនេះ គប្បីជ្រាបការកើតឡើងនៃទោមនស្ស ដោយអំណាចការអត់ធន់មិនបានថា បាបធម៌ទាំងនេះ កើតឡើងធ្វើអ្វី ឬដោយអំណាចវិប្បដិសារៈថា អាត្មាអញ ធ្វើកម្មអាក្រក់ អាត្មាអញ ធ្វើកម្មគ្រោតគ្រាតជាដើម ។*

*បទថា* **ចក្ខុំ អនិច្ចតោ** *សេចក្ដីថា រូប ១១ គឺឱឡារិកាយតនៈ ១០ និងវត្ថុរូប ១ លោកកាន់យកហើយ ព្រោះប្រាកដតាមលំដាប់វិបស្សនា រូបាយតនៈជាដើម លោកក៏កាន់យកទៀត ព្រោះជាអារម្មណ៍នៃចក្ខុវិញ្ញាណជាដើម ព្រោះទេសនានេះ ត្រាស់ដោយអំណាចនៃវិញ្ញាណ មិនបានត្រាស់ដោយអំណាចធាតុ ព្រោះហេតុនោះ ទើបមិនកាន់យកមនោធាតុដែរ ។ គប្បីជ្រាបអារម្មណ៍ដែលកាន់យកហើយ និងមិនបានកាន់យកក្នុងទីទាំងពួងយ៉ាងនេះ ។ បទថា* **ផលំ បច្ចវេក្ខន្តិ និព្វានំ បច្ចវេក្ខន្តិ** *ទ្រង់ត្រាស់ដើម្បីសម្ដែងអារម្មណ៍នៃកុសលដែលជាធម្មជាតពិចារណា ។*

*[ ៤៩៦-៥០៤ ] ក្នុងអារម្មណាធិបតិនិទ្ទេស ទ្រង់សម្ដែងកុសលដែលទាក់ទងក្នុងភូមិ ៤ ដោយអំណាចព្រះសេក្ខៈ និងបុថុជ្ជន ។ ក្នុងសហជាតាធិបតិនិទ្ទេសក៏ដូចគ្នា ។ ព្រះអរហន្ត រមែងមិនមានការធ្វើឲ្យធ្ងន់ក្នុង*

លោកិយកុសលទាំងឡាយ ព្រោះបានសម្រេចធម៌ជាន់ខ្ពស់ហើយ ព្រោះហេតុនោះ ទើបទ្រង់សម្ដែងចំពោះអរហត្តមគ្គប៉ុណ្ណោះ ។

[ ៥០៥-៥១១ ] ក្នុងអនន្តរប្បច្ច័យ បទថា **បុរិមា បុរិមា** ព្រះមានព្រះភាគត្រាស់រួមយកកុសល ដែលកើតក្នុងភូមិតែមួយ និងភូមិផ្សេងគ្នា ។ បទថា **អនុលោមំ គោត្រភុស្ស អនុលោមំ វោទានស្ស** ទ្រង់ត្រាស់ដោយអំណាចអារម្មណ៍ដែលផ្សេងគ្នា ។ បទថា **គោត្រភូ មគ្គស្ស វោទានំ មគ្គស្ស** ទ្រង់ត្រាស់ដោយអំណាចភូមិដែលផ្សេងគ្នា ។ បទថា **កុសល** ក្នុងបទថា **កុសលំ វុដ្ឋានស្ស** នេះ បានដល់ កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **វុដ្ឋានំ** គឺវិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ព្រះយោគាវចរទាំងឡាយ រមែងចេញចាកកុសលជវនវីថិដោយវិបាកទាំងនោះ ព្រោះហេតុនោះ ទើបវិបាកនោះ លោកហៅថា **វុដ្ឋាន** វុដ្ឋាននោះ មាន ២ យ៉ាង គឺ តទារម្មណៈ ១ ភវង្គ ១ ។ បណ្ដាវុដ្ឋានទាំងនោះ ទាំង ២ យ៉ាង ជាវុដ្ឋានរបស់កាមាវចរកុសលភវង្គតែម្យ៉ាង ជាវុដ្ឋាននៃមហគ្គតកុសល ។ បទថា **មគ្គោ ផលស្ស** នេះ ទ្រង់ត្រាស់បំបែក ព្រោះលោកុត្តរវិបាកជាសមុដ្ឋានមិនបាន ព្រោះទាក់ទងក្នុងជវនវីថិ ។ បទថា **អនុលោមំ សេក្ខាយ** សេចក្ដីថា កុសល រមែងមិនជាអនន្តរប្បច្ច័យដល់សេក្ខធម៌ ព្រោះហេតុនោះ ទើបទ្រង់ធ្វើការបែក ។ បទថា **ផលសមាបត្តិយា** គឺផលសមាបត្តិរបស់សោតាបត្តិផល សកទាគាមិផល អនាគាមិផល ។

បទថា **ផលសមាបត្តិយា** គឺអនាគាមិផលសមាបត្តិ ។ ក្នុងអកុ-

សលចិត្ត រមែងបានវុដ្ឋានវិបាកទាំង ២ ។ ក្នុងបទថា **វិបាកាព្យាកតា កិរិយាព្យាកតា** នេះ អ្នកសិក្សាគប្បីជ្រាបវិបាកាព្យាកតៈចំពោះដល់វិបា-កាព្យាកតៈផងគ្នាប៉ុណ្ណោះ និងកិរិយាព្យាកតៈចំពោះដល់កិរិយាព្យាកតៈផងគ្នាប៉ុណ្ណោះដូចគ្នា ។ បទថា **ភវង្គំ អាវជ្ជនាយ** ជាដើម ទ្រង់ត្រាស់ដោយអំណាចធម៌ដែលលាយឡំគ្នា ។ ក្នុងបទថា **កិរិយា** នោះ កាមាវចរកិរិយាជាអនន្តរប្បច្ច័យដល់វុដ្ឋានវិបាកទាំង ២ មហគ្គតកិរិយា ជាអនន្តរប្បច្ច័យដល់ភវង្គប៉ុណ្ណោះ ។ ព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា ពួកកុសលក្ខន្ធមុនៗជាបច្ច័យនៃពួកកុសលក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ដូច្នេះហើយ សម្ដែងវារៈ ៧ ទាំងឡាយណា ក្នុងបច្ចយវិភង្គខាងដើមថា កុសលជាបច្ច័យដល់កុសល កុសលជាបច្ច័យដល់អព្យាកតៈ អកុសលជាបច្ច័យដល់អកុសល អកុសលជាបច្ច័យដល់អព្យាកតៈ អព្យាកតៈជាបច្ច័យដល់អព្យាកតៈ អព្យាកតៈជាបច្ច័យដល់កុសល អព្យាកតៈជាបច្ច័យដល់អកុសល ( ដោយអនន្ត-រប្បច្ច័យ ) ។ ក្នុងអធិការនេះ លោកចែកទុកអនន្តរប្បច្ច័យដោយសង្ខេបដោយអំណាចនៃវារៈទាំងនោះ តែដោយពិស្ដារ ក្នុងអធិការនេះ លោកពោលថា

បណ្ឌិតគប្បីកំណត់និទ្ទេស ១០-១៧-៦០ និងច្រើនជាងនោះឲ្យល្អ ។

ពិតហើយ អនន្តរប្បច្ច័យនេះ មិនបាននិទ្ទេស ៧ យ៉ាងប៉ុណ្ណោះ តែរមែងបាននិទ្ទេស ១០ យ៉ាង គឺកុសលជាបច្ច័យដល់កុសល ១ ដល់វិបាក ១ អកុសលជាបច្ច័យដល់អកុសល ១ ដល់វិបាក ១ វិបាកជាបច្ច័យដល់

វិបាក ១ ដល់កិរិយា ១ កិរិយាជាបច្ច័យដល់កុសល ១ ដល់អកុសល ១ ដល់វិបាក ១ ដល់កិរិយា ១ ។

អនន្តរប្បច្ច័យនេះ បាននិទ្ទេសចំពោះ ១០ យ៉ាងប៉ុណ្ណោះក៏មិនមែន តែគង់បាននិទ្ទេស ១៧ យ៉ាង យ៉ាងនេះទៀត គឺកុសលជាបច្ច័យដល់កុសល ១ ដល់កុសលវិបាក ១ ដល់អកុសលវិបាក ១ អកុសលជាបច្ច័យដល់អកុសល ១ ដល់អកុសលវិបាក ១ ដល់កុសលវិបាក ១ កុសលវិបាកជាបច្ច័យដល់កុសលវិបាក ១ ដល់អកុសលវិបាក ១ ដល់កិរិយា ១ អកុសលវិបាកជាបច្ច័យដល់អកុសលវិបាក ១ ដល់កុសលវិបាក ១ ដល់កិរិយា ១ កិរិយាជាបច្ច័យដល់កិរិយា ១ ដល់កុសល ១ ដល់អកុសល ១ ដល់កុសលវិបាក ១ ដល់អកុសលវិបាក ១ ។

អនន្តរប្បច្ច័យនេះ បាននិទ្ទេសចំពោះ ១៧ យ៉ាងប៉ុណ្ណោះក៏មិនមែន គង់បាននិទ្ទេស ៦០ ទៀត ។ សេចក្តីនេះ ដូចម្តេច

គឺកុសលជាអនន្តរប្បច្ច័យដល់កុសល ៦ យ៉ាង បានដល់ កាមាវចរកុសល ជាអនន្តរប្បច្ច័យដល់កុសលទាំង ៤ យ៉ាង តាមការផ្សេងគ្នានៃភូមិ រូបាវចរកុសល និងអរូបាវចរកុសល ជាអនន្តរប្បច្ច័យដល់កុសល ដែលកើតក្នុងភូមិរៀងៗ ខ្លួន ។

ឯកុសលជាអនន្តរប្បច្ច័យដល់វិបាក ១២ យ៉ាង គឺកាមាវចរកុសលជាបច្ច័យដល់កាមាវចរកុសលវិបាក ដល់អកុសលវិបាក ដល់រូបាវចរវិបាក ដល់អរូបាវចរវិបាក ដល់លោកុត្តរវិបាក រូបាវចរកុសល ជាបច្ច័យដល់

រូបាវចរវិបាក ដល់កាមាវចរកុសលវិបាក អរូបាវចរកុសល ជាបច្ច័យដល់ កាមាវចរកុសលវិបាក ដល់រូបាវចរវិបាក ដល់អរូបាវចរវិបាក ដល់ លោកុត្តរវិបាក លោកុត្តរកុសល ជាបច្ច័យដល់លោកុត្តរវិបាក ។

អកុសល ជាអនន្តរប្បច្ច័យ ៥ យ៉ាង គឺដល់អកុសល ដល់ អកុសលវិបាក ដល់វិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

កាមាវចរកុសលវិបាក ជាអនន្តរប្បច្ច័យដល់វិបាក ៤ យ៉ាង គឺដល់ កាមាវចរកុសលវិបាក ដល់អកុសលវិបាក ដល់រូបាវចរវិបាក ដល់អរូបា-វចរវិបាក ។

រូបាវចរវិបាក ជាអនន្តរប្បច្ច័យ ៣ យ៉ាង គឺដល់កុសលវិបាកដែល ប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ។

អរូបាវចរវិបាក ជាអនន្តរប្បច្ច័យ ២ យ៉ាង គឺដល់អរូបាវចរវិបាក និងកាមាវចរកុសលវិបាក ។

លោកុត្តរវិបាក ជាអនន្តរប្បច្ច័យ ៤ យ៉ាង គឺដល់កុសលវិបាកដែល ប្រព្រឹត្តទៅក្នុងភូមិ ៤ ។ កុសលវិបាក ជាអនន្តរប្បច្ច័យ ១៣ យ៉ាង ដល់ វិបាក ដោយប្រការដូច្នេះ ។

អកុសលវិបាក ជាអនន្តរប្បច្ច័យ ២ យ៉ាង គឺដល់អកុសលវិបាក និងកាមាវចរកុសលវិបាក ។ វិបាកក្នុងទីទាំងពួង ជាអនន្តរប្បច្ច័យ ១៥ យ៉ាង ដល់វិបាក ដោយប្រការដូច្នេះ ។

វិបាក ជាអនន្តរប្បច្ច័យ ៤ យ៉ាងដល់កិរិយា គឺកាមាវចរកុសលវិបាក

ជាបច្ច័យដល់កាមាវចរកិរិយា ដល់អកុសលវិបាក ដល់រូបាវចរកិរិយា ហើយអរូបាវចរវិបាក ក៏ជាបច្ច័យដល់កាមាវចរកិរិយាបានដូចគ្នា ។

កិរិយា ជាអនន្តរប្បច្ច័យដល់កិរិយា ៥ យ៉ាង គឺកាមាវចរកិរិយា ជាបច្ច័យដល់កិរិយាដែលប្រព្រឹត្តទៅក្នុងភូមិ ៣ រូបាវចរកិរិយា អរូបាវចរកិរិយា ជាបច្ច័យចំពោះដល់កិរិយាក្នុងភូមិរៀងៗ ខ្លួន ។

កិរិយាជាអនន្តរប្បច្ច័យដល់វិបាក ១១ យ៉ាង គឺកាមាវចរកិរិយា ជាបច្ច័យដល់អកុសលវិបាក និងកុសលវិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៤ រូបាវចរកិរិយា ជាបច្ច័យដល់កាមាវចរកុសលវិបាក និងរូបាវចរវិបាក អរូបាវចរកិរិយា ជាបច្ច័យដល់កុសលវិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។

ឯកាមាវចរកិរិយា ជាអនន្តរប្បច្ច័យ ២ យ៉ាង ដល់កុសល និងអកុសល គឺដល់កាមាវចរកុសល និងអកុសល ។

អនន្តរប្បច្ច័យ រមែងបាននិទ្ទេស ៦០ ដោយប្រការដូច្នេះ ។

អនន្តរប្បច្ច័យនេះ បាននិទ្ទេស ៦០ ប៉ុណ្ណោះក៏ទេ គង់បាននិទ្ទេសច្រើនយ៉ាងទៀត សេចក្តីនេះដូចម្តេច គឺ

កាមាវចរមហាកុសលចិត្តដួងទី ១ ជាអនន្តរប្បច្ច័យដល់ចិត្ត ៥៣ ដួង គឺដល់ខ្លួនឯង ដល់រូបាវចរកុសល ៤ ដួង ដល់លោកុត្តរកុសល-សោមនស្ស ១៦ ដួង ព្រោះប្រកបដោយបាទ រួមសេចក្តីថា ជាបច្ច័យដល់កុសលចិត្ត ២១ ដួង ជាបច្ច័យដល់វិបាក ៣២ ដួងទៀត គឺដល់កាមាវចរវិបាក ១១ ដួង ដែលកើតដោយអំណាចតទារម្មណៈ និងភវង្គក្នុង

*ទីបំផុតនៃជវនៈ ដល់រូបាវចរវិបាក និងអរូបាវចរវិបាកដែលប្រព្រឹត្តទៅដោយអំណាចកវគ្គតែម្យ៉ាង ដល់លោកុត្តរវិបាក ១២ ដែលប្រព្រឹត្តទៅដោយអំណាចផលសមាបត្តិ ។ កុសលចិត្តដួងទី ២ ក៏ដូចគ្នា ។ ឯដួងទី ៣ និងទី ៤ រមែងជាអនន្តរប្បច្ច័យដល់ចិត្ត ២១ ដួងដ៏សេស វៀរកុសលដែលកើតក្នុងភូមិដែលខ្ពស់ឡើងទៅ និងលោកុត្តរវិបាក ។ មហាកុសលចិត្តដួងទី ៥ និងទី ៦ ជាអនន្តរប្បច្ច័យដល់ចិត្ត ៣៣ ដួង គឺដល់ខ្លួនឯង ដល់កុសលចិត្តដែលសហគតៈដោយឧបេក្ខា ដែលកើតក្នុងភូមិខ្ពស់ឡើងទៅ ៩ ដួង និងដល់វិបាកចិត្ត ២៣ ដួង ។ មហាកុសលចិត្តដួងទី ៧ និងទី ៨ ជាអនន្តរប្បច្ច័យដល់ចិត្ត ២១ ដួងប៉ុណ្ណោះ ។*

*រូបាវចរកុសលចិត្ត ៥ ជាអនន្តរប្បច្ច័យដល់ចិត្ត ១០ ដួង គឺដល់រូបាវចរកុសលដែលកើតខាងក្រោយខ្លួន ១ ដល់មហាវិបាកញាណសម្បយុត្ត ៤ ដួង និងដល់រូបាវចរវិបាក ៥ ដួង ។*

*ដោយន័យនេះឯង បណ្ដាអរូបាវចរកុសលទាំងឡាយ ដួងទី ១ ជាអនន្តរប្បច្ច័យដល់ចិត្ត ១១ ដួង មួយអន្លើដោយវិបាករបស់ខ្លួន ។ អរូបាវចរកុសលដួងទី ២ ជាអនន្តរប្បច្ច័យដល់ចិត្ត ១២ ដួង ។ អរូបាវចរកុសលដួងទី ៣ ជាអនន្តរប្បច្ច័យដល់ចិត្ត ១៣ ដួង ។ អរូបាវចរកុសលដួងទី ៤ ជាអនន្តរប្បច្ច័យដល់ចិត្ត ១៥ ដួង គឺចិត្ត ១៤ ដួង និងផលសមាបត្តិ ១ ដួង ។ លោកុត្តរកុសល ជាអនន្តរប្បច្ច័យដល់វិបាករៀងៗ ខ្លួនប៉ុណ្ណោះ ។*

*បណ្ដាចិត្តដែលសហគតៈដោយលោភៈ ៨ ដួង អកុសលចិត្ត ១ ដួងៗ*

ជាអនន្តរប្បច្ច័យដល់ចិត្ត ២១ ដួង គឺកាមាវចរវិបាកមនោវិញ្ញាណធាតុ ១១ ដួង មហគ្គតវិបាក ៩ ដួង និងដល់ខ្លួនឯងដែលកើតខាងក្រោយ ១ ដួង ។

ចិត្តដែលសហគតៈដោយទោសៈ ២ ដួង ជាអនន្តរប្បច្ច័យដល់ចិត្ត ៧ ដួង គឺកាមាវចរវិបាកមនោវិញ្ញាណធាតុ ៦ ដួង ដែលសហគតៈដោយឧបេក្ខា និងដល់ខ្លួនឯងដែលកើតខាងក្រោយ ១ ដួង ។

ចិត្ត ២ ដួង ដែលសហគតៈដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ជាអនន្តរប្បច្ច័យដល់ចិត្ត ២១ ដួង គឺកាមាវចរវិបាកមនោវិញ្ញាណធាតុ ១១ ដួង មួយអន្លើដោយអហេតុកវិបាក ដែលសហគតៈដោយសោមនស្ស រូបាវចរវិបាក និងអរូបាវចរវិបាក ៩ ដួង និងដល់ខ្លួនឯងដែលកើតខាងក្រោយ ១ ដួង ។

បញ្ចវិញ្ញាណខាងកុសលវិបាក ជាអនន្តរប្បច្ច័យ ដល់មនោធាតុខាងកុសលវិបាក ។

មនោធាតុ ជាអនន្តរប្បច្ច័យដល់មនោវិញ្ញាណធាតុខាងវិបាក ២ ដួង ។ បណ្ដាមនោវិញ្ញាណធាតុខាងវិបាក ២ ដួងនោះ ដួងដែលសហគតៈដោយសោមនស្ស ជាអនន្តរប្បច្ច័យដល់ចិត្ត ១២ ដួង គឺមនោវិញ្ញាណធាតុខាងវិបាក ១០ ដួង ដែលធ្វើកវន្តកិច្ចដល់ខ្លួនឯង ដែលកើតខាងក្រោយខ្លួនក្នុងកាលជាតទារម្មណៈ និងដល់វោដ្ឋព្វនកិរិយា ។

ឯអហេតុកមនោវិញ្ញាណធាតុ ដែលសហគតៈដោយឧបេក្ខា ជាអនន្តរប្បច្ច័យដល់ចិត្ត ១២ ដួងដូចគ្នា គឺដល់អាវជ្ជនមនោធាតុ អាវជ្ជន-

មនោវិញ្ញាណធាតុដែលមានឋាន ២ និងវិបាកមនោវិញ្ញាណធាតុ ១០ ។

មហាវិបាកដែលជាតិហេតុកៈ ជាអនន្តរប្បច្ច័យដល់ចិត្ត ២១ ដួង គឺ ដល់មនោវិញ្ញាណធាតុខាងវិបាកដែលជាកាមាវចរ ១០ ដួង វៀរសោមនស្សសន្តីរណៈ ដល់រូបាវចរវិបាក ដល់អរូបាវចរវិបាក និងដល់អាវជ្ជនចិត្តទាំង ២ ។

ទុហេតុកវិបាក ជាអនន្តរប្បច្ច័យដល់ចិត្ត ១២ ដួងដ៏សេស វៀរមហគ្គតវិបាក ។

រូបាវចរវិបាក ៥ ជាអនន្តរប្បច្ច័យដល់ចិត្ត ១៩ ដួង គឺដល់សហេតុកកុសលវិបាកបដិសន្ធិចិត្ត ដែលប្រព្រឹត្តទៅក្នុងភូមិទាំងបី ១៧ ដួង និងអាវជ្ជនចិត្ត ២ ដួង ។

បណ្តាអរូបាវចរវិបាក អរូបាវចរវិបាកចិត្តដួងទី ១ ជាអនន្តរប្បច្ច័យដល់ចិត្ត ៩ ដួង គឺតិហេតុកបដិសន្ធិខាងកុសលវិបាកជាន់កាមាវចរ ៤ ដួង អរូបាវចរវិបាក ៤ ដួង និងមនោទ្វារាវជ្ជនចិត្ត ១ ដួង ។

អរូបាវចរវិបាកចិត្តដួងទី ២ ជាអនន្តរប្បច្ច័យដល់ចិត្ត ៨ ដួង វៀរវិបាកជាន់ទាប ១ ដួង ។

អរូបាវចរវិបាកចិត្តដួងទី ៣ ជាអនន្តរប្បច្ច័យដល់ចិត្ត ៧ ដួង វៀរវិបាកដែលទាបជាង ២ ដួង ។

អរូបាវចរវិបាកចិត្តដួងទី ៤ ជាអនន្តរប្បច្ច័យដល់ចិត្ត ៦ ដួង វៀរវិបាកខាងក្រោម ៣ ដួង ។

លោកុត្តរវិបាក ៤ ដួង ជាអនន្តរប្បច្ច័យដល់ចិត្ត ១៤ ដួង គឺ តិហេតុកវិបាក ១៣ ដួង និងដល់ខ្លួនឯង ដែលកើតខាងក្រោយ ១ ដួង ។ បញ្ចវិញ្ញាណខាងអកុសលវិបាក ជាអនន្តរប្បច្ច័យដល់អកុសលវិបាក-មនោធាតុ ។ មនោធាតុ ជាអនន្តរប្បច្ច័យដល់អហេតុកមនោវិញ្ញាណធាតុខាងអកុសលវិបាក ។ អហេតុកមនោវិញ្ញាណធាតុខាងអកុសលវិបាកនោះ ជាអនន្តរប្បច្ច័យដល់ចិត្ត ១២ ដួង គឺដល់ខ្លួនឯងដែលកើតខាងក្រោយ ក្នុងវេលាជាតទារម្មណៈ ដល់កាមាវចរវិបាក ៩ ដួង ដែលប្រព្រឹត្តទៅដោយអំណាចបដិសន្ធិ និងភវង្គក្នុងចុតិកាល និងដល់កាមាវចរកិរិយា ២ ដួង ដែលសហគតៈដោយឧបេក្ខា ។

កិរិយាមនោធាតុ ជាបច្ច័យដល់ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួង ។

ហសិតុប្បាទកិរិយា ជាអនន្តរប្បច្ច័យដល់ចិត្ត ១៣ ដួង ដោយមិនរាប់ដដែល គឺដល់តិហេតុកវិបាក ៩ ដួង ដែលប្រព្រឹត្តទៅដោយអំណាចភវង្គក្នុងបញ្ចវោការភព និងដល់វិបាកដែលសហគតៈដោយសោមនស្ស ៥ ដែលប្រព្រឹត្តទៅដោយអំណាចតទារម្មណៈ និងដល់ខ្លួនឯង ដែលកើតខាងក្រោយ ១ ដួង ។

វោដ្ឋព្វនកិរិយា ជាបច្ច័យដល់ចិត្ត ៤៥ ដួង គឺកាមាវចរកិរិយា ១០ ដួង វៀរកិរិយាមនោធាតុ កាមាវចរកុសល ៨ ដួង អកុសល ១២ ដួង និងវិបាកចិត្ត ១៥ ដួង ដែលប្រព្រឹត្តទៅដោយអំណាចភវង្គ ក្នុងបញ្ច-វោការភព ។

កាមាវចរតិហេតុកកិរិយាដែលសហគតៈដោយសោមនស្ស ២ ដួង ជាអនន្តរប្បច្ច័យដល់ចិត្ត ២៥ ដួង ដែលរាប់ហើយមិនរាប់ទៀត គឺដល់តិហេតុកវិបាក ១៣ ដួង ដែលប្រព្រឹត្តទៅដោយអំណាចភវង្គ ដល់វិបាកដែលសហគតៈដោយសោមនស្ស ៥ ដួង ដោយអំណាចតទារម្មណៈ ដល់រូបាវចរកិរិយា ៤ ដួង ដែលប្រព្រឹត្តទៅដោយអំណាចបរិកម្ម ដល់អរហត្ត-ផលសមាបត្តិ ដែលសហគតៈដោយសោមនស្ស ៤ ដួង ដោយអំណាចនៃអរហត្តផលសមាបត្តិ និងដល់ខ្លួនឯង ដែលកើតខាងក្រោយ ១ ដួង ។

ទុហេតុកសោមនស្សសហគតកិរិយា ២ ដួង ជាអនន្តរប្បច្ច័យដល់ចិត្ត ១៧ ដួង ដោយមិនរាប់ដដែល គឺដល់ភវង្គចិត្ត ១៣ ដួង តាមដែលពោលហើយ ដល់តទារម្មណៈ ៥ ដួង និងដល់ខ្លួនឯង ដែលកើតខាងក្រោយ ១ ដួង ។

កាមាវចរតិហេតុកឧបេក្ខាសហគតកិរិយា ២ ដួង ជាអនន្តរប្បច្ច័យដល់ចិត្ត ២៤ ដួង ដោយមិនរាប់ដដែល គឺដល់ភវង្គចិត្តទាំង ១៣ ដួងនោះឯង ដល់ឧបេក្ខាសហគតវិបាក ៦ ដួង ដែលប្រព្រឹត្តទៅដោយអំណាចតទារម្មណៈ ដល់រូបាវចរកិរិយា ១ ដួង ដែលប្រព្រឹត្តទៅដោយអំណាចបរិកម្ម ដល់អរូបាវចរកិរិយា ៤ ដួង ដល់អរហត្តផលសមាបត្តិ ១ ដួង និងដល់ខ្លួនឯង ដែលកើតឯក្រោយ ១ ដួង ។

ទុហេតុកឧបេក្ខាសហគតកិរិយា ២ ដួង ជាអនន្តរប្បច្ច័យដល់ចិត្ត ១៨ ដួង ដោយមិនរាប់ដដែល គឺដល់ភវង្គចិត្តទាំង ១៣ ដួងនោះ ដល់

តទារម្មណចិត្ត ៦ ដួង និងដល់ខ្លួនឯង ដែលកើតឯក្រោយ ១ ដួង ។

បណ្តារូបាវចរកិរិយា ១ ដួងៗ ជាអនន្តរប្បច្ច័យដល់ចិត្ត ១០ ដួង គឺតិហេតុកភវង្គ ក្នុងបញ្ចវោការភព ៩ ដួង និងដល់ខ្លួនឯង ដែលកើតឯក្រោយ ១ ដួង ។

បណ្តាអរូបាវចរកិរិយាចិត្តទាំងឡាយ អរូបាវចរកិរិយាចិត្តដួងទី ១ ជាអនន្តរប្បច្ច័យដល់ចិត្ត ១១ ដួង គឺភវង្គចិត្ត ៩ ដួង ក្នុងបញ្ចវោការភព ១ ដួងទៀត ក្នុងចតុវោការភព និងដល់ខ្លួនឯងដែលកើតខាងក្រោយ ១ ដួង ។

អរូបាវចរកិរិយាចិត្តដួងទី ២ រមែងបានភវង្គចិត្ត ២ ដួង ក្នុងចតុ-វោការភព ។

អរូបាវចរកិរិយាចិត្តដួងទី ៣ បាន ៣ ដួង ។

អរូបាវចរកិរិយាចិត្តដួងទី ៤ រមែងបានភវង្គចិត្ត ៤ ដួង និងផល-សមាបត្តិ ១ ដួងទៀត ។ បណ្តាអរូបាវចរកិរិយាទាំងនោះ ដួងនីមួយៗ ជាអនន្តរប្បច្ច័យដល់ចិត្ត ១១-១២-១៣ និង ១៥ ដួង តាមលំដាប់ដូច្នេះឯងអនន្តរប្បច្ច័យ រមែងបាននិទ្ទេសច្រើនយ៉ាង ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា

បណ្ឌិតគួរកំណត់និទ្ទេស ១០-១៧-៦០ និងច្រើនជាងនោះ ឲ្យល្អចុះ ។

[ ៥១២-៥១៨ ] សមនន្តរប្បច្ច័យ មានអត្ថងាយយល់ហើយ ។

[ ៥១៩-៥២៧ ] ក្នុងសហជាតប្បច្ច័យ មានអត្ថងាយយល់ហើយ ។

[ ៥២៨-៥៣០ ] ក្នុងអញ្ញមញ្ញប្បច្ច័យ មានអត្ថងាយយល់ហើយ ។

[ ៥៣១-៥៤៣ ] ក្នុងនិស្សយបច្ច័យ មានអត្ថងាយយល់ហើយ ។

[ ៥៤៤-៥៥៥ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងឧបនិស្សយបច្ច័យដូចតទៅ

បទថា **សទ្ធំ ឧបនិស្សាយ** គឺធ្វើនូវសទ្ធាក្នុងកម្ម បានដល់ ការជឿក្នុងកម្មផលរបស់កម្ម លោកនេះ និងលោកខាងមុខជាដើម ឲ្យជាទីអាស្រ័យដ៏មានកម្លាំង ដូចបុគ្គលជឿថា ខាងក្រោមផែនដីមានទឹក ហើយជីកនូវផែនដីយ៉ាងណា កុលបុត្តមានសទ្ធាក៏យ៉ាងនោះ ជឿផល និងអានិសង្សរបស់ទានជាដើមហើយ រមែងបរិច្ចាគទានជាដើម ព្រោះហេតុនោះ ទើបលោកពោលថា **សទ្ធំ ឧបនិស្សាយ** ។ ក្នុងបទថា **សីលំ ឧបនិស្សាយ** ជាដើម អធិប្បាយថា ធ្វើនូវធម៌ មានសីលជាដើមនេះ ឲ្យជាទីអាស្រ័យដ៏មានកម្លាំង ។ ពិតហើយ បុគ្គលមានសីល ជាអ្នកឈ្លាសក្នុងសីលានុភាព និងក្នុងអានិសង្សនៃសីល ព្រោះអាស្រ័យសីល ទើបឲ្យទានដល់បុគ្គលអ្នកមាននូវសីល សមាទានសីលជាន់ខ្ពស់ជាលំដាប់ រក្សាឧបោសថក្នុងបក្ខ មានថ្ងៃ ១៤ ជាដើមឲ្យបរិសុទ្ធ មិនឲ្យដាច់ ព្រោះអាស្រ័យសីលសម្បត្តិ រមែងញុំាងគុណធម៌ មានឈានជាដើមឲ្យកើតឡើង ។ សូម្បីបុគ្គលដែលបានឮ បានស្តាប់ច្រើន ដឹងនូវសម្បត្តិគ្រប់យ៉ាង ដែលទាក់ទងដោយបុញ្ញកិរិយាវត្ថុ មានទានជាដើម និងការផ្សេងគ្នានៃភាពសៅហ្មង និងផូរផង់នៃកុសល មានទានជាដើម ដោយសុតមយប្បញ្ញាហើយ អាស្រ័យសុតៈ បំពេញកុសល មានទានជាដើម ។ សូម្បីបុគ្គលដែលលះបង់ មានចិត្តបង្អោនទៅខាងបរិច្ចាគ អាស្រ័យការដល់ព្រមដោយចាគៈរបស់ខ្លួន ទើបឲ្យទាន សមាទានសីល

ព្រោះយល់ថា ទានដែលបុគ្គលមានសីលឲ្យហើយ រមែងមានផលច្រើន រក្សាឧបោសថ ព្រោះបដិបត្តិយ៉ាងនោះ ទើបជាអ្នកមានចិត្តបរិសុទ្ធ រមែងធ្វើឲ្យគុណធម៌ មានឈានជាដើមកើតឡើងបាន ។ ឯបុគ្គលដែលមានបញ្ញាកំណត់ដឹងប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ និងឧបាយដែលឆ្លងផុតចាកលោក អាស្រ័យការដឹងទូទៅថា ព្រោះបដិបទានេះ បុគ្គលអាចធ្វើខ្លួនឲ្យដល់នូវប្រយោជន៍ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ដូច្នេះ រមែងបំពេញកុសល មានទានជាដើម ធម៌មានសទ្ធាជាដើម ជាឧបនិស្ស័យនៃទានជាដើមតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន រមែងជាឧបនិស្ស័យនៃសទ្ធាជាដើមដែលកើតឡើងដល់ខ្លួនខាងក្រោយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **សទ្ធា សីលំ សុតំ ចាគោ បញ្ញា សទ្ធាយ សីលស្ស សុតស្ស ចាគស្ស បញ្ញាយ ។**

បទថា **បរិកម្មំ** សេចក្តីថា អ្នកសិក្សាគប្បីកាន់យកបរិកម្មក្នុងចំណែកខាងដើម មិនមែនជាអនន្តរប្បច្ច័យ បរិកម្មនៃទិព្វចក្ខុញ្ញាណនោះឯង រមែងមានដល់ញាណទាំង ២ នេះ គឺយថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ មិនមានបរិកម្មដទៃឡើយ ញាណទាំង ២ នេះ ជាបរិវារនៃទិព្វចក្ខុនោះឯង កាលទិព្វចក្ខុនោះសម្រេចហើយ ញាណទាំង ២ នេះ ក៏សម្រេចផងដែរ ។ កាលបើយ៉ាងនោះ អ្នកសិក្សាគប្បីជ្រាបថា បរិកម្មនៃទិព្វចក្ខុញ្ញាណ ដែលប្រាថ្នាចំពោះការបង្អោនចិត្តទៅ ដើម្បីការដឹងយ៉ាងនោះ ជាបរិកម្មនៃញាណទាំង ២ នោះ ព្រោះថា ញាណទាំង ២ នោះ មានគតិដូចទិព្វចក្ខុសព្វយ៉ាង

*ក៏មិនមែន ព្រោះហេតុនោះ ទើបមានបរិកម្មពិសេសក្នុងញាណទាំង ២ នេះទៀត ។ បទថា* **ទិព្វចក្ខុ ទិព្វាយ សោតធាតុយា** *សេចក្តីថា ទិព្វចក្ខុរបស់បុគ្គលដែលឃើញរូបក្នុងទីឆ្ងាយ ហើយចង់ស្តាប់សំឡេងនៃរូបទាំងនោះ ជាឧបនិស្សយប្បច្ច័យដល់ការផ្គូរផ្គង់នៃសោតធាតុ ។ ទិព្វសោតធាតុ រមែងជាឧបនិស្សយប្បច្ច័យដល់ឥទ្ធិវិធញ្ញាណ ដោយអំណាចភាពជាអ្នកបានឮសំឡេងនៃរូបទាំងនោះ ហើយបំណងនឹងទៅក្នុងទីនេះ ។ បណ្ឌិតគប្បីជ្រាបភាពជាឧបនិស្សយប្បច្ច័យ ដោយអំណាចភាពជាឧបការៈដល់ធម៌នោះៗ ក្នុងទីទាំងពួង ដោយប្រការដូច្នេះ ។ បទថា* **មគ្គំ ឧបនិស្សាយ អនុប្បន្នំ សមាបត្តឹ** *សេចក្តីថា ព្រះអរិយបុគ្គលទាំងឡាយណា ញ៉ាំងសមាបត្តិនោះៗឲ្យកើតឡើង ព្រោះអន្តរាយជាសភាវៈស្រាលស្តើងហើយ និងលះបានហើយដោយមគ្គនោះៗ ព្រោះហេតុនោះ ទើបមគ្គរបស់ព្រះអរិយបុគ្គលទាំងនោះ ឈ្មោះថា ជាឧបនិស្សយប្បច្ច័យដល់សមាបត្តិ ។ បទថា* **វិបស្សន្តិ** *គឺរមែងឃើញច្បាស់ ដើម្បីមគ្គដែលខ្ពស់ជាលំដាប់ ។ បទថា* **អត្ថប្បដិសម្ភិទាយ** *ជាដើម ព្រះមានព្រះភាគ ត្រាស់ដោយភាពជាបដិសម្ភិទាទាំងឡាយសម្រេចបាន ព្រោះការបានសម្រេចមគ្គនោះឯង ។ មគ្គនោះ ឈ្មោះថា ជាឧបនិស្ស័យព្រោះប្រព្រឹត្តទៅក្នុងអារម្មណ៍នោះៗ ខាងក្រោយនៃបដិសម្ភិទាទាំងនេះសម្រេចហើយ ដោយប្រការដូច្នេះ ។*

*បទថា* **សទ្ធំ ឧបនិស្សាយ មានំ ជប្បេតិ** *សេចក្តីថា រមែងញ៉ាំងមានៈឲ្យប្រព្រឹត្តទៅថា អញជាអ្នកមានសទ្ធាជ្រះថ្លា ។ បទថា* **ទិដ្ឋឹ គណ្ហាតិ**

សេចក្តីថា បុគ្គលដល់ដោយអំណាចការជឿក្នុងពាក្យនោះៗ មិនពិចារណាអត្ថដោយបញ្ញា គឺកាន់យកទិដ្ឋិដោយអំណាចការយល់ខុសថា បុគ្គលមានជាដើម ។ បទថា **សីលំ សុតំ ចាគំ បញ្ញំ** សេចក្តីថា កើតនូវមានះថាអញជាអ្នកមានសីល ជាអ្នកស្តាប់ហើយ មានការលះបង់ មានការដឹងសព្វអន្វើ ។ កាលបុគ្គលញ៉ាំងនូវការសម្គាល់ខុស ដោយអំណាចទិដ្ឋិឲ្យកើតឡើងក្នុងសីល សុតៈ ចាគៈ និងបញ្ញា ដូចការសម្គាល់ខុសដោយអំណាចមានះ រមែងកាន់យកនូវទិដ្ឋិ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **រាគស្ស** ជាដើម បណ្តាទិដ្ឋិ និងមានះទាំងនោះ ធម៌ទីមួយៗ ជាឧបនិស្សយប្បច្ច័យដល់រាគៈ ក្នុងវេលាអាស្រ័យសម្បត្តិ មានសទ្ធាជាដើម ហើយលើកតម្កើងខ្លួន ជាឧបនិស្សយប្បច្ច័យដល់ទោសៈ ក្នុងវេលាអាស្រ័យសម្បត្តិ មានសទ្ធាជាដើមហើយ មើលងាយអ្នកដទៃ ជាឧបនិស្សយប្បច្ច័យដល់មោហៈដែលសម្បយុត្តដោយរាគៈ និងទោសៈទាំង ២ ជាឧបនិស្សយប្បច្ច័យដល់មានះ និងទិដ្ឋិ មានប្រការដូចពោលហើយ ជាឧបនិស្សយប្បច្ច័យដល់សេចក្តីប្រាថ្នាភវសម្បត្តិ និងភោគសម្បត្តិ ។ ព្រោះអាស្រ័យសម្បត្តិ មានសទ្ធាជាដើម ព្រះមានព្រះភាគទ្រង់សម្តែងលោកិយកុសលប៉ុណ្ណោះ ក្នុងអធិការនេះ ដោយប្រការដូច្នេះ ។

ឯលោកុត្តរកុសល ជាធម៌ស្ងប់ ប្រណីត ខ្ពង់ខ្ពស់ កម្ចាត់អកុសលបានជាសមុច្ឆេទ ព្រោះហេតុនោះ ទើបទ្រង់មិនកាន់យកថា ជាឧបនិស្សយប្បច្ច័យដល់អកុសល ក្នុងអធិការនេះ ដូចព្រះចន្ទមិនជាឧបនិស្ស័យដល់

ភាពនឹងនឹត ដូច្នោះ ។

បទថា **អាតាបេតិ** ជាដើម សេចក្ដីថា ព្រះមានព្រះភាគត្រាស់ដើម្បីសម្ដែងអព្យាកតធម៌ ដោយអំណាចកាយិកទុក្ខ ។ ពិតហើយ បុគ្គលមានសទ្ធា អាស្រ័យសទ្ធា មិនរួញរាចំពោះត្រជាក់ ក្ដៅ យកចិត្តទុកដាក់ចំពោះការកសាងជាដើម មានប្រការផ្សេងៗ ឈ្មោះថា រមែងធ្វើខ្លួនឲ្យក្ដៅធ្វើខ្លួនឲ្យក្រវល់ក្រវាយ ។ បុគ្គលគិតថា អាត្មាអញបានភោគសម្បត្តិហើយ នឹងធ្វើបុណ្យ ឈ្មោះថា រមែងសោយទុក្ខ ព្រោះមានការស្វែងរកជាមូល ។ បុគ្គលអ្នកមានសីល ឈ្មោះថា រមែងធ្វើខ្លួនឲ្យក្ដៅ ធ្វើខ្លួនឲ្យក្រវល់ក្រវាយ ដោយអំណាចការសមាទានធុតង្គ មានការនៅក្នុងទីវាលជាវត្តជាដើម ដើម្បីរក្សាសីល ។ ឈ្មោះថា រមែងសោយទុក្ខដែលមានការស្វែងរកជាមូល ដោយអំណាចភាពជាអ្នកសមាទានបិណ្ឌបាតិកធុតង្គជាដើម ។ បុគ្គលដែលស្ដាប់ហើយ គិតថា អញនឹងបដិបត្តិឲ្យសមគួរដល់ភាពជាពហុស្សុត បដិបត្តិតាមន័យដែលពោលហើយនោះឯង ឈ្មោះថា រមែងធ្វើខ្លួនឲ្យក្ដៅ ធ្វើខ្លួនឲ្យក្រវល់ក្រវាយ ។ ឈ្មោះថា រមែងសោយទុក្ខ ដែលមានការស្វែងរកជាមូល ។ សូម្បីបុគ្គលដែលលះបង់ ព្រោះមានចិត្តបង្អោនទៅក្នុងការបរិច្ចាគ លះបង់រហូតមិនសេសសល់បច្ច័យសម្រាប់ចិញ្ចឹមជីវិតខ្លួន ឬធ្វើការលះបង់អវយវៈជាដើម ឈ្មោះថា ធ្វើខ្លួនឲ្យក្ដៅ ធ្វើខ្លួនឲ្យក្រវល់ក្រវាយ ។ ឈ្មោះថា រមែងសោយទុក្ខ ដែលមានការស្វែងរកជាមូល ដើម្បីបានមកនូវវត្ថុដែលនាំមកបរិច្ចាគ ។ សូម្បីបុគ្គលអ្នកមានបញ្ញា អាស្រ័យភាពជាអ្នកមានបញ្ញា មិន

*ពិចារណាដល់ត្រជាក់ ក្តៅ ជាដើម ព្យាយាមដាក់ចិត្តក្នុងការចាំ ដោយគិតថា អញនឹងមានបញ្ញាឲ្យខ្ពស់ជាលំដាប់ ឈ្មោះថា រមែងធ្វើខ្លួនឲ្យក្តៅ ធ្វើខ្លួនឲ្យរោលរាល ។ ឃើញទោសក្នុងមិច្ឆាជីវៈ និងអានិសង្សក្នុងសម្មាជីវៈ ទើបលះមិច្ឆាជីវៈ និងស្វែងរកគ្រឿងចិញ្ចឹមជីវិត ដោយអាជីវៈដែលបរិសុទ្ធ ឈ្មោះថា រមែងសោយទុក្ខដែលមានការស្វែងរកជាមូល ។*

*បទថា* **កាយិកស្ស សុខស្ស** *គឺដល់កាពសុខកាយក្នុងពេលសុខកើតឡើងដោយកាយដែលមានបណីតរូប មានសទ្ធាជាដើមជាសមុដ្ឋានពាល់ត្រូវហើយ ក្នុងវេលាប្រើប្រាស់ឧបករណ៍នៃសេចក្តីសុខ ដែលកើតឡើងព្រោះអាស្រ័យសម្បត្តិ មានសទ្ធាជាដើម និងដល់សេចក្តីសុខផ្លូវកាយដែលមានមានបាមោជ្ជ និងបីតិ ដែលមិនមានការក្តៅក្រហាយ ដោយអំណាចនៃឧបករណ៍ នៃសេចក្តីសុខទាំងនោះជាមូល ជាសមុដ្ឋានពាល់ត្រូវហើយ និងដល់សេចក្តីសុខកាយ ក្នុងពេលវិបាកសុខកើតឡើង ព្រោះឧបករណ៍នៃសេចក្តីសុខទាំងនោះ ធ្វើហើយក្នុងការកើតឡើងនៃសេចក្តីសុខ និងដល់ទុក្ខផ្លូវកាយ ក្នុងវេលាទុក្ខកើតឡើង តាមន័យដែលពោលហើយនោះឯង និងក្នុងពេលមានការសម្លាប់ ការចង ដែលបុគ្គលអត់ធ្មត់មិនបាន នូវគុណ-សម្បត្តិ មានសទ្ធាជាដើមប្រកបហើយ ។ ក្នុងកាលផលសមាបត្តិ អាស្រ័យសទ្ធាជាដើមប្រព្រឹត្តទៅ ធម៌និមួយៗ បណ្តាធម៌ មានសទ្ធាជាដើម គប្បីជ្រាបថា ជាឧបនិស្សយប្បច្ច័យដល់ផលសមាបត្តិផងដែរ ។ បទថា* **កុសលំ កម្មំ** *គឺកុសលចេតនា ជាឧបនិស្សយប្បច្ច័យដល់វិបាករបស់ខ្លួន ។ តែ*

*ចេតនានោះ បានចំពោះចេតនាដែលមានកម្លាំងប៉ុណ្ណោះ ដែលមានកម្លាំងខ្សោយ រមែងមិនបាន ។ ក្នុងសេចក្ដីនេះ មានរឿងជាឧទាហរណ៍ដូចតទៅ*

*បានឮថា ស្រីម្នាក់ ប្រាថ្នាចង់-**ក**ឲ្យស្លាប់ ទើបទាក់ខ្សែត្រង់ដើមឈើ រៀបចំរបស់ដែលគួររៀបចំ ពេលនោះ ចោរម្នាក់គិតថា ក្នុងពេលយប់ អញនឹងទៅកាន់ផ្ទះនោះ ហើយនឹងយកខ្សែនេះចងទ្រព្យខ្លះ ហើយលួចទៅ ទើបយកកាំបិតចូលទៅកាត់ លំដាប់នោះ ខ្សែនោះ ក៏ក្លាយជាពស់មានពិស បញ្ចេញសំឡេង ចោរខ្លាចមិនហ៊ានចូលទៅ ស្រីនោះចេញអំពីផ្ទះ ដាក់-**ក** ចូលក្នុងអន្ទាក់ខ្សែ ចង-**ក**ស្លាប់ហើយ ចេតនាដែលមានកម្លាំង ហាមនូវអន្តរាយហើយ ជាឧបនិស្សយប្បច្ច័យដល់វិបាករបស់ខ្លួន ដោយប្រការដូច្នេះ ។*

*តែពាក្យនេះ មិនគួរកាន់យកដោយពិតប្រាកដ ព្រោះថា កម្មដែលបានឱកាសហាមអន្តរាយនៃវិបាកយ៉ាងនេះហើយ រមែងឲ្យផល ឯកម្មដែលញុំាងវិបាកឲ្យកើត ពោលមិនបានថា មិនជាឧបនិស្ស័យដល់វិបាក ។ ក្នុងបទថា* **កម្មំ** *នេះ បណ្ឌិតគប្បីជ្រាបថា បានដល់ កម្មដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៤ ។ ពាក្យដែលពោលបន្ថមកថា មគ្គ ជាឧបនិស្សយប្បច្ច័យដល់ផល-សមាបត្តិនោះ ពោលដោយអំណាចធម៌ដែលមិនមានចេតនា ។ ដោយពាក្យនោះ សម្ដែងឲ្យឃើញថា ធម៌ដែលញុំាងវិបាកឲ្យកើតឡើងនោះឯង ជាឧបនិស្សយប្បច្ច័យដល់វិបាករបស់ខ្លួន ។*

*បទថា* **រាគំ ឧបនិស្សាយ ឈានំ ឧប្បាទេតិ** *សេចក្ដីថា បុគ្គលជាអ្នក*

គ្រេកត្រអាលក្នុងវត្ថុណា រមែងសម្លាប់សត្វដែលរាំពាំងក្នុងវត្ថុនោះ ឬដើម្បីប្រយោជន៍ដល់វត្ថុនោះ ។ ក្នុងអទិន្នាទានជាដើម អ្នកសិក្សាគប្បីជ្រាបអត្ថដោយឧបាយនេះ ។ បទថា **សន្ធឹ ឆិន្ទតិ** ជាដើម ត្រាស់ដោយអំណាចអទិន្នាទាន ។ បទថា **សន្ធឹ** ក្នុងអធិការនោះ សំដៅយកជញ្ជាំងផ្ទះ ។ បទថា **និល្លោបំ ហរតិ** គឺលបចូលទៅលួច ។ បទថា **ឯកាគារិកំ ករោតិ** គឺរួមគ្នាច្រើននាក់ព័ទ្ធផ្ទះមួយខ្នង ។ បទថា **បរិបន្ថេ តិដ្ឋតិ** គឺធ្វើនូវការប្រទូស្តអ្នកដំណើរ ។ ក្នុងបទថា **ទោសំ ឧបនិស្សាយ** ជាដើម សេចក្តីថា ធ្វើទោសៈដែលកើតឡើងដោយអំណាចការចង្អៀតចង្អល់ថា បុគ្គលនោះបានធ្វើសេចក្តីវិនាសឲ្យដល់អញជាដើម ឲ្យជាឧបនិស្ស័យ ។ បទថា **មោហំ ឧបនិស្សាយ** គឺធ្វើមោហៈដែលបិទបាំងទោស ក្នុងបាណាតិបាតជាដើមឲ្យជាឧបនិស្ស័យ ។ បទថា **មានំ ឧបនិស្សាយ** គឺធ្វើមានះថា ហេតុអ្វី ទើបសម្លាប់មិនបាន ហេតុអ្វី ទើបអញលួចមិនបាន ឲ្យជាឧបនិស្ស័យ ឬអធិប្បាយថា ត្រូវបុគ្គលណាមើលងាយ មើលថោក ហើយលើកអាការដែលគេមើលងាយនោះមក ជាឧបនិស្ស័យក៏មាន ។ បទថា **ទិដ្ឋឹ ឧបនិស្សាយ** គឺធ្វើទិដ្ឋិក្នុងយញ្ញទាំងឡាយ ឲ្យជាឧបនិស្ស័យ ដូចព្រាហ្មណ៍ទាំងឡាយ និងពួកបារាសិកៈ និងមិលក្ខៈជាដើម ។ បទថា **បត្ថនំ ឧបនិស្សាយ** គឺធ្វើសេចក្តីប្រាថ្នាថា បើការងារបែបនេះរបស់ខ្ញុំសម្រេច ខ្ញុំនឹងធ្វើពលីកម្មយ៉ាងនេះដល់លោក ឬសូមលោកនាំគ្រឿងបណ្ណាការបន់ស្រន់ទេវតាប្រភេទនោះមកឲ្យខ្ញុំ ឬចូរនាំយកទៅឲ្យបុគ្គលនោះ ឬថា សូមលោកមករួមជាសម្លាញ់របស់ខ្ញុំ

*ដែលកំពុងធ្វើការងារទាំងនេះ ឲ្យជាឧបនិស្ស័យជាដើម ។ ក្នុងបទថា* **រាគោ ទោសោ មោហោ មានោ ទិដ្ឋិ បត្ថនា រាគស្ស** *នេះ រាគៈជាឧបនិស្ស័យដល់រាគៈផង ដល់ធម៌ទាំងឡាយ មានទោសៈជាដើមផង ។ ក្នុងទោសៈជាដើម ក៏ន័យនេះដូចគ្នា ។*

*បទថា* **បាណាតិបាតោ បាណាតិបាតស្ស** *សេចក្ដីថា បុគ្គលអ្នកសម្លាប់សត្វ រមែងសម្លាប់សត្វដទៃទៀត ព្រោះតាំងនៅក្នុងភាពដែលមិនសង្រួម ឬថា រមែងសម្លាប់ញាតិមិត្តរបស់បុគ្គលដែលត្រូវសម្លាប់ ដែលមកប្រទូស្តបន្តទៀត ។ បាណាតិបាត ជាឧបនិស្សយប្បច្ច័យដល់បាណាតិបាត ដោយប្រការដូច្នេះ ។ម្យ៉ាងទៀត បាណាតិបាត ជាឧបនិស្សយប្បច្ច័យដល់អទិន្នាទានជាដើម ក្នុងពេលសម្លាប់ម្ចាស់ទ្រព្យ ឬអ្នកយាមទ្រព្យ លួចយករបស់គេទៅ ក្នុងការសម្លាប់ក្ដី ហើយបំពានកិរិយាអ្នកដទៃ ក្នុងពេលនិយាយកុហកថា មិនបានសម្លាប់ ក្នុងពេលនិយាយញុះញង់ ដើម្បីបិទបាំងកម្មដែលខ្លួនឯងធ្វើហើយ ឬដើម្បីធ្វើកម្ម ដែលមិនទាន់បានធ្វើក្នុងពេលពោលពាក្យគ្រោតគ្រាត ពាក្យរវើរវាយ ដោយន័យនោះ ក្នុងពេលសម្លឹងរំពៃសម្បត្តិដែលចង់បានរបស់អ្នកដទៃ ក្នុងពេលគិតថា កាលបុគ្គលនោះ ត្រូវសម្លាប់ឲ្យស្លាប់ ហើយពួកមិត្តអមាត្យនៃបុគ្គលនោះ ត្រូវអស់ទៅជាដើម និងក្នុងពេលកាន់យកនូវមិច្ឆាទិដ្ឋិ ដោយអំណាចបុគ្គលដែលធ្វើកម្ម ដែលធ្វើបានដោយក្រថា បាណាតិបាត របស់អាត្មាអញនឹងធ្ងន់ពិតយ៉ាងនេះជាដើម ។ បណ្ឌិតគប្បីជ្រាបអត្ថ ក្នុងការធ្វើចក្ខុៈឲ្យវិលទៅក្នុងធម៌ មានអទិន្នាទាន*

ជាដើមជាមូល ដោយឧបាយនេះ ។

បទថា **មាតុឃាតិកម្មំ មាតុឃាតិកម្មស្ស** សេចក្តីថា មាតុឃាតកម្ម ជាឧបនិស្សយប្បច្ច័យដល់មាតុឃាតកម្ម សម្រាប់បុគ្គលដែលឃើញអ្នកដទៃសម្លាប់មាតា ហើយសម្លាប់នូវមាតារបស់ខ្លួនខ្លះ ដោយគិតថា ការធ្វើយ៉ាងនោះ សមគួរ ឬដោយអំណាចការសម្លាប់ក្នុងភពមួយហើយ សម្លាប់ក្នុងភពដទៃទៀត ឬក្នុងភពតែមួយ ដោយអំណាចការសន្សំរឿយៗ ថា ចូរអ្នកទៅសម្លាប់ម្តាយរបស់ខ្ញុំ ឬដោយអំណាចការប្រហារលើកទី ២ ដើម្បីឲ្យស្លាប់ពិតប្រាកដ ដោយការប្រហារ ២ ដង ។ បទដ៏សេស អ្នកសិក្សាគប្បីជ្រាបអត្ថតាមសមគួរដោយន័យនេះដូចគ្នា ។

អាចារ្យពួកខ្លះពោលថា អកុសលដែលមានកម្លាំង មិនជាឧបនិស្សយប្បច្ច័យដល់អកុសលដែលមានកម្លាំងខ្សោយឡើយ ព្រោះហេតុនោះ ទើបទេសនា ព្រះមានព្រះភាគត្រាស់ដោយអំណាចអនន្តរិយកម្ម ដែលទាក់ទងដោយកម្មបថប៉ុណ្ណោះ ។ ហេតុនោះ មិនគួរកាន់យកដោយពិតប្រាកដ ព្រោះថា បុគ្គលធ្វើកម្ម មានបាណាតិបាតជាដើមហើយ ត្រូវចោទសួរថា ហេតុអ្វី ទើបធ្វើយ៉ាងនោះ រមែងធ្វើអាការក្រោធខ្លះ ក្តៅក្រហាយខ្លះ កាលកិលេសមានប្រមាណតិចកើតហើយ បុគ្គលនោះ បណ្តោយឲ្យកិលេសនោះរីកធំធាត់ រមែងធ្វើនូវការកន្លងល្មើសបាន ព្រោះហេតុនោះ អកុសលដែលមានកម្លាំង រមែងជាឧបនិស្សយប្បច្ច័យដល់អកុសលដែលខ្សោយកម្លាំង ហើយអកុសលដែលខ្សោយកម្លាំង ក៏រមែងជាឧបនិស្សយប្បច្ច័យសូម្បីដល់

អកុសលដែលមានកម្លាំងបានដូចគ្នា ពាក្យណា ដែលលោកពោលក្នុងវណ្ណនានិទ្ទេស នៃបច្ចយវិភង្គថា ធម៌ដែលឈ្មោះថា ជាឧបនិស្សយប្បច្ច័យព្រោះអត្ថថា ជាហេតុមានកម្លាំង ពាក្យនោះ លោកពោលព្រោះភាវៈនៃភាពជាហេតុប៉ុណ្ណោះមានកម្លាំង មិនមែនធម៌ដែលជាឧបនិស្សយប្បច្ច័យ ។ ពិតហើយ កម្ម និងកិលេសទាំងឡាយ ដែលមានកម្លាំងច្រើនក្តី ដែលខ្សោយកម្លាំងក្តី រាប់ថា ជាហេតុដែលមានកម្លាំងទាំងអស់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **រាគំ ឧបនិស្សាយ ទានំ ទេតិ** ជាដើមដូចតទៅ បុគ្គលចូលទៅអាស្រ័យការត្រេកអរក្នុងឧបបត្តិភព ឬក្នុងភោគៈទាំងឡាយថា ហេតុអ្វីហ្ន៎ ទើបអាត្មាអញចូលដល់ភាពជាសម្លាញ់របស់ពួកទេវតាជាន់ចាតុម្មហារាជិកាជាដើមបាន ដូច្នេះហើយ ក៏ឲ្យទាន ក្នុងការសមាទានសីល និងការរក្សាឧបោសថជាដើម ក៏ន័យនេះដូចគ្នា បុគ្គលកាលធ្វើឈានឲ្យកើត ដើម្បីសង្កត់រាគៈ ធ្វើវិបស្សនាឲ្យកើត ដើម្បីលះរាគៈ ធ្វើមគ្គឲ្យកើត ដើម្បីការកាត់កព កាត់ជាតិ ឈ្មោះថា ចូលទៅអាស្រ័យរាគៈ ធ្វើឲ្យកើតឡើង ។ ម្យ៉ាងទៀត កាលញុំាងអភិញ្ញា និងសមាបត្តិឲ្យកើត ដើម្បីឲ្យប្រាសចាករាគៈ ក៏ឈ្មោះថា ចូលទៅអាស្រ័យរាគៈឲ្យកើតឡើងដូចគ្នា ។ ពិតហើយ ដោយតម្រូវការប៉ុណ្ណោះ បុគ្គលនោះ រមែងជាបុគ្គលដែលប្រាសចាករាគៈបាន ។

បទថា **សទ្ធាយ** គឺការជឿ ដែលប្រព្រឹត្តទៅដោយអំណាចទានជាដើមសូម្បីក្នុងសីលជាដើម ក៏ន័យនេះដូចគ្នា ដូចកាលញុំាងសទ្ធាជាដើមឲ្យកើត

ដោយអំណាចទានជាដើម ឈ្មោះថា ចូលទៅអាស្រ័យរាគៈឲ្យកើត យ៉ាងណា អ្នកសិក្សាគប្បីជ្រាបថា រាគៈជាដើម ក៏ឈ្មោះថា ជាឧបនិស្សយប្បច្ច័យដល់សទ្ធាជាដើម ក៏យ៉ាងនោះ ។ បទថា **តស្ស បដិឃាតត្ថាយ** គឺដើម្បីហាមនូវវិបាកនោះ អធិប្បាយថា ដើម្បីមិនឲ្យឱកាសនៃវិបាកកើតឡើង ក្នុងសប្បដិឃាតធម៌ទាំងឡាយ មានអធិប្បាយប្រមាណប៉ុណ្ណេះ ។ សួរថា អនន្តរិយកម្មទាំងឡាយណា មិនមានបដិឃាត ហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ថា ដើម្បីប្រយោជន៍ដល់ការឃាត់នូវផលនៃកម្មនោះ ក្នុងអនន្តរិយកម្មទាំងនោះ ឆ្លើយថា ទ្រង់ត្រាស់ដោយអំណាចអជ្ឈាស្រ័យនៃបុគ្គលនោះ ។ ពិតហើយ បុគ្គលនោះ រមែងមានអជ្ឈាស្រ័យថា នឹងប្រព្រឹត្តដើម្បីកម្ចាត់វត្ថុនោះ ( វិបាក ) ។ ព្រះមានព្រះភាគ ទ្រង់កាន់យកអជ្ឈាស្រ័យនោះ ទើបត្រាស់យ៉ាងនេះ ។

បទថា **រាគំ ឧបនិស្សាយ អត្តានំ អាតាបេតិ** អ្នកសិក្សាគប្បីជ្រាបសេចក្តីទាំងអស់ ដោយន័យមុននោះឯងថា អ្នកឃើញនូវចំណែកបុណ្យដោយជាការធ្វើបាទលំបាករបស់បុគ្គលត្រេកអរហើយ ក្នុងសម្បត្តិណា រមែងធ្វើយ៉ាងនោះក៏មាន ។ បទថា **កាយិកស្ស សុខស្ស** គឺសេចក្តីសុខដែលបានព្រោះការធ្វើកុសល ដោយអំណាចការឈានកន្លងអកុសល មានរាគៈជាដើម ឬពោលដោយអំណាចការបរិភោគកាមនៃបុគ្គល ដែលមិនទាន់ឃើញទោស ដោយអំណាចរាគៈជាដើម ។ បទថា **ទុក្ខស្ស** គឺសេចក្តីទុក្ខដែលកើតឡើង ដោយអំណាចការធ្វើកិលេសជាដើម ឬសេចក្តីទុក្ខដែលកើត

ឡើង ដោយអំណាចការសម្លាប់ និងការចង ដែលប្រព្រឹត្តទៅព្រោះហេតុនៃរាគៈជាដើម ។ បទថា **ផលសមាបត្តិយា** សំដៅដល់គុណធម៌ ដែលព្រះយោគាវចរឲ្យកើតឡើង ព្រោះកាត់កិលេស មានរាគៈជាដើមបាន ឬសំដៅដល់គុណជាត ដែលលោកអ្នកទៀយណាយក្នុងរាគៈជាដើម ចូលដល់ហើយ ។

បទថា **កាយិកំ សុខំ** ជាដើម សេចក្តីថា កាលសេចក្តីសុខកើតឡើង បុគ្គលត្រេកអរនឹងសេចក្តីសុខនោះ ធ្វើសេចក្តីសុខនោះឲ្យកើតរឿយៗ ដោយបច្ច័យតែមួយនោះឯង សេចក្តីសុខក្នុងកាលមុន ឈ្មោះថា ជាឧបនិស្សយប្បច្ច័យដល់សេចក្តីសុខក្នុងកាលក្រោយ ។

បណ្តាត្រជាក់ជាដើម កាលបុគ្គលសេពពេកនូវភាពក្តៅ មានកម្តៅព្រោះភ្លើងជាដើម សេចក្តីសុខខាងដើម រមែងជាឧបនិស្សយប្បច្ច័យដល់ទុក្ខខាងក្រោយ ។ ម្យ៉ាងទៀត ក្នុងអធិការនេះ កាយិកសុខនៃបុគ្គលដែលងប់ជ្រប់ក្នុងកាមទាំងឡាយថា សម្ផស្សនៃដើមដៃ ដែលមានរោមទន់របស់បរិព្វាជិកានេះ ជាសុខពិតហ្ន៎ ដូច្នេះ រមែងជាឧបនិស្សយប្បច្ច័យនៃកាយិកទុក្ខក្នុងនរក ។ ឯព្រះយោគី កាលមានសេចក្តីសុខ ព្រោះមិនមានរោគ ចូលផលសមាបត្តិ កាយិកសុខ រមែងជាឧបនិស្សយប្បច្ច័យដល់ផលសមាបត្តិ ។

កាលបុគ្គលសេពនូវសេចក្តីសុខ ដើម្បីកម្ចាត់ទុក្ខ ដូចព្រះមានព្រះភាគចូលផលសមាបត្តិរម្ងាប់អាពាធ ដើម្បីកម្ចាត់ទុក្ខ កាយិកទុក្ខ រមែងជាឧប-

និស្សយប្បច្ច័យដល់កាយិកសុខ និងដល់ផលសមាបត្តិ ។ ឧតុដែលសប្បាយ រមែងជាឧបនិស្សយប្បច្ច័យដល់សុខ និងដល់ផលសមាបត្តិ ឧតុដែលមិនជាទីសប្បាយ រមែងជាឧបនិស្សយប្បច្ច័យដល់ទុក្ខ ។ ម្យ៉ាងទៀត កាលបុគ្គលប្រាថ្នាសោយសេចក្ដីសុខដែលកើតហើយ ដោយអំណាចរូបដែលកើតក្នុងសមាបត្តិ ដោយសង្កត់ការមិនសប្បាយព្រោះឧតុ ទោះឧតុមិនសប្បាយ ក៏ជាបច្ច័យដល់ផលសមាបត្តិបានដូចគ្នា ។ ក្នុងភោជន និងសេនាសនៈ ក៏ន័យនេះដូចគ្នា ។ បទបន្ទាប់ថា **កាយិកំ សុខំ** ជាដើម ព្រះមានព្រះភាគទ្រង់សម្ដែងរួមគ្នាដោយចំពោះ ។ តែអ្នកសិក្សាគប្បីជ្រាបភាពជាបច្ច័យនៃធម៌ទាំងនោះ តាមន័យដែលពោលហើយខាងដើមដូចគ្នា ។ បទថា **ផល-សមាបត្តិ កាយិកស្ស សុខស្ស** គឺសមាបត្តិជាបច្ច័យដល់សេចក្ដីសុខដែលកើតឡើងដោយអំណាចរូប ដែលមានសមាបត្តិជាសមុដ្ឋាន ពិតហើយព្រះយោគីចេញអំពីសមាបត្តិហើយ រមែងបានសោយសេចក្ដីសុខនោះ ។

ក្នុងបទថា **កាយិកំ សុខំ ឧបនិស្សាយ ទានំ** ជាដើម អ្នកសិក្សាគប្បីជ្រាបសេចក្ដីសុខ និងសេចក្ដីទុក្ខ ជាឧបនិស្សយប្បច្ច័យដោយអំណាចសុខដែលបានទទួលហើយ មិនទាន់វិនាសទៅថា ធ្វើម្ដេចហ្ន៎ សេចក្ដីសុខរបស់អញនេះ កុំគប្បីវិនាសទៅ ឬដោយអំណាចការសម្រេចសុខដែលខ្លួនមិនទាន់ដល់ថា ធ្វើម្ដេចហ្ន៎ អញគប្បីចូលដល់សេចក្ដីសុខយ៉ាងនេះ ក្នុងកាលតទៅ សូម្បីក្នុងទុក្ខ ក៏គប្បីជ្រាបដោយអំណាចការវិនាសទៅថា ធ្វើម្ដេចហ្ន៎ ទុក្ខគប្បីវិនាសទៅ ឬដោយអំណាចប្រាថ្នាមិនឲ្យទុក្ខកើតថា ទុក្ខ

*យ៉ាងនេះ មិនគប្បីកើតតទៅ ។ ឧតុ ភោជន និងសេនាសនៈ មានន័យដូចពោលហើយនោះឯង ។*

*ក្នុងបទបន្ទាប់មកថា* **កាយិកំ សុខំ** *ជាដើម សេចក្តីថា ព្រោះសទ្ធារមែងកើតដល់បុគ្គលដែលដល់សេចក្តីសុខបាន ដូចក្នុងពាក្យ ( សំយុត្តនិកាយ សឡាយតនវគ្គ ) ថា បពិត្រព្រះមោគ្គល្លាន អ្នកទិទុក្ខ ការដល់នូវព្រះពុទ្ធជាទីពឹង ប្រពៃណាស់ ដូច្នេះ ។ រមែងកើតដល់បុគ្គលដែលដល់នូវសេចក្តីទុក្ខលំបាក ដូចក្នុងពាក្យ ( ខុទ្ទកនិកាយ ឧទាន ) ថា ព្រះមានព្រះភាគ ព្រះអង្គនោះ ត្រាស់ដឹងញ្ញេយ្យធម៌ចំពោះព្រះអង្គឯង ដោយប្រពៃព្រោះទ្រង់សម្តែងធម៌ ដើម្បីលះបង់ទុក្ខបែបនេះ ដូច្នេះ ។ ម្យ៉ាងទៀត បុគ្គលរមែងធ្វើឲ្យបរិបូណ៌ក្នុងសីលជាដើម ដើម្បីប្រកបខ្លួនក្នុងសុខ និងប្រាសចាកសេចក្តីទុក្ខ ព្រោះហេតុនោះ ទើបសុខ និងទុក្ខ ព្រះមានព្រះភាគទ្រង់សម្តែងដោយជាឧបនិស្ស័យនៃសទ្ធាជាដើម សូម្បីឧតុជាដើម អ្នកសិក្សាគប្បីប្រកបអធិប្បាយតាមសមគួរ ។*

*ក្នុងបទថា* **កាយិកំ សុខំ ឧបនិស្សាយ ចាណាំ ហាណតិ** *ជាដើម គប្បីជ្រាបភាពដែលសុខជាដើម ជាឧបនិស្សយប្បច្ច័យតាមគន្លងរបស់ន័យដែលខ្ញុំពោលហើយនោះឯង ។*

*ក្នុងបទភាជនីយនៃឧបនិស្សយប្បច្ច័យនេះ អ្នកសិក្សាគប្បីជ្រាបថា ឧបនិស្សយប្បច្ច័យ ទ្រង់ចែក ២៣ វារៈ គឺកុសលជាបច្ច័យដល់កុសលដោយឧបនិស្សយប្បច្ច័យ ៣ វារៈ ដល់អកុសល ២ វារៈ ដល់អព្យាកតៈ*

៣ វារៈ ។ អកុសលជាបច្ច័យដល់អកុសល ដោយឧបនិស្សយប្បច្ច័យ ៣ វារៈ ដល់កុសល ១ វារៈ ដល់អព្យាកតៈ ២ វារៈ សូម្បីអព្យាកតៈ ក៏ជាបច្ច័យដល់អព្យាកតៈ ដោយឧបនិស្សយប្បច្ច័យ ៣ វារៈ ដល់កុសល ៣ វារៈ ដល់អកុសល ៣ វារៈ ហេតុនោះ ទើបជាកុសល ៨ វារៈ អកុសល ៦ វារៈ អព្យាកតៈ ៩ វារៈ ។

[ ៥៥៦-៥៥៨ ] ក្នុងបុរេជាតប្បច្ច័យ ចក្ខាយតនៈជាដើម ព្រះមានព្រះភាគ ត្រាស់ដោយអំណាចរូបគ្រោតគ្រាត ឯអាបោធាតុជាដើម ជាអារម្មណបុរេជាតប្បច្ច័យប៉ុណ្ណោះ ។ បទថា **វត្ថុ បុរេជាតំ ចក្ខាយតនំ** ជាដើម ព្រះមានព្រះភាគត្រាស់ដើម្បីសម្ដែងហទយវត្ថុដែលកើតមុន ។ បទថា **វត្ថុ វិបាកាព្យាកតានំ** ទ្រង់ត្រាស់សំដៅដល់បុរេជាតប្បច្ច័យ ក្នុងបវត្តិកាល ។

[ ៥៥៩-៥៦១ ] ក្នុងបច្ឆាជាតប្បច្ច័យ បទថា **ឥមស្ស កាយស្ស** បានដល់ កាយដែលប្រកបដោយមហាភូតរូប ៤ ។ បទថា **បច្ឆាជាតប្បច្ចយេន បច្ចយោ** សេចក្ដីថា ជាធម៌ដែលកើតខាងក្រោយ និងជាបច្ច័យ ដោយអំណាចការឧបត្ថម្ភ ។ បច្ឆាជាតប្បច្ច័យនេះ មកហើយដោយអនុលោមក្នុងបញ្ហាវារៈនេះថា ភាពជាបច្ច័យ ព្រោះអត្ថថា ឧបត្ថម្ភនេះឯង ឈ្មោះថា បច្ឆាជាតប្បច្ច័យ ។

[ ៥៦២-៥៦៤ ] ក្នុងការកាន់យកបទថា **អនុលោមំ គោត្រភុស្ស** ជាដើម ក្នុងអាសេវនប្បច្ច័យ ចែកទៅមួយចំណែក គប្បីជ្រាបហេតុនៃការ

ចែកទៅនោះ ដោយន័យដែលពោលហើយខាងដើមនោះឯង ។

[ ៥៦៥-៥៧១ ] ក្នុងបទនេះថា **កុសលា ចេតនា សម្បយុត្តកានំ** ក្នុងកម្មប្បច្ច័យ ចេតនា ព្រះមានព្រះភាគមិនត្រាស់ថា សហជាត ព្រោះមិនមានការចែកជាសហជាតកម្មប្បច្ច័យ និងនានាខណិកកម្មប្បច្ច័យ តែក្នុងការវិសជ្ជនា អព្យាកតធម៌ ការចែកនោះមាន ព្រោះហេតុនោះ ទើបចេតនាដែលជាសហជាត និងនានាខណិក ព្រះមានព្រះភាគត្រាស់ក្នុងវារៈនេះ ។ **បដិសន្ធិ** សព្វ ត្រាស់ដោយអំណាចកដត្តារូប ។

បទថា **ចេតនា វត្ថុស្ស** ទ្រង់ត្រាស់ដើម្បីសម្តែងថា អរូបធម៌អាស្រ័យហទយវត្ថុក្នុងបដិសន្ធិក្ខណៈ រមែងប្រព្រឹត្តទៅ ព្រោះហទយវត្ថុជាបច្ច័យដោយពិត ចេតនា ក៏ជាបច្ច័យដល់ហទយវត្ថុបាន ។

[ ៥៧២ ] ក្នុងវិបាកប្បច្ច័យ អ្នកសិក្សាគប្បីជ្រាបអត្ថក្នុងបដិសន្ធិវារៈដោយន័យនេះដូចគ្នា ។

[ ៥៧៣-៥៧៩ ] បទថា **ឥមស្ស កាយស្ស** ក្នុងអាហារប្បច្ច័យ សេចក្តីថា ជាបច្ច័យដោយអាហារប្បច្ច័យ ដោយអំណាចញ៉ាំងរូប មានអាហារជាសមុដ្ឋានឲ្យកើតឡើង ដោយអំណាចការឧបត្ថម្ភដល់រូបដ៏សេស

ក្នុងកាយ ដែលសម្រេចដោយមហាភូតរូប ៤ នេះ ដែលប្រព្រឹត្តទៅ ដោយអំណាចសន្តតិ ៤ ។

[ ៥៨០-៦២៤ ] ក្នុងឥន្ទ្រិយប្បច្ច័យជាដើម អ្នកសិក្សាគប្បីជ្រាប បដិសន្ធិវារៈ តាមដែលខ្ញុំពោលហើយនោះឯង ។ ពាក្យដ៏សេស ក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ដូច្នោះឯង ។ល។

## អដ្ឋកថាបញ្ហាវារវិភង្គ ចប់

# ក្បាលទី ៧៦

# អភិធម្មបិដក បាលីប្រែ ~៩៤

## បដ្ឋាន បឋមភាគ

*សន្ទឹកចង្អុលប្រាប់មាតិកា*

*មាតិកា* *លេខទំព័រ*


| | |
|---|---|
| *អភិធម្មបិដក មាតិកានិក្ខេបវារៈ* ...... ...... ...... ...... | *២* |
| *អារម្ភកថា* .... ...... ...... ...... ...... ...... ...... | *៣* |
| *អធិប្បាយបច្ចយុទ្ទេស* ...... ...... ...... ...... | *៣* |
| *អភិធម្មបិដក បច្ចយវិភង្គវារៈ* ...... ...... ...... ...... | *៣១* |
| *អធិប្បាយ ហេតុប្បច្ចយនិទ្ទេស* ...... ...... ...... ...... | *៣២* |
| *អភិធម្មបិដក អារម្មណប្បច្ច័យ* ...... ...... ...... ...... | *៤៣* |
| *អធិប្បាយ អារម្មណប្បច្ចយនិទ្ទេស* ...... ...... ...... ...... | *៤៤* |
| *អភិធម្មបិដក អធិបតិប្បច្ច័យ* ...... ...... ...... ...... | *៤៩* |
| *អធិប្បាយ អធិបតិប្បច្ចយនិទ្ទេស* ...... ...... ...... ...... | *៥០* |
| *អភិធម្មបិដក អនន្តរប្បច្ច័យ* ...... ...... ...... ...... | *៥៥* |
| *អធិប្បាយ អនន្តរប្បច្ចយនិទ្ទេស* ...... ...... ...... ...... | *៥៧* |
| *អភិធម្មបិដក សមនន្តរប្បច្ច័យ* ...... ...... ...... ...... | *៦១* |
| *អធិប្បាយ សមនន្តរប្បច្ចយនិទ្ទេស* ...... ...... ...... ...... | *៦៣* |
| *អភិធម្មបិដក សហជាតប្បច្ច័យ* ...... ...... ...... ...... | *៦៤* |
| *អធិប្បាយ សហជាតប្បច្ចយនិទ្ទេស* ...... ...... ...... ...... | *៦៥* |
| *អភិធម្មបិដក អញ្ញមញ្ញប្បច្ច័យ* ...... ...... ...... ...... | *៦៩* |
| *អធិប្បាយ អញ្ញមញ្ញប្បច្ចយនិទ្ទេស* ...... ...... ...... ...... | *៧០* |
| *អភិធម្មបិដក និស្សយប្បច្ច័យ* ...... ...... ...... ...... | *៧២* |

អធិប្បាយ និស្សយប្បច្ចយនិទ្ទេស ...... ...... ...... ...... ៧៣
អភិធម្មបិដក ឧបនិស្សយប្បច្ច័យ ...... ...... ...... ...... ៧៦
អធិប្បាយ ឧបនិស្សយប្បច្ចយនិទ្ទេស ...... ...... ...... ...... ៧៧
អភិធម្មបិដក បុរេជាតប្បច្ច័យ ...... ...... ...... ...... ៨៣
អធិប្បាយ បុរេជាតប្បច្ចយនិទ្ទេស ...... ...... ...... ...... ៨៥
អភិធម្មបិដក បច្ឆាជាតប្បច្ច័យ ...... ...... ...... ...... ៨៨
អធិប្បាយ បច្ឆាជាតប្បច្ចយនិទ្ទេស ...... ...... ...... ...... ៨៩
អភិធម្មបិដក អាសេវនប្បច្ច័យ ...... ...... ...... ...... ៩១
អធិប្បាយ អាសេវនប្បច្ចយនិទ្ទេស ...... ...... ...... ...... ៩២
អភិធម្មបិដក កម្មប្បច្ច័យ ...... ...... ...... ...... ៩៦
អធិប្បាយ កម្មប្បច្ចយនិទ្ទេស ...... ...... ...... ...... ៩៧
អភិធម្មបិដក វិបាកប្បច្ច័យ ...... ...... ...... ...... ១០១
អធិប្បាយ វិបាកប្បច្ចយនិទ្ទេស ...... ...... ...... ...... ១០២
អភិធម្មបិដក អាហារប្បច្ច័យ ...... ...... ...... ...... ១០៤
អធិប្បាយ អាហារប្បច្ចយនិទ្ទេស ...... ...... ...... ...... ១០៥
អភិធម្មបិដក ឥន្ទ្រិយប្បច្ច័យ ...... ...... ...... ...... ១០៨
អធិប្បាយ ឥន្ទ្រិយប្បច្ចយនិទ្ទេស ...... ...... ...... ...... ១០៩
អភិធម្មបិដក ឈានប្បច្ច័យ ...... ...... ...... ...... ១១២
អធិប្បាយ ឈានប្បច្ចយនិទ្ទេស ...... ...... ...... ...... ១១៣
អភិធម្មបិដក មគ្គប្បច្ច័យ ...... ...... ...... ...... ១១៥
អធិប្បាយ មគ្គប្បច្ចយនិទ្ទេស ...... ...... ...... ...... ១១៦
អភិធម្មបិដក សម្បយុត្តប្បច្ច័យ ...... ...... ...... ...... ១១៨
អធិប្បាយ សម្បយុត្តប្បច្ចយនិទ្ទេស ...... ...... ...... ...... ១១៩

អភិធម្មបិដក វិប្បយុត្តប្បច្ច័យ ...... ...... ...... ...... ១២០
អធិប្បាយ វិប្បយុត្តប្បច្ចយនិទ្ទេស ...... ...... ...... ...... ១២១
អភិធម្មបិដក អត្ថិប្បច្ច័យ ...... ...... ...... ...... ១២៥
អធិប្បាយ អត្ថិប្បច្ចយនិទ្ទេស ...... ...... ...... ...... ១២៧
អភិធម្មបិដក នត្ថិប្បច្ច័យ ...... ...... ...... ...... ១៣៣
អធិប្បាយ នត្ថិប្បច្ចយនិទ្ទេស ...... ...... ...... ...... ១៣៤
អភិធម្មបិដក វិគតប្បច្ច័យ ...... ...... ...... ...... ១៣៥
អធិប្បាយ វិគតប្បច្ចយនិទ្ទេស ...... ...... ...... ...... ១៣៥
អភិធម្មបិដក អវិគតប្បច្ច័យ ...... ...... ...... ...... ១៣៦
អធិប្បាយ អវិគតប្បច្ចយនិទ្ទេស ...... ...... ...... ...... ១៣៨
បច្ចយនិទ្ទេសបកិណ្ណកវិនិច្ឆយកថា ...... ...... ...... ...... ១៣៩

## បដិច្ចវារៈ

អភិធម្មបិដក បដិច្ចវារៈ ...... ...... ...... ...... ១៥៧
អដ្ឋកថាបច្ចយានុលោម ...... ...... ...... ...... ១៦៩
អដ្ឋកថាបច្ចយបច្ចនីយៈ ...... ...... ...... ...... ១៩៣
អដ្ឋកថាអនុលោមប្បច្ចនីយៈ ...... ...... ...... ...... ១៩៥
អដ្ឋកថាបច្ចនីយានុលោម ...... ...... ...... ...... ១៩៧
អភិធម្មបិដក ( អនុលោម ) ...... ...... ...... ...... ២០០
អដ្ឋកថាបច្ចយានុលោម ...... ...... ...... ...... ...... ...... ...... ២១៨
វិភង្គវារៈ ...... ...... ...... ...... ...... ...... ...... ២១៨
សង្ខ្យាវារៈ ...... ...... ...... ...... ...... ...... ...... ២៣១
អភិធម្មបិដក ( បច្ចនីយៈ ) ...... ...... ...... ...... ២៣៨

អដ្ឋកថាបច្ចយបច្ចនីយៈ ...... ...... ...... ...... ២៥៨

អភិធម្មបិដក ( អនុលោមប្បច្ចនីយៈ ) ...... ...... ...... ...... ២៦៣

អដ្ឋកថាបច្ចយានុលោមបច្ចនីយៈ ...... ...... ...... ...... ២៨១

អភិធម្មបិដក ( បច្ចនីយានុលោម ) ...... ...... ...... ...... ២៨៣

អដ្ឋកថាបច្ចយបច្ចនីយានុលោម ...... ...... ...... ...... ៣០០

## សហជាតវារៈ

អភិធម្មបិដក សហជាតវារៈ ...... ...... ...... ...... ៣០៥

អដ្ឋកថាសហជាតវារៈ ...... ...... ...... ...... ៣១០

## បច្ចយវារៈ

អភិធម្មបិដក បច្ចយវារៈ ( អនុលោម ) ...... ...... ...... ...... ៣១១

អដ្ឋកថាបច្ចយវារៈ ( អនុលោម ) ...... ...... ...... ...... ៣៣០

អភិធម្មបិដក ( បច្ចនីយៈ ) ...... ...... ...... ...... ៣៣៦

អដ្ឋកថាបច្ចនីយៈ ...... ...... ...... ...... ៣៤៩

អភិធម្មបិដក ( អនុលោមប្បច្ចនីយៈ ) ...... ...... ...... ...... ៣៥២

អភិធម្មបិដក ( បច្ចនីយានុលោម ) ...... ...... ...... ...... ៣៦៣

អដ្ឋកថាអនុលោមប្បច្ចនីយៈ និងបច្ចនីយានុលោម ... ...... ...... ៣៧៦

## និស្សយវារៈ

អភិធម្មបិដក និស្សយវារៈ ...... ...... ...... ...... ៣៧៧

អដ្ឋកថានិស្សយវារៈ ...... ...... ...... ...... ៣៨៤

## សំសដ្ឋវារៈ

អភិធម្មបិដក សំសដ្ឋវារៈ ( អនុលោម ) ...... ...... ...... ...... ៣៨៦

អដ្ឋកថាសំសដ្ឋវារៈ ( អនុលោម ) ...... ...... ...... ...... ៣៩០
អភិធម្មបិដក ( បច្ចនីយៈ ) ...... ...... ...... ...... ៣៩២
អដ្ឋកថាបច្ចនីយៈ ...... ...... ...... ...... ៣៩៩
អភិធម្មបិដក ( អនុលោមប្បច្ចនីយៈ ) ...... ...... ...... ...... ៤០១
អដ្ឋកថាអនុលោមប្បច្ចនីយៈ ...... ...... ...... ...... ៤០៨
អភិធម្មបិដក ( បច្ចនីយានុលោម ) ...... ...... ...... ...... ៤០៩
អដ្ឋកថាបច្ចនីយានុលោម ...... ...... ...... ...... ៤១៨

## សម្បយុត្តវារៈ

អភិធម្មបិដក សម្បយុត្តវារៈ ...... ...... ...... ...... ៤១៩
អដ្ឋកថាសម្បយុត្តវារៈ ...... ...... ...... ...... ៤២២

## បញ្ហាវារៈ

អភិធម្មបិដក បញ្ហាវារៈ ...... ...... ...... ...... ៤២៤
អដ្ឋកថាបញ្ហាវារវិភង្គ ...... ...... ...... ...... ...... ...... ៤៧២